សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍវិស័យកសិកម្ម
# នៅប្រទេសកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ០១ មេសា ២០១៧ ដល់ថ្ងៃទី ៣១ ឧសភា ២០១៧


គាត់តែងឡើងដោយ
និស្សិតឈ្មោះ **ខៃ្ន មូរ៉ាពីន**

សាស្ត្រាចារ្យណែនាំ
លោក បណ្ឌិត **ឈុន ពហុ**


| | | |
|---|---|---|
| ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច | ឆ្នាំចូលសិក្សា | ២០១៣ |
| ជំនាញ សេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាន់ទី ១៦ | ឆ្នាំសរសេរសារណា | ២០១៧ |

សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត
និងវិទ្យាសាស្រ្តសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍវិស័យកសិកម្ម
# នៅប្រទេសកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ០១ មេសា ២០១៧ ដល់ថ្ងៃទី ៣១ ឧសភា ២០១៧

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ខៃ្ល មូរ៉ាពីន**

សាស្រ្តាចារ្យណែនាំ
លោក បណ្ឌិត **ឈុន ពហុ**

| | |
|---|---|
| ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្រ្តសេដ្ឋកិច្ច | ឆ្នាំចូលសិក្សា ២០១៣ |
| ជំនាញ សេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាន់ទី ១៦ | ឆ្នាំសរសេរសារណា ២០១៧ |

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ ឡៃ បូរ៉ាពីន ជានិស្សិតថ្នាក់បរិញ្ញាបត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍៖

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**

- លោកឪពុក ឡៃ សុគន្ធ
- អ្នកម្ដាយ ធឹង រ៉ានីន

ដែលអ្នកមានគុណទាំងទ្វេបានជួយផ្ដល់កំណើត និងបានចិញ្ចឹមបីបាច់ថែរក្សា រូបកូនតាំងពីតូចរហូតដល់ធំដឹងក្ដី ប្រកបដោយក្ដីមេត្តា និងព្រហ្មវិហារធម៌។ អ្នកមានគុណទាំងទ្វេបានជម្នះនូវរាល់ឧបសគ្គគ្រប់ស្ថានភាព និងឧបត្ថម្ភគ្រប់បែបយ៉ាងដោយមិនគិតពីការលំបាក នឿយហត់ដើម្បីចិញ្ចឹមកូន។ លោកទាំងពីរបានផ្ដល់ដំបូន្មានគ្រប់បែបយ៉ាង ដើម្បីឱ្យកូនដើរលើមាគ៌ាដ៏ត្រឹមត្រូវក្នុងសង្គមតាមរយៈ ការបញ្ជូនកូនទៅសិក្សាតាំងពីកុមាររហូតដល់ បញ្ចប់ថ្នាក់ឧត្តមសិក្សា។ គុណនូបការៈដ៏ធំធេងនេះ ពិតជាមិនអាចយកអ្វីមកប្រៀបផ្ទឹមបាន រូបកូនចងចាំនឹងដឹងគុណជានិច្ចក្នុងមួយជីវិតកូន។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖**

លោកឯកឧត្ដមសាកលវិទ្យាធិការ ឯកឧត្ដមសាលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំងសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀនខ្ញុំបាទ ក៏ដូចជានិស្សិតដទៃទៀតតាំងពីថ្នាក់មូលដ្ឋាន រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រ។

លោកសាស្ត្រាចារ្យ បណ្ឌិត ឈុន ពហុ ដែលបានបង្ហាត់បង្រៀន និងដឹកនាំខ្ញុំបាទ ដើម្បីចងក្រងសារណានេះឡើង អស់ពីកម្លាំងកាយចិត្ត ដោយផ្ដល់ជាយោបល់ ការពិភាក្សា និងជួយកែតម្រូវឯកសាររហូតដល់ការចងក្រងចប់ជាស្ថាពរ។

ជាចុងបញ្ចប់ ខ្ញុំបាទសូមបួងសួងដល់វត្ថុសក្ដិសិទ្ធនានាលើលោក ជួយថែរក្សាសិរី សួស្ដីដល់អ្នកមានគុណទាំងទ្វេ ព្រមទាំងលោកឯកឧត្ដមសាកលវិទ្យាធិការ ឯកឧត្ដមសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកសាស្ត្រាចារ្យ ឈុន ពហុ បណ្ដាសាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់ឱ្យជួបតែសេចក្ដីសុខ មានសុខភាពបរិបូរណ៍ ទទួលជោគជ័យគ្រប់ភារកិច្ច កុំបីអាក់ខាន និងជួបតែព្រះពុទ្ធពរទាំង ៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានបញ្ចប់ការសិក្សាប្រកបដោយជោគជ័យ អស់រយៈពេល ៤ឆ្នាំនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចរួចមក ខ្ញុំបាទត្រូវបានសាកលវិទ្យាល័យតម្រូវឱ្យជ្រើសរើស ក្នុងការសរសេរសារណាបញ្ចប់ការសិក្សា ទៅតាមជំនាញឯកទេសដែលបានសិក្សា។ ការសរសេរសារណានេះជាចំណែកមួយដ៏សំខាន់ របស់និស្សិតក្នុងការអនុវត្តផ្ទាល់ និងដកស្រង់បទពិសោធន៍ជាក់ស្តែង ដើម្បីឆ្លុះបញ្ចាំងពីទ្រឹស្តី ក្រោយពីបានសិក្សាកន្លងមក។

ជាក់ស្តែង បន្ទាប់ពីបានឆ្លងកាត់សង្គ្រាមដ៏រ៉ាំរ៉ៃអស់រយៈពេលជាងបីទសវត្ស ប្រទេសកម្ពុជាបានអភិវឌ្ឍន៍លើគ្រប់វិស័យ និងហេដ្ឋារចនាសម្ព័ន្ធទាំងអស់ ជាពិសេសវិស័យកសិកម្ម ដោយឈរលើមូលដ្ឋានការស្តារលើប្រព័ន្ធធារាសាស្ត្រ ការណែនាំ និងការបង្រៀនកសិករឱ្យយល់ពីការប្រើប្រាស់ដី ជ្រើសរើសពូជឱ្យសមស្របតាមប្រភេទដំណាំ ជាពិសេសការអនុវត្តកសិកម្មតាមបែបទំនើប ឬហៅថាប្រពលវប្បកម្ម។ ការរីកចម្រើននូវកម្រិតជីវភាព របស់ប្រជាកសិករជាកត្តាសំខាន់ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។ ដោយឃើញពីតួនាទីយ៉ាងសំខាន់របស់វិស័យកសិកម្ម ក្នុងការអភិវឌ្ឍន៍ជីវភាពប្រជាពលរដ្ឋកម្ពុជា និងសេដ្ឋកិច្ចជាតិ ទើបខ្ញុំបាទបានស្រាវជ្រាវ និងខិតខំរកឯកសារពត៌មានដែលមានជាប់ទាក់ទង ដើម្បីចងក្រងជាសារណាមួយនេះឡើង ក្នុងគោលបំណង ទុកជាឯកសារសម្រាប់មិត្តអ្នកអាន និងមិត្តនិស្សិតទាំងឡាយណាដែលមានបំណងស្វែងយល់ និងស្រាវជ្រាវពីបញ្ហាអភិវឌ្ឍន៍កសិកម្ម និងពង្រឹងចំណេះដឹងបន្ថែមដែលទាក់ទងនឹងវិស័យកសិកម្ម។ ទោះបីជាសារណានេះបានបញ្ចប់ទៅយ៉ាងណាក៏ដោយ ប៉ុន្តែខ្ញុំបាទដឹងថាចំណេះដឹងរបស់ខ្លួនខ្ញុំផ្ទាល់ នៅមានកម្រិតការស្រាវជ្រាវ និងឯកសារនៅមានភាពខ្វះខាត ដែលជាហេតុនាំឱ្យសារណានេះនៅមានកម្រិតនៅឡើយ។ ខ្ញុំបាទសង្ឃឹមយ៉ាងមុតមាំ និងជឿជាក់ថា ទោះបីជាសារណានេះនៅមានភាពខ្វះខាត តែវាអាចក្លាយទៅជាឯកសារសម្រាប់ការសិក្សាពិគ្រោះ និងសម្រាប់ការសិក្សាស្រាវជ្រាវសម្រាប់អ្នកអាននានា ដែលនឹងក្លាយជាទុនមួយដ៏មានន័យសម្រាប់ពង្រីកចំណេះដឹងផ្ទាល់ខ្លួន និងអាចចងក្រងជាឯកសារយោងជាក់ជាពុំខាន។

ជាចុងក្រោយខ្ញុំបាទសង្ឃឹមយ៉ាងមុតមាំថា រាល់ទ្រឹស្តីដែលបានសិក្សាកន្លងមក ខ្ញុំបាទនឹងស្វែងរកឱកាសដើម្បីបង្ហាញចេញ និងអនុវត្តរាល់ទ្រឹស្តីទាំងឡាយណា ឱ្យមានប្រយោជន៍ដល់វិស័យកសិកម្ម សម្រាប់ជាការរួមចំណែកអភិវឌ្ឍន៍ និងចូលរួមលើកស្ទួយវិស័យកសិកម្មនៅប្រទេសកម្ពុជា ជាពិសេសតំបន់ដែលមានការខ្វះខាត លើចំណេះដឹងបច្ចេកទេសឱ្យមានការរីកចម្រើន។

# មាតិកា


តារាងសម្គាល់អក្សរកាត់ ........ vi
បញ្ជីតារាង ........ vii
បញ្ជីក្រាហ្វិក ........ viii
បញ្ជីរូប ........ ix


## សេចក្តីផ្តើម


១ លំនាំបញ្ហា ........ ១
២ ចំណោទបញ្ហា ........ ២
៣ គោលបំណងនៃការស្រាវជ្រាវ ........ ២
៤ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៣
៥ វិធីសាស្ត្រស្រាវជ្រាវ ........ ៣
ក. ការប្រមូលទិន្នន័យ ........ ៣
ខ. ការវិភាគទិន្នន័យ ........ ៤
៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៤
៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤


## ជំពូកទី១ ផ្នែកទ្រឹស្តី


១.១ និយមន័យ និងទ្រឹស្តីនៃពាក្យគន្លឹះ ........ ៦
១.១.១ និយមន័យការអភិវឌ្ឍ ........ ៦
១.១.២ ទ្រឹស្តីការអភិវឌ្ឍ ........ ៦
១.១.២.១ ទ្រឹស្តីរបស់លោក Michel P. Todaro ........ ៦
១.១.២.២ ទ្រឹស្តីរបស់លោក Rostow ........ ៧
ក. សង្គមប្រពៃណី ........ ៧
ខ. សង្គមដែលស្ថិតក្នុងចំណុចរបត់ទៅរកការអភិវឌ្ឍ ........ ៧
គ. ដំណាក់កាលនៃការចាប់ផ្តើមអភិវឌ្ឍន៍ ........ ៧
ឃ. ដំណាក់កាលទុំ ........ ៧
ង. ដំណាក់កាលនៃបម្រើបម្រាស់ទ្រង់ទ្រាយធំ ........ ៧
១.១.២.៣ ទ្រឹស្តីរបស់លោក Simon Kuznets (១៩២៩) ........ ៨
១.១.២.៤ ទ្រឹស្តីរបស់លោក J. Bruton (១៩៦៥) ........ ៨

១.១.២.៥ ទ្រឹស្តីរបស់លោក Francois Peroux....................................................៨
១.១.២.៦ ទ្រឹស្តីរបស់លោក W. Arthur Lewis ....................................................៨
១.១.២.៧ ទ្រឹស្តីរបស់លោក Angelito G. Manalili.................................................៨
១.១.២.៨ ទ្រឹស្តីរបស់លោក Mabud Vi-Haq........................................................៩
១.១.៣ គោលបំណងនៃការអភិវឌ្ឍ.......................................................................៩
១.១.៤ កត្តាដែលនាំឱ្យមានការអភិវឌ្ឍ ...................................................................១០
១.១.៥ ឧបសគ្គនៃការអភិវឌ្ឍ..............................................................................១០
១.១.៥.១ ទស្សនៈផ្គត់ផ្គង់សរុប .........................................................................១០
១.១.៥.២ ទស្សនៈតម្រូវការសរុប .......................................................................១១
១.១.៥.៣ សំយោគទស្សនៈទាំងពីរ......................................................................១១
ក. មូលធន និងផលិតភាពកសិកម្ម..............................................................១១
ខ. ការអភិវឌ្ឍធនធានមនុស្ស.....................................................................១២
១.១.៦ ទ្រឹស្តីជាមូលដ្ឋានជំរុញការអភិវឌ្ឍកសិកម្ម .....................................................១២
១.១.៦.១ និយមន័យ .........................................................................................១២
១.១.៦.២ មុខងារកសិកម្មក្នុងការអភិវឌ្ឍ ............................................................១២
ក. ការដកហូតកម្លាំងពលកម្ម.................................................................... ១៣
ខ. ស្បៀង និងវត្ថុធាតុដើមសម្រាប់វិស័យឧស្សាហកម្ម............................. ១៣
គ. បង្កើតទីផ្សារសម្រាប់ផលិតកម្មឧស្សាហកម្ម ........................................ ១៣
ឃ. ផ្តល់ទុនបង្កើនធនធានហិរញ្ញវត្ថុ...........................................................១៤
ង. ការបង្កើតរូបិយវត្ថុអន្តរជាតិ ....................................................................១៤
ច. ការធ្វើបដិវត្តន៍បៃតង..............................................................................១៤
ឆ. បច្ចេកវិទ្យាបដិវត្តន៍បៃតង .......................................................................១៥
១.១.៦.៣ លក្ខណៈពិសេសរបស់វិស័យកសិកម្ម ...................................................១៥
ក. កសិកម្មចម្រុះ និងការសម្រេចចិត្តជាលក្ខណៈគ្រួសារ ...........................១៥
ខ. ការប្រើប្រាស់កម្លាំងពលកម្ម និងដី...........................................................១៦
គ. ការងារតាមរដូវ ......................................................................................១៦
ឃ. ផលិតភាព និងផលប្រយោជន៍.............................................................. ១៧
ង. តួនាទីរបស់បសុសត្វ ...............................................................................១៨

# ជំពូកទី២ ស្ថានភាពទូទៅនៃវិស័យកសិកម្ម

២.១ ស្ថានភាពសេដ្ឋកិច្ចប្រទេសកម្ពុជា ....................................................................២០

២.២ ការរួមចំណែកវិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ ...................................................... ២២

២.២.១ កំណើនផលិតផលក្នុងស្រុកសរុប GDP ពីឆ្នាំ២០០៧-២០១៦ ....................... ២២

២.២.២ ការបែងចែកនៃ GDP តាមវិស័យសំខាន់ៗឆ្នាំ២០១៥ .....................................២៤

២.២.៣ អត្រាភាគរយផ្នែកកសិកម្មក្នុង GDP ចាប់ពីឆ្នាំ២០១១-២០១៥........................២៥

២.២.៤ សមាសភាគ GDP នៃអនុវិស័យក្នុងវិស័យកសិកម្ម ..........................................២៦

២.៣ ការវិវឌ្ឍនៃផលិតកម្មកសិកម្មទៅតាមបណ្ដាអនុវិស័យ.................................................២៨

២.៣.១ ការវិវឌ្ឍនៃផលិតកម្មដំណាំស្រូវ ២០១១-២០១៦ .............................................២៨

២.៣.២ ការវិវឌ្ឍផលិកម្មដំណាំរួមផ្សំនិងឧស្សាហាកម្មពីឆ្នាំ២០០៩-២០១៥..................៣២

២.៣.៣ ការវិវឌ្ឍផលិតផលជលផល ២០១១-២០១៦................................................ ៣៥

២.៣.៤ ការវិវឌ្ឍផលិតផលបសុសត្វ ២០១០-២០១៦................................................. ៣៦

២.៣.៥ ការវិវឌ្ឍផលិផលកៅស៊ូ ២០១១-២០១៦ ..................................................... ៣៩

២.៣.៦ ការវិវឌ្ឍផ្នែករុក្ខកម្ម ២០១១-២០១៥ ............................................................៤២

២.៤ សារៈសំខាន់នៃវិស័យកសិកម្មក្នុងការកាត់បន្ថយភាពក្រីក្រនៅជនបទ......................... ៤៣

២.៤.១ សារៈសំខាន់ចំពោះជីវភាពរស់នៅជនបទ ...................................................... ៤៣

២.៤.១.១ ការបរិភោគអង្ករ និងប្រាក់ចំណូល........................................................៤៤

២.៤.១.២ ការបរិភោគបន្លែ និងប្រាក់ចំណូល .......................................................៤៤

២.៤.១.៣ ការបរិភោគបសុសត្វ និងប្រាក់ចំណូល ..................................................៤៥

២.៤.១.៤ តួនាទីរបស់យេនឌ័រ និងជនជាតិភាគតិចនៅក្នុងវិស័យកសិកម្ម ..........៤៥

២.៥ តួនាទីរបស់ស្ថាប័ននានានៅក្នុងវិស័យកសិកម្ម..............................................................៤៦

២.៥.១ តួនាទីរបស់អង្គការក្រៅរដ្ឋាភិបាលក្នុងការអភិវឌ្ឍ ...........................................៤៦

២.៦ គោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម ............................. ៤៧

២.៦.១ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល.................................................... ៤៧

២.៦.២ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨ ...........................៤៨

២.៦.៣ ផែនការសកម្មភាព សម្រាប់អនុវត្តគោលនយោបាយ អភិវឌ្ឍន៍វិស័យឧស្សាហាកម្ម កម្ពុជាឆ្នាំ២០១៥-២០២៥.......................................................................................៥០

## ជំពូកទី៣ ការព្យាករណ៍កំណើនអនុវិស័យកសិកម្មសំខាន់ៗ

៣.១ ការវិភាគលើកំណើនអនុវិស័យសំខាន់ៗ ....................................................................៥៣
៣.១.១ ការប៉ាន់ស្មានការវិវត្តនៃផលិតកម្មដំណាំស្រូវ...................................................៥៣
៣.១.២ ការប៉ាន់ស្មានដំណាំរួមផ្សំនិងឧស្សាហកម្ម ពីឆ្នាំ២០១៦-២០២១.......................៥៦
៣.១.៣ ការវិវត្ត ការនេសាទទឹកសាប ទឹកសមុទ្រ និងវារីវប្បកម្ម .................................៥៨
៣.១.៤ ការវិវត្តនៃផលិតផលបសុសត្វ ២០១៦-២០២១..............................................៥៩
៣.១.៤.១ ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម...............................................៦១
៣.១.៥ ការវិវត្តផ្នែករុក្ខកម្ម..................................................................................៦៣

## ជំពូកទី៤ ការសិក្សាលើបញ្ហាប្រឈម និងដំណោះស្រាយ

៤.១ បញ្ហាប្រឈមនៅក្នុងវិស័យកសិកម្ម ..........................................................................៦៥
៤.១.១ បញ្ហាប្រឈមចំពោះវិស័យកសិកម្មក្នុងឆ្នាំ២០១២............................................៦៥
៤.១.២ បញ្ហាប្រឈមចំពោះវិស័យកសិកម្មក្នុងឆ្នាំ២០១៣............................................៦៦
៤.១.៣ បញ្ហាប្រឈមចំពោះវិស័យកសិកម្មក្នុងឆ្នាំ២០១៤ ...........................................៦៩
៤.១.៤ បញ្ហាប្រឈមចំពោះវិស័យកសិកម្មក្នុងឆ្នាំ២០១៥ ...........................................៧១
៤.១.៥ ការចែកចាយកម្មសិទ្ធិដីធ្លីដោយគ្មានប្រសិទ្ធភាព និងសមធម៌........................ ៧៣
៤.១.៦ បញ្ហាប្រឈមជារួមដែលរាំងស្ទះដល់កំណើនវិស័យកសិកម្ម.......................... ៧៣
៤.២ ដំណោះស្រាយក្នុងការបង្កើនផលិតកម្មកសិកម្ម......................................................... ៧៩
៤.២.១ កែលម្អមធ្យោបាយផលិតកម្មក្នុងការជំរុញកំណើនកសិកម្ម ............................ ៧៩
៤.២.១.១ ការពង្រីក និងកែលម្អការប្រើប្រាស់ ប្រព័ន្ធស្រោចស្រព ដី និងជី........ ៧៩
៤.២.២ ទីផ្សារផលិតកម្មកសិកម្ម និងការរក្សាលំនឹងថ្លៃលក់.........................................៨៣
៤.២.៣ ដំណោះស្រាយទៅនឹងបញ្ហាប្រឈមចំពោះអនុវិស័យកសិកម្ម .......................៨៧
៤.២.៤ ការកែលម្អពូជស្រូវ និងពូជបន្លែ.................................................................៩០
៤.២.៥ ការបង្កើតកសិកម្មចម្រុះ និងការកែច្នៃកសិផល ..........................................៩០
៤.២.៦ ការកាត់បន្ថយនៃការខាតបង់ក្រោយពេលប្រមូលផល និងថ្លៃម៉ាយីធីង.............៩១
៤.២.៧ បង្កើនការគាំទ្រដល់សេវាកម្មកសិកម្ម.........................................................៩១
៤.២.៨ លើកទឹកចិត្តដល់កសិករដែលប្រើប្រាស់បច្ចេកវិទ្យាកសិកម្ម............................៩២
៤.២.៩ ការបន្តស្ដារ និងការកសាងហេដ្ឋារចនាសម្ព័ន្ធ ..................................................៩២

៤.២.១០ ការជំរុញវិស័យកសិ-ឧស្សាហកម្ម ........................................................................ ៩៣
៤.២.១១ កំណែទម្រង់ស្ថាប័ន និងគោលនយោបាយ ...................................................... ៩៣
៤.២.១១.១ ការវិនិយោគសាធារណៈ.................................................................. ៩៣
៤.២.១១.២ ការលើកកម្ពស់ផលិតភាព និងពិពិធកម្មកសិកម្ម............................ ៩៣
៤.២.១១.៣ កំណែទម្រង់ដីសម្បទានកសិកម្ម ..................................................... ៩៥
៤.២.១១.៤ កំណែទម្រង់នេសាទ និងជលផល.................................................... ៩៥
៤.២.១១.៥ កំណែទម្រង់ព្រៃឈើ ...................................................................... ៩៦
៤.២.១១.៦ ការប្រកួតប្រជែងនៃផលិតផលកសិកម្មកម្ពុជា................................... ៩៧
៤.២.១១.៧ ការកសាងសមត្ថភាពក្នុងការរៀបចំផែនការអភិវឌ្ឍកសិកម្ម ........... ៩៧
៤.២.១១.៨ ច្បាប់............................................................................................ ៩៨
ក. ច្បាប់ចំពោះដីធ្លី........................................................................... ៩៩
ខ. ច្បាប់ក្នុងការការពារព្រៃឈើ.......................................................... ៩៩
គ. ច្បាប់ការការពារបទល្មើសនេសាទ ................................................ ១០០

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១ សេចក្តីសន្និដ្ឋាន ...................................................................................................... ១០១
២ អនុសាសន៍ ............................................................................................................... ១០២

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| ពាក្យអក្សរកាត់ | | ការពន្យល់ |
|---|---|---|
| គ.ម២ | ៖ | គីឡូម៉ែត្រការេ |
| គ.ក្រ | ៖ | គីឡូក្រាម |
| ហ.ត | ៖ | ហិកតា |
| ត/ហ.ត | ៖ | តោនក្នុង១ហិកតា |
| ល.រ | ៖ | លេខរៀង |
| ផសស | ៖ | ផលិតផលក្នុងស្រុកសរុប |
| % | ៖ | ភាគរយ |
| AFTA | ៖ | ASEAN Free Trade Area<br>កិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន |
| CDRI | ៖ | Cambodia Development Research Institute<br>វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា |
| EIC | ៖ | Economic Institute of Cambodia<br>វិទ្យាស្ថានសេដ្ឋកិច្ចនៃកម្ពុជា |
| FAO | ៖ | Food and Agriculture Organization<br>អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ |
| GDP | ៖ | Gross Domestic Product<br>ផលិតផលក្នុងស្រុកសរុប |
| IMF | ៖ | International Monetary Fund<br>មូលនិធិរូបិយវត្ថុអន្តរជាតិ |
| UNDP | ៖ | United Nation Development Programme<br>កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ |

# បញ្ជីតារាង


តារាងទី២.១ បង្ហាញពីការប្រៀបធៀបកំណើនដំណាំស្រូវប្រចាំឆ្នាំ២០១១-១៦ .................. ៣០

តារាងទី២.២ ផ្ទៃដីដាំដុះផលិតកម្មដំណាំរួមផ្សំ និងឧស្សាហកម្មឆ្នាំ២០០៩-២០១៥........... ៣៣

តារាងទី២.៣ បរិមាណផលផលិតកម្មដំណាំរួមផ្សំ និងឧស្សាហកម្មឆ្នាំ២០១៣-២០១៥....... ៣៤

តារាងទី៣.១ ការប៉ាន់ស្មានផលិតកម្មដំណាំស្រូវនៅកម្ពុជាឆ្នាំ២០១៥-២០២១ ....................៥៤

តារាងទី៣.២ ការប៉ាន់ស្មាននៃបរិមាណផលស្រូវវស្សា និងប្រាំងចាប់ពីឆ្នាំ២០១៦-២០២១........
........................................................................................................៥៥

តារាងទី៣.៣ បង្ហាញអំពីការព្យាករណ៍ផ្ទៃដីដាំដុះដំណាំរួមផ្សំ និងឧស្សាហកម្មសំខាន់ៗ .....៥៦

តារាងទី៣.៤ បង្ហាញអំពីការព្យាករណ៍បរិមាណផលដំណាំរួមផ្សំ និងឧស្សាហកម្មសំខាន់ៗ .....
........................................................................................................ ៥៧

តារាងទី៣.៥ បង្ហាញអំពីស្ថិតិព្យាករណ៍ផលនេសាទទឹកសាប សមុទ្រ និងវារីវប្បកម្ម ..........៥៨

តារាងទី៣.៦ បង្ហាញពីស្ថិតិព្យាករណ៍ការចិញ្ចឹមសត្វពីឆ្នាំ២០១៦-២០២១ ...........................៦០

តារាងទី៣.៧ បង្ហាញពីស្ថិតិព្យាករណ៍ការចិញ្ចឹមសត្វលក្ខណៈពាណិជ្ជកម្ម ..........................៦១

តារាងទី៣.៨ ស្ថិតិព្យាករណ៍ការដាំដើមឈើ បណ្តុះកូនឈើ និងសហគមន៍ព្រៃឈើ ..........៦៣

# បញ្ជីក្រាហ្វិក


ក្រាហ្វិកទី២.១ បង្ហាញអំពីកំណើន GDP ពីឆ្នាំ២០០៧-២០១៦ ........................................ ២៣
ក្រាហ្វិកទី២.២ ការបែងចែកនៃ GDP តាមវិស័យសំខាន់ៗ ឆ្នាំ២០១៥ ................................ ២៤
ក្រាហ្វិកទី២.៣ អត្រាភាគរយនៃផ្នែកកសិកម្មក្នុង GDP ចាប់ពីឆ្នាំ២០១១-២០១៥ ................ ២៥
ក្រាហ្វិកទី២.៤ កំណើនភាគរយនៃវិស័យកសិកម្មចាប់ពីឆ្នាំ២០០៨-២០១២ ........................ ២៦
ក្រាហ្វិកទី២.៥ សមាសភាគ GDP នៃអនុវិស័យ ក្នុងវិស័យកសិកម្មឆ្នាំ២០១៥ .................... ២៧
ក្រាហ្វិកទី២.៦ ការចូលរួមចំណែកនៃអនុវិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិឆ្នាំ២០១១-២០១៦ .... ........................................................................................................ ២៨
ក្រាហ្វិកទី២.៧ បង្ហាញអំពីផ្ទៃដីដាំដុះដំណាំស្រូវឆ្នាំ២០១១-២០១៥ .................................. ៣០
ក្រាហ្វិកទី២.៨ បង្ហាញអំពីផ្ទៃដីប្រមូលផលដំណាំស្រូវឆ្នាំ២០១១-២០១៦ .......................... ៣១
ក្រាហ្វិកទី២.៩ បង្ហាញអំពីបរិមាណផលដំណាំស្រូវឆ្នាំ២០១១-២០១៦ .............................. ៣២
ក្រាហ្វិកទី២.១០ បង្ហាញអំពីស្ថិតិនេសាទទឹកសាប សមុទ្រ និងវារីវប្បកម្ម ២០១១-១៦ ......... ៣៦
ក្រាហ្វិកទី២.១១ បង្ហាញអំពីការវិវឌ្ឍសត្វនៅកម្ពុជាពីឆ្នាំ២០១០-២០១៦ ............................ ៣៧
ក្រាហ្វិកទី២.១២ បង្ហាញអំពីការវិវឌ្ឍផលិតកម្មសត្វស្លាបពីឆ្នាំ២០១០-២០១៦ ...................... ៣៨
ក្រាហ្វិកទី២.១៣ ការវិវឌ្ឍអំពីការដាំដុះដំណាំកៅស៊ូឆ្នាំ២០១១-២០១៦ ................................. ៤០

# បញ្ជីរូប

ដ្យាក្រាមទី១.១  ទស្សនៈផ្គត់ផ្គង់សរុប ........................................................................... ១០
ដ្យាក្រាមទី១.២  ទស្សនៈតម្រូវការសរុប ........................................................................... ១១
ដ្យាក្រាមទី១.៣  សំយោគទស្សនៈតម្រូវការសរុប និងផ្គត់ផ្គង់សរុប ....................................... ១១
ដ្យាក្រាមទី២.១  អភិក្រមយុទ្ធសាស្ត្រភាពជាដៃគូក្នុងចំណោម រដ្ឋ-ឯកជន-ផលិតករ.............. ៥២

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ប្រទេសកម្ពុជា គឺជាប្រទេសដែលមានខឿនសេដ្ឋកិច្ចជាតិ ពឹងផ្អែកមួយភាគធំលើវិស័យកសិកម្ម នៅឡើយ ហើយមានប្រជាពលរដ្ឋប្រមាណ ៨០% រស់នៅជនបទ ក្នុងនោះភាគច្រើនប្រកបរបរកសិកម្ម សម្រាប់ចិញ្ចឹមជីវិត។ ក្នុងលក្ខខណ្ឌនៃដំណើរការវិវឌ្ឍន៍សេដ្ឋកិច្ចសង្គមបែបនេះរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា បាននឹងកំពុងពង្រឹងនូវវិស័យកសិកម្ម ព្រោះថាការលើកស្ទួយវិស័យកសិកម្ម ជាកត្តាគន្លឹះសម្រាប់ការកាត់បន្ថយភាពក្រីក្រ ហើយក៏រួមចំណែកយ៉ាងច្រើនដើម្បីជំរុញកំណើនផលិតផលសរុបក្នុងស្រុក (GDP) និងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច។ កម្រិតនៃភាពក្រីក្រខ្ពស់នៅទីជនបទ ជាពិសេសតំបន់ដាច់ស្រយាល ដែលប្រជាជន៨០% ពឹងផ្អែកលើវិស័យកសិកម្ម ព្រៃឈើ និងការនេសាទជាដើម ខណៈដែល៧៥%នៃគ្រួសារក្រីក្រ ដែលមានមេគ្រួសារជាកសិករ។ ចំពោះផលិតកម្មកសិកម្ម នៅតែបន្តជារណបទៅនឹងការប្រែប្រួល របស់ធម្មជាតិ ហើយមាននិន្នាការថយចុះ ដោយសារភាពរាំងស្ងួត ទឹកជំនន់ និងការបំផ្លាញរបស់សត្វល្អិតជាដើម។ ការអភិវឌ្ឍវិស័យនេះ ជួបការលំបាកជាច្រើនដោយសារ ទិន្នផលទទួលបានមានកម្រិតទាប។ ជាមួយគ្នានេះ តម្រូវទាមទារឱ្យមានការប្រឹងប្រែងរួមគ្នា ដើម្បីជម្នះរាល់ឧបសគ្គទាំងឡាយរួមមាន ការកសាងផ្លូវលំ ផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រ ក្នុងការផ្គត់ផ្គង់សម្ភារៈ និងឧបករណ៍កសិកម្ម ជំរុញទីផ្សារកសិផល ការកសាងស្ថាប័នសុទ្ធ សឹងតែជាការងារអាទិភាពសម្រាប់កិច្ចអភិវឌ្ឍន៍កសិកម្ម និងកំណើនជីវភាពរស់នៅរបស់ប្រជាជននៅជនបទ។

រយៈពេលប៉ុន្មានអាណត្តិនេះការស្តារនិងរៀបចំអភិវឌ្ឍន៍ប្រទេសកំពុងត្រូវបានរៀបចំ ការកែទម្រង់ និងត្រូវបានដោះស្រាយជាបណ្តើរៗ ដោយរាជរដ្ឋាភិបាល និងអង្គការមួយចំនួនដែលពាក់ព័ន្ធទៅនឹងវិស័យកសិកម្ម។ យុទ្ធសាស្ត្រផ្សេងៗតែងតែត្រូវបានយកមកសាកល្បង និងសិក្សាដែលផ្សាភ្ជាប់ទៅនឹងស្ថានភាពជាក់ស្តែង ដើម្បីបង្កើនប្រសិទ្ធភាពលើគម្រោងអភិវឌ្ឍន៍នីមួយៗទម្លាប់ និង ផ្នត់គំនិតដែលផ្សាភ្ជាប់ប្រជាពលរដ្ឋកម្ពុជានឹងវិស័យកសិកម្ម ព្រមទាំងលក្ខណ្ឌធម្មជាតិ និងភូមិសាស្ត្រអំណោយផល ដល់វិស័យនេះបានជំរុញ ឱ្យកសិកម្មក្លាយជាវិស័យ ដែលមានសក្តានុពល ក្នុងការកែប្រែមុខមាត់សេដ្ឋកិច្ចជាតិ។ ប៉ុន្តែទន្ទឹមនឹងការងារអភិវឌ្ឍន៍កែលម្អវិស័យកសិកម្ម ដើម្បីឱ្យមាននិរន្តរភាពរីកចម្រើនទៅមុខបាន ដរាបណាមានការចូលរួមពីប្រជាជននៅតាមមូលដ្ឋានជាកត្តាសំខាន់បំផុត។ ការចូលរួមរបស់ប្រជាជនមូលដ្ឋានមានន័យថា គឺរាល់ការជាប់ទាក់ទងទាំងអស់របស់ប្រជាជនមូលដ្ឋានជាមួយ និងគោលដៅអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល

ក្នុងនោះរួមមានការសម្រេចចិត្តនូវសកម្មភាព ការកំណត់អាទិភាព ការផ្ដួចផ្ដើមគំនិត អនុវត្ត សកម្មភាពជាដៃគូ ដោយរួមចំណែកនូវគំនិត កម្លាំងពលកម្ម សកម្មភាពអភិវឌ្ឍន៍ផ្សេងៗ ពេលវេលា ព្រមទាំងរិះរកដំណោះស្រាយ នូវបញ្ហានានាដែលជាបញ្ហាប្រឈម ចំពោះការអភិវឌ្ឍវិស័យកសិកម្ម។

## ២. ចំណោទបញ្ហា

ប្រទេសកម្ពុជា កំពុងស្ថិតនៅលើផ្លូវឆ្ពោះទៅរក សមាហរណកម្មសេដ្ឋកិច្ច ក្នុងកម្រិតតំបន់ និងពិភពលោក។ ដូចនេះ នៅថ្ងៃអនាគត ការប្រកួតប្រជែងនៅលើទីផ្សារក្នុងស្រុក និងក្រៅស្រុក នឹងមានការកើនឡើង។ ការអនុវត្ត AFTA និង WTO ធ្វើឱ្យរបាំងនានាត្រូវបានលុបចោល ដូចនេះ ផលិតកម្មក្នុងស្រុក នឹងទទួលរងពីការប្រកួតប្រជែង។ ទំនិញ និងកសិកម្ម គឺដូចគ្នាដែរពេល ផលិតផលកសិកម្មបរទេសចូលមកកម្ពុជាដោយសេរីនោះ កសិកម្មកម្ពុជានឹងអាចមានបញ្ហាបើ យើងមិនបានពង្រឹកវាឱ្យខ្លាំងក្លាទេនោះ។ ដូចនេះ យើងត្រូវប្រញាប់ រៀបចំកម្មវិធីអភិវឌ្ឍន៍ឱ្យមានប្រសិទ្ធភាពចាប់ពីពេលនេះតទៅ ប៉ុន្តែ មុននឹងឈានទៅរកដំណោះស្រាយដែលមានប្រសិទ្ធភាព ជាដំបូងយើងត្រូវសិក្សាស្វែងយល់ពី បញ្ហាប្រឈមនានា ឱ្យបានច្បាស់លាស់អំពីស្ថានភាព កសិកម្មរបស់យើង ទើបអាចដោះស្រាយបញ្ហា ដែលកើតមានឡើងក្នុងវិស័យនេះ មានប្រសិទ្ធភាព។ មានបញ្ហាជាច្រើនដែលគួរយកមកពិភាក្សា ស្វែងរកបញ្ហាប្រឈម និងធ្វើការដោះស្រាយ។ រួមមាន៖

- តើកសិកម្មកម្ពុជាមានស្ថានភាពយ៉ាងដូចម្ដេច?
- តើកសិកម្មកម្ពុជាជួបនឹងបញ្ហាប្រឈមអ្វីខ្លះ?
- តើមានដំណោះស្រាយយ៉ាងដូចម្ដេចខ្លះដើម្បីឱ្យកសិកម្មកម្ពុជាមានការអភិវឌ្ឍ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ជាការពិតណាស់ ដើម្បីឱ្យការសិក្សាស្រាវជ្រាវប្រកបដោយភាពជោគជ័យនោះ គឺយើងត្រូវកំណត់នូវគោលបំណងឱ្យបានច្បាស់លាស់ជាមុនសិន។ ជាមួយគ្នានេះដែរ គោលបំណងនៃការសិក្សាស្រាវជ្រាវក្នុងប្រធានបទគឺ៖

- ការសិក្សាលើទ្រឹស្ដីដែលពាក់ព័ន្ធ
- ចង់បង្ហាញអំពីស្ថានភាពកសិកម្មរបស់ប្រទេសកម្ពុជា
- ចង់បង្ហាញអំពីបញ្ហាប្រឈមនានាដែលជះឥទ្ធិពលទៅលើការអភិវឌ្ឍវិស័យកសិកម្ម

- ចង់បង្ហាញពីដំណោះស្រាយ ចំពោះបញ្ហាប្រឈម ដែលជះឥទ្ធិពលទៅលើការអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជា
- បង្ហាញពីយុទ្ធសាស្ត្រនានាដែលបង្កើតឡើងដោយរដ្ឋាភិបាល និងអង្គការដែលជាប់ពាក់ព័ន្ធនានាក្នុងការអភិវឌ្ឍវិស័យកសិកម្ម
- ចង់ចែករំលែក និងផ្សព្វផ្សាយជាសាធារណៈ នូវបច្ចេកទេស និងវិធីសាស្ត្រ ដើម្បីជំរុញឱ្យមានការអភិវឌ្ឍវិស័យកសិកម្ម។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវអំពីប្រធានបទ ការអភិវឌ្ឍវិស័យកសិកម្មនៅប្រទេសកម្ពុជា ខ្ញុំបាទបានលើកយកការអភិវឌ្ឍវិស័យកសិកម្មត្រឹមតែ ឆ្នាំ ២០០៧ ដល់ ២០១៦ ដោយផ្តោតលើអនុវិស័យកសិកម្មសំខាន់ៗ រួមមានដំណាំស្រូវ ដំណាំកសិ-ឧស្សាហកម្ម និងការចិញ្ចឹមសត្វដែលទាក់ទងទៅនឹងការអភិវឌ្ឍវិស័យកសិកម្ម និងពិភាក្សាពីបញ្ហាប្រឈម ចំពោះវិស័យកសិកម្ម ដើម្បីឆ្ពោះទៅរកភាពជោគជ័យ និងសម្រេចបានប្រសិទ្ធភាពខ្ពស់។

## ៥. វិធីសាស្ត្រស្រាវជ្រាវ

វិធីសាស្ត្រនៃការស្រាវជ្រាវនេះ ធ្វើឡើងតាមរបៀបពិពណ៌នាពន្យល់ (វិធីសាស្ត្រគុណភាព) និងប្រើស្ថិតិពិពណ៌នាសម្រាប់ជាជំនួយក្នុងការបកស្រាយ និងបញ្ជាក់ឱ្យកាន់តែច្បាស់។

### ក. ការប្រមូលទិន្នន័យ

ក្នុងសារណានេះ ក្នុងទិន្នន័យទាំងអស់ ត្រូវបានកំណត់តាមទិន្នន័យបន្ទាប់បន្សំ (Secondary data) សម្រាប់ស្រង់យកទិន្នន័យសំខាន់ៗដែលពាក់ព័ន្ធ។ ទិន្នន័យបន្ទាប់បន្សំ (Secondary data) គឺសំដៅលើប្រភេទទិន្នន័យស្រាវជ្រាវ ដែលប្រមូលបានតាមរយៈ សៀវភៅ ឯកសារផ្សេងៗជាច្រើនដូចជា៖

- សៀវភៅសារណា និងរបាយការណ៍បញ្ចប់ការសិក្សា នៅក្នុងសាកលវិទ្យាល័យភូមិន្ទ-នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- ឯកសាររបាយការណ៍បូកសរុបការងារប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម
- ឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ឆ្នាំ២០១៤-២០១៨
- ឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨
- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល
- ឯកសារបានមកពីការស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធឺណែត...។

**ខ. ការវិភាគទិន្នន័យ**

បន្ទាប់ពីប្រមូលពត៌មាន យើងធ្វើការជ្រើសរើសពត៌មាន ដែលមានប្រយោជន៍សម្រាប់បង្កើតជាវិធីសាស្ត្រព្យាករណ៍ទៅលើអនុវិស័យកសិកម្មសំខាន់ៗនៅឆ្នាំបន្ទាប់ដោយប្រើក្នុង Excel ដើម្បីជាជំនួយក្នុងការវិភាគទិន្នន័យទាំងអស់ ឱ្យមានសុក្រិតភាព និងបង្ហាញជាតារាងក្រោយពីការព្យាករណ៍ទិន្នន័យរួច ដើម្បីងាយស្រួលក្នុងការបកស្រាយ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

អត្ថប្រយោជន៍នៃការសិក្សាស្រាវជ្រាវ អំពីប្រធានបទ "ការអភិវឌ្ឍវិស័យកសិកម្មនៅប្រទេសកម្ពុជា" មានដូចខាងក្រោម៖

-ទទួលបាននូវចំណេះដឹងផ្នែកទ្រឹស្តី និងការវិភាគទិន្នន័យជាក់ស្តែង។

-ទទួលបានចំណេះដឹងថ្មី និងការពិគ្រោះយោបល់ពីសាស្ត្រាចារ្យណែនាំ តាំងពីចាប់ផ្តើមដំណើរការនៃការប្រមូលទិន្នន័យ ចងក្រង ពិភាក្សា និងរហូតដល់សារណាលេចចេញជារូបរាងឡើង។

-ទទួលបានទំនាក់ទំនងល្អ ក្នុងសង្គមការងារស្រាវជ្រាវក្នុងជួររដ្ឋាភិបាល។

-ទទួលបាននូវបទពិសោធន៍យ៉ាងច្រើនទាក់ទងទៅនឹងវិស័យកសិកម្ម ដូចជា ផលិតកម្មដំណាំស្រូវ ដំណាំរួមផ្សំនិងឧស្សាហកម្ម ផលិតកម្មសត្វ ផលិតផលជលផល និងព្រៃឈើជាដើម ជាពិសេសបានដឹងពីទិន្នន័យពិតប្រាកដពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

-អាចចែករំលែកពីការសិក្សាស្រាវជ្រាវពីវិស័យកសិកម្ម ដល់និស្សិតជំនាន់ក្រោយ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងប្រធានបទ "ការអភិវឌ្ឍវិស័យកសិកម្មនៅប្រទេសកម្ពុជា" ត្រូវបានបែងចែកជាប្រាំមួយផ្នែកសំខាន់ៗដូចខាងក្រោម៖

- **សេចក្តីផ្តើម** គឺជាចំណុចចាប់ផ្តើមនៃប្រធានបទ ដែលនឹងធ្វើការសិក្សាទៅលើផ្នែកមួយចំនួន ដូចជាស្ថានភាពទូទៅ មូលហេតុនៃការសិក្សា គោលបំណងនៃការសិក្សា ទំហំ និងដែនកំណត់ និងវិធីសាស្ត្រស្រាវជ្រាវ ដែលនាំឱ្យកម្ពុជា ផ្តោតសំខាន់លើការអភិវឌ្ឍវិស័យកសិកម្ម និងសិក្សាពីបញ្ហាប្រឈម ដើម្បីឈានទៅរកដំណោះស្រាយសមស្របមួយ។
- **ជំពូកទី១៖ ផ្នែកទ្រឹស្តី** នៃការអភិវឌ្ឍវិស័យកសិកម្ម ដោយបានលើកយកទ្រឹស្តីរបស់អ្នកប្រាជ្ញមួយចំនួន មកធ្វើការសិក្សា ដែលធ្វើយ៉ាងណាជំរុញឱ្យមានការអភិវឌ្ឍ និង ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

- **ជំពូកទី២៖ ស្ថានភាពទូទៅនៃវិស័យកសិកម្ម** ក្នុងជំពូកនេះ យើងសិក្សាទៅលើស្ថានភាពទូទៅនៃការអភិវឌ្ឍវិស័យកសិកម្មកម្ពុជា និងបង្ហាញពីការរួមចំណែករបស់វិស័យកសិកម្មនៅក្នុងសេដ្ឋកិច្ច។
- **ជំពូកទី៣៖ ការព្យាករណ៍កំណើនអនុវិស័យកសិកម្មសំខាន់ៗ** ក្នុងជំពូកនេះ បង្ហាញអំពី ការព្យាករណ៍កំណើន ទៅតាមអនុវិស័យកសិកម្មនីមួយៗ ដោយផ្អែកលើមូលដ្ឋាន រូបមន្តនៃការព្យាករណ៍កំណើន។
- **ជំពូកទី៤៖ ការសិក្សាលើបញ្ហាប្រឈម និងដំណោះស្រាយ** ក្នុងជំពូកនេះ បកស្រាយអំពីទិដ្ឋភាពសំខាន់ៗដែលជាបញ្ហាប្រឈមចំពោះវិស័យកសិកម្ម និង សិក្សាវែកញែកថាតើត្រូវរកដំណោះស្រាយបែបណា ដែលសមស្របទៅនឹងបញ្ហាទាំងអស់នោះ។
- **សន្និដ្ឋាន និងអនុសាសន៍** ជាចំណុចចុងក្រោយបង្អស់ ដែលធ្វើការសង្ខេប ប្រធានបទឡើងវិញ និងមិនត្រឹមតែប៉ុណ្ណោះថែមទាំងបានផ្តល់ជាអនុសាសន៍ដល់ប្រធានបទថែមទៀតផង។

# ជំពូកទី១ ផ្នែកទ្រឹស្តី

# ជំពូកទី១

# ផ្នែកទ្រឹស្តី

## ១.១ និយមន័យ និងទ្រឹស្តីនៃពាក្យគន្លឹះ

### ១.១.១ និយមន័យការអភិវឌ្ឍ

ការអភិវឌ្ឍ ជាដំណើរការនៃការប្រែក្លាយរចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និង ស្ថាប័នដែលបង្កលក្ខណៈងាយស្រួល ឬអំណោយផលដល់ការធ្វើឱ្យសេដ្ឋកិច្ចរីកចម្រើននិងធ្វើឱ្យ កំណើនសេដ្ឋកិច្ចអាចបន្តបានយូរ ឬអាចនិយាយបានម៉្យាងទៀត ការអភិវឌ្ឍជាការបង្កលក្ខខណ្ឌ ឱ្យកំណើនសេដ្ឋកិច្ចមានចីរភាព។

អភិវឌ្ឍន៍ ជាដំណើរធ្វើឱ្យប្រសើរឡើងខាងគុណភាព នៃការរស់នៅ របស់មនុស្សទាំង អស់ដែលបានបង្ហាញក្រោមលក្ខខណ្ឌចំនួនបីដូចខាងក្រោម៖

១. ការធ្វើឱ្យប្រសើរឡើងនូវ កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ដូចជាកម្រិតប្រាក់ចំណូល និងបម្រើបម្រាស់របស់ប្រជាពលរដ្ឋកើនឡើង សេវាសុខាភិបាល និងការអប់រំប្រសើរជាងមុន ដោយយោងតាមកំណើននៃកម្រិតសេដ្ឋកិច្ច។

២. ការបង្កើតលក្ខខណ្ឌដែលនាំឱ្យមានការគោរពខ្លួនឯង ដោយឆ្លងតាមរយៈការបង្កើន ស្ថាប័នសង្គម ស្ថាប័ននយោបាយ ស្ថាប័នសេដ្ឋកិច្ច។

៣. ការបង្កើនសេរីភាពក្នុងការប្រើប្រាស់ឱ្យកាន់តែមានទំហំធំ ដូចជាប្រជាជនមានសិទ្ធិ ក្នុងការសម្រេច ជ្រើសរើសការប្រើប្រាស់ទំនិញ និងសេវា។

### ១.១.២ ទ្រឹស្តីការអភិវឌ្ឍ

អភិវឌ្ឍន៍ គឺជាពាក្យមួយដែលមានន័យទូលំទូលាយ ហើយផ្លាស់ប្តូរអត្ថន័យទៅតាម សម័យកាលនីមួយៗ និងទៅតាមទស្សនៈយល់ឃើញ របស់អ្នកប្រាជ្ញនីមួយៗ។ ដើម្បីយល់ច្បាស់ ពីពាក្យ "អភិវឌ្ឍន៍" សូមលើកយកតាមការបកស្រាយ របស់អ្នកប្រាជ្ញនិពន្ធនីមួយៗមួយចំនួន ដូច ខាងក្រោម៖

#### ១.១.២.១ ទ្រឹស្តីរបស់លោក Michel P. Todaro

ការអភិវឌ្ឍអាចកើតមានឡើងនិងប្រកបដោយចីរភាពចាប់ផ្តើមពីតំបន់ជនបទ ជាពិសេស ផ្តោតទៅលើវិស័យកសិកម្ម។ លោក Michel P. Todaro បានលើកឡើងទៀតថា ប្រជាជាតិមួយ អាចឈានទៅដល់ការអភិវឌ្ឍយ៉ាងហោចណាស់ត្រូវមានកត្តាបី៖ ការពន្លឿន Output តាមរយៈ ការធ្វើកំណែទម្រង់ផ្នែកស្ថាប័ន និងបច្ចេកវិទ្យា ដែលត្រូវរៀបចំឡើង ដើម្បីបង្កើតផលិតភាព

សម្រាប់កសិកម្មតូចតាច បង្កើតតម្រូវការក្នុងស្រុកសម្រាប់ផលិតភាពកសិកម្មដែលមានប្រភពពីយុទ្ធសាស្ត្រអភិវឌ្ឍន៍ការងារជាយក្រុង សកម្មភាពអភិវឌ្ឍន៍ជនបទ ដើម្បីពង្រីកកម្លាំងពលកម្មមិនមែនកសិកម្ម និងវិស័យដទៃទៀតដែលគាំទ្រដោយផ្ទាល់ ឬដោយប្រយោលពីសមាគមន៍កសិកម្ម។

**១.១.២.២ ទ្រឹស្តីរបស់លោក** Rostow

លោក Rostow បានឱ្យនិយមន័យថា គ្រប់ប្រជាជាតិទាំងអស់អាចនឹងឈានទៅរកម្រិតនៃការអភិវឌ្ឍ ប្រសិនបើគេដើរតាមគន្លងប្រទេសអភិវឌ្ឍន៍ ហើយរក្សាលក្ខខណ្ឌក្នុងការធានាឱ្យមានសេដ្ឋកិច្ចបានយូរអង្វែង ម៉្យាងទៀតលុះត្រាតែប្រទេសទាំងនោះត្រូវឆ្លងកាត់ ៥ជំហានជាចម្បងះ

**ក. សង្គមប្រពៃណី**

ប្រភពចំណូលមានតែមួយគត់គឺកសិកម្ម (កសិកម្មបែបគ្រួសារ) លទ្ធភាពក្នុងការជំរុញឱ្យមានការកែប្រែសង្គម និងទំនាក់ទំនងផលិតកម្មស្មើសូន្យ មានការប្រកាន់ឋានានុក្រមខ្លាំងនៅក្នុងទំនាក់ទំនងសង្គម មានន័យថាវាជាប្រទេសមួយដែលមានការរីកចម្រើនតិចតួចបំផុត។

**ខ. សង្គមដែលស្ថិតក្នុងចំណុចរបត់ទៅរកការអភិវឌ្ឍ**

មានការធ្វើបដិវត្តនៅក្នុងផ្នត់គំនិត (កែប្រែទំនាក់ទំនងក្នុងការផលិត) មានការកើនឡើងនៃធាតុ និងវិនិយោគ មានន័យថា ជាប្រទេសដែលស្ថិតនៅក្នុងចន្លោះអន្តរកាលនៃការអភិវឌ្ឍ។

**គ. ដំណាក់កាលនៃការចាប់ផ្តើមអភិវឌ្ឍន៍**

វិស័យចលករ (Matric) នៃសេដ្ឋកិច្ចបានចាប់កំណើត និងរីកចម្រើនធំធាត់ជាលំដាប់ ដំណើរសេដ្ឋកិច្ចក្លាយជាបញ្ហាសាមញ្ញ មានការរក្សាបានដោយស្វ័យប្រវត្តិនូវស្ថេរភាពសេដ្ឋកិច្ចប្រទេស ដែលមានលក្ខណៈដូចជាខាងលើគេហៅថា ប្រទេសឧស្សាហកម្មថ្មី។

**ឃ. ដំណាក់កាលទុំ**

ការអភិវឌ្ឍបានជ្រាបចូល ទៅដល់គ្រប់ច្រកល្ហក នៅក្នុងប្រទេសការរុះរើផ្លាស់ប្តូរវិស័យឧស្សាហកម្មដែលមានវ័យចំណាស់ដែលធ្វើការផ្លាស់ប្តូរវិស័យ។ គេហៅប្រទេសទាំងនោះថាជាប្រទេសឧស្សាហកម្មថ្មី។

**ង. ដំណាក់កាលនៃបម្រើបម្រាស់ទ្រង់ទ្រាយធំ**

មានកំណើនខ្លាំងនៃបម្រើបម្រាស់ និងសេចក្តីត្រូវការជាមូលដ្ឋានត្រូវបានដោះស្រាយជាស្ថាពរ។ ការអភិវឌ្ឍវិស័យសុខាភិបាលសង្គម ពង្រីកអំណាចសេដ្ឋកិច្ច ប្រទេសដែលមានលក្ខណៈដូចខាងលើគេហៅថាប្រទេសមហាអំណាចសេដ្ឋកិច្ច។

**១.១.២.៣ ទ្រឹស្តីរបស់លោក** Simon Kuznets ( 1929 )

ការអភិវឌ្ឍអាចធ្វើឱ្យថយចុះ នូវរង្វាស់ផលិតកម្មដុលក្នុងពលរដ្ឋម្នាក់ៗ។ សាស្ត្រាចារ្យនិពន្ធ នៅសាលា Ango-Saxonne បានចាប់អារម្មណ៍ថារង្វាស់ផលិតផលជាដុល ក្នុងនោះម្នាក់ៗនៅតែជាមធ្យោបាយដ៏ល្អសម្រាប់ដាក់ទម្ងន់ទៅលើការអភិវឌ្ឍ។

**១.១.២.៤ ទ្រឹស្តីរបស់លោក** J. Bruton ( 1965 )

ការអភិវឌ្ឍ គឺជាសញ្ញានៃពហុទំហំដែលមានសារៈសំខាន់ ប៉ុន្តែវាមិនចាំបាច់ឱ្យមានការស្រាវជ្រាវជាមួយនឹងការវាស់ពហុទំហំនោះទេ ផលិតផលរបស់មនុស្សម្នាក់ៗ គឺជាប្រសិទ្ធភាពដ៏ចាំបាច់សម្រាប់កំណត់នូវកម្រិតអភិវឌ្ឍន៍។

**១.១.២.៥ ទ្រឹស្តីរបស់លោក** Francois Peroux

លោក Francois Peroux ជាអ្នកទ្រឹស្តីនៃការអភិវឌ្ឍលើមនុស្ស (ការអភិវឌ្ឍតាម និងសម្រាប់មនុស្ស) បានឱ្យនិយមន័យថា ការអភិវឌ្ឍជាដំណើរនៃការប្រែក្លាយរចនាសម្ព័ន្ធសេដ្ឋកិច្ចសង្គម វប្បធម៌ និងស្ថាប័ន ដើម្បីបង្កលក្ខណៈដល់ការជំរុញកំណើនសេដ្ឋកិច្ច ហើយរក្សាកំណើននេះឱ្យមានភាពយូរអង្វែង។

តាមរយៈនិយមន័យនេះដើម្បីឱ្យមានការអភិវឌ្ឍគេចាំបាច់ត្រូវបង្កើតឱ្យមានការរីកចម្រើនខាងសេដ្ឋកិច្ចជាមុនសិន ហើយផលទទួលបានពីការរីកចម្រើនសេដ្ឋកិច្ចនោះ ត្រូវបានគេយកទៅរៀបចំជាមូលដ្ឋានដើម្បី ពង្រឹងកំណើនសេដ្ឋកិច្ចហើយបែងចែក ដោយសមធម៌ទៅលើគ្រប់ផ្នែកសេដ្ឋកិច្ចទាំងអស់។ ក្នុងន័យនេះដែរយើងឃើញថា ការដែលមានកំណើនសេដ្ឋកិច្ច មិនមែនសុទ្ធតែមានការអភិវឌ្ឍនោះទេ តែផ្ទុយទៅវិញការអភិវឌ្ឍចាំបាច់ត្រូវតែមានកំណើនសេដ្ឋកិច្ច។

**១.១.២.៦ ទ្រឹស្តីរបស់លោក** W. Arthur Lewis

លោក Lewis បានឱ្យនិយមន័យអភិវឌ្ឍន៍ថា ជាការផ្លាស់ប្តូរនូវអ្វីដែលជាភាពចាំបាច់ដំបូងសម្រាប់ជាតម្រូវការមូលដ្ឋានរបស់ប្រជាពលរដ្ឋ។ ជាក់ស្តែងការអភិវឌ្ឍប្រទេសមួយជាដំបូងគេត្រូវពឹងផ្អែកយ៉ាងសំខាន់លើការងារកសិកម្ម ហើយទើបគេធ្វើបម្លាស់ប្តូរទៅរកវិស័យផ្សេងៗទៀតដែលទាក់ទងគ្នា។ នេះគេហៅថាការផ្លាស់ប្តូររចនាសម្ព័ន្ធ (Structural Transformation) ។

**១.១.២.៧ ទ្រឹស្តីរបស់លោក** Angelito G. Manalili

លោក Angelito G. Manalili យល់ថាការពិភាក្សាស្តីអំពីកិច្ចការអភិវឌ្ឍមានន័យថាទាល់តែវាត្រូវបានគេគិតក្នុងបរិបទ នៃបទពិសោធន៍ជីវិត និងសេចក្តីប្រាថ្នារបស់ប្រជាពលរដ្ឋទាំងឡាយ។ ដើម្បីឱ្យមានកិច្ចអភិវឌ្ឍន៍ ត្រូវតែទាក់ទងទៅនឹងជីវិតរបស់ពួកគេ និងផ្តល់ឱ្យពួកគេនូវក្តី

សង្ឃឹម។ ការអភិវឌ្ឍត្រូវតែចាប់ផ្តើមពីកន្លែងដែលពួកគេស្នាក់នៅ និងពីអ្វីដែលពួកគេមានឆ្ពោះទៅរកការកសាងសមត្ថភាព ការផ្តល់សិទ្ធិអំណាច និងជឿជាក់លើពួកគាត់។

**១.១.២.៨ ទ្រឹស្តីរបស់លោក** Mabud Vi-Haq

លោក Mabud យល់ថាយើងត្រូវចេះព្រួយបារម្ភពីផលិតផលជាតិសរុបពីព្រោះវានឹងអាចដោះស្រាយបាននូវភាពក្រីក្រ ដើម្បីបង្កើននូវផលិតផលជាតិសរុប។ ការអភិវឌ្ឍគ្មានន័យទាល់តែសោះ ប្រសិនបើវាគ្រាន់តែមានការកើនឡើងនូវផលិតផលជាតិសរុបរបស់ប្រទេសមួយ។ យើងត្រូវប្រឈម នឹងការពិតមានន័យថា ប្រសិនបើវាអាចដោះស្រាយនូវតម្រូវការអភិវឌ្ឍសង្គម។ គោលដៅសំខាន់នៃការអភិវឌ្ឍ ធ្វើឱ្យប្រសើរឡើងនូវគុណភាពជីវិតរបស់ប្រជាពលរដ្ឋ ការកើនឡើងនៃផលិតកម្ម ឬការរីកចម្រើននៃសេដ្ឋកិច្ច គឺគ្រាន់តែជាមធ្យោបាយដើម្បីសម្រេចឱ្យបានគោលដៅប៉ុណ្ណោះ សម្រាប់ការអភិវឌ្ឍនៃប្រជាជន។ ការអភិវឌ្ឍសំខាន់បំផុតត្រូវតែផ្តល់ផលប្រយោជន៍ឱ្យប្រជាជនក្រីក្រ។ ការអភិវឌ្ឍត្រូវតែធ្វើព្រមគ្នា ទាំងបីផ្នែក គឺធ្វើការអភិវឌ្ឍ សេដ្ឋកិច្ច បុគ្គល និង សង្គម ។ ការអភិវឌ្ឍសេដ្ឋកិច្ចសំដៅលើការបង្កើនប្រាក់ចំណូលបំប៉នជីវភាពគ្រួសារ។ ការអភិវឌ្ឍបុគ្គលសំដៅលើការអភិវឌ្ឍស្មារតីរបស់បុគ្គលម្នាក់ៗឱ្យគាត់យល់នូវអ្វីដែលល្អសម្រាប់សហគមន៍របស់ពួកគាត់។ ការអភិវឌ្ឍសង្គមសំដៅលើការបង្កើនការយល់ដឹង របស់ប្រជាពលរដ្ឋទាំងអស់។ ចំពោះការបង្កើនវិជ្ជាជីវៈ គឺជាមធ្យោបាយសំខាន់សម្រាប់ឱ្យគាត់មានប្រាជ្ញាឈ្លាសវៃមានការងារធ្វើ ហើយអាចធ្វើវិភាគទានពេញលេញដល់សង្គមជាតិ ហើយមិនអាចទទួលយកគំនិតបុគ្គលនិយមជាគំនិតប្រឆាំងនឹងការអភិវឌ្ឍបានទេ។

**១.១.៣ គោលបំណងនៃការអភិវឌ្ឍ**

មានសមាសធាតុគ្រឹះ ឬតម្លៃឈ្នូល ៣យ៉ាងត្រូវបានព្រមព្រៀងជាមូលដ្ឋានគ្រឹះដែលផ្អែកលើគំនិត និងគោលការណ៍ប្រតិបត្តិ ដើម្បីយល់ដឹងពីអត្ថន័យខាងក្នុងនៃ "ការអភិវឌ្ឍ" ។ តម្លៃស្នូលទាំងបីនោះគឺ ចីរភាព ការគោរពខ្លួនឯង និងសេរីភាពដែលបានបង្ហាញនូវគោលបំណងរួមរបស់បុគ្គលមួយរូបៗ និងសង្គមនានា។ តម្លៃទាំងនេះទាក់ទងទៅនឹងតម្រូវការជាមូលដ្ឋានរបស់មនុស្សដែលមាននៅក្នុងសង្គម និងវប្បធម៌នានាជារៀងរហូត។

យើងអាចសន្និដ្ឋានថា ការអភិវឌ្ឍជាសច្ចភាព ជារូបវន្ត និងជាសភាពផ្លូវចិត្តដែលតាមរយៈការរួមផ្សំនៃដំណើរការសង្គម សេដ្ឋកិច្ច និងស្ថាប័ននេះ សង្គមនានាឱ្យមានមធ្យោបាយនានាដើម្បីសម្រេចបាននូវជីវិតដ៏ប្រសើរមួយ។ ទោះជាសមត្ថភាពនៃជីវិតល្អបែបណាក៏ដោយ យ៉ាងហោចណាស់ការអភិវឌ្ឍក្នុងសង្គមត្រូវមានគោលដៅ ៣ដូចតទៅ៖

១. ដើម្បីបង្កើនលទ្ធភាពអាចរកបាន និងដើម្បីពង្រីកការបែងចែកទំនិញទ្រទ្រង់ជីវិតជាមូលដ្ឋានដូចជាម្ហូបអាហារ ផ្ទះសម្បែង សុខភាព និងការថែរក្សាសុវត្ថិភាព។

២. ដើម្បីបង្កើនកម្រិតជីវភាពដែលរួមមានការផ្តល់ការងារច្រើនមុខ ការអប់រំប្រសើរជាងមុន និងយកចិត្តទុកដាក់ខ្លាំងជាងមុនទៅលើតម្លៃវប្បធម៌ និងមនុស្សធម៌ជាបន្ថែមទៅលើចំណូលខ្ពស់ជាងមុន ហើយដែលធាតុនីមួយៗ ទាំងនេះនឹងជួយលើកកម្ពស់សុខុមាលភាពជាសម្ភារៈថែមទាំងជួយបង្កើតការគោរពជាតិ និងបុគ្គលម្នាក់ៗផងដែរ។

៣. ដើម្បីពង្រីកលំដាប់នៃជម្រើសផ្នែកសេដ្ឋកិច្ច និងសង្គម ដែលបុគ្គលនីមួយៗ និងជាតិនានា គឺត្រូវប្រោសចេញពីភាពអវិជ្ជា និងទុក្ខសោក។

### ១.១.៤ កត្តាដែលនាំឱ្យមានការអភិវឌ្ឍ

សេដ្ឋវិទូបានកំណត់ថា ប្រទេសអ្នកមាន និងប្រទេសអ្នកក្រក៏ត្រូវការ កត្តាផ្សំ ៤យ៉ាងដើម្បីឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ច ដែលកត្តាទាំងនោះមាន៖

- ធនធានមនុស្ស (កម្លាំងពលកម្ម ការអប់រំ វិន័យ ការលើកទឹកចិត្ត...)
- ធនធានធម្មជាតិ (ដី រ៉ែ ប្រេង គុណភាពនៃបរិស្ថាន...)
- មូលធន (ម៉ាស៊ីន រោងចក្រ ហេដ្ឋារចនាសម្ព័ន្ធ...)
- បច្ចេកវិទ្យា ( វិទ្យាសាស្ត្រ វិស្វកម្ម ការគ្រប់គ្រង...)

### ១.១.៥ ឧបសគ្គនៃការអភិវឌ្ឍ

ប្រទេសជាច្រើន បានឃើញឧបសគ្គជាចម្បងមួយដែលជារនាំងនៃការអភិវឌ្ឍគឺ វដ្តនៃភាពក្រីក្រ។ ទ្រឹស្តីវដ្តនៃភាពក្រីក្រ អាចពន្យាបានតាមទស្សនៈ២យ៉ាង គឺ៖

- ទស្សនៈផ្គត់ផ្គង់សរុប
- និង ទស្សនៈតម្រូវការសរុប។

#### ១.១.៥.១ ទស្សនៈផ្គត់ផ្គង់សរុប

ដ្យាក្រាមទី ១.១ ទស្សនៈផ្គត់ផ្គង់សរុប



### ១.១.៥.២ ទស្សនៈតម្រូវការសរុប

ដ្យាក្រាមទី ១.២ ទស្សនៈតម្រូវការសរុប




### ១.១.៥.៣ សំយោគទស្សនៈទាំងពីរ

ដ្យាក្រាមទី ១.៣ សំយោគទស្សនៈតម្រូវការសរុប និងផ្គត់ផ្គង់សរុប




ផលិតភាពទាបជាមូលហេតុរារាំងការអភិវឌ្ឍសេដ្ឋកិច្ចវដ្តនៃភាពក្រីក្រនេះ ឱ្យមនុស្សរស់នៅក្នុងភាពក្រីក្រដែលជាលទ្ធផល នៃការបណ្តុះបណ្តាលទាប ហើយបណ្តាលឱ្យប្រជាពលរដ្ឋមានកំណើនយ៉ាងលឿន។ គេមានមធ្យោបាយពីរយ៉ាង ក្នុងការបង្កើនផលិតភាពដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចដែលមធ្យោបាយ២យ៉ាងគឺៈ

#### ក. មូលធន និងផលិតភាពកសិកម្ម

ដើម្បីឱ្យផលិតភាពពលកម្មកើនឡើង ទាមទារឱ្យបង្កើនមូលធនទាំងបរិមាណ និងគុណភាពហើយដែលប្រភពធនធានដើម្បីឱ្យសម្រេចគោលដៅនេះបានមកពី ការអនុវត្តនយោបាយគៀងគរនូវការសន្សំតូចតាច ដែលរាយប៉ាយពាសពេញផ្ទៃប្រទេស ដោយជំរុញឱ្យមហាជនឱ្យចូលរួមសន្សំ។ បញ្ចូលខ្លួនទៅនឹងខ្សែសង្វាក់ផលិតកម្ម នៃសមាហរណកម្មសេដ្ឋកិច្ចពិភពលោក (ដើម្បីទទួលបានជំនួយអភិវឌ្ឍន៍ និងឥណទានអភិវឌ្ឍន៍)។

**ខ. ការអភិវឌ្ឍធនធានមនុស្ស**

បង្កើនសមត្ថភាពផលិតកម្មរបស់ពលកម្មតាមរយៈការសិក្សាបណ្តុះបណ្តាលវិជ្ជាជីវៈ និងការវិនិយោគធនធានមនុស្សតាមរយៈការថែរក្សាសុខភាព ការបង្កើនសុវត្ថិភាពពលកម្ម ហើយនិងការទប់ស្កាត់កំណើនប្រជាពលរដ្ឋ។

### ១.១.៦ ទ្រឹស្តីជាមូលដ្ឋានជំរុញការអភិវឌ្ឍកសិកម្ម

#### ១.១.៦.១ និយមន័យ

កសិកម្ម ត្រូវបានគេឱ្យនិយមន័យខុសៗគ្នា ទៅតាមទស្សនៈយល់ឃើញរបស់អ្នកប្រាជ្ញនីមួយៗ ក៏ប៉ុន្តែអត្ថន័យរបស់វាមិនមានភាពខុសប្លែកគ្នាប៉ុន្មានទេ។ និយមន័យទាំងនោះមានដូចជា៖

**កសិកម្ម** គឺជាផ្នែកមួយនៃផលិតកម្មរបស់មនុស្សជំនាន់ដើម ដែលមានការចូលរួមពីកត្តាផលិតកម្មរបស់វា (ការងារពលកម្មរបស់មនុស្សក្នុងការកែប្រែដី ការដាំដុះ និងការចិញ្ចឹមសត្វ)។

**កសិកម្ម** ជាអំពើរបស់មនុស្សក្នុងការកែប្រែដី ការដាំដុះ និងការចិញ្ចឹមសត្វ។

**កសិកម្ម** គឺជាសិល្បៈ ឬវិទ្យាសាស្ត្រ នៃការកែច្នៃដី ការផលិត ការធ្វើគ្រាប់ពូជ ការបង្កាត់ពូជ និងស្បៀងអាហារគ្រប់មុខដើម្បីផ្គត់ផ្គង់ទីផ្សារ។

ការអភិវឌ្ឍវិស័យកសិកម្មសំដៅលើការធ្វើឱ្យប្រែប្រួល ទិន្នផលកសិកម្មជាវិជ្ជមាន និងកែប្រែគុណភាពពីទាបទៅខ្ពស់ ឬធ្វើការផ្លាស់ប្តូរបច្ចេកវិទ្យាថ្មីក្នុងផលិតកម្មកសិកម្ម[1]។

#### ១.១.៦.២ មុខងារកសិកម្មក្នុងការអភិវឌ្ឍ

បច្ចុប្បន្ននេះ យើងឃើញថាប្រទេសដែលមានការអភិវឌ្ឍកាន់តែខ្ពស់ ការចូលរួមចំណែករបស់វិស័យកសិកម្ម ចំពោះផលិតផលសរុបក្នុងស្រុកកាន់តែតិចទៅៗ ដោយផ្ទុយពីវិស័យឧស្សាហកម្ម។ សម្រាប់ប្រទេសក្រីក្រ និងប្រទេសកំពុងអភិវឌ្ឍន៍ ផ្ទុយពីប្រទេសអភិវឌ្ឍន៍កសិកម្មមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍ សេដ្ឋកិច្ចអភិវឌ្ឍន៍ ការរួមចំណែករបស់វិស័យកសិកម្មក្នុងផលិតផលសរុបមានកម្រិត និងបានចូលរួមកម្លាំងពលកម្មច្រើនជាង៧០%។ ដូច្នេះសម្រាប់ប្រទេសក្រីក្រ ឬប្រជាជនក្រីក្រ ឬ ប្រទេសកំពុងអភិវឌ្ឍន៍គួរពិចារណា និងសិក្សាឱ្យបានស៊ីជម្រៅទៅលើទំនាក់ទំនង និងកត្តាដែលវិស័យកសិកម្មជំរុញឱ្យមានការអភិវឌ្ឍ។

[1] ឈុន ពហុ, *ការអភិវឌ្ឍជនបទ* (ភ្នំពេញ៖ ស.ភ.ន.វ.ស, ២០០៩), ២៣។

**ក. ការដកហូតកម្លាំងពលកម្ម**

ដោយសារប្រទេសក្រីក្រ ឬប្រទេសកំពុងអភិវឌ្ឍន៍ ពុំទាន់មានការរីកចម្រើននៅក្នុងវិស័យកសិកម្មការប្រើប្រាស់ឧបករណ៍តាមបែបបុរាណ មានតួនាទីយ៉ាងសំខាន់ក្នុងការផលិត។ ប្រសិនបើពួកគេផ្លាស់ប្តូរពីកសិកម្មបែបប្រពៃណី ឱ្យទៅជាប្រពលវប្បកម្មដោយប្រើម៉ាស៊ីនជំនួសកម្លាំងគោក្របី និងមនុស្សនោះគេអាចដកហូតកម្លាំងពលកម្មមួយចំនួន ទៅបម្រើការក្នុងវិស័យផ្សេងៗទៀត។

**ខ. ស្បៀង និងវត្ថុធាតុដើមសម្រាប់វិស័យឧស្សាហកម្ម**

ផលិតផលកសិកម្ម មានតួនាទីយ៉ាងចាំបាច់សម្រាប់វិស័យកសិកម្ម និងវិស័យដទៃទៀត។ សម្រាប់ការផលិតកម្លាំងពលកម្មគឺ ជាកត្តាចលករមួយ ដែលមិនអាចអត់បានជាពិសេសក្នុងវិស័យកសិកម្ម។ មិនត្រឹមតែប៉ុណ្ណោះ ការពង្រឹងវិស័យផ្សេងៗទៀត ធ្វើឱ្យមានកំណើនពលករ ហើយភាគច្រើនពលករក្នុងវិស័យទាំងនោះ មានប្រាក់ចំណូលច្រើនជាងវិស័យកសិកម្ម។ កាលណាពលករទាំងនោះមានប្រាក់ចំណូលច្រើន ពួកគេក៏មានតម្រូវការលើ ផលិតផលឧស្សាហកម្មក៏ដូចជាកសិឧស្សាហកម្ម។ ចំពោះកសិផលក៏ជាវត្ថុធាតុដើម យ៉ាងចាំបាច់សម្រាប់កសិឧស្សាហកម្ម ដូចជា ជ័រកៅស៊ូ ឈើ។ល។ ដូចនេះកសិករចាំបាច់ត្រូវបំពេញមុខងារជាអ្នកផ្គត់ផ្គង់សម្រាប់កម្លាំងពលកម្មបំពេញសេចក្តីត្រូវការ របស់កសិករក្នុងវិស័យកសិកម្ម និងកំណើនប្រជាជនយ៉ាងឆាប់រហ័សព្រមទាំងជាវត្ថុធាតុដើមសម្រាប់កសិឧស្សាហកម្មផងដែរ។

**គ. បង្កើតទីផ្សារសម្រាប់ផលិតកម្មឧស្សាហកម្ម**

វិស័យកសិកម្មដែលមានការអភិវឌ្ឍ ឬបែបប្រពលវប្បកម្មតែងតែមានតម្រូវការផលិតផលឧស្សាហកម្ម។ ជាក់ស្តែងដូចជា ផ្លែនង្គ័ល ចប កណ្តៀវ មានការជំនួសបណ្តើរៗដោយត្រាក់ទ័រគោយន្ត ម៉ាស៊ីនច្រូតកាត់ ម៉ាស៊ីនបាកស្រូវ ជីគីមីត្រូវបានគេបន្ថែមលើជីកំប៉ុសនិងជីលាមកសត្វ។

ការអភិវឌ្ឍវិស័យកសិកម្ម ធ្វើឱ្យបង្កើនទិន្នផលខ្ពស់ ដែលអាចជួយឱ្យកសិករមានប្រាក់ចំណូលច្រើនជាងមុន។ ដូច្នេះកសិករនឹងមាន តម្រូវការច្រើនលើ ផលិតផលឧស្សាហកម្មផ្សេងៗ ដើម្បីសម្រួលការរស់នៅរបស់ពួកគាត់ដូចជា សម្លៀកបំពាក់ ចាន ឆ្នាំង គ្រឿងសំណង់ដើម្បីសង់ផ្ទះជាដើម។ល។ ក្នុងដំណាក់កាលដំបូង ប្រទេសកំពុងអភិវឌ្ឍន៍គួរកាត់បន្ថយការនាំចូលនូវផលិតផលឧស្សាហកម្មណា ដែលអាចមានលទ្ធភាពផលិតបានដូចជា ចាន ឆ្នាំង ឬគ្រឿងឧបភោគបរិភោគ ងាយៗផ្សេងៗទៀត ដើម្បីទុកលទ្ធភាពឱ្យវិស័យឧស្សាហកម្ម ដំណាក់កាលដំបូង (សិប្បកម្ម) មានការរីកចម្រើន។ បើពុំមានការរីកចម្រើនផ្នែកសិប្បកម្មទេពិតជាមានការនាំ

ចូលផលិតផលឧស្សាហកម្មច្រើនលើសលុប ហើយពលករក្នុងប្រទេសមិនមានការងារធ្វើ មិនបែកគំនិតចង់អភិវឌ្ឍន៍វិស័យឧស្សាហកម្មដែរ។

**ឃ. ផ្តល់ទុនបង្កើនធនធានហិរញ្ញវត្ថុ**

វិស័យកសិកម្មមានលទ្ធភាពមួយចំនួន ក្នុងការផ្តល់ទុនដល់ការបង្កើន ធនធានហិរញ្ញវត្ថុ ត្រង់ថាកសិករអាចយកប្រាក់ទៅទិញ នង្គ័ល ចប សំបកបារ ម៉ាស៊ីនច្រូតស្រូវ ម៉ាស៊ីនបាកស្រូវ។ ម្យ៉ាងទៀតកសិករអាចយកប្រាក់សន្សំ ពីការឈប់ធ្វើស្រែ ហើយបង្កើតរោងចក្រ ឬរោងសិប្បកម្មដោយខ្លួនឯង។ លើសពីនេះទៅទៀតកសិករយកប្រាក់ទៅផ្ញើរនៅធនាគារ ហើយបង្កើនធនាគារយកប្រាក់នេះទៅវិនិយោគក្នុងវិស័យផ្សេងៗទៀត។

**ខ. ការបង្កើតរូបិយវត្ថុអន្តរជាតិ**

លទ្ធភាពរបស់វិស័យកសិកម្ម ក្នុងការបង្កើតរូបិយវត្ថុអន្តរជាតិអាចធ្វើឡើងតាមរយៈ៖

- ការនាំចេញផលិតផលកសិកម្មទៅលក់នៅបរទេស។
- ការកាត់បន្ថយ ការនាំចូលផលិតផលមកពីក្រៅ ហើយរៀបចំឱ្យមានការលក់ផលិតផលក្នុងស្រុកឱ្យបានច្រើន ហើយប្រាក់ចំណូលនោះប្តូរជារូបិយវត្ថុអន្តរជាតិ។
- វិស័យកសិកម្មចាំបាច់ត្រូវផលិតឱ្យលើសពីសេចក្តីត្រូវការនៃអ្នកផលិតផ្ទាល់។
- រាល់កសិផលដែលលើសពីសេចក្តីត្រូវការ ត្រូវនាំចេញទៅបរទេស ឬជំនួសអ្វីដែលបាននាំចូល។
- រូបិយវត្ថុអន្តរជាតិគួរតែយកទៅប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម ឬវិស័យផ្សេងទៀតដែលចាំបាច់បំផុតក្នុងការអភិវឌ្ឍប្រទេស។

**ច. ការធ្វើបដិវត្តន៍បៃតង**

ការចាប់ផ្តើមរបស់បដិវត្តន៍បៃតង ជាការផ្លាស់ប្តូរបច្ចេកទេស ដែលមានលក្ខណៈច្បាស់លាស់ ហើយស្រប់ទៅតាមអាកាសធាតុ សណ្ឋានដី សេដ្ឋកិច្ច សង្គម ប្រពៃណីរបស់ប្រទេសតតីលោក ។

លោក Schultz ជាមនុស្សម្នាក់ ដែលបានបរិហា អំពីការចម្លងបច្ចេកទេស ពីប្រទេសអភិវឌ្ឍន៍។ គាត់បានស្នើសុំឱ្យមានការផ្ទេរបច្ចេកទេសទាំងនេះ ទៅកាន់ប្រទេសក្រីក្របំផុត ដែលគ្មានបច្ចេកទេស ពោលគឺជាប្រទេសកំពុងអភិវឌ្ឍន៍។ ប៉ុន្តែបច្ចេកទេសទាំងនោះមិនមែនជាបច្ចេកទេសហួសសម័យ ដែលប្រទេសជឿនលឿនលែងប្រើនោះទេ។ ជាទូទៅអ្វីដែលស្ថិតនៅទំនេរនោះ គឺការប្រើប្រាស់នូវបណ្តុំចំណេះដឹង ដែលអាចឱ្យប្រទេសជឿនលឿនផលិត ដោយប្រើ

បច្ចេកទេសខ្ពស់ជាងកន្លែងផ្សេងទៀត។ បណ្តុំនៃចំណេះដឹងទាំងនេះ អាចត្រូវគេប្រើប្រាស់ក្នុងគោលបំណងអភិវឌ្ឍន៍ កត្តាផលិតកម្មសមស្របទៅនឹងលក្ខខណ្ឌជីវសាស្ត្រ និងកសិកម្មសហគមន៍ក្រីក្រ។ ការយកលំនាំតាមបច្ចេកទេសជាច្រើន តាមរយៈការប្រើប្រាស់នូវចំណេះដឹងរបស់ប្រទេសឧស្សាហកម្មនឹងត្រូវបានយក មកប្រើប្រាស់ឡើងវិញ ដោយអ្នកផ្តើមបដិវត្តន៍បៃតងជាច្រើនរូប។ គំនិតផ្សេងៗទៀតយល់ថា ការធ្វើបដិវត្តន៍បៃតងជាការបន្តពឹងផ្អែកលើបច្ចេកវិទ្យារបស់ប្រទេសភាគខាងត្បូង និងជាការបង្កើតនូវបច្ចេកទេសជម្រើស។ នៅក្នុងការស្រាវជ្រាវពីបច្ចេកវិទ្យាជម្រើស គេឃើញមានការកង្វល់ពីការលាយឡំបញ្ចូលគ្នាពីបច្ចេកទេសរបស់ កសិករក្នុងប្រទេសតតីលោក នូវការបញ្ចូលអ្វីដែលថ្មី ហើយគោរពតាមនិងជំរុញ នូវដំណើរការផ្លាស់ប្តូរបច្ចេកទេសដោយស្វ័យប្រវត្តិ។ ក្រុមអ្នកធ្វើបដិវត្តន៍បៃតងបានទទួលយកនូវគំនិត ដែលផ្ទុយពីបុព្វហេតុនៃការបង្កើតថ្មី ក្រៅពីវិស័យកសិកម្ម តាមរយៈការអន្តរាគមន៍ពីការស្រាវជ្រាវសាធារណៈ ការផ្គត់ផ្គង់ Input ដោយឧស្សាហកម្ម និងការកសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។

**ឆ. បច្ចេកវិទ្យាបដិវត្តន៍បៃតង**

ការធ្វើបដិវត្តន៍បៃតងត្រូវបានបង្កើតជា ៤ វិធីសាស្ត្រថ្មី៖

១. ការផ្សព្វផ្សាយពីសម្ភារៈជីវសាស្ត្រដែលទទួលបានលទ្ធផលល្អបំផុត គឺគ្រប់ពូជ ដែលមានទិន្នផលខ្ពស់

២. ការផ្សព្វផ្សាយពីការប្រើប្រាស់ជី (គីមីកំប៉ុស) ពូជ ដែលជាផ្នែកមួយដ៏ល្អបំផុតនៃការបង្កើនទិន្នផល

៣. ការរៀបចំកសាងស្ថាបនាប្រព័ន្ធធារាសាស្ត្រឱ្យបានល្អប្រសើរ

៤. ការធ្វើប្រពលវប្បកម្មក្នុងការប្រើប្រាស់ដីតាមរយៈការបង្កើនល្បឿននៃវដ្តរុក្ខជាតិ ដែលបានអនុវត្តន៍ដូចជា បច្ចេកទេសនៃការដាំដុះ និងការប្រមូល។

**១.១.៦.៣ លក្ខណៈពិសេសរបស់វិស័យកសិកម្ម**

គោលបំណងនៃផ្នែកនេះ ចង់ឱ្យអ្នកសិក្សាយល់ថាតើយើងធ្វើការអភិវឌ្ឍប្រទេស គួរចាប់ផ្តើមពីចំណុចណាទៅ? តើការផ្លាស់ប្តូរវិស័យកសិកម្មពីបែបប្រពៃណីឱ្យទៅជាកសិកម្មបែបទំនើបអាចមានផលប៉ះពាល់យ៉ាងណាខ្លះដល់អ្នកចូលរួម?

**ក. កសិកម្មចម្រុះ និងការសម្រេចចិត្តជាលក្ខណៈគ្រួសារ**

កសិកម្មប្រពៃណី អាចមានរូបភាពច្រើន នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍តែលក្ខណៈមួយដែលគួរឱ្យកត់សម្គាល់ជាងគេនោះ គឺការដាំដុះភាគច្រើនធ្វើឡើងដោយក្រុមគ្រួសារកសិករនៅ

លើផ្ទៃដីតូចតាច។ ការសម្រេចចិត្តលើការងារកសិកម្មភាគច្រើនមានការលាយឡំគ្នា ជាមួយការសម្រេចចិត្តផ្ទាល់របស់ក្រុមគ្រួសារ។ ភាពសំខាន់របស់ក្រុមគ្រួសារ និងទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងការសម្រេចចិត្តក្នុងផលិតកម្ម និងការប្រើប្រាស់កើតមានឡើងព្រោះថាកម្លាំងពលកម្ម ការគ្រប់គ្រង និងមូលធន គឺមកពីក្រុមគ្រួសារតែមួយ។ ដោយសារប្រាក់ចំណូលមានកម្រិតទាប ការដាំដំណាំ និងចិញ្ចឹមសត្វចម្រុះ គឺជាភាពចាំបាច់ ហើយគ្រោះមហន្តរាយរបស់ស្រែចម្ការគឺជាគ្រោះមហន្តរាយរបស់គ្រួសារ។ កសិកម្មបែបចម្រុះ គឺមិនអនុញ្ញាតឱ្យប្រជាកសិករមានលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាខ្ពង់ខ្ពស់ឡើយ។ កសិផលដែលទទួលបាន មានការប្រើប្រាស់នៅនឹងកន្លែងផលិត និងលក់ដូរខ្លះៗនៅលើទីផ្សារជិតៗ ហើយការលក់ដូរនេះភាគច្រើនមិនមានគម្រោងច្បាស់ទេ សេដ្ឋកិច្ចបែបនេះហៅថាសេដ្ឋកិច្ចពាក់កណ្តាលប្រព្រឹត្តកម្ម (Semi Subsistence Economy)។

**ខ. ការប្រើប្រាស់កម្លាំងពលកម្ម និងដី**

កសិដ្ឋានប្រពៃណីភាគច្រើនមានទំហំតូច មានផ្ទៃដីសរុបភាគច្រើនតិចជាង១ហិចតា ហើយតិចបំផុតត្រឹម៣ហិចតា។ ចំណែកឯការប្រើប្រាស់កម្លាំងពលកម្មវិញមានចំនួនច្រើនកន្លែងខ្លះមានការខ្វះខាតដីពីមួយឆ្នាំទៅមួយឆ្នាំ ព្រោះមានកំណើនប្រជាជនបន្តបន្ទាប់។ កម្លាំងពលកម្មភាគច្រើនមិនបានប្រើឱ្យអស់លទ្ធភាពទេ ដោយហេតុថាមូលធនដែលមានតិចតួចបានប្រើអស់លទ្ធភាពរួចទៅហើយ។

នៅកម្ពុជាដើមឡើយ មិនសូវមានអ្នកស៊ីឈ្នួលធ្វើស្រែទេ បើប្រៀបធៀបនឹងប្រទេសដទៃ ប៉ុន្តែតែឥឡូវនេះមានការប្រែប្រួលច្រើន។ ដោយសារប្រាក់ឈ្នួលមានកម្រិតទាប ការធ្វើកសិកម្មតាមបែបប្រពៃណី ជួនកាលក៏មានការខ្ចីកម្លាំងពលកម្មពីកន្លែងផ្សេងមកដែរ ដើម្បីបង្កើតពេលទំនេរ និងបង្កើនឋានៈក្នុងសង្គមដោយសារការចេញថ្លៃឈ្នួលតិចតួចនេះ។ ជាទូទៅ អ្នកមានស្រែឬចម្ការច្រើន (ទំហំធំ) តែងជួលដីតិចតួច ឬសល់កម្លាំងពលកម្មឱ្យទៅធ្វើការលើដីចម្ការ ឬដីស្រែរបស់ខ្លួន។ក្នុងករណីលើកលែងខ្លះនាពេលបច្ចុប្បន្ននេះ ដោយសារពលករមួយចំនួនបានចាកចេញពីវិស័យកសិកម្ម មករកមុខរបរផ្សេងទៀត នៅទីក្រុងបានផ្ញើប្រាក់កម្រៃរបស់ខ្លួនឱ្យឪពុកម្តាយនៅឯជនបទ ជួលអ្នកដទៃធ្វើការនៅលើស្រែចម្ការរបស់ខ្លួន។ នេះមិនមែនបានសេចក្តីថាក្រុមគ្រួសារនោះមានដីស្រែ ឬចម្ការធំទូលាយទេ តែមានកង្វះខាតកម្លាំងពលកម្ម។

**គ. ការងារតាមរដូវ**

ការប្រើប្រាស់កម្លាំងពលកម្ម ក្នុងកសិកម្មប្រពៃណីប្រែប្រួលខ្លាំងណាស់ ទៅតាមពេលវេលាគឺពេលខុសគ្នាតម្រូវការកម្លាំងពលកម្មខុសគ្នា។

ធម្មជាតិនៃផលិតកម្មកសិកម្ម ជាមូលហេតុនៃភាពខុសគ្នា តាមរដូវកាលរបស់ការប្រើប្រាស់ និងស្ថានភាពនៃការផ្គត់ផ្គង់ចំណីអាហារ។ បើយើងធ្វើការពិចារណាដល់គ្រួសារកសិករប្រកបមុខរបរដាំដំណាំស្រូវធ្ងន់ ឃើញថាពីខែមករា ដល់ខែឧសភា កសិករពុំសូវមានការងារធ្វើទេ តែមានស្បៀងច្រើននៅក្នុងជង្រុក តែផ្ទុយទៅវិញពីខែកក្កដា ដល់ខែតុលា ជាពិសេសការងាររបស់គេមានច្រើន តែស្បៀងហាក់ដូចជាខ្សត់ខ្សោយ។ ដោយសារការខ្វះខាតកន្លែងសម្រាប់ទុកដាក់ និងយន្តការសម្រាប់សន្សំ និងខ្ចីមិនទៀងទាត់ការប្រើប្រាស់ស្បៀងដូចជាយោងទៅតាមវដ្តនៃកសិកម្ម បានន័យថានៅរដូវវស្សាពេលមានកង្វះខាតស្បៀងកសិករ ធ្វើការខ្ចីបុលពីអ្នកដែលមានស្បៀងនៅរដូវច្រូតកាត់ ចាំបាច់ត្រូវសងទៅវិញ។ ម្ល៉ោះហើយផលដែលទទួលបានសេសសល់មិនច្រើនប៉ុន្មានតែនៅក្នុងជង្រុក។

ទោះជាកសិករមិនមានការងារធ្វើគ្រប់ពេលវេលាក៏ដោយ មួយចំនួនធំនៃអ្នកទាំងនោះមិនអាចមានលទ្ធភាពប្រកបមុខរបរផ្សេងទៀតបានឡើយ ជាពិសេសនៅប្រទេសកម្ពុជា ក្រៅពីឡើងត្នោត ឬរកអុសទុកដុតបន្តិចបន្តួច ព្រោះថាអ្នកទាំងនោះពុំមានចំណេះដឹងអ្វីផ្សេង ក្រៅពីធ្វើស្រែចម្ការ កង្វះខាតដើមទុន និងម៉្យាងទៀតពុំមានប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់សម្រាប់ធ្វើស្រែចម្ការនៅរដូវប្រាំង។

### ឃ. ផលិតភាព និងផលប្រយោជន៍

កសិកម្មប្រពៃណី ត្រូវបានកត់សម្គាល់ដោយការប្រើប្រាស់វត្ថុធាតុដើមបានទិញ ដោយតម្លៃមានកម្រិតទាបជាងការប្រើប្រាស់កម្លាំងពលកម្ម ពោលគឺការប្រើប្រាស់កម្លាំងពលកម្មមានច្រើន។ ទិន្នផលទាប ផលិតភាពរបស់មនុស្សម្នាក់ៗតិច និងកត្តាដទៃទៀតរបស់កសិកម្មប្រពៃណីកាន់តែទាប ។ ទាំងនេះមិនមែនបានសេចក្តីថាកសិកម្មប្រពៃណីផ្តល់ប្រយោជន៍តិចនោះទេ។

យើងធ្វើការប្រៀបធៀបដូចខាងក្រោម៖

| | **ឧស្សាហកម្ម** | **កសិកម្មប្រពៃណី** |
|---|---|---|
| *រយៈពេលផលិត* | ១ ឆ្នាំ | ១ ឆ្នាំ |
| *ធនធានមនុស្ស* | មានការបណ្តុះបណ្តាល<br>ប្រើប្រាស់ចំនួនតិច | គ្មានការបណ្តុះបណ្តាល<br>ប្រើប្រាស់ចំនួនច្រើន |
| *តម្លៃវត្ថុធាតុដើម* | តម្លៃខ្ពស់ | តម្លៃទាប<br>(ជី និងគ្រឿងបន្លាស់តិចតួច) |
| *ឧបករណ៍ផលិតកម្ម* | ទំនើប តម្លៃខ្ពស់ | ប្រពៃណី តម្លៃតិចតួច |

ធ្វើការពិចារណាលើរូបមន្តៈ ផលិតភាព = ផលិតផល / ចំណាយ ចំពោះកសិកម្មប្រពៃណី យើងឃើញថាការប្រើប្រាស់ធនធានតិចផលិតភាពទាបក៏ប៉ុន្តែផលប្រយោជន៍សេដ្ឋកិច្ចដែលបានមកខ្ពស់។ ទាំងនេះអាចទទួលបាននៅក្នុងលក្ខខណ្ឌមិនប្រែប្រួល។ បើសិនជាផលិតភាពចាំបាច់ត្រូវតែបង្កើនឡើងៈ

- បច្ចេកវិទ្យាថ្មីអាចជួយលទ្ធភាពផលិតកម្មដល់កសិករ
- ការសិក្សាអាចជួយកសិករឱ្យចេះថ្លឹងថ្លែងការប្រើប្រាស់ធនធានទៅនឹងការផ្លាស់ប្តូរលក្ខខណ្ឌក៏ដូចជាការទាញយកផលប្រយោជន៍ក្នុងកម្រិតខ្ពស់របស់ពួកគេដែរ។

**ខ. តួនាទីរបស់បសុសត្វ**

បសុសត្វមានតួនាទីយ៉ាងសំខាន់ ក្នុងកសិកម្មប្រពៃណី ភាគច្រើននៃអ្នកមានបំណងបង្កើនផលិតភាពបសុសត្វ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ពេលខ្លះមានការយល់ច្រឡំអំពីតួនាទីរបស់វា។

បសុសត្វជាបញ្ហាមួយដែលលើកយកមកពិចារណាដែរ ព្រោះថាដំណាំ និងសត្វប្រកួតប្រណាំងគ្នាចំពោះធនធាន តែមួយតាមធម្មជាតិ មនុស្សត្រូវការគ្រាប់ធុញ្ញជាតិ ជាងការផ្តល់ធញ្ញជាតិនោះឱ្យសត្វ ដើម្បីយកសាច់សត្វបរិភោគ។ ទោះជាយ៉ាងណាក៏ដោយនៅក្នុងកសិកម្មប្រពៃណីបសុសត្វមានតួនាទីយ៉ាងសំខាន់ជាច្រើនដូចជាៈ

**ទ្រនាប់ និងអ្នកពង្រីកនៃការផ្គត់ផ្គង់ចំណីអាហារៈ** សត្វពាហនៈនៃគ្រួសារកសិករ ផ្តល់នូវការការពារយ៉ាងពិសេសដល់អ្នកទាំងនោះ គឺមានតួនាទីជា ទ្រនាប់ រវាង គ្រួសារ និង ភាពមិនទៀងទាត់នៃការផ្គត់ផ្គង់ចំណីអាហារ។ សត្វពាហនៈគឺជា ធនាគារសន្សំ ។ កសិករអាចវិនិយោគទៅសត្វពាហនៈ នៅពេលដែលសត្វទាំងនោះធំធាត់កសិករអាចសម្លាប់ធ្វើជាចំណីអាហារ ឬលក់នៅពេលមានការរអាក់រអួលក្នុងការដាំដុះ។ នៅក្នុងកសិកម្មប្រពៃណីបសុសត្វមិនប្រកួតប្រណាំងដោយផ្ទាល់ជាមួយដំណាំទេ ព្រោះវាស៊ីតែកាកសំណល់របស់ដំណាំ ស៊ីអ្វីដែលកំពប់ប្រឡាក់ និងខូច និងជាទូទៅអ្វីដែល ពង្រីក ការផ្គត់ផ្គង់ចំណីអាហារតែប៉ុណ្ណោះ។ សត្វពាហនៈភាគច្រើនជាសត្វទំពារអៀង (គោ ក្របី សេះ ចៀម ពពែ) ស៊ីស្មៅជាអាហារ និងចំណីសត្វផ្សេងៗដែលមនុស្សមិនអាចនឹងកែច្នៃទៅជាផលិតផលសម្រាប់ការប្រើប្រាស់របស់គេ។ ជាការពិតណាស់ បសុសត្វផ្តល់នូវការរួមចំណែកយ៉ាងសំខាន់ សម្រាប់ពង្រីកគុណភាពនៃអាហាររូបត្ថម្ភតាមរយៈការផ្តល់សាច់ ទឹកដោះគោ និងស៊ុត។ ចំនួនដ៏តូចនៃអាហារប្រកបដោយប្រូតេអ៊ីនកម្រិតខ្ពស់ អាចមានឥទ្ធិពលយ៉ាងសំខាន់ដល់សុខភាពរបស់មនុស្ស។

**ជាប្រភពកម្តៅ ស្បែក និងរោម៖** លាមកសត្វពាហនៈគឺជាប្រភពយ៉ាងសំខាន់សម្រាប់ធ្វើជី និងជាប្រភពសម្រាប់កម្តៅក្នុងប្រទេសជាច្រើន។ លាមកសត្វបន្ថែមនូវជី និងរូបធាតុដល់ដី។ នៅក្នុងប្រទេស ឬតំបន់ខ្លះដែលពុំសូវសម្បូរឈើនោះ លាមកសត្វ ត្រូវបានគេយកទៅហាលហើយប្រើប្រាស់ជាប្រភពកម្តៅ។ នៅក្នុងប្រទេសជាច្រើន ប្រភេទនៃការប្រើប្រាស់លាមកសត្វទាំងពីរខាងលើមានការប្រកួតប្រជែងគ្នា។ លាមកសត្វដែលដុតហើយមិនអាចប្រើជាជីបានទេ។ បើយកធ្វើជីត្រូវខ្វះប្រភពកម្តៅ និងបញ្ច្រាសមកវិញ។ ផលិតផលសត្វមួយចំនួន ត្រូវបានគេយកមកប្រើយ៉ាងខ្ជះខ្ជាយនៅក្នុងសង្គមប្រពៃណី។ សម្លៀកបំពាក់ និងភួយអាចធ្វើពីស្បែកសត្វ និងរោមសត្វផ្សេងៗដូចជា គោ ក្របី ចៀម ពពែ និង បសុសត្វផ្សេងទៀត។

**កម្លាំង និងការដឹកជញ្ជូន៖** នៅក្នុងប្រទេសជាច្រើន បសុសត្វជាប្រភពចម្បងនៃកម្លាំង។ សត្វទាំងនោះជួយក្នុងការភ្ជួររាស់ស្រែ ដឹកជញ្ជូនផលិតផលទៅកាន់ទីផ្សារ និងបំពេញការងារផ្សេងៗ ដូចជា កិនអំពៅ ជាន់កណ្តាប់ស្រូវជាដើម។ ត្រាក់ទ័រគឺជាការរកឃើញថ្មីនៅក្នុងពិភពលោក។ ការវិនិយោគយ៉ាងធំធេង ដើម្បីទិញត្រាក់ទ័របានធ្វើឱ្យ កសិករប្រពៃណីមានការលំបាកយ៉ាងខ្លាំង។ ដូចនេះការជំនួសកម្លាំងសត្វពាហនៈ ដោយគ្រឿងយន្ត នៅក្នុងតំបន់ជាច្រើននៃប្រទេសកំពុងអភិវឌ្ឍន៍អាចទាមទាររយៈពេលច្រើនឆ្នាំ។

**សង្គម និងវប្បធម៌៖** បសុសត្វ ដោយឡែក គោ ក្របី និងពពែ មានតម្លៃយ៉ាងខ្ពស់ នៅក្នុងប្រទេសខ្លះសម្រាប់មូលហេតុសង្គម និងវប្បធម៌។ ឋានៈក្នុងសង្គមរបស់គ្រួសារមួយ គេអាចកំណត់តាមចំនួនសត្វពាហនៈរបស់គ្រួសារនោះ។ គោ ក្របី គឺជាវត្ថុអនុស្សាវរីយ៍ ឬរង្វាន់នៅក្នុងពិធីបុណ្យខ្លះៗ។ ដោយសារបសុសត្វមានតួនាទីសេដ្ឋកិច្ចយ៉ាងចម្បង។ សត្វទាំងនោះក៏មានតួនាទីផ្នែកសង្គម និងវប្បធម៌ដែរ។ ជាការពិតណាស់ តួនាទីនេះមានការវិវត្តន៍ដោយសារភាពសំខាន់របស់វាជាមូលធន និងទ្រព្យសម្បត្តិសម្រាប់រកប្រាក់ចំណូល។

# ជំពូកទី២

# ស្ថានភាពទូទៅនៃ

# វិស័យកសិកម្ម

# ជំពូកទី២
# ស្ថានភាពទូទៅនៃវិស័យកសិកម្ម

## ២.១ ស្ថានភាពសេដ្ឋកិច្ចប្រទេសកម្ពុជា[2]

ក្នុងលក្ខណៈជាសេដ្ឋកិច្ចបើកចំហតូចមួយ ស្ថានភាពសេដ្ឋកិច្ចកម្ពុជា ក្នុងពេលចំពោះមុខ វាអាស្រ័យលើបរិយាកាសខាងក្រៅ។ ពិតហើយ សេដ្ឋកិច្ចកម្ពុជាហាក់ចាប់ផ្តើមមានកំណើនយឺត ចាប់តាំងពីពេលមានវិបត្តិហិរញ្ញវត្ថុ សាកលឆ្នាំ២០០៨-០៩ មក ទោះជាមិនគិតបញ្ចូលនូវការធ្លាក់ចុះសេដ្ឋកិច្ចយ៉ាងគំហុកនៅឆ្នាំ២០០៩ក្តី។ កំណើនសេដ្ឋកិច្ចចំនួនបួនឆ្នាំ ពីឆ្នាំ២០០៨-១២ (មិនគិតឆ្នាំ២០០៩) មានជាមធ្យមប្រហែល ៦.៦% ដែលទាបជាងអត្រាប្រចាំឆ្នាំជាមធ្យម ១១% ពីឆ្នាំ ២០០៤-២០០៧ គឺនៅមុនពេលមានវិបត្តិសកល។ ការថយចុះកំណើនមាន លក្ខណៈកាន់តែធ្ងន់ធ្ងរថែមទៀត ក្នុងវិស័យមិនមែនកសិកម្ម ជាពិសេសវិស័យឧស្សាហកម្ម។ កំណើនប្រចាំឆ្នាំក្នុងវិស័យឧស្សាហកម្ម ដែលមានអត្រាជាមធ្យម ១៩% ពីឆ្នាំ២០០៤-០៧ បានធ្លាក់មកត្រឹម ៨.៥% ពីឆ្នាំ២០០៨-១២ (មិនគិតឆ្នាំ២០០៩)។ ដូច្នេះស្ថានភាពសេដ្ឋកិច្ចក្នុងពេលចំពោះមុខ វាផ្សារភ្ជាប់ជាខ្លាំងទៅនឹងកម្លាំងរើបឡើងវិញនៃសេដ្ឋកិច្ចសាកល។

នៅក្នុងឯកសារចេញផ្សាយនៅខែតុលា ២០១២ ស្តីពី អនាគតសេដ្ឋកិច្ចពិភពលោក IMF (International Monetary Fund: មូលនិធិរូបិយវត្ថុអន្តរជាតិ) បានប៉ាន់ស្មានថា ផសស ពិភពលោក មានកំណើនប្រហែល ៣.៦% នៅឆ្នាំ២០១៣ ឬកើនឡើងបន្តិច បើធៀបនឹងកំណើន ៣.៣% នៅឆ្នាំ២០១២។ ជារួម តួលេខនេះបង្ហាញពីការកែតម្រូវ បញ្ចុះយ៉ាងខ្លាំងនូវអត្រាកំណើន ផសស សាកល សម្រាប់ឆ្នាំ ២០១៣ ដែល IMF បានបញ្ជាក់ថាមានកម្រិត ៣.៩% និង ៤.១% តាមការព្យាករណ៍កាលពីខែកក្កដា ២០១២ និងមេសា ២០១២។ កំណើន ផសស នៅសហរដ្ឋអាមេរិករំពឹងថា កើនលើស ២% បន្តិច នៅឆ្នាំ២០១៣ រីឯកំណើន នៅតំបន់អឺរ៉ុប គេព្យាករណ៍ថាមានកម្រិតខ្សោយ ហើយ ផសស នៅប្រទេសជប៉ុន រំពឹងថា នឹងធ្លាក់ចុះពី ២.២% នៅឆ្នាំ២០១២ មកត្រឹម ១.១% នៅឆ្នាំនេះ។ ការព្យាករណ៍សម្រាប់ប្រទេស មានសេដ្ឋកិច្ចកំពុងលេចធ្លោឡើង នៅអាស៊ីមានតួលេខល្អ ប៉ុន្តែចំណងទាក់ទងច្រើនជាមួយ សហរដ្ឋអាមេរិក និងតំបន់អឺរ៉ូ ប្រហែលធ្វើឱ្យប្រទេសទាំងនោះ មិនមានកំណើនខ្លាំងក្លាប៉ុន្មានទេក្នុងឆ្នាំនេះ។

---

[2] CDRI, *សង្ខេបរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០១២-២០១៣* (ភ្នំពេញ៖ វ.ប.ស.ក, ២០១៣) ។

ដោយសារការព្យាករណ៍ ពីសេដ្ឋកិច្ចសាកលវាមិនសូវល្អនោះ ការនាំចេញរបស់កម្ពុជាទំនងមិនអាចស្ទុះឡើង បានច្រើនទេនៅឆ្នាំ២០១៣។ នាបច្ចុប្បន្ន ការនាំចេញរបស់កម្ពុជាទៅសហរដ្ឋអាមេរិក មានប្រហែល ៣៨% (ធៀបនឹង ៧០% ក្នុងឆ្នាំ២០០០) ទៅសហភាពអឺរ៉ុប ៣៥% (២០% ក្នុងឆ្នាំ២០០០) និងទៅប្រទេសផ្សេងទៀត ២៧% (១០% ក្នុងឆ្នាំ ២០០០)។ ការបន្តរើបសេដ្ឋកិច្ចយឺតៗនៅសហរដ្ឋអាមេរិក និងអឺរ៉ុប មិនផ្តល់ប្រផ្នូលល្អ សម្រាប់ការនាំចេញរបស់កម្ពុជានោះទេ។ យោងតាមនិន្នាការបច្ចុប្បន្ន ការនាំចេញទំនងកើនឡើងប្រហែល ២៦% ដែលស្រដៀងគ្នានឹងតួលេខ ឆ្នាំ ២០១២។ ចំណូលពីវិស័យទេសចរណ៍ ប្រហែលអាចរក្សាលំនឹងបានមួយរយៈដោយសារមួយចំណែក មានភ្ញៀវទេសចរមកពីកាន់តែច្រើន ប្រទេសឡើងចូលមកកម្ពុជាក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ ការអនុវត្តកម្មវិធី ទិដ្ឋការរួម រវាងថៃ និងកម្ពុជា (ទម្រង់អនុវត្តនៅអាស៊ាននៃគម្រូប្រព័ន្ធទិដ្ឋាការ Schengen របស់សហភាពអឺរ៉ុប) ដែលបានដាក់អនុវត្តនៅខែធ្នូ ២០១២ និងផ្លូវហោះហើរថ្មីរបស់ ក្រុមហ៊ុនអាកាសចរណ៍ Tiger Airline ពីភ្នំពេញ ទៅសិង្ហបុរី ដែលបានចាប់ដំណើរការក្នុងខែតុលា ២០១២ ទំនងអាចជួយដល់វិស័យទេសចរណ៍។

ដោយបន្តមានលទ្ធផលរឹងមាំក្នុងវិស័យអចលនទ្រព្យ និងសំណង់កម្ពុជាអាចរក្សាកំណើន ផសស សម្រាប់វិស័យកសិកម្មក្នុងអត្រាប្រហែល ៧.៥%។ ប្រសិនបើមិនមានគ្រោះធម្មជាតិអ្វីធ្ងន់ធ្ងរទេនោះ កំណើន ផសស ៤.៥%ក្នុងវិស័យកសិកម្ម ប្រហែលជាអាចរក្សាបាន។ តាមនេះកំណើន ផសស សរុប សម្រាប់ឆ្នាំ២០១៣ អាចមានប្រហែល ៧%។ អត្រាកំណើនទំហំប៉ុណ្ណោះមិនគួរដាក់សម្ពាធអ្វីជ្រុលទៅលើអតិផរណា ឬឱនភាពគណនីចរន្តនោះទេ ហើយគួរតែអាចជួយរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចបាន។

ទោះជាយ៉ាងណាក្តី ដូច IMF បានដាស់តឿនដែរ និន្នាការផុសឡើងមួយចំនួន ដូចជា ការរីកធំយ៉ាងឆាប់រហ័សនៃឥណទានធនាគារ ការថយចុះកម្លាំងខាងហិរញ្ញវត្ថុជាលទ្ធផលនៃចំណូលពន្ធធ្លាក់កំណើន និងបំណុលធំៗដែលអាចកើតមាន (ដោយសាររដ្ឋាភិបាលអនុវត្តគម្រោងជាដៃគូរវាងរដ្ឋ-ឯកជន ក្នុងវិស័យថាមពល) អាចបង្កជាហានិភ័យដល់ស្ថិរភាពម៉ាក្រូហិរញ្ញវត្ថុ ក្នុងប៉ុន្មានឆ្នាំខាងមុខនេះ។ ពិតហើយអ្នកគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវតែប្រុងប្រយ័ត្ន និងពិនិត្យតាមដានការវិវត្តផ្នែកឥណទានឱ្យបានដិតដល់។ ប៉ុន្តែអត្រាខ្ពស់នៃកំណើនឥណទាន ក្នុងប៉ុន្មានឆ្នាំថ្មីៗអាចបណ្តាលជាចម្បងមកពីកំណែទម្រង់រចនាសម្ព័ន្ធ ដូចជា ច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចនានាឆ្នាំ២០០៩ (លុបបំបាត់របាំងចំពោះការប្រើប្រាស់ចលនទ្រព្យធ្វើជាវត្ថុនានា) បទបញ្ញត្តិថ្មីដែល

អនុញ្ញាតឱ្យ ការិយាល័យឥណទាន ប្រមូល និងចែកចាយពត៌មានឥណទានវិជ្ជមាន និងអវិជ្ជមាន និងការបង្កើតការិយាល័យឥណទានដំបូងនៅកម្ពុជាក្នុងឆ្នាំ២០១២។

## ២.២ ការរួមចំណែកវិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ

### ២.២.១ កំណើនផលិតផលក្នុងស្រុកសរុប GDP ពីឆ្នាំ ២០០៧-២០១៦

ចាប់តាំងពីឆ្នាំ២០០៤ រហូតដល់ឆ្នាំ ២០០៧ ប្រទេសកម្ពុជាទទួលបាននូវកំណើនសេដ្ឋកិច្ចពីរខ្ទង់ជាប់គ្នាគួរជាទីពេញចិត្ត។ ពោលគឺ កំណើនGDP បានកើន ១០% នៅឆ្នាំ ២០០៤ កើនខ្លាំងនៅឆ្នាំ២០០៥ រហូតដល់ ១៣.៥% កំណើន GDP នៅឆ្នាំ២០០៦ បានធ្លាក់ចុះមកវិញត្រឹម ១០.៨% និងនៅឆ្នាំ២០០៧ កំណើន GDP មានប្រមាណ ១០.២%។ នេះក៏អាស្រ័យដោយការចូលរួមចំណែកដ៏ធំមួយនៃវិស័យកសិកម្មផងដែរ។ ប៉ុន្តែដោយសារវិបត្តិសេដ្ឋកិច្ចពិភពលោក ដែលបានកើតឡើងនៅពាក់កណ្តាលឆ្នាំ២០០៨ បានធ្វើឱ្យកំណើនដែលធ្លាប់មានពីរខ្ទង់ ធ្លាក់ចុះត្រឹមតែ ៦.៨%។ ក្នុងនោះ វិស័យកសិកម្មក៏បានទទួលនូវវិបត្តិហិរញ្ញវត្ថុផងដែរ។ ជាក់ស្តែង ចាប់ពីដើមឆ្នាំរហូតដល់ពាល់កណ្តាលឆ្នាំ២០០៨ តម្លៃម្ហូមអាហារបានកើនឡើងយ៉ាងគំហុកពី ១៥-២៥% ស្របជាមួយការឡើងនៃតម្លៃប្រេងលើពិភពលោក និងមធ្យោបាយផលិតកម្មកសិកម្ម ប៉ុន្តែត្រូវបានធ្លាក់ចុះមកវិញចាប់ពីជាងពាក់កណ្តាល ឆ្នាំរហូតដល់ចុងឆ្នាំ២០០៨ (ត្រឹម១៥-១៧.៥%)។ ជាដំណោះស្រាយដ៏សមស្រប រាជរដ្ឋាភិបាល បានផ្តល់នូវការឧបត្ថម្ភធនលើការនាំចូលប្រេងឥន្ទនៈ ផ្តល់ការឧបត្ថម្ភធនរយៈពេលខ្លីលើការផលិតថាមពលអគ្គិសនី ដើម្បីរក្សាតម្លៃនៅថេរ ការផ្តល់ហិរញ្ញប្បទានពិសេសដោយធនាគារអភិវឌ្ឍន៍ជនបទ ដល់រោងម៉ាស៊ីនកិនស្រូវឯកជន ដើម្បីជាទុនទិញស្រូវពីកសិករសម្រាប់កិនផ្គត់ផ្គង់ តម្រូវការហូបចុកក្នុងស្រុក (មានទឹកប្រាក់ ១២លានដុល្លារអាមេរិកនៅឆ្នាំ២០០៨)។

សេដ្ឋកិច្ចកម្ពុជា បន្តមានភាពរឹងមាំ ហើយកំណើនសេដ្ឋកិច្ច ត្រូវបានរំពឹងថានឹងបន្តមានអត្រាខ្ពស់ ក្នុងរយៈពេលមធ្យមខាងមុខ។ ក្នុងឆ្នាំ ២០១៥ បើទោះជាជួបប្រទះនូវកត្តាហានិភ័យខាងក្រៅ និងបញ្ហាប្រឈមក្នុងស្រុកមួយចំនួនក្តី ក៏កម្ពុជានៅតែអាចរក្សាបាននូវកំណើនសេដ្ឋកិច្ចដ៏រឹងមាំក្នុងអត្រា ៧% ដោយសារកំណើនដ៏ខ្ពស់នៃវិស័យឧស្សាហកម្ម ដែលជួយបំពេញបន្ថែមដល់ការថមថយកំណើននៃវិស័យកសិកម្ម និងសេវាកម្ម។ យោងតាមទិន្នន័យស្ថិតិផ្លូវការក្នុងរយៈពេល ៦ ខែដើមឆ្នាំ ២០១៦ របស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ, សេដ្ឋកិច្ចកម្ពុជា ក្នុងឆ្នាំ ២០១៦ ត្រូវបានប៉ាន់ស្មានថា នឹងរក្សាបានកំណើនក្នុងរង្វង់៧%។ ក្នុងនោះ វិស័យឧស្សាហកម្មនៅតែមានកំណើនរឹងមាំក្នុងអត្រាពីរខ្ទង់ដដែល ពោលគឺប្រមាណ ១១.៥%និងបន្តដើរតួនាទីជាក្បាលម៉ាស៊ីនជំរុញ

កំណើនសេដ្ឋកិច្ចទីមួយ ដែលវិស័យនេះនៅតែបន្តដឹកមុខដោយវិស័យកាត់ដេរ បើទោះបីជាវិស័យសំណង់មានការថមថយបន្តិចក្តី។ វិស័យសេវាកម្មអាចនឹងមានកំណើន យឺតជាងឆ្នាំមុនជាមួយនឹងអត្រាកំណើន ៦.៧% ដោយសារការបន្តថមថយនៃ វិស័យទេសចរណ៍, និងវិស័យអចលនទ្រព្យ និង ជំនួញខណ:ដែលវិស័យកសិកម្មអាចនឹងមានកំណើនល្អជាងឆ្នាំ២០១៥ បន្តិចពោលគឺក្នុងអត្រា ០.៥% ដោយសារតែកត្តាអាកាសធាតុ ដែលមានស្ថានភាពល្អប្រសើរជាងឆ្នាំមុន។

បើយោងតាម IMF ក៏បានបន្ថែមថា កាលពីឆ្នាំ២០១៣ អត្រាអតិផរណា ៤.១ភាគរយ នឹងធ្លាក់មកនៅ ៣ភាគរយក្នុងឆ្នាំនេះ ក្នុងនោះការនាំចេញនឹងកើនពី៦.៧ពាន់លានដុល្លារ ដល់៨ពាន់លានដុល្លារ ហើយការនាំចូលនឹងកើនពី ៩.៧ពាន់លានដុល្លារ ដល់ ១១.១៣ពាន់លានដុល្លារ[3]។ ក្នុងឆ្នាំ២០១៦នេះ ផសស ថ្លៃបច្ចុប្បន្នត្រូវបានប៉ាន់ស្មានថា នឹងកើនឡើងដល់ ១៩,៨៤៣ លានដុល្លារអាមេរិក ដែលធ្វើឱ្យ ផសស សម្រាប់មនុស្សម្នាក់អាចនឹងកើនឡើងដល់ ១,៣០០ ដុល្លារអាមេរិក។ លើសពីនេះ កម្ពុជាអាចរក្សាបាននូវអតិផរណា ដែលស្ថិតក្នុងកម្រិតទាប និងអាចគ្រប់គ្រងបាន ដោយអតិផរណាជាមធ្យមប្រចាំឆ្នាំ ត្រូវបានប៉ាន់ស្មានថា នឹងមានអត្រា ២.៨ ភាគរយក្នុងឆ្នាំ ២០១៦ ដោយសារនិន្នាការកើនឡើងនៃថ្លៃប្រេងក្នុងទីផ្សារអន្តរជាតិ។ ជាមួយគ្នានេះដែរ អត្រាប្តូរប្រាក់នៅបន្តមានស្ថិរភាព ជាមួយនឹងការរំពឹងទុកថា ប្រាក់រៀល នឹងនៅបន្តរក្សាបាននូវតម្លៃ ប្រមាណ ៤,០៥០ រៀលក្នុង ១ ដុល្លារអាមេរិក នៅក្នុងឆ្នាំ ២០១៦[4]។

ក្រាហ្វិកទី ២.១៖ បង្ហាញអំពីកំណើន GDP ពីឆ្នាំ ២០០៧-២០១៦[5]




[3] សារពត៌មានកោះសន្តិភាព, *កំណើនផលិតផលក្នុងស្រុកសរុប GDP នៅកម្ពុជាក្នុងឆ្នាំ២០១៤ នឹងកើនឡើង ៧.២%* , ផ្សាយថ្ងៃទី៥ ខែកុម្ភ: ឆ្នាំ២០១៤, https://kohsantepheapdaily.com.kh/article/89700.html ។

[4] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, *ការវាយតម្លៃកំណើនសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០១៦*, ចូលមើលថ្ងៃទី៣០ ធ្នូ ២០១៦, http://www.mef.gov.kh/ ។

[5] ប្រភព៖ ស្រង់ចេញពីគេហទំព័រ http://www.tradingeconomics.com/cambodia/gdp-growth-annual។

ចាប់ពីឆ្នាំ២០១០ កំណើន GDP មានការកើនឡើងវិញប្រមាណ ៦% ហើយចាប់ពីឆ្នាំ ២០១១-២០១៦ អត្រាកំណើននៃ GDP អាចរក្សាបានក្នុងរង្វង់៧% ដោយសារកំណើន ដ៏ខ្ពស់នៃវិស័យឧស្សាហកម្ម ដែលជួយបំពេញបន្ថែម ដល់ការថមថយកំណើននៃវិស័យកសិកម្ម និងសេវាកម្ម។

### ២.២.២ ការបែងចែកនៃ GDP តាមវិស័យសំខាន់ៗឆ្នាំ ២០១៥

វិស័យកសិកម្ម បានរួមចំណែកប្រហែល ២៩.៧% នៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ ២០០៧ និងកើនឡើងដល់ ៣៩.៤% ក្នុងឆ្នាំ ២០០៨។ ខណៈដែលវិស័យឧស្សាហកម្មបានរួមចំណែកប្រមាណ ៣០.២% នៅឆ្នាំ២០០៧ និងធ្លាក់ចុះមកវិញត្រឹម ២៣.៨% ក្នុងឆ្នាំ២០០៨ និងសេវាកម្មមានចំណែក ៨១.៣% នៅឆ្នាំ២០០៧ និង ៨១.៨% ក្នុងឆ្នាំ២០០៨។

ក្រាហ្វិកទី ២.២៖ ការបែងចែកនៃ GDP តាមវិស័យសំខាន់ៗឆ្នាំ ២០១៥




វិស័យកសិកម្ម បានរួមចំណែកប្រហែល ២៨.៩% នៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ ២០១៤ ហើយកំណើននេះបានថយចុះបន្តិចត្រឹម ២៨.៦% នៅឆ្នាំ ២០១៥។ ដោយឡែក វិស័យឧស្សាហកម្មបានរួមចំណែកប្រមាណ ២៥.៦% នៅឆ្នាំ២០១៤ និងកើនឡើងដល់ ២៩.៧% ក្នុងឆ្នាំ ២០១៥ និងវិស័យសេវាកម្មមានប្រហែល ៣៩.៧% ក្នុងឆ្នាំ២០១៤ និងបានកើនឡើងដល់ ៤១.៧% ក្នុងឆ្នាំ២០១៥។ ការកើនឡើង ឬថយនូវចំណែកនៃការចូលរួមរបស់វិស័យកសិកម្ម គឺអាស្រ័យទៅនឹងការរីកលូតលាស់ នៃផ្នែកពីរសំខាន់ផ្សេងៗទៀតក្នុងវិស័យសេដ្ឋកិច្ច (វិស័យឧស្សាហកម្ម សំណង់ និងវិស័យសេវាកម្ម) ដែលជាការកត់សម្គាល់នាពេលកន្លងមក ការចូលរួម

ចំណែករបស់វិស័យកសិកម្មមានការប្រែប្រួលពី ៣៤.៦%-២៨.៦% ក្នុងចន្លោះឆ្នាំ ២០១១-២០១៥ ដោយសារតែវិស័យឧស្សាហកម្ម សំណង់ និងវិស័យសេវាកម្មមានការកើនឡើង[6]។

**២.២.៣ អត្រាភាគរយផ្នែកកសិកម្មក្នុង GDP ចាប់ពីឆ្នាំ ២០១១-២០១៥**

អត្រាភាគរយនៃ GDP ផ្នែកកសិកម្មគឺ មានការថយចុះពី ៤១.៥% នាឆ្នាំ ១៩៩៩ មកនៅត្រឹម ២៩.៦% នៅឆ្នាំ ២០០៦ និងមានការកើនឡើង ២៩.៧% នៅឆ្នាំ ២០០៧ និង ៣៤.៤% ឆ្នាំ ២០០៨។ តែវិស័យនេះបានរើបឡើងវិញពី ២៩.៧% នៅឆ្នាំ២០០៧ មក ៣៤.៤% នៅឆ្នាំ២០០៨ ក៏ដោយសារតែវិស័យឧស្សាហកម្ម និងសេវាកម្មមានជួបនូវវិបត្តិហិរញ្ញវត្ថុ។ បើពិនិត្យឱ្យច្បាស់ទៀតនោះ តម្លៃបន្ថែមសរុបនៃផលិតផលកសិកម្មបានកើនឡើងពី ៥.០៧៨ ពាន់លានរៀល នៅឆ្នាំ ១៩៩៩ រហូតដល់ ៧.១៧៤ ពាន់លានរៀលនៅឆ្នាំ ២០០៧ (កើនប្រហែល ៤០%) និងបានបន្តកើនថែមទៀតដល់ ៧.៥៦២ពាន់លានរៀល ឆ្នាំ២០០៨។ ផលដែលទទួលបាននោះគឺ នៅឆ្នាំ ១៩៩៨ កំណើនផ្នែកកសិកម្មមានប្រមាណ ៥.២% នៅឆ្នាំ២០០១ កើនក្នុងរង្វង់ ៣.៦% ឆ្នាំ២០០៣ កើនប្រហែល ១០.៥%ឆ្នាំ២០០៥ កើនខ្លាំងរហូតដល់ ១៥.៧% ឆ្នាំ២០០៦ កើនប្រមាណ៥.៥% និងឆ្នាំ២០០៧ ប្រហែល ៥.១%។ ដោយឡែក នៅឆ្នាំ២០០៨ កំណើនមានប្រហែល ៥.៤%។ គួរកត់សម្គាល់ថា នៅឆ្នាំ ២០០០ ២០០២ និង ២០០៤ កំណើនផ្នែកកសិកម្មជាចំនួនវិជ្ជមាន នេះគឺអាស្រ័យដោយការជួបប្រទះធ្ងន់ធ្ងរពីកត្តាធម្មជាតិ ដែលរួមមាន ទឹកជំនន់ រាំងស្ងួត និងការបំផ្លាញដំណាំដោយសត្វចង្រៃ។

ក្រាហ្វិកទី ២.៣៖ អត្រាភាគរយនៃផ្នែកកសិកម្មក្នុង GDP ចាប់ពីឆ្នាំ ២០១១-២០១៥




ប្រភព៖ របាយការណ៍បូកសរុបការងារឆ្នាំ២០១៥-២០១៦ របស់ក្រសួងកសិកម្ម ទំព័រទី៩

[6] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ២០១៥-២០១៦* (ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ២០១៦), ៩។

តាមក្រាហ្វិកខាងលើបង្ហាញថា អត្រាភាគរយនៃ GDP ផ្នែកកសិកម្មគឺ មាននិន្នាការថយចុះពី ៣៤.៦% នៅឆ្នាំ២០១១ ហើយបានបន្តថយចុះពី ៣៣.៥% នៅឆ្នាំ២០១២ មកនៅត្រឹម ៣១.៦% នាឆ្នាំ២០១៣។ នៅឆ្នាំ២០១៤ ក៏បានបន្តធ្លាក់ចុះមកនៅត្រឹម២៨.៩% និង ២៨.៦% នៅឆ្នាំ២០១៥។ នេះមិនមែនមានន័យថា វិស័យកសិកម្មមានការធ្លាក់ចុះនោះទេ តែជាការរីកចម្រើនវិស័យឧស្សាហកម្ម និង សេវាកម្ម ដែលធ្វើឱ្យចំណែកនៃវិស័យកសិកម្មរួមតូច។

ក្រាហ្វិកទី ២.៤៖ កំណើនភាគរយនៃវិស័យកសិកម្មចាប់ពីឆ្នាំ ២០០៨-២០១២




ប្រភព៖ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ខែមេសា ឆ្នាំ២០១៣

នាពេលបច្ចុប្បន្ន ទោះបីជាវិស័យកសិកម្មប្រឈមមុខ ជាមួយតម្រូវការស្បៀងអាហារកើនឡើង តាមកំណើនប្រជាជនយ៉ាងរហ័ស ការរងសម្ពាធលើធនធានធម្មជាតិ បម្រែបម្រួលអាកាសធាតុ និងការប្រកួតប្រជែងទីផ្សារផលិតផលកសិកម្ម។ល។ កំណើននៃវិស័យកសិកម្ម ជាទូទៅមានការប្រែប្រួលខ្លាំងអាស្រ័យទៅលើការ ប្រែប្រួលនៃអាកាសធាតុ។ ទោះជាយ៉ាងណាក៏វិស័យកសិកម្មកម្ពុជាធានាបាន កំណើនជាមធ្យមប្រចាំឆ្នាំប្រមាណពី ៤%ទៅ ៥% នៅចន្លោះឆ្នាំ ២០០៨-២០១២ និងកំណើនជាមធ្យមប្រមាណ ៤.៣% ក្នុងឆ្នាំ២០១២[7]។

### ២.២.៤ សមាសភាគ GDP នៃអនុវិស័យក្នុងវិស័យកសិកម្ម

នៅក្នុងឆ្នាំ២០០៨ ដំណាំគ្រប់ប្រភេទចូលរួមជាងពាក់កណ្តាល ៥២.៧% នៃផលិតផលសរុបរបស់វិស័យកសិកម្ម។ នេសាទមានចំណែក ២៥% ផលិតកម្មសត្វបានចូលរួម ១៥.៥% និង

[7] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *សមិទ្ធផលសំខាន់ៗរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* (ភ្នំពេញ៖ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, វិច្ឆិកា ២០១៣), ១។

ព្រៃឈើនិងអាជីវកម្មមានត្រឹមតែ ៦.៩%ប៉ុណ្ណោះ។ ក្នុងឆ្នាំ២០០៨ កម្ពុជាបានប្រកាសថាខ្លួននៅសល់អង្ករ ២លានតោន (គិតជាស្រូវប្រមាណជា ៣លានតោន)។ នេះមិនមែនជាលើកទីមួយទេ ដែលកម្ពុជានៅសល់ស្បៀង ប៉ុន្តែជាង ១០ឆ្នាំកន្លងមកនេះ កម្ពុជាផលិតស្រូវលើសរហូត[8]។

ក្រាហ្វិកទី ២.៥៖ សមាសភាគ GDP នៃអនុវិស័យក្នុងវិស័យកសិកម្មឆ្នាំ២០១៥




ប្រភព៖ របាយការណ៍បូកសរុបការងារឆ្នាំ២០១៥-២០១៦ របស់ក្រសួងកសិកម្ម ទំព័រទី៨

នៅក្នុងឆ្នាំ ២០១៥ ផលិតកម្មដំណាំគ្រប់ប្រភេទចូលរួមជាងពាក់កណ្តាល ពោលគឺកើនដល់ ៦០% នៃផលិតផលសរុបរបស់វិស័យកសិកម្ម។ ផលិតកម្មនេសាទ បានចូលរួមចំណែកបន្ទាប់ពីដំណាំ គឺមានប្រមាណ ២២% ផលិតកម្មសត្វបានចូលរួម១១% និងអាជីកម្មព្រៃឈើប្រមាណ៧%។ នៅក្នុងចំណែកនៃផលិតកម្មដំណាំគ្រប់មុខ ស្រូវគឺជាចំណែកដ៏ធំ ដែលផ្គត់ផ្គង់ដល់ការរស់នៅរបស់ប្រជាកសិករជនបទ។ ក្នុងឆ្នាំ២០១២កន្លងទៅនេះ ផលិតផលស្រូវសរុបចំនួនប្រមាណ ៩.២៩លានតោន និងមានសល់ស្បៀងអាហារក្រៅពីហូបចុកគិតជា ស្រូវប្រមាណ ៤.៧៣លានតោន និងគិតជាអង្ករសល់ប្រមាណជាង ៣លានតោនសម្រាប់នាំចេញ[9]។

សមាសភាពផ្នែកដំណាំមានការកើនឡើងខ្លាំង ដែលមានចំនួន ៤៦.១% នៅឆ្នាំ២០០៤ ឆ្នាំ២០០៥ មានចំនួន ៥០.៩% ឆ្នាំ២០០៦ ថយចុះបន្តិច ៥០.៨% បើធៀបនឹងឆ្នាំ ២០០៥ តែបើគិតរយៈពេលបីឆ្នាំចុងក្រោយ (២០០៦-២០០៨) សមាសភាគនៃដំណាំមានការកើនឡើងពី ៥០.៨% (ឆ្នាំ២០០៦) រហូតដល់ ៥២.៧% នៅឆ្នាំ២០០៨។ ចំពោះសមាសភាគផ្នែកជលផល មានការថយ

---

[8] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ២០០៨-២០០៩* (ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ២០០៩), ១។

[9] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *សមិទ្ធផលសំខាន់ៗរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* (ភ្នំពេញ៖ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, វិច្ឆិកា ២០១៣), ១។

ចុះពី ២៨.៨%នាឆ្នាំ២០០៤ រហូតដល់ ២៤.៨%នាឆ្នាំ២០០៧ ដោយទទួលរងនូវកត្តាជះឥទ្ធិពលផ្សេងៗ និងមានការកើនវិញចំនួន ២៥.0% នៅឆ្នាំ២០០៨។ ដោយឡែកសមាសភាគផ្នែកព្រៃឈើ និង អាជីវកម្មមានការថយចុះ បើធៀបនឹងឆ្នាំ២០០៤ ពី៨.១% (ឆ្នាំ២០០៤) មកត្រឹមតែ ៦.៩% នៅឆ្នាំ ២០០៨។ រីឯសមាសភាគផ្នែកបសុសត្វមានការប្រែប្រួល និងថយចុះបន្តិចបន្តួចបើធៀបរយៈពេល ៥ឆ្នាំកន្លងទៅនេះ។

ក្រាហ្វិកទី ២.៦៖ ការចូលរួមចំណែកនៃអនុវិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ ឆ្នាំ២០១១-២០១៥




ប្រភព៖ របាយការណ៍បូកសរុបការងារឆ្នាំ២០១៥-២០១៦ របស់ក្រសួងកសិកម្ម ទំព័រទី៩

នៅក្នុងឆ្នាំ ២០១៥ ការចូលរួមចំណែក នៃអនុវិស័យក្នុងផលិតផលក្នុងស្រុកសរុប (GDP) រួមមាន៖ ផ្នែកដំណាំ ១៥.៨% ផ្នែកផលិតកម្មសត្វ ៣% ផ្នែកជលផល ៥.៩% និងផ្នែកព្រៃឈើ ១.៨%។ ជាការកត់សម្គាល់ ផលិតកម្មដំណាំ និងជលផល គឺជាកម្លាំងចលករនាំមុខក្នុងផលិតកម្មកសិកម្ម។ ផលិតកម្មសត្វ គឺជាមុខព្រួញសំខាន់មួយទៀត ក្នុងការផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងនាំចេញ ដែលផ្នែកនេះត្រូវជំរុញអភិវឌ្ឍន៍ឱ្យបានខ្លាំងក្លាផងដែរ។

## ២.៣ ការវិវឌ្ឍនៃផលិតកម្មកសិកម្មទៅតាមបណ្តាអនុវិស័យ

### ២.៣.១ ការវិវឌ្ឍនៃផលិតកម្មដំណាំស្រូវ ២០១១-២០១៦

ដំណាំស្រូវ គឺជាដំណាំដ៏ចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃរបស់មនុស្ស។ បញ្ហាដំណាំស្រូវ ជាបញ្ហាចម្បងមួយដែលត្រូវយកចិត្តទុកដាក់ ពីព្រោះវាជាបញ្ហា ដែលតែងតែកើតមាននៅក្នុងប្រទេសក្រីក្រនានាលើពិភពលោក។ ជាការពិតណាស់ នៅក្នុងប្រទេសកម្ពុជាយើង បញ្ហាដំណាំស្រូវ និងភាពក្រីក្រ គឺមានទំនាក់ទំនងគ្នាយ៉ាងស្អិទ្ធ ហើយជារៀងរាល់ឆ្នាំ ប្រទេសកម្ពុជាមានការវិវឌ្ឍន៍កើនឡើងនៃផលិតកម្មដំណាំស្រូវគួរឱ្យកត់សម្គាល់។

នៅឆ្នាំ២០០៨ ផ្ទៃដីដាំដុះសរុបទូទាំងប្រទេសមានប្រមាណ ២,៦១៥,៧៥១ហិកតា គឺលើសឆ្នាំមុន ២៩,៨៣៦ ហិកតា ដែរក្នុងនោះ រដូវវស្សាអនុវត្តបាន ២,២៥៥,១០៥ហិកតា និងខ្ពស់ជាងមធ្យមភាគ ១០ឆ្នាំ (១៩៩៩-២០០៨) ចំនួន ២៦៥,១២៥ ហិកតា។ ចំណែកឯផ្ទៃដីខូចខាតសរុបមានចំនួន ៣,១៦៣ ហិកតា ក្នុងនោះរដូវវស្សាខូចខាត ៣,១៥៦ ហិកតា តែស្តារបានវិញ ៧៨៥ ហិកតា។ ចំពោះផ្ទៃដីប្រមូលផលសរុបវិញមានចំនួន ២,៦១៣,៣៦៣ហិកតា លើសឆ្នាំមុន ៨៦,៥១១ ហិកតា ក្នុងនោះរដូវវស្សា ២,២៥២,៧៣៣ ហិកតា លើសឆ្នាំមុន ៣០,១៣៧ ហិកតា។ ដែលទិន្នន័យមធ្យមប្រចាំឆ្នាំមាន ២.៧៥ តោន/ហាត លើសឆ្នាំមុន ០.១៣ តោន/ហាត ដែលក្នុងនោះរដូវវស្សា ២.៥តោន/ហាត (លើសឆ្នាំមុន ០.១២៧តោន/ហាត) និងរដូវប្រាំង៥.០៣តោន/ហាត។ បើមើលទៅលើ បរិមាណផលទទួលមានចំនួនសរុប ៧,១៧៥,៤៧៣ តោន លើសឆ្នាំមុន ៤៨៨,៣៨៦តោន ក្នុងនោះរដូវវស្សា ៥,៧២២,១៤២ តោន (លើសឆ្នាំមុន ៣៥៨,៨៥២ តោន) និងរដូវប្រាំងឆ្នាំ២០០៨-២០០៩ ចំនួន ១,៤៥៣,៣៣១ តោន។ ដោយទូទាត់ផ្សេងៗទៅតុល្យភាពស្បៀង នៅសល់ចំនួន ២,០២៥,០៣៣តោនអង្ករ គិតជាស្រូវ ៣,១៦៥,១១៥តោន លើសឆ្នាំមុនចំនួន ៥៨៦,៥៥២តោនស្រូវ ហើយខ្ពស់ជាងមធ្យមភាគ ១០ឆ្នាំកន្លងមកចំនួន ២,៣០៥,៥៦៣ តោនអង្ករ[10]។

ចាប់តាំងពីឆ្នាំ ១៩៩៩ ដល់ ២០០៨ បរិមាណផលសរុបប្រចាំឆ្នាំ ក៏ដូចជាបរិមាណស្រូវរដូវវស្សា និងស្រូវរដូវប្រាំង មានការកើនឡើងជាលំដាប់រហូតដល់ឆ្នាំ ២០០៨។ ប៉ុន្តែបរិមាណផលនៅឆ្នាំ២០០២ និងឆ្នាំ ២០០៤ មានការថយចុះបើប្រៀបធៀបទៅនឹងឆ្នាំ២០០១ និងឆ្នាំ២០០៣ ដោយសារជួបប្រទះនូវគ្រោះធម្មជាតិ រាំងស្ងួតអូសបន្លាយ ចាប់ពីពាក់កណ្តាលរដូវរហូតដល់ចុងរដូវ។ នៅឆ្នាំ ២០០៨ បរិមាណផលសរុបគឺ កើនឡើងប្រមាណ ៤៨៨,៣៨៦ តោន ស្មើនឹង ៦.៦% បើធៀបនឹងឆ្នាំ២០០៧ នេះដោយសារអាកាសធាតុល្អ ការផ្លាស់ប្តូរ បច្ចេកទេស និងពូជ ដែលមានបរិមាណផលខ្ពស់។ ជាពិសេស នៅឆ្នាំ ២០០៨ យើងអាចនៅសល់ស្បៀងជាអង្ករប្រមាណជាង ២ លានតោន បើគិតជាស្រូវប្រមាណជាង ៣លានតោន។

[10] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ២០០៨-២០០៩* (ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ២០០៩), ២៣។

តារាងទី ២.១៖ បង្ហាញពីការប្រៀបធៀបកំណើនដំណាំស្រូវប្រចាំឆ្នាំ ២០១១-២០១៦

| បរិយាយ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦[11] |
|---|---|---|---|---|---|---|
| ផ្ទៃដីដាំដុះ(ហ.ត) | 2,968,529 | 3,007,545 | 3,052,420 | 3,055,507 | 3,051,412 | 3,090,000 |
| ផ្ទៃដីប្រមូលផល(ហ.ត) | 2,766,617 | 2,980,297 | 2,968,967 | 3,028,836 | 3,025,630 | 3,080,000 |
| ទិន្នផល(តោន/ហ.ត) | 3.173 | 3.117 | 3.163 | 3.079 | 3.085 | 3.189 |
| បរិមាណផល(តោន) | 8,779,365 | 9,290,940 | 9,389,961 | 9,324,416 | 9,335,284 | 9,820,000 |
| បរិមាណអង្ករសល់ | 2,780,328 | 3,031,017 | 3,090,452 | 3,013,783 | 2,975,809 | 3,200,000 |
| គិតជាស្រូវសល់ | 4,344,263 | 4,735,964 | 4,828,832 | 4,709,036 | 4,649,702 | 4,990,000 |

ប្រភព៖ របាយការណ៍បូកសរុបការងារឆ្នាំ២០១៥-២០១៦ របស់ក្រសួងកសិកម្ម ទំព័រទី១២, និង របាយការណ៍សង្ខេបស្តីពី សមិទ្ធផលសំខាន់ៗមួយចំនួនរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១២-២០១៦ ទំព័រទី ២១។

ជាលទ្ធផលជាក់ស្តែង ផលិតកម្មដំណាំស្រូវ ក្នុងឆ្នាំ២០១៥-២០១៦ អនុវត្តបានលើផ្ទៃដីចំនួន ៣,០៥១,៤១២ ហិកតា។ ផ្ទៃដីអាចប្រមូលផលបានមានចំនួនប្រមាណ ៣,០២៥,៦៣០ ហិកតា និងបរិមាណផលសរុបទទួលបានចំនួន ៩,៣៣៥,២៨៤ តោន។ ទិន្នផលមធ្យមប្រចាំឆ្នាំ ២០១៥ ទទួលបានមានចំនួន ៣.០៨៥តោន/ហ.ត។ អតិរេកស្បៀងគិតជាអង្ករមានចំនួនប្រមាណ ២,៩៧៥,៨០៩ តោន ឬស្មើនឹង ៤,៦៤៩,៧០២ តោនស្រូវ (សូមមើលផ្នែកឧបសម្ព័ន្ធ ១)។

ក្រាហ្វិកទី ២.៧៖ បង្ហាញអំពីផ្ទៃដីដាំដុះដំណាំស្រូវឆ្នាំ២០១១-២០១៥




ប្រភព៖ របាយការណ៍បូកសរុបការងារឆ្នាំ២០១៥-២០១៦ របស់ក្រសួងកសិកម្ម ទំព័រទី១០

[11] តួលេខស្រង់ចេញពី របាយការណ៍សង្ខេប ស្តីពីសមិទ្ធផលសំខាន់ៗមួយចំនួនរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១២-២០១៦, ទំព័រទី ២១។

ក្រាហ្វិកទី ២.៨៖ បង្ហាញអំពីផ្ទៃដីប្រមូលផលដំណាំស្រូវឆ្នាំ២០១១-២០១៦




ប្រភព៖ របាយការណ៍បូកសរុបការងារឆ្នាំ២០១៥-២០១៦ របស់ក្រសួងកសិកម្ម ទំព័រទី១០

ការបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៥ មានផ្ទៃដីសរុបចំនួន ៧០,១២១ហិកតា តិចជាងឆ្នាំមុនចំនួន ៩៣,២៤១ ហិកតា។ ការងារប្រមូលផលស្រូវរដូវវស្សា សម្រេចបានលើផ្ទៃដីសរុបចំនួន ២,៥៣៦,១៧៥ហិកតា តិចជាងឆ្នាំមុនចំនួន ១,៨០១ ហិកតា ដោយទទួលបានបរិមាណផលប្រមាណ ៧,១៧០,៦៨៤តោន លើសឆ្នាំមុនចំនួន ២៧,១៦៣តោន។ ទិន្នផលជាមធ្យម ២.៨២៧ តោន/ហ.ត (ឆ្នាំមុនទិន្នផលមធ្យម ២.៨១៥ តោន/ហ.ត)។ ចំណែកឯការបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៥-២០១៦ ផ្ទៃដីអនុវត្តបានមានចំនួន ៤៨៩,៤៥៥ ហិកតា តិចជាឆ្នាំមុន ១,៤៨០ ហិកតា។ ផ្ទៃដីប្រមូលផលសម្រេចបានចំនួន ៤៨៩,៤៥៥ ហិចតា តិចជាឆ្នាំមុន ១,៤០៥ ហិកតា ហើយបរិមាណផលទទួលបានចំនួន ២,១៦៤,៦០០តោន តិចជាងឆ្នាំមុន ១៦,២៩៦តោន។ ទិន្នផលជាមធ្យម ៤.៤២២ តោន/ហ.ត (ឆ្នាំមុនទទួលបាន៤.៤៤៣តោន/ហ.ត)។ ស្ថានភាពប៉ះពាល់ និង ខូចខាតដោយគ្រោះធម្មជាតិ (ស្រូវរដូវវស្សា) រួមមាន ផ្ទៃដីប៉ះពាល់ដោយគ្រោះធម្មជាតិ ដែលប៉ះពាល់លើផ្ទៃដីសរុបចំនួន ២៥៣,០២៩ ហិចតា ក្នុងនោះរាំងស្ងួតចំនួន ២៥២,១៨៩ ហិកតា សត្វល្អិតចំនួន ៨៤០ហិកតា និងផ្ទៃដីខូចខាតដោយគ្រោះធម្មជាតិ ដែលខូចខាតលើផ្ទៃដីសរុបចំនួន ២៥,៧៨៣ហិកតា ដោយរាំងស្ងួត[12]។ (មើលបន្ថែមក្នុងឧបសម្ព័ន្ធ ២)។

នៅក្នុងឆ្នាំ២០១៥នេះ ស្ថានភាពទឹកភ្លៀងបានចាប់ផ្តើមធ្លាក់យឺតជាងរដូវវស្សាឆ្នាំមុន និងមានភ្លៀងធ្លាក់ច្រើននៅចុងរដូវវស្សា។ ជាមួយគ្នានេះដែរ កសិករបានជួបប្រទះនូវគ្រោះធម្មជាតិ

[12] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ២០១៥-២០១៦* (ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ២០១៦), ៩-១០។

(រាំងស្ងួតដើមរដូវ និងទឹកជំនន់ពាក់កណ្ដាលរដូវ) ដែលជះឥទ្ធិពលអវិជ្ជមាន ដល់ការងារបង្កបង្កើនផល។ ស្ថានភាពនៃអាកាសធាតុបែបនេះ បានបណ្ដាលឱ្យប៉ះពាល់ ដល់ទំហំផ្ទៃដីបង្កបង្កើនផល ការលូតលាស់របស់ដំណាំស្រូវ និងបង្កការខូចខាតដល់ដំណាំស្រូវវស្សាមួយចំនួន។

ក្រាហ្វិកទី ២.៩៖ បង្ហាញអំពីបរិមាណផលដំណាំស្រូវឆ្នាំ ២០១១-២០១៦




ប្រភព៖ របាយការណ៍បូកសរុបការងារឆ្នាំ២០១៥-២០១៦ របស់ក្រសួងកសិកម្ម ទំព័រទី១០-១១

ក្នុងរយៈពេល៥ឆ្នាំ គឺចាប់រាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៥ ការងារបង្កបង្កើនផលស្រូវមានការកើនឡើងជាលំដាប់ ទាំងផ្ទៃដី និងបរិមាណផល គឺអាស្រ័យដោយប្រជាកសិករមានភាពរីកចម្រើនក្នុងការគ្រប់គ្រងស្រែចម្ការ ការកែលម្អបច្ចេកទេស និងការផ្លាស់ប្ដូរពូជដែលមានទិន្នផលខ្ពស់។ ដោយឡែកក្នុងឆ្នាំ២០១៥ ទោះបីជាផ្ទៃដីដាំដុះមានការថយចុះចំនួន ០.១៣% និងផ្ទៃដីប្រមូលផលថយចុះចំនួន ០.១១% ក៏ដោយ បរិមាណផល ស្រូវសរុបមានការកើនឡើងប្រមាណ ០.១២% បើប្រៀបធៀបទៅនឹងឆ្នាំ២០១៤ ដោយសារទិន្នផលមានការកើនឡើង ០.២២%។

គិតត្រឹមឆ្នាំ២០១៦នេះ បរិមាណផលស្រូវប្រចាំឆ្នាំសរុបទទួលបាន ៩,៨២០ពាន់តោន ដែលក្នុងនោះស្រូវវស្សាមានចំនួន ៧,៦២០ពាន់តោន និងស្រូវប្រាំងមាន ២,២០០ពាន់តោន អតិរេកស្រូវ មាន ៤.៩៩លានតោន គិតជាអង្ករស្មើនឹង ៣.២លានតោន។

## ២.៣.២ ការវិវឌ្ឍផលិតកម្មដំណាំរួមផ្សំនិងឧស្សាហកម្ម ពីឆ្នាំ ២០០៩-២០១៥

ក្នុងចំណោមដំណាំកសិកម្មទាំងបួនមុខ ដូចជា ពោត ដំឡូងមី សណ្ដែកបាយ និងសណ្ដែកសៀង ឃើញថាចាប់ពីឆ្នាំ១៩៩៩ ដំណាំពោត និងដំឡូងមី គឺជាដំណាំឈានមុខគេក្នុងការដាំដុះ ចំណែកឯដំណាំសណ្ដែកបាយ និងសណ្ដែកសៀង គឺមានការប្រែប្រួលឡើងចុះទៅតាមអាកាសធាតុ ។ ជាលទ្ធផល នៅក្នុងឆ្នាំ ២០០៨ ផ្ទៃដីដាំដុះដំណាំទាំងបួនមុខសរុបមានចំនួន ៤៦៣,០៦៩ហិកតា ដែលក្នុងនោះផ្ទៃដីដាំពោតមានចំនួន ១៦៣,១០៦ ហិកតា ដំឡូងមី មានចំនួន

១៧៩,៩៤៥ ហិកតា សណ្តែកបាយមានចំនួន ៩៥,៦០៥ ហិកតា និងសណ្តែកសៀងមានចំនួនប្រមាណ ៧៤,៤១៣ ហិកតា។

ផលិតកម្មដំណាំរួមផ្សំនិងឧស្សាហកម្ម ដូចជា ពោត ដំឡូងមី សណ្តែកបាយ សណ្តែកសៀង មានការប្រែប្រួលចុះឡើង ទៅតាមប្រភេទដំណាំនីមួយៗ ហើយក៏អាស្រ័យទៅតាមឥទ្ធិពលនៃកត្តាថ្លៃ និងទីផ្សារ។ ផ្ទៃដីដាំដុះដំណាំរួមផ្សំ និងឧស្សាហកម្មទូទាំងប្រទេសសម្រាប់ឆ្នាំ ២០១៣ សម្រេចបានប្រមាណជាង ៩៤១ពាន់ហិចតា កើនលើសឆ្នាំ២០០៩ ប្រមាណ៤០%។ ការកើនឡើងភាគច្រើន គឺទៅលើដំណាំ ដំឡូងមី និងពោត។

តារាងទី ២.២៖ ផ្ទៃដីដាំដុះផលិតកម្មដំណាំរួមផ្សំនិងឧស្សាហកម្ម ឆ្នាំ២០០៩-២០១៥

| ដំណាំរួមផ្សំ និង ឧស្សាហកម្ម | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|---|---|
| ពោត | 221,287 | 213,622 | 174,257 | 216,330 | 239,748 | 143,517 | 112,574 |
| ដំឡូងឈើ | 160,326 | 206,226 | 391,854 | 361,854 | 421,375 | 521,459 | 573,624 |
| ដំឡូងជ្វា | 9,283 | 11,452 | 8,204 | 10,428 | 7,432 | 5,915 | 5,757 |
| បន្លែ | 50,278 | 52,732 | 52,830 | 76,495 | 52,449 | 51,637 | 47,373 |
| សណ្តែកបាយ | 49,599 | 69,206 | 68,111 | 66,850 | 54,312 | 53,294 | 57,172 |
| សណ្តែកដី | 16,474 | 20,041 | 16,287 | 18,048 | 19,954 | 17,818 | 15,519 |
| សណ្តែកសៀង | 96,388 | 103,198 | 70,584 | 71,337 | 80,688 | 72,511 | 66,824 |
| ល្ង | 42,206 | 48,299 | 42,599 | 36,722 | 34,136 | 28,170 | 26,544 |
| អំពៅ | 13,533 | 17,207 | 22,614 | 48,586 | 23,810 | 48,357 | 19,514 |
| ក្រចៅ | 347 | 594 | 342 | 286 | 243 | 192 | 135 |
| ថ្នាំជក់ | 9,269 | 10,062 | 8,318 | 5,947 | 6,881 | 10,727 | 6,545 |
| **សរុបរួម (ហ.ត)** | **669,990** | **752,639** | **855,860** | **912,883** | **941,028** | **953,597** | **931,581** |
| **សរុបបរិមាណផល (តោន)** | **5,425,310** | **5,728,175** | **6,138,532** | **10,859,806** | **10,536,742** | **14,727,262** | **15,065,186** |

ប្រភព៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨ ទំព័រទី១៥-១៦

ក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះ (២០០៩-២០១៣) ដំណាំឈើហូបផ្លែ ដូចជា ចេក ដូងមៀន ស្វាយ ទឹកដោះ ល្មុត ធូរេន ខ្នុរ ទៀប ក្រូច សារម៉ាវ ត្របែក ម្នាស់ និងដំណាំអចិន្ត្រៃយ៍ (ស្វាយចន្ទី ដូងប្រេង ម្រេច...។ល។) មាននិន្នាការរីកចម្រើនលូតលាស់គួរឱ្យកត់សម្គាល់ដែរ។ ជាក់ស្តែង ផ្ទៃដីដាំដុះឈើហូបផ្លែ និងដំណាំអចិន្ត្រៃយ៍សម្រេចបានសរុបចំនួន ១៨៣ ពាន់ហិកតា

ក្នុងឆ្នាំ ២០១៣ កើនលើសឆ្នាំ ២០០៩ ប្រមាណ៥% (ឆ្នាំ២០០៩ សម្រេចបានចំនួន ១៧៤ ពាន់ហិកតា)។

តារាងទី ២.៣៖ បរិមាណផលផលិតកម្មដំណាំរួមផ្សំនិងឧស្សាហកម្ម ឆ្នាំ២០០៩-២០១៥

| ដំណាំរួមផ្សំ និង ឧស្សាហកម្ម (តោន) | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|
| ពោត | ៩២៦,៦០៧ | ៥៤៩,៦០៧ | ៣៩៩,៦៤៩ |
| ដំឡូងឈើ | ៧,៩៣៣,៣៨១ | ១១,៩៤៣,២០៤ | ១៣,២៩៨,១០៨ |
| ដំឡូងជ្វា | ៥០,៥៤១ | ៥៤,២៥៩ | ៤៥,៤២៤ |
| បន្លែ | ៤៥៣,២០០ | ៤១៥,២៣៩ | ៤០៥,៥២៧ |
| សណ្ដែកបាយ | ៦៧,៥៦១ | ៦០,៦៥២ | ៥៩,២២០ |
| សណ្ដែកដី | ២៩,២៩៤ | ២៧,៧៦០ | ២៥,១៤៩ |
| សណ្ដែកសៀង | ១៣១,០៩២ | ១០៤,១៨០ | ៩៦,៩៤២ |
| ល្ង | ២៤,៤៧២ | ១៧,២៦០ | ១៧,៨៦៩ |
| អំពៅ | ៩១១,៣៣៣ | ១,៥៤០,៩៩៦ | ៧០៩,១៧៥ |
| ក្រចៅ | ២០៨ | ១៦៧ | ៧៥ |
| ថ្នាំជក់ | ៨,៨១៥ | ១៣,៩៣៩ | ៨,០៥៨ |
| **សរុបរួម (តោន)** | **១០,៥៣៦,៧៤២** | **១៤,៧២៧,២៦២** | **១៥,០៦៥,១៨៦** |

នៅក្នុងឆ្នាំ ២០១៥ ផ្ទៃដីផលិតកម្មដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម អនុវត្តបានសរុបចំនួន ៩៣១,៥៨១ ហិកតា តិចជាឆ្នាំមុនចំនួន ២២,០១៦ ហិកតា និងទទួលបានបរិមាណផលសរុបចំនួន ១៥,០៦៥,១៨៦ ហិកតា លើសឆ្នាំមុនចំនួន ៣៣៧,៩២៣ តោន។ ដែលក្នុងនោះដំណាំរួមផ្សំអនុវត្តបានសរុបចំនួន ៧៩៦,៥០០ហិកតា(រដូវវស្សា ៦៩២,០២៣ហិកតា និងរដូវប្រាំង ១០៤,៤៦៨ហិកតា) និងមានបរិមាណផលចំនួន ១៤,២០៧,៩២៨តោន។ ចំណែកឯ ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ១៣៥,០៨១ហិកតា (រដូវវស្សា ១២០,២៤៩ហិកតា និងរដូវប្រាំង ១៤,៨៣២ ហិកតា) និងមានបរិមាណផលចំនួន ៨៥៧,២៥៨ តោន (សូមមើលផ្នែកឧបសម្ព័ន្ធ៣) ។ ជាការកត់សម្គាល់ឃើញថា ផ្ទៃដីផលិតកម្ម និងផលិតភាពមានការកើនឡើងព្រមគ្នា ដែលនេះឆ្លុះបញ្ចាំងអំពីការវិវត្តជាវិជ្ជមាន នៅក្នុងប្រព័ន្ធផលិតកម្មដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម តាមរយៈការធ្វើប្រពល-វប្បកម្ម ដោយប្រើប្រាស់បច្ចេកទេសសមស្រប និងការប្រើប្រាស់ធាតុចូលមានគុណភាព។

### ២.៣.៣ ការវិវឌ្ឍផលិតផលជលផល ២០១១-២០១៦

លក្ខណៈនៃទីតាំងភូមិសាស្ត្រ ដែលមានឆ្នេរសមុទ្រ និងសណ្ឋានដីដែលនាំឱ្យមានផ្លូវទឹកខ្វាត់ខ្វែង ធ្វើឱ្យវិស័យជលផលទទួលបាននូវចំណូលយ៉ាងច្រើន។ ជារៀងរាល់ឆ្នាំ នៅរដូវវស្សាទឹកដីនិងទន្លេមេគង្គបានបង្កើនតំបន់ទឹកជាច្រើន ជាពិសេសតំបន់ជុំវិញបឹងទន្លេសាប ហើយនៅពេលនោះតំបន់ព្រៃលិចទឹកមួយចំនួនបានក្លាយជាជម្រកត្រីពង និងប្រភពចំណីសំខាន់ៗសម្រាប់ការលូតលាស់របស់ត្រី។ នៅរដូវវស្សាផ្ទៃទឹកជុំវិញបឹងទន្លេសាបកើនឡើងប្រហែលជា ៤-៥ដង គឺកើនពី ២,០០០ គម²-៣,០០០គម² ទៅ ១០,០០០គម²-១៥,០០០ គម² ជាមួយបម្រែបម្រួលជម្រៅទឹកពី ១-២ម៉ែត្រ នៅរដូវប្រាំង និង ពី៨-១០ម៉ែត្រនៅរដូវវស្សា។

អាជីវកម្មនេសាទទឹកសាបបានថយចុះពី ៣៩៥,០០០ តោន (២០០៧) មកត្រឹម ៣៦៥,០០០ តោន (២០០៨) ដោយសារកត្តាធម្មជាតិ នៃទឹកទន្លេមានកម្រិតទាបជាងឆ្នាំមុន។ ក្នុងនោះអាជីវកម្មឡូត៍នេសាទ-នេសាទសិប្បកម្ម រដូវនេសាទអនុវត្តបាន ១១៥,០០០ តោន នេសាទគ្រួសារ ១៤០,០០០តោន និងនេសាទតាមវាលស្រែបាន ១១០,០០០តោន។ ចំណែកអាជីវកម្មនេសាទសមុទ្រទទួលបានផល ៦៦,០០០តោន (២០០៨) កំណើន ១៨% រយៈពេល ៥ឆ្នាំ និងការចិញ្ចឹមត្រី បង្គា ការភ្ញាស់កូនត្រីពូជ និងក្រពើ កើនបាន ៩៤% (២០០៤ ធៀបនឹងឆ្នាំ២០០៨) កើនពី ២០,៥៣៥ តោន ដល់ ៤០,០០០តោន។ ការរីកចម្រើននេះ ដោយសារតែមានការបង្កើតស្ថានីយ៍ផលិតកូនត្រីពូជរបស់រដ្ឋចំនួន ១៣កន្លែង របស់កសិករ ១៥២កន្លែង ស្រះចំនួន ៤៩,៤៦៣ ស្រះ បែរចំនួន ៣,៨០២បែរ និងស៊ងចំនួន ៩ស៊ង។ ដោយទទួលបានលទ្ធផលខាងលើ ផលនេសាទស្រស់ និងកែច្នៃគ្រប់ប្រភេទអនុវត្តបាន ២៥,០០០តោន លើសឆ្នាំមុន ៩០០ តោន[13]។

ជាមួយគ្នានេះផងដែរ អាជីវកម្មនេសាទទឹកសាបបានថយចុះពី ៥០៥,០០៥ តោន (២០១៤) មកត្រឹម ៤៨៧,៩០៥ តោន (២០១៥) ដោយសារកត្តាធម្មជាតិនៃទឹកទន្លេមានកម្រិតទាបជាងឆ្នាំមុន។ ក្នុងនោះនេសាទដាយត្រីរដូវនេសាទ អនុវត្តបានចំនួន ១៣,៤២៦តោន នេសាទគ្រួសារក្នុងដែននេសាទ អនុវត្តបានចំនួន ៣៣៩,២៦៩ តោន និងនេសាទគ្រួសារក្នុងវាលស្រែអនុវត្តបានចំនួន ១៣៥,២១០ តោន។ ចំណែកអាជីវកម្មនេសាទសមុទ្រ ទទួលបានផល ១២០,២៥០ តោន (២០១៤) និងកើនឡើងបន្តិចនៅឆ្នាំ ២០១៥ មានប្រមាណ ១២០,៥០០ តោន។ ការចិញ្ចឹមត្រី បង្គា ការភ្ញាស់កូនត្រីពូជ និងក្រពើ គ្រប់ប្រភេទឆ្នាំ២០១៥ សម្រេចបានចំនួន

[13] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ២០០៨-២០០៩* (ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ២០០៩), ១៩-២០-៤៣។

១៨៣,១៨១ តោន ធៀបនឹងឆ្នាំមុនកើនឡើងចំនួន ២៣,០៨៦ តោន។ ការរីកចម្រើននេះ ដោយសារតែមានការបង្កើត កន្លែងភ្ញាស់កូនត្រីនៅទូទាំងប្រទេសចំនួន ៣០៧កន្លែង ដែលក្នុងនោះចំនួន ២៩៤ កន្លែងជារបស់ប្រជាពលរដ្ឋតាមរយៈ ការផ្តល់បច្ចេកទេសពីមន្ត្រីរដ្ឋបាល-ជលផល[14]។ ទន្ទឹមនឹងនេះ វឌ្ឍនភាពផ្នែកជលផលសម្រេចបានសរុបចំនួន ៨០២,៨៥០ តោន។ ដែលក្នុងនោះ អាជីវកម្មនេសាទទឹកសាប បានកើនឡើងពី ៤៨៧,៩០៥តោន (២០១៥) ទៅ ៥០៩,៣៥០តោន នៅឆ្នាំ២០១៦។ ចំណែកឯ អាជីវកម្មនេសាទសមុទ្រមានការកើនឡើងបន្តិចពី ១២០,៥០០តោន នៅឆ្នាំ២០១៥ ទៅ១២០,៦០០តោន នៅឆ្នាំ២០១៦ និង វារីវប្បកម្ម កើនឡើងពី ១៨៣,១៨១តោន នៅឆ្នាំ២០១៥ ឡើងដល់ ១៧២,៥០០តោន នៅឆ្នាំ២០១៦[15]។

ក្រាហ្វិកទី ២.១០៖ បង្ហាញអំពីស្ថិតិនេសាទទឹកសាប សមុទ្រ និងវារីវប្បកម្ម ២០១១-២០១៦




ប្រភព៖ របាយការណ៍បូកសរុបការងារឆ្នាំ២០១៥-២០១៦ របស់ក្រសួងកសិកម្ម ទំព័រទី៣៥

### ២.៣.៤ ការវិវឌ្ឍផលិតផលបសុសត្វ ២០១០-២០១៦

ចាប់ពីឆ្នាំ ២០០៤ រហូតដល់ឆ្នាំ ២០០៨ បរិមាណនៃសត្វគោចិញ្ចឹមមានការកើនឡើងជាទៀងទាត់បើប្រៀបធៀបឆ្នាំ ២០០៨ ទៅនឹងឆ្នាំ២០០៤ បរិមាណនៃសត្វគោចិញ្ចឹមមានកំណើនប្រមាណ ១៣% ក្នុងរយៈពេល ៥ ឆ្នាំកន្លងមកនេះ។ ប៉ុន្តែ ផលិតកម្មជ្រូកមានការធ្លាក់ចុះយ៉ាងខ្លាំងពី ២.៨២ លានក្បាល នៅឆ្នាំ២០០៤ មកត្រឹមតែ ២.២លានក្បាល នៅឆ្នាំ២០០៨។ នេះមកពីមាន

[14] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ២០១៥-២០១៦* (ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ២០១៦), ៣៣-៣៤។

[15] ទីស្តីការគណៈរដ្ឋមន្ត្រី, *សមិទ្ធផលសំខាន់ៗមួយចំនួនរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១២-២០១៦* (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០១៧), ២៧។

ការនាំចូលជ្រូកពីខាងក្រៅ ដែលធ្វើឱ្យផលិតផលក្នុងស្រុក មានការថយចុះប្រមាណ -៨% បើធៀបនឹងឆ្នាំ ២០០៧។

ផលិតកម្មសត្វគោក្នុងរយៈពេល៥ឆ្នាំ ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣ មានការប្រែប្រួលថយចុះប្រមាណ៤.២% ដោយបានថយចុះពី ៣.៦លានក្បាលនាឆ្នាំ២០០៩ មកត្រឹម ៣.៤លានក្បាលនាឆ្នាំ២០១៣។ រីឯក្របីក៏មានការប្រែប្រួលថយចុះប្រមាណ ១៦.៤% គឺថយចុះពីចំនួន ៧៤០ពាន់ក្បាលនាឆ្នាំ២០០៩ មកត្រឹម ៦១៩ពាន់ក្បាលនាឆ្នាំ២០១៣។ ការថយចុះចំពោះផលិតកម្ម ចិញ្ចឹមសត្វគោ ក្របីនេះ គឺជាការថយចុះគោ ក្របីអូសទាញ មូលហេតុបណ្ដាលមកពីកសិករ កាន់តែច្រើនឡើង បោះបង់ការភ្ជួររាស់ដោយគោ ក្របី មកប្រើប្រាស់សេវាគ្រឿងយន្ត (៧០% នៃផ្ទៃដីដាំដុះដំណាំស្រូវត្រូវបានអនុវត្តដោយគ្រឿងយន្ត) កង្វះកម្លាំងពលកម្មនៅជនបទ (ចំណាកស្រុក) មានការលំបាកក្នុងការស្វែងរកតំបន់មានទឹក និងចំណីគ្រប់គ្រាន់ សម្រាប់ការចិញ្ចឹមសត្វគោក្របី។ ទន្ទឹមនឹងការថយចុះគោអូសទាញនេះ កសិករបានងាកមកចិញ្ចឹមគោមេ និងគោយកសាច់ និងជាមួយគ្នានោះ ក៏មានការចាប់ផ្ដើមការវិនិយោគឯកជនចិញ្ចឹមគោសាច់វិញផងដែរ។

ក្រាហ្វិកទី ២.១១៖ បង្ហាញអំពីការវិវឌ្ឍសត្វនៅកម្ពុជាពីឆ្នាំ២០១០-២០១៦




ប្រភព៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨ ទំព័រទី១៨-១៩

ការចិញ្ចឹមជ្រូកមានការប្រែប្រួលកើនឡើង ក្នុងអំឡុងពេល៥ឆ្នាំកន្លងទៅនេះ ពោលគឺផលិតកម្មជ្រូកមានកើនប្រមាណ ១៥% ដោយបានកើនឡើងពី ២.១លានក្បាលនាឆ្នាំ២០០៩ ដល់ចំនួនជាង ២.៤លានក្បាលនាឆ្នាំ២០១៣ ដោយសារមានការវិនិយោគ បង្កើតកសិដ្ឋានចិញ្ចឹម

សត្វខ្នាតមធ្យម និងខ្នាតធំ[16]។ ជាមួយគ្នានេះផងដែរ នៅឆ្នាំ២០១៥ ការចិញ្ចឹមសត្វគោ មានចំនួន ២,៩០៣,៨០២ក្បាល ក្របីមានចំនួន ៥០៦,១៦៥ក្បាល ជ្រូកមានចំនួន ២,៣៥៧,៨៣៩ក្បាល និងការចិញ្ចឹមសត្វស្លាប មានចំនួន ២៦,៦៨៨,៦៧៥ក្បាល។ ចំពោះការចិញ្ចឹមគោមានការប្រែប្រួលថយចុះប្រមាណពី ៣.៣៨លានក្បាលនាឆ្នាំ២០១២ មកត្រឹមតែ ២.៩២លានក្បាលនាឆ្នាំ២០១៦។ រីឯក្របីក៏មានការប្រែប្រួលថយចុះប្រមាណពី ៦៥៧ពាន់ក្បាលនាឆ្នាំ២០១២ មកត្រឹមតែ ៥២៨ ពាន់ក្បាលនាឆ្នាំ២០១៦។ ការថយចុះចំពោះផលិតកម្មចិញ្ចឹមសត្វគោ ក្របីនេះ គឺជាការថយចុះគោ ក្របីអូសទាញ បណ្ដាលមកពីកសិករកាន់តែច្រើនឡើងៗបោះបង់ការភ្ជួររាស់ដោយគោ ក្របី មកប្រើប្រាស់សេវាគ្រឿងយន្តកសិកម្មជាង ៩២% នៃផ្ទៃដីដាំដុះដំណាំស្រូវ[17]។

ក្រាហ្វិកទី ២.១២៖ បង្ហាញអំពីការវិវឌ្ឍផលិតកម្មសត្វស្លាបពីឆ្នាំ២០១០-២០១៦




ប្រភព៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨ ទំព័រទី១៩

សត្វស្លាបនៅក្នុងប្រទេសកម្ពុជា មានការកើនជាលំដាប់ចាប់ពីឆ្នាំ ២០០៥ ប្រមាណ ៧.៨% ហើយកំណើនប្រមាណ ៩.០% នៅឆ្នាំ២០០៦ ប្រមាណ ០.៨%នៅឆ្នាំ២០០៧ និងប្រមាណ ៧.០% ឆ្នាំ២០០៨។ នេះដោយសារប្រទេសកម្ពុជា មានវិធានការល្អប្រសើរក្នុងការការពារមិនឱ្យផ្ទុះឡើងជំងឺផ្ដាសាយបក្សី។

ការចិញ្ចឹមសត្វស្លាប (មាន់ ទា) មានការកើនឡើងយ៉ាងខ្លាំងរហូតដល់ ៣៥.២៨% ក្នុងនោះការចិញ្ចឹមជាលក្ខណៈគ្រួសារអំឡុងពេល៥ឆ្នាំ (ឆ្នាំ២០០៩ដល់២០១៣) បានកើនពីជាង ២០.១៩លានក្បាល ឆ្នាំ២០០៩ ដល់ជិត ២៧.៣២លានក្បាល នាឆ្នាំ២០១៣។ ជាមួយគ្នានោះ នៅ

[16] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨* (ភ្នំពេញ៖ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ២០១៥), ១៨-១៩។

[17] ទីស្ដីការគណៈរដ្ឋមន្ត្រី, *សមិទ្ធផលសំខាន់ៗមួយចំនួនរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១២-២០១៦* (ភ្នំពេញ៖ ទីស្ដីការគណៈរដ្ឋមន្ត្រី, ២០១៧), ២៥។

ឆ្នាំ២០១៣ ផលិតកម្មសត្វស្លាបមានការកើនឡើងប្រមាណ ១៨.២៦% បើប្រៀបធៀបនឹងឆ្នាំ ២០១២។ នេះបញ្ជាក់ថាឱ្យឃើញថា មានកំណើនការវិនិយោគក្នុងការចិញ្ចឹមសត្វស្លាប។ នៅឆ្នាំ ២០១៥ ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម មានការកើនឡើង ដោយកសិដ្ឋានចិញ្ចឹមសត្វ មានចំនួនរហូតដល់ ២,៨៥៦កន្លែង[18]។

### ២.៣.៥ ការវិវឌ្ឍផលិតផលកៅស៊ូ ២០១១-២០១៦

កៅស៊ូ គឺជាដំណាំសំខាន់មួយបន្ទាប់ពីដំណាំស្រូវ ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការ ជួយទ្រទ្រង់ដល់សេដ្ឋកិច្ច និងសង្គម។ ក្នុងនោះកៅស៊ូបានចូលរួមយ៉ាងសកម្មក្នុងការផ្តល់ប្រាក់ ចំណូលដល់ខឿនសេដ្ឋកិច្ចជាតិ និងសង្គមគ្រួសារ បង្កើតការងារនៅមូលដ្ឋានជនបទ និងទប់ ស្កាត់ការធ្វើចំណាកស្រុក និងរួមចំណែកការពារ បរិស្ថាន ទប់ទល់នឹងភាពក្តៅខ្លាំងនៃអាកាស ធាតុ ការហូរច្រោះដី និងបង្កើតជាគម្របបៃតង។ កៅស៊ូធម្មជាតិបានដាំជាលើកដំបូងនៅកម្ពុជានា ឆ្នាំ១៩១០ នៅស្រុកព្រៃនប់។ រហូតដល់ឆ្នាំ១៩២១ ទើបមានការដាំជាលក្ខណៈឧស្សាហកម្ម ទ្រង់ទ្រាយធំដោយក្រុមហ៊ុនវិនិយោគរបស់បារាំង នៅក្នុងខេត្តកំពង់ចាម និងក្រចេះ។ មកដល់ឆ្នាំ ១៩៦៩ ដំណាំកៅស៊ូនៅកម្ពុជាមានពង្រីកផ្ទៃដីជាង ៦៩,០០០ហិកតា ក្នុងនោះផ្ទៃដីចៀរមានជាង ៣៩,០០០ ហិកតា ដោយទទួលបានផលិតផលកៅស៊ូបានជាង ៥០,០០០តោន សម្រាប់ការប្រើ ប្រាស់នៅក្នុងស្រុក និងនាំចេញទៅបរទេស។

គិតមកដល់ឆ្នាំ ២០០៨ ផ្ទៃដីដាំដុះកៅស៊ូទូទាំងប្រទេសមានចំនួន ១០៧,៩០០ហិកតា គឺ កើនឡើង ៣១% បើធៀបទៅនឹងឆ្នាំ២០០៧ ឬស្មើនឹង ៧២% នៃផែនការយុទ្ធសាស្ត្រឆ្នាំ២០១៥ (សម្រេចឱ្យបានផ្ទៃដីដាំដុះកៅស៊ូចំនួន ១៥០,០០០ ហិកតា)។ នេះមកពីការកើនឡើងនៃការ វិនិយោគលើដីសម្បទានសេដ្ឋកិច្ច និងផ្នែកគ្រួសារ ដោយការកើនឡើងនេះមានផ្ទៃដីប្រមាណ ១៦,០០០ហិកតា និង ៦,៤៧០ ហិកតា រៀងគ្នាក្នុងឆ្នាំ២០០៨។ ចំណែកឯផ្ទៃដីចៀរជ័រមានចំនួន ៣៣,៦៧០ ហិកតា ក្នុងនោះ ផ្ទៃដីចៀរជ័រកៅស៊ូគ្រួសារមានចំនួន ១៣,០៣៧ ហិកតា ផលិតបាន ជាកៅស៊ូស្ងួត ៣១,៦៧៦ តោន ក្នុងនោះផលិតផលកៅស៊ូគ្រួសារមាន ១២,៣៨៥ តោន និងធ្វើការ នាំចេញបានចំនួន ៣០ពាន់តោន ក្នុងនោះផលិតផលកៅស៊ូគ្រួសារមានចំនួន ១២ពាន់តោន។ ចំពោះតម្លៃកៅស៊ូមានការធ្លាក់ចុះចំនួន ៦០% នៅលើទីផ្សារអន្តរជាតិចាប់ពីឆមាសទី២ ឆ្នាំ២០០៨ ធៀបទៅនឹងតម្លៃកៅស៊ូកាលពីក្នុងឆមាសទី១ ឆ្នាំ២០០៨ (ពីតម្លៃ ៣,៥០០ដុល្លារ មកនៅប្រមាណ

[18] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ២០១៥-២០១៦* (ភ្នំពេញ៖ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ២០១៦), ២៧។

១,៥០០ដុល្លារ/តោន) ការធ្លាក់ថ្លៃនេះ បណ្តាលមកពីកត្តា ៤យ៉ាងសំខាន់គឺ: ការផ្គត់ផ្គង់ និងតម្រូវការកៅស៊ូ តម្លៃប្រេងនៅ និងវិបត្តិសេដ្ឋកិច្ចពិភពលោក[19]។

នៅឆ្នាំ២០១០ ផ្ទៃដីដាំកៅស៊ូសរុបទូទាំងប្រទេសមានប្រមាណ ១៨០,០០០ហិកតា និងនៅឆ្នាំ២០១១ ផ្ទៃដីដាំកៅស៊ូសរុបមានប្រមាណជាង ២០០,០០០ ហិកតា។ ផលិតផលកៅស៊ូដែលបាននាំចេញមានប្រមាណ ៣២,០០០តោន ដែលគិតជាទំហំទឹកប្រាក់ប្រមាណជា ១៨០ លានដុល្លារ[20]។

ការនាំចេញកៅស៊ូ ឆ្នាំ២០១៥ សម្រេចបានចំនួន ១២៨,០៤៧ តោន ស្មើនឹងទឹកប្រាក់ជាង ១៥៤លានដុល្លារអាមេរិក បើធៀបនឹងឆ្នាំ ២០១៤ ដែលការនាំចេញមានចំនួន ១០០,១៥១តោន កើនឡើងចំនួន ២៧,៨៩៦តោន ស្មើនឹង ២៧.៨៥%។ ស្ថានភាពតម្លៃកៅស៊ូនៅលើទីផ្សារអន្តរជាតិបានបន្តធ្លាក់ចុះយ៉ាងខ្លាំងក្នុងឆ្នាំ២០១៥ ដែលមិនធ្លាប់មានក្នុងរយៈពេល៧ឆ្នាំ កន្លងមកនេះ ពិសេសតម្លៃកៅស៊ូនាំចេញកម្ពុជាជាមធ្យមនៅសល់តែ ១,២០៣ដុល្លារអាមេរិកក្នុងមួយតោន បើធៀបនឹងឆ្នាំ២០១៤ ដែលតម្លៃមធ្យម ១,៥៣៩ដុល្លារអាមេរិកក្នុងមួយតោន ថយចុះ ៣៣៦ដុល្លារអាមេរិកក្នុងមួយតោន ស្មើនឹង ២១.៨៤%។ កត្តានេះបានធ្វើឱ្យផលចំណូលសរុបថយចុះផងដែរ ទោះបរិមាណនាំចេញកើនលើសឆ្នាំ ២០១៤ក៏ដោយ[21]។

ក្រាហ្វិកទី ២.១៣៖ ការវិវឌ្ឍអំពីការដាំដុះដំណាំកៅស៊ូឆ្នាំ ២០១១-២០១៦




ប្រភព៖ របាយការណ៍បូកសរុបការងារឆ្នាំ២០១៥-២០១៦ របស់ក្រសួងកសិកម្ម ទំព័រទី២៤

[19] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ២០០៨-២០០៩* (ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ២០០៩), ២០-៣៦-៣៨។

[20] ស្ថានីយ៍ទូរទស្សន៍បាយ័ន, *ពត៌មានពេលព្រឹក* (ភ្នំពេញ៖ ស្ថានីយ៍ទូរទស្សន៍បាយ័ន), ទស្សនាថ្ងៃទី ១៦ វិច្ឆិកា ២០១១។

[21] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ២០១៥-២០១៦* (ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ២០១៦), ២៤-២៥។

នៅក្នុងឆ្នាំ២០១៥ ផ្ទៃដីកៅស៊ូកម្ពុជាសរុបមានចំនួន ៣៨៨,៩៥៥ហិកតា បើធៀបទៅនឹងឆ្នាំ២០១៤មានចំនួន ៣៥៧,៨០៩ហិកតា កើនឡើងចំនួន ៣១,១៤៦ហិកតា ស្មើ៨.៧% (សូមមើលផ្នែកឧបសម្ព័ន្ធ៤)។ ផ្ទៃដីកៅស៊ូទាំងនេះ ត្រូវបានបែងចែកជា២ផ្នែកគឺៈ ផ្ទៃដីក្រុមហ៊ុនកៅស៊ូកសិ-ឧស្សាហកម្ម (អតីតចម្ការកៅស៊ូរដ្ឋ ផ្ទៃដីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងផ្ទៃដីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច) សរុបមានចំនួន ២៣៩,១០២ ហិកតា ស្មើនឹង ៦១.៤៧%នៃផ្ទៃដីកៅស៊ូសរុប និងកៅស៊ូគ្រួសារមានចំនួន ១៤៩,៨៥៣ហិកតាស្មើនឹង ៣៨.៥៣% នៃផ្ទៃដីកៅស៊ូសរុប[22]។

នៅក្នុងឆ្នាំ២០១៦នេះ ផ្ទៃដីកៅស៊ូកម្ពុជាសរុបមានចំនួន ៤៣២,៧២៥ហិកតា បើធៀបទៅនឹងឆ្នាំ២០១៥មានចំនួន ៣៨៨,៩៥៥ហិកតា កើនឡើងចំនួន ៤៣,៧៧០ហិកតា ស្មើ១១.២៥%។ ផ្ទៃដីកៅស៊ូទាំងនេះ ត្រូវបានបែងចែកជា២ផ្នែកគឺៈ ផ្ទៃដីក្រុមហ៊ុនកៅស៊ូកសិឧស្សាហកម្ម (អតីតចម្ការកៅស៊ូរដ្ឋ ផ្ទៃដីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងផ្ទៃដីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច) សរុបមានចំនួន ២៧៨,២៧១ ហិកតា ស្មើនឹង ៦៤.២៩%នៃផ្ទៃដីកៅស៊ូសរុប និងកៅស៊ូគ្រួសារមានចំនួន ១៥៤,៤៥៤ ហិកតាស្មើនឹង ៣៥.៧១% នៃផ្ទៃដីកៅស៊ូសរុប។

តាមការប៉ាន់ស្មានរបស់អគ្គនាយកដ្ឋានកៅស៊ូ ការនាំចេញកៅស៊ូឆ្នាំ២០១៦ អាចសម្រេចបានចំនួន ១៤៥.១៣ពាន់តោន ស្មើនឹងទឹកប្រាក់ជាង ១៨៧លានដុល្លារអាមេរិក បើធៀបនឹងឆ្នាំ២០១៥ មាន ១២៨.០៨ពាន់តោន កើនឡើងចំនួន ១៧,០៥៣តោន ស្មើនឹង ១១.៧៥% តែចំណូលកើនឡើងតិចតួច ដោយសារស្ថានភាព ថ្លៃកៅស៊ូនៅលើទីផ្សារអន្តរជាតិបន្តធ្លាក់ចុះយ៉ាងខ្លាំងនៅបីត្រីមាសដើមឆ្នាំ២០១៦ និងកើនឡើងបន្តិចនៅចុងឆ្នាំ។ កៅស៊ូនាំចេញគិតជាមធ្យមតម្លៃ១,២៩០ដុល្លារអាមេរិក/តោន បើធៀបនឹងឆ្នាំ២០១៤ ដែលតម្លៃមធ្យម ១,៥៣៩ដុល្លារអាមេរិក/តោន គឺថយចុះ ២៤៩ដុល្លារអាមេរិក/តោន ស្មើនឹង ១៩.៣០%។ ប៉ុន្តែបើធៀបនឹងឆ្នាំ២០១៥ ដែលមានតម្លៃមធ្យម១,២០៣ដុល្លារអាមេរិក/តោន ឃើញថាមានការកើនឡើងបន្តិច គឺ ៨៧ដុល្លារអាមេរិក/តោន ស្មើនឹង ៧.២៣%។[23]

[22] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ២០១៥-២០១៦* (ភ្នំពេញៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ២០១៦), ២៣-២៤។

[23] ទីស្តីការគណៈរដ្ឋមន្ត្រី, *សមិទ្ធផលសំខាន់ៗមួយចំនួនរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១២-២០១៦* (ភ្នំពេញៈ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០១៧), ២៤-២៥។

### ២.៣.៦ ការវិវឌ្ឍផ្នែករុក្ខកម្ម ២០១១-២០១៥

បើគិតចាប់ពីឆ្នាំ ២០០៤ ដល់ឆ្នាំ២០០៨ ដីព្រៃដែលកាប់ទន្រ្ទានដោយខុសច្បាប់មានចំនួន ៤៦៤,៨៦១ ហិកតា និងដកហូតដីព្រៃបានមកវិញចំនួន ៩១,០៩៩ ហិកតា។ បង្គោលចំនួន ៣,៩៧៣បង្គោល ស្មើនឹង ៧៣៣គីឡូម៉ែត្រ នៅក្នុងខេត្តចំនួន ១៣ ដើម្បីការពារ និងកំណត់ជារបស់រដ្ឋ ព្រមទាំងបង្កើតរុក្ខទិវា និងការដាំឈើជាចម្ការ។ ក្នុងការដាំដើមឈើឡើងវិញនេះ រដ្ឋបាលព្រៃឈើដាំបាន ៩០០ហិកតា កងយោធាបាន ២០០ហិកតា ក្រុមហ៊ុនឯកជនបាន ៧,៩៥០ ហិកតា និងដាំក្នុងបុណ្យរុក្ខទិវាបាន ៥០ហិកតា។

ធនធានគម្របព្រៃឈើបានធ្លាក់ចុះជាបន្តបន្ទាប់ ពិសេសក្នុងកំឡុងពេលចុងក្រោយនេះ (ចុងឆ្នាំ២០១០-២០១៤) បានថយចុះពី ៥៧.០៧% នៅឆ្នាំ២០១០ មកនៅត្រឹម ៥៩.៤៨% នៅឆ្នាំ ២០១៤។ ចំនួនសហគមន៍ព្រៃឈើសរុបកើនឡើងដល់ ៤៩៩ ប្រៀបធៀបនឹងឆ្នាំ២០១៤ មានចំនួន ៤៨៥។ បទល្មើសព្រៃឈើ សត្វព្រៃ និងការកាប់រានដីព្រៃពីរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន ២,១៨៩ ករណី គឺថយចុះចំនួន ២១១ករណី បើធៀបនឹងឆ្នាំ២០១៤។ ចំពោះវត្ថុតាងបទល្មើសព្រៃឈើ និងសត្វព្រៃដែលបានចាប់ឃាត់ និងដកហូតមានឈើមូល-ជ្រុង ៩៩៦ម៉ែត្រគូប ឈើអារ ៤,៧០៥ម៉ែត្រគូប ឈើគ្រាក់គ្រញូង ១១៣ម៉ែត្រគូប និង ៥,៧៩៣គីឡូក្រាម សត្វព្រៃចម្រុះគ្រប់ប្រភេទ ៤,០១៨ក្បាល និង២,៣៩៤គីឡូក្រាម និងអនុផលព្រៃឈើ ព្រមទាំងសម្ភារៈផ្សេងៗមួយចំនួនទៀត។ ដីព្រៃឈើដែលបានកាប់រានចំនួន ២,៧០៩ហិកតា ត្រូវបានបញ្ជូនសំណុំរឿងទៅតុលាការ និងបានដកហូតរណាយន្តបានចំនួន ៤៨៦គ្រឿង។ នៅឆ្នាំ២០១៥ ការបោះបង្គោលព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ សម្រេចបានសរុប ៥៧៤បង្គោល សរុបប្រវែង ៩៣គ.ម ដែលក្នុងនោះដែនសមត្ថកិច្ចខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារ បានបោះបង្គោលសរុបចំនួន ១១២បង្គោល ខណ្ឌរដ្ឋបាលព្រៃឈើកំពង់ធំបានចំនួន ១១២បង្គោល ខណ្ឌរដ្ឋបាលព្រៃឈើក្រចេះបានចំនួន ១៧៥បង្គោល ខណ្ឌរដ្ឋបាលព្រៃឈើកោះកុងបានចំនួន ១៧៥បង្គោល ។ ប្រៀបធៀបនឹងឆ្នាំ២០១៤ បានចំនួន ១,៤៧៣ បង្គោល ដែលប្រើប្រាស់ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍។ នៅឆ្នាំ២០១៥ ការដាំដើមឈើសរុបចំនួន ៤,៦៩០ហិកតា ក្នុងនោះ ស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើរបស់រដ្ឋបាលព្រៃឈើបានចំនួន ៩១៥ហិកតា ក្រុមហ៊ុនដាំឈើជាលក្ខណៈដៃគូ សហការជាមួយរដ្ឋបាលព្រៃឈើដាំឈើបានចំនួន ១,៨៧៥ហិកតា និងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច

ដាំបានចំនួន២,៣៧០ហិកតា និងដាំក្នុងពិធីបុណ្យរុក្ខទិវាទូទាំងប្រទេសបាន ៣០ហិកតា បើប្រៀបធៀបទៅនឹងឆ្នាំ២០១៤ មានការថយចុះចំនួន ៧៣២ ហិកតា[24]។

## ២.៤ សារៈសំខាន់នៃវិស័យកសិកម្មក្នុងការកាត់បន្ថយភាពក្រីក្រនៅជនបទ

វិស័យកសិកម្មមិនត្រឹមតែបានចូលរួមចំណែក ឱ្យមានកំណើនសេដ្ឋកិច្ចប៉ុណ្ណោះទេ គឺថែមទាំងបានចូលរួមចំណែកដ៏សំខាន់ក្នុងកិច្ចការសង្គម ក៏ដូចជាការចូលរួមចំណែក កាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជាផងដែរ។ ពោលគឺវិស័យកសិកម្ម អាចដោះស្រាយបាននូវការងារធ្វើរបស់ប្រជាជនរហូតដល់ប្រមាណជិត ៧០% និងអាចចូលរួមមួយចំណែកធំដល់ការកាត់បន្ថយភាពក្រីក្រ តាមរយៈការធ្វើផលិតកម្មកសិកម្មនេះ។ កន្លងមកនេះ ដោយសារតែការវិវត្តន៍ជឿនលឿននៃវិស័យ កសិកម្ម អត្រាភាពក្រីក្ររបស់ប្រជាជនកម្ពុជា បានធ្លាក់ចុះពី ២៩.៩% ក្នុងឆ្នាំ ២០០៨ មកត្រឹម ២២.៩% ក្នុងឆ្នាំ២០០៩ ហើយអត្រានេះបានបន្តធ្លាក់ចុះដល់ ២១.១% ក្នុងឆ្នាំ ២០១០ និង ១៩.៨% ក្នុងឆ្នាំ២០១១។ ដូចនេះ គេអាចវាយតម្លៃបានថា កម្ពុជាអាចកាត់បន្ថយភាពក្រីក្របានប្រមាណជាង ១% ក្នុងមួយឆ្នាំ។ សក្តានុពលភាព សម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម ដូចជា កត្តាដីកសិកម្មដែលអាចពង្រីកផលិតកម្មកសិកម្ម លទ្ធភាពបង្កើនទិន្នផលដំណាំ ប្រភពធនធាន ទឹកនិងការស្រោចស្រព កម្លាំងពលកម្មកសិកម្ម។ល។ នឹងអាចជំរុញការរីកលូតលាស់សេដ្ឋកិច្ចជនបទ និងអាចធ្វើឱ្យមានការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនថែមទៀត[25]។

### ២.៤.១ សារៈសំខាន់ចំពោះជីវភាពរស់នៅជនបទ

ដំណាំស្រូវ គឺជាអាហារយ៉ាងសំខាន់ចំពោះគ្រួសារនៅតាមជនបទ និងមិនអាចខ្វះបានសម្រាប់ធានានូវសន្តិសុខស្បៀង។ ប្រសិនបើគិតជាមធ្យមភាគស្រូវ បានផ្តល់នូវតម្រូវការថាមពល ៣/៤ កាល់ឡូរី ប្រមាណ៦៥-៧៥% សម្រាប់ប្រជាជនកម្ពុជា។ ស្រូវត្រូវបានរួមបញ្ចូលជាមួយនឹងត្រី (ត្រីស្រស់ ឬត្រីប្រហុក) និងបន្លែគឺជាអាហារសម្រាប់ទ្រទ្រង់ជីវភាពប្រជាជននៅតាមជនបទ។ ប្រទេសកម្ពុជាមានប្រជាជនជាង ៨០% រស់នៅតំបន់ជនបទ ហើយក្នុងនោះប្រមាណជា ៧០%រស់នៅដោយពឹងផ្អែកទៅលើវិស័យកសិកម្ម ដើម្បីទ្រទ្រង់ជីវភាពរបស់ខ្លួន។ ចំពោះគ្រួសារទាំងនេះ មានដីសម្រាប់ដាំដុះដំណាំស្រូវជាមធ្យមត្រឹមតែ ១.៤ហិកតាប៉ុណ្ណោះ។

[24] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ២០១៥-២០១៦* (ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ២០១៦), ៣៥-៣៨។

[25] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ២០១៣-២០១៤* (ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ២០១៤), ១៤។

ប្រាកដណាស់ថាទំហំដី កសិកម្ម មានការប្រែប្រួល ទៅតាមតំបន់ ឧទាហរណ៍ តំបន់ដែលមានដង់ស៊ីតេខ្ពស់ ដូចជា ខេត្តកណ្តាល និងកំពង់ស្ពឺ មានផ្ទៃដីតូចជាងគេ (តិចជាង ១ហិកតា) ចំណែកខេត្តស្ថិតនៅតំបន់អាគ្នេយ៍មានផ្ទៃដី ១-២ហិកតា រីឯតំបន់ដែលមានដង់ស៊ីតេតិច ដូចជាខេត្តនៅតំបន់ពាយ័ព្យមានផ្ទៃដី ប្រមាណជា ២-៥ហិកតា។

**២.៤.១.១ ការបរិភោគអង្ករ និងប្រាក់ចំណូល**

នៅក្នុងប្រទេសកម្ពុជា ការបរិភោគអង្ករក្នុងមនុស្សម្នាក់ក្នុងមួយឆ្នាំ មានអត្រា ១៥០គីឡូក្រាមចំនួននេះស្មើនឹងស្រូវ ២៥០គីឡូក្រាម ឬតម្រូវការ ១.៣ តោនក្នុងមួយគ្រួសារ។ តម្រូវការស្រូវ ប្រមាណ ៥០០គីឡូក្រាម បន្ថែមទៀតអាចទុកធ្វើពូជជារៀងរាល់ឆ្នាំ ការបាត់បង់ក្រោយប្រមូលផល បុណ្យទាន និងសកម្មភាពផ្សេងៗ។ ដូច្នេះ គិតជាមធ្យមក្នុងមួយគ្រួសារត្រូវការស្រូវប្រហែល ១.៨តោន សម្រាប់ទុកបរិភោគ[26]។ ប្រសិនបើប្រៀបធៀបផលិតផលជាមធ្យមឆ្នាំ ២០១៦ មាន ៣.១៨៩តោន/ហិកតា និងតម្លៃស្រូវក្នុងមួយគីឡូក្រាមប្រហែល ៨០០រៀល គឺបានសេចក្តីថាផលិតផលស្រូវក្នុងមួយគ្រួសារមាន ២៨០ដុល្លារ[27] សម្រាប់ធ្វើការទូទាត់ទៅលើថ្លៃដី ថ្នាំពុល និងជួលកម្លាំងពលកម្ម(ចំពោះអ្នកមានដី១ហិកតានៅសល់ស្រូវ ១.៤តោន (៣.១៨៩-១.៨))។

**២.៤.១.២ ការបរិភោគបន្លែ និងប្រាក់ចំណូល**

ការដាំបន្លែ និងដំណាំផ្សេងៗទៀត គឺជាប្រភពនៃជីវជាតិវីតាមីន ជីវជាតិរ៉ែ និងប្រូតេអ៊ីនដែលអាចជួយប្រឆាំងនឹងកង្វះជីវជាតិ និងបញ្ហារួមផ្សំផ្សេងទៀត។ អត្រានៃការបរិភោគបន្លែនៅក្នុងប្រទេសកម្ពុជា ហាក់ដូចជានៅក្រោមកម្រិតអនុសាសន៍ដែលបានកំណត់។ អង្គការ FAO បានផ្តល់អនុសាសន៍ ក្នុងការបរិភោគបន្លែក្នុងមួយថ្ងៃ ២០០ក្រាម និងអង្គការសុខភាពពិភពលោកផ្តល់អនុសាសន៍ក្នុងការបរិភោគបន្លែ ក្នុងមួយថ្ងៃប្រមាណជា ៣០០ក្រាមឯណោះ។ ប៉ុន្តែប្រភពរបាយការណ៍ទាំងពីរខាងលើ ពុំបានបូកបញ្ចូលបន្ថែមពីការបរិភោគបានពីផលិតកម្ម ក្រៅផ្លូវការ ឧទាហរណ៍ សួនបន្លែគ្រួសារ និងការនាំចូលបន្លែយ៉ាងសន្ធឹកសន្ធាប់ពី ប្រទេសវៀតណាម និងថៃ។ ជាការពិត លទ្ធផលដែលបានមកពីការអង្កេតដែលមានកម្រិតកំណត់ បានរកឃើញថា បន្លែដែលបានបរិភោគនៅក្នុងប្រទេសកម្ពុជា គឺបានមកពីការនាំចូលដែលមានអត្រា ២៥-៥០%។ នៅពេលដែលគេធ្វើការគណនាផលិតផល បន្លែក្រៅផ្លូវការ និងបន្លែនាំចូល រួមបញ្ចូលគ្នានៅក្នុង

---

[26] ព្រំ តុលា, និង Brue Mckenney, *ធនធានធម្មជាតិ និងជីវភាពនៅតាមជនបទប្រទេសកម្ពុជា* (ភ្នំពេញ៖ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា, ២០០២), ៣៩។
[27] កំណត់យក ១.៤តោន ស្មើនឹង ១,៤០០គីឡូក្រាម, ១ដុល្លារ ស្មើនឹង ៤,០០០រៀល។

ផលិតកម្មបន្លែសរុបនោះ ការបរិភោគក្នុងមនុស្សម្នាក់ៗប្រហែល ៨០-៩០ ក្រាមក្នុងមួយថ្ងៃ ឬ ៣០-៣៥គីឡូក្រាមក្នុងមួយឆ្នាំ។

### ២.៤.១.៣ ការបរិភោគបសុសត្វ និងប្រាក់ចំណូល

ដោយសារវាជាប្រភពផ្តល់ប្រូតេអ៊ីន ផលិតផលបសុសត្វ បន្តដើរតួនាទីបន្តិចបន្តួចនៅក្នុងការផ្តល់នូវជីវជាតិជាមធ្យម ដល់ប្រជាជនកម្ពុជានៅតាមជនបទ បើគេធៀបនឹងការបរិភោគត្រី។ លោក Maclean បានប៉ាន់ស្មានថា ការបរិភោគសាច់បសុសត្វប្រចាំឆ្នាំក្នុងមនុស្សម្នាក់ គឺប្រហែល ១៧.៥គីឡូក្រាម ដែលក្នុងនោះការបរិភោគសាច់ជ្រូកមាន ៨គីឡូក្រាម ការបរិភោគសាច់បសុបក្សីមាន ៦.៥គីឡូក្រាម ការបរិភោគសាច់គោក្របីមាន ៣គីឡូក្រាម។ បើធៀបជាមួយនឹងការសិក្សាស្តីពីការបរិភោគត្រី បានបញ្ជាក់ថា ការបរិភោគត្រីជាមធ្យមក្នុងមនុស្សម្នាក់ក្នុងមួយឆ្នាំ មានប្រមាណ ២៧-៣៨គីឡូក្រាម។ ការប៉ាន់ស្មានថ្នាក់ជាតិបានបញ្ជាក់ថា ផលិតផលបសុសត្វមានប្រមាណ ១/៣នៃសាច់ដែលបានបរិភោគ ដែលអត្រានេះ ហាក់ដូចជាមានកម្រិតទាបយ៉ាងខ្លាំងនៅតាមតំបន់ជនបទ។ នេះក៏ព្រោះ គោ ក្របី និងជ្រូក គឺជាប្រភពចំណូលយ៉ាងសំខាន់សម្រាប់គ្រួសារកសិករ។ ជ្រូកត្រូវគេចិញ្ចឹមដោយផ្ទាល់សម្រាប់លក់យកប្រាក់ ចំណែកឯ គោ ក្របី ត្រូវបានគេចិញ្ចឹមសម្រាប់ធ្វើជាកម្លាំងអូសទាញយ៉ាងសំខាន់ និងលក់ទៅឱ្យឈ្មួញសត្តឃាត[28]។

### ២.៤.១.៤ តួនាទីរបស់យេនឌ័រ និងជនជាតិភាគតិចនៅក្នុងវិស័យកសិកម្ម

តើយេនឌ័រ និងជនជាតិភាគតិច អាចមានប្រសិទ្ធភាព យ៉ាងដូចម្តេច ទៅលើផលិតកម្មសន្តិសុខស្បៀង និងប្រាក់ចំណូល។ តាមការសិក្សាកន្លងមកបង្ហាញឱ្យឃើញថា ជនជាតិខ្មែរ និងជនជាតិភាគតិច ដែលរស់នៅតំបន់ខ្ពង់រាប តែងតែប្រកាន់យករបរសិកម្មជាមូលដ្ឋានសំខាន់សម្រាប់ធ្វើជាសកម្មភាពជីវភាពរស់នៅរបស់ពួកគេ ចំណែកឯជនជាតិចាម និងវៀតណាមជីវភាពរស់នៅរបស់ពួកគេ ពឹងផ្អែកយ៉ាងសំខាន់ទៅលើការនេសាទ។ តួនាទីជាប្រពៃណីរបស់យេនឌ័រ គឺមានស្រាប់នៅក្នុងវិស័យកសិកម្ម ប៉ុន្តែតួនាទីទាំងនេះនៅរឹងឆ្អឹង ឬមិនអាចបត់បែនបាន។ ចំពោះកសិកម្មដំណាំស្រូវ និងដំណាំបន្លែ ស្ត្រីចូលរួមច្រើននៅក្នុងការដាំដុះ ស្ទូង ការជម្រះស្មៅ ដាក់ជី ការប្រមូលផល និងសកម្មភាពម៉ាឃីធីង និងជំនួញ។ ចំពោះបុរសវិញ មានតួនាទីសំខាន់នៅក្នុងការរៀបចំដី ការថែរក្សាភ្លឺ និងការដឹកជញ្ជូន។

[28] ព្រំ តុលា, និង Brue Mckenney, *ធនធានធម្មជាតិ និងជីវភាពនៅតាមជនបទប្រទេសកម្ពុជា* (ភ្នំពេញ៖ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា, ២០០២), ៤១។

## ២.៥ តួនាទីរបស់ស្ថាប័ននានានៅក្នុងវិស័យកសិកម្ម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាស្ថាប័នដ៏សំខាន់មួយ ដែលទទួលខុសត្រូវទៅលើការអភិវឌ្ឍវិស័យកសិកម្ម។ បណ្តានាយកដ្ឋានកសិកម្ម និងកម្មវិធីនានា ដែលស្ថិតនៅក្រោមក្រសួងនេះផ្តោតជាសំខាន់ទៅលើ ការអភិវឌ្ឍដំណាំ (រួមបញ្ចូលទាំងការស្រោចស្រព) អភិវឌ្ឍន៍ការចិញ្ចឹមសត្វ ជំរុញការកែលម្អបច្ចេកទេសផលិតផលកសិកម្ម ការស្រាវជ្រាវនិងការអប់រំ ការផ្សព្វផ្សាយនិងសេវាបច្ចេកទេស។ បណ្តាក្រសួង និងភ្នាក់ងារសាធារណៈនានា ក៏មានតួនាទីសំខាន់នៅក្នុងវិស័យកសិកម្មផងដែរ ដែលអាណត្តិរបស់ខ្លួនបំពេញគ្នា (ជួនកាលជាន់គ្នា) ជាមួយនឹងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ស្ថាប័នសំខាន់ៗ និងការទទួលខុសត្រូវដែលទាក់ទងនឹងវិស័យកសិកម្ម រួមមាន៖

-ក្រសួងអភិវឌ្ឍន៍ជនបទ គឺទទួលខុសត្រូវលើការអភិវឌ្ឍន៍ដំណាំ ការស្តារផ្លូវលំឡើងវិញ ការគ្រប់គ្រងធនធានទឹក ការស្រាវជ្រាវ និងការផ្សព្វផ្សាយ

-ក្រសួងធនធានទឹក និងឧតុនិយម គឺគ្រប់គ្រងធនធានទឹក ដោយរួមបញ្ចូលទាំងប្រព័ន្ធស្រោចស្រព

-ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ទទួលបន្ទុកគ្រប់គ្រងដីធ្លី ការវាស់វែងចេញប័ណ្ណកម្មសិទ្ធិ

-ក្រសួងបរិស្ថាន គឺត្រូវការពារ និងគ្រប់គ្រងតំបន់បរិស្ថានវាយតម្លៃ និងការបន្ធូរបន្ថយសក្តានុពលភាពនៃផលប៉ះពាល់ដល់បរិស្ថាន

-ក្រសួងពាណិជ្ជកម្ម មានតួនាទីជំរុញ និងគាំទ្រ ម៉ាឃីធីង ជំនួញ និងការនាំចេញ

-ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ជួយជំរុញទៅដល់ផលិតកម្មស្បៀងអាហារលក្ខណៈគ្រួសារ

-វិទ្យាស្ថានកម្ពុជាស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម ធ្វើការអភិវឌ្ឍពូជស្រូវថ្មីៗ និងពង្រីកពូជស្រូវ។

### ២.៥.១ តួនាទីរបស់អង្គការក្រៅរដ្ឋាភិបាលក្នុងការអភិវឌ្ឍ

អង្គការក្រៅរដ្ឋាភិបាល គឺជាអង្គការមិនស្វែងរកប្រាក់ចំណេញ ហើយបង្កើតឡើងដើម្បីបម្រើផលប្រយោជន៍សាធារណៈ។ អង្គការក្រៅរដ្ឋាភិបាល ជាច្រើនបានបំពេញតួនាទីយ៉ាងសំខាន់ក្នុងសង្គម ដោយធ្វើសកម្មភាពមួយចំនួនដែលរាជរដ្ឋាភិបាល និងអង្គភាពឯកជនមួយចំនួនមិនអាចធ្វើទៅបាន។ ទោះបីជាការងាររបស់អង្គការក្រៅរដ្ឋាភិបាល មានសារៈសំខាន់ក៏

ដោយក៏អង្គការទាំងនេះ នឹងអាចបន្តសកម្មភាពរបស់ខ្លួនបានលុះត្រាណាតែ អង្គការនេះចាត់ចែងការងារបានល្អ ហើយផ្តល់សេវាកម្មចាំបាច់ដែលបម្រើផលប្រយោជន៍សាធារណៈ។

-អង្គការក្រៅរដ្ឋាភិបាល ជាស្ថាប័នអភិវឌ្ឍន៍មួយអាចចូលរួមវិភាគទានយ៉ាងច្រើន ចំពោះផែនការកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។

-កិច្ចការប្រចាំថ្ងៃរបស់អង្គការក្រៅរដ្ឋាភិបាល គឺធ្វើការយ៉ាងជិតស្និតជាមួយអ្នកក្រីក្រ និងក្រុមជនងាយរងគ្រោះ។

-អង្គការក្រៅរដ្ឋាភិបាល ក៏មានទំនាក់ទំនងជិតស្និតជាមួយ បណ្តាក្រសួងក្នុងផ្នែកជាច្រើនដើម្បីដោះស្រាយនូវរាលបញ្ហាដែលជួបប្រទះរហូតឈានដល់ការអភិវឌ្ឍ។

## ២.៦ គោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម

### ២.៦.១ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល

យុទ្ធសាស្ត្រចតុកោណ គឺជាយុទ្ធសាស្ត្រមួយរបស់រាជរដ្ឋាភិបាល សម្រាប់ជំរុញកំណើនសេដ្ឋកិច្ច ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់នៅឆ្នាំ ២០០៥។ នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ សម្រាប់នីតិកាលទី៥ (២០១៣-២០១៨) ក្នុងនោះរួមមានចតុកោណ៤សំខាន់ៗគឺ៖

ចតុកោណទី១: ការលើកស្ទួយវិស័យកសិកម្ម

ចតុកោណទី២: ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

ចតុកោណទី៣: ការអភិវឌ្ឍវិស័យឯកជន និងការងារ

ចតុកោណទី៤: ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស។

ការលើកស្ទួយវិស័យកសិកម្មរួមមានមុំបួនសំខាន់ៗគឺ៖

-មុំទី១: ការលើកកម្ពស់ផលិតភាព, ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្ម

-មុំទី២: ការលើកកម្ពស់ការចិញ្ចឹមសត្វ និងវារីវប្បកម្ម

-មុំទី៣: កំណែទម្រង់ដីធ្លី, ការបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

-មុំទី៤: ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព[29]។

នយោបាយកសិកម្មរបស់រាជរដ្ឋាភិបាល គឺសំដៅលើការលើកកម្ពស់វិស័យកសិកម្មឱ្យក្លាយជាវិស័យនាំមុខនៅក្នុងកំណើនសេដ្ឋកិច្ចជាតិ និងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រនៅ

[29] រាជរដ្ឋាភិបាលកម្ពុជា, *យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា* (ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា, ២០១៣), ២៤-៣១។

ជនបទ។ ក្នុងទិសដៅនេះរាជរដ្ឋាភិបាល និងបង្កើនការប្រើប្រាស់ធនធានក្នុងស្រុកសម្រាប់អនុវត្ត ពហុវប្បកម្ម និងប្រពលវប្បកម្មកសិកម្មដោយដោះស្រាយនូវបញ្ហាបច្ចេកទេសកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធជនបទរួមមាន: ផ្លូវថ្នល់ ធារាសាស្ត្រ និងអគ្គិសនី ឥណទាន ទីផ្សារ និងកែច្នៃ កសិផល ជាពិសេសការកែច្នៃសម្រាប់ ការនាំចេញដើម្បីធានានូវនិរន្តរភាពនៃកំណើនសេដ្ឋកិច្ច បង្កើតការងារបង្កើនប្រាក់ចំណូលនៅជនបទ ព្រមទាំងធានាសន្តិសុខស្បៀង សម្រាប់ប្រជាជនទូទៅ ហើយធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភ និងបង្កើនការនាំចេញនូវផលិតផលកសិកម្ម (មើលបន្ថែមផ្នែកឧបសម្ព័ន្ធ៥)។

**២.៦.២ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨**

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨នេះ គឺជាឯកសារផែនការគោលនយោបាយ និងយុទ្ធសាស្ត្រមួយដ៏សំខាន់សម្រាប់រយៈពេលមធ្យម និងជាផែនទីបង្ហាញផ្លូវដែលបានកំណត់ច្បាស់អំពីទិសដៅអភិវឌ្ឍន៍វិស័យកសិកម្ម ជាមួយនឹងគោលបំណង លទ្ធផលរំពឹងទុក សូចនាករ និងចង្កោមសកម្មភាព របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រាប់អនុវត្តក្នុងរយៈពេល ៥ឆ្នាំពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ និងបានឆ្លុះបញ្ចាំងពី គោលនយោបាយរបស់រាជរដ្ឋាភិបាល ពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ សំដៅរួមចំណែកដល់ការរីកចម្រើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំសម្រាប់អនុវត្ត ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការធ្វើទំនើបកម្មវិស័យកសិកម្មកម្ពុជា ទៅតាមអភិក្រមក្នុងវិសាលភាព និងល្បឿនថ្មី សំដៅជំរុញការរីកលូតលាស់សេដ្ឋកិច្ចកសិកម្ម និងការនាំចេញផលិតផលកសិកម្ម រួមនឹងការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

ការកំណត់ទិសដៅ គោលនយោបាយរួមរបស់ក្រសួង សម្រាប់អនុវត្តរយៈពេល ៥ឆ្នាំគឺ៖ "ជំរុញកំណើនកសិកម្មប្រចាំឆ្នាំឱ្យបានក្នុងរង្វង់ ៥% តាមរយៈការលើកកម្ពស់ផលិតភាព ពពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ដោយយកចិត្តទុកដាក់ខ្ពស់ លើការការពារ និងគ្រប់គ្រងធនធានធម្មជាតិព្រៃឈើ និងជលផលប្រកបដោយចីរភាព"។ ដើម្បីសម្រេចបានទិសដៅគោលនយោបាយនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតកម្មវិធីយុទ្ធសាស្ត្រចំនួន៥ ដូចខាងក្រោម៖

**កម្មវិធីទី១៖** បង្កើនផលិតភាព ពពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម:

ជំរុញកំណើនផលិតកម្មគ្រប់មុខដំណាំក្នុងរង្វង់ ១០%ក្នុងមួយឆ្នាំ តាមរយៈការបង្កើនការស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មសំដៅបង្កើនទិន្នផលដំណាំ លើកកម្ពស់គុណភាពផលិតផល ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ដោយផ្សារភ្ជាប់ជាមួយផលិតកម្មកសិកម្មតាមកិច្ចសន្យា និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្មប្រកបដោយនិរន្តរភាព។ កម្មវិធីនេះត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន ២០ និងត្រូវអនុវត្តដោយអង្គភាពជំនាញពាក់ព័ន្ធ។

**កម្មវិធីទី២៖** ជំរុញផលិតកម្មសត្វ និងសុខភាពសត្វ

ជំរុញការចិញ្ចឹមសត្វក្នុងអត្រាកំណើន ៣%ក្នុងមួយឆ្នាំ ដោយផ្អែកលើប្រសិទ្ធភាពនៃការពិសោធន៍ស្រាវជ្រាវ និងផ្សព្វផ្សាយ បង្កើនសមត្ថភាពបង្ការទប់ស្កាត់ជំងឺឆ្លងសត្វ និងជំងឺសូណូស៊ីស ធានាការផ្គត់ផ្គង់សត្វ ប្រកបដោយអនាម័យ សុវត្ថភាព និងបង្កើនសក្តានុពលនៃការនាំចេញ។ កម្មវិធីនេះត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន៩។

**កម្មវិធីទី៣៖** ការគ្រប់គ្រងធនធាជលផលប្រកបដោយនិរន្តរភាព

បង្កើនការការពារ និងអភិរក្សធនធានជលផល ដោយលុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព ពង្រឹងសមត្ថភាពគ្រប់គ្រង១០០សហគមន៍នេសាទ និងជំរុញការអភិវឌ្ឍវារីវប្បកម្មក្នុងកំណើន ១៥%រៀងរាល់ឆ្នាំ ដើម្បីធានាឱ្យបាននូវនិរន្តរភាពធនធានជលផល ព្រមទាំងកែលម្អគុណភាពនិងសុវត្ថិភាពផល ផលិតផលជលផល សម្រាប់ការប្រើប្រាស់ក្នុងស្រុក និងនាំចេញ។ កម្មវិធីនេះត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន១១។

**កម្មវិធីទី៤៖** ការគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តរភាព

បង្កើនការគ្រប់គ្រងព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តរភាព តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ជំរុញការដាំដើមឈើឱ្យបាន ២៥,០០០ហិកតាក្នុងមួយឆ្នាំ បង្កើតព្រៃការពារ និងតំបន់អភិរក្សសត្វព្រៃឱ្យបាន ៥០,០០០ហិកតា ក្នុងមួយឆ្នាំ និងសហគមន៍ព្រៃឈើឱ្យបាន ៣២សហគមន៍ក្នុង១ឆ្នាំ។ កម្មវិធីនេះ ត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន៨។

កម្មវិធីទី៥៖ ពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស

បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន ការផ្តល់សេវាគាំទ្រនិងពង្រឹងសមត្ថភាពផ្នែកអប់រំ និងបណ្តុះបណ្តាល សម្រាប់ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព។ កម្មវិធីនេះត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន១២ និងត្រូវអនុវត្តដោយអង្គភាពជំនាញពាក់ព័ន្ធ។

ផ្អែកលើផែនការយុទ្ធសាស្ត្រនេះ ការរៀបចំ និងអនុវត្តតាមប្រព័ន្ធ " អភិក្រមផ្អែកតាមកម្មវិធី (Programme Based Approach)" ត្រូវបានជំរុញ និងលើកទឹកចិត្តឱ្យអនុវត្ត ដោយបញ្ចូល

គ្នានូវធនធាន ដែលមានទាំងថវិកាជាតិ និងថវិកាពីដៃគូអភិវឌ្ឍន៍ ដើម្បីសម្រេចបាននូវគោលដៅរួមគ្នា។ ជាងនេះទៀត ការកសាងផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី គឺចាំបាច់ត្រូវអនុវត្តឱ្យស្របទៅនឹងផែនការយុទ្ធសាស្ត្រនេះផងដែរ។ ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទកំពុងរៀបចំកសាង "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មខេត្តឆ្នាំ ២០១៦-២០២០" និងគ្រោងរៀបចំកសាង "ផែនការមេស្តីពីការអភិវឌ្ឍវិស័យកសិកម្មឆ្ពោះទៅឆ្នាំ ២០៣០"។

### ២.៦.៣ ផែនការសកម្មភាព សម្រាប់អនុវត្តគោលនយោបាយ អភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥

រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវ "គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥" នៅដើមខែមិថុនា ឆ្នាំ២០១៥ កន្លងទៅ ដើម្បីជំរុញការអភិវឌ្ឍឧស្សាហកម្មកម្ពុជា ដែលនឹងរួមចំណែក ដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ពង្រីកការប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព។

ឯកសារគោលនយោបាយ អភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជានេះ បានកំណត់ច្បាស់អំពីស្ថាប័ននាំមុខ និងស្ថាប័នទទួលខុសត្រូវ ព្រមទាំងបានកំណត់ច្បាស់នូវចំណុចវិធានការគោលនយោបាយ និងផែនការសកម្មភាពសំខាន់ៗពាក់ព័ន្ធផលិតកម្មកសិ-ឧស្សាហកម្ម រួមមាន (ទី១)-ការពិនិត្យលទ្ធភាពបង្កើតនូវតំបន់កែច្នៃកសិផល និងការផ្តល់ការលើកទឹកចិត្ត ចំពោះក្រុមហ៊ុនទាំងឡាយណាដែលបោះទីតាំងនៅក្នុងតំបន់នោះ (ទី២)-បង្កើតមូលនិធិសម្រាប់ជំរុញការអភិវឌ្ឍផលិតផលបច្ចេកទេសកែច្នៃកសិផល និងការអភិវឌ្ឍបច្ចេកទេសដោយភ្ជាប់ទៅនឹងសក្តានុពលនាំចេញ (ទី៣)-រៀបចំសម្រួលយន្តការដល់ការនាំចេញផលិតផលកែច្នៃ ដោយដោះស្រាយនូវបញ្ហាឡូជីស្ទិក លុបបំបាត់កម្រៃក្រៅផ្លូវការ និងកែលម្អការសម្រួលពាណិជ្ជកម្ម (ទី៤)-កំណត់នូវមុខងារទំនិញអាទិភាព ដែលមានសក្តានុពលកែច្នៃសម្រាប់នាំចេញ និងរៀបចំផែនការសកម្មភាពជាក់លាក់គាំទ្រការអភិវឌ្ឍវិស័យនេះ។

ចំណុចគន្លឹះដែលត្រូវយកចិត្តទុកដាក់ ក្នុងការជំរុញការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្មដើម្បីឆ្លើយតបទៅនឹងគោលនយោបាយដែលបានដាក់ឱ្យអនុវត្តនេះ គឺការតម្រង់ទិសការអភិវឌ្ឍតំបន់កែច្នៃកសិផល តំបន់កែច្នៃ និងផលិតផលសង្ហារឹម តំបន់កែច្នៃផលិតសម្ភារអំពីកៅស៊ូ តំបន់កែច្នៃផលិតម្ហូបអាហារពីផលិតផលដំណាំ សត្វ និងជលផល និងការអភិវឌ្ឍសួនកសិ-ឧស្សាហកម្មសម្រាប់គោលដៅនៃការប្រមូលផ្តុំកសិផល ដែលមានសក្តានុពលសម្រាប់កែច្នៃប្រើប្រាស់ក្នុង

ស្រុក និងនាំចេញ។ យន្តការគន្លឹះដែលត្រូវយកចិត្តទុកដាក់ ជំរុញការអភិវឌ្ឍកសិឧស្សាហកម្ម នោះគឺ ការសម្របសម្រួល និងការលើកទឹកចិត្តវិស័យឯកជន ក្នុងការអភិវឌ្ឍបច្ចេកទេសកែច្នៃកសិផល ស្របតាមស្តង់ដារផលិតផលអាហ៊ាន និងតម្រូវការស្តង់ដារទីផ្សារអន្តរជាតិ។ ការផ្សារភ្ជាប់រវាងក្រុមអ្នក ផលិតជាមួយអ្នកប្រមូលទិញ តាមយន្តការ "ផលិតកម្មកសិកម្មតាមកិច្ចសន្យា" ដើម្បីធានាការផ្គត់ផ្គង់កសិផលប្រកបដោយនិរន្តរភាព គឺជាចំណុចយុទ្ធសាស្ត្រដ៏សំខាន់ផងដែរ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រមូលផ្តុំនូវសក្តានុពលក្នុងការរៀបចំផែនការសកម្មភាព ដើម្បីចូលរួមចំណែកជំរុញការអនុវត្ត គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ដោយផ្តល់លើវិធានការជាយុទ្ធសាស្ត្រចំនួន៤គឺ៖

១. វិធានការជំរុញការទាក់ទាញវិនិយោគក្នុងវិស័យកសិកម្ម ដែលពាក់ព័ន្ធនឹងការកំណត់តំបន់សក្តានុពលផលិតកម្មកសិកម្ម ការបង្កើតតំបន់កសិឧស្សាហកម្មកែច្នៃកសិផល។

២. វិធានការពង្រីក និងទំនើបកម្មសហគ្រាសកសិកម្មធុនតូច និងមធ្យម សំដៅពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ជំរុញឱ្យអនុវត្តបច្ចេកវិទ្យាសមស្រប ការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា។

៣. វិធានការពាក់ព័ន្ធនឹងការកែលម្អបរិស្ថាននិយ័តកម្ម ដែលមានការពាក់ព័ន្ធនឹងការកសាងច្បាប់ លិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់។

៤. វិធានការសម្របសម្រួលគោលនយោបាយ ដែលផ្តោតជាសំខាន់លើយន្តការសម្របសម្រួលពិសេសយន្តការច្រកចេញចូលតែមួយ ការចរចារការតម្រូវនានា ពិសេសកិច្ចការអនាម័យ និងភូតគាមអនាម័យ ដើម្បីសម្រួលការនាំចេញ...។ល។

ក្រសួងនឹងយកចិត្តទុកដាក់លើវិធានការពង្រីក និងទំនើបកម្មសហគ្រាសកសិកម្មធុនតូច និងមធ្យម និងពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ឱ្យមានលក្ខណៈជាអាជីព ដោយជំរុញឱ្យអនុវត្តបច្ចេកវិទ្យាសមស្រប និងអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ព្រមទាំងលើកកម្ពស់ការចូលរួមពីវិស័យឯកជន ក្នុងគ្រប់ខ្សែសង្វាក់តម្លៃកសិកម្ម ដើម្បីផ្សារភ្ជាប់កសិករខ្នាតតូច ទៅនឹងទីផ្សារតាមអភិក្រម "**ភាពជាដៃគូក្នុងចំណោម រដ្ឋ-ឯកជន-ផលិតករ** (Public Private Producer Partnership -PPPP ឬ 4P)" ។

ដ្យាក្រាមទី ២.១ អភិក្រមយុទ្ធសាស្ត្រ ភាពជាដៃគូក្នុងចំណោម រដ្ឋ-ឯកជន-ផលិតករ




បន្ថែមលើនេះទៀត ក្រសួងនឹងបន្តលើកកម្ពស់វិធានអនាម័យ និងភូតគាមអនាម័យ (SPS) ដោយយកចិត្តទុកដាក់ទៅលើយន្តការ ក្របខណ្ឌគតិយុត្ត និងបច្ចេកវិទ្យា ព្រមទាំងពង្រីក និងពង្រឹងសមត្ថកិច្ចត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យនៅតាមច្រកទ្វារព្រំដែន ដើម្បីសម្រួលពាណិជ្ជកម្ម សមាហរណកម្មសេដ្ឋកិច្ច និងទទួលបានទីផ្សារផលិតផលកសិកម្មក្នុងតំបន់ និងអន្តរជាតិ[30]។

[30] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ២០១៥-២០១៦* (ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ២០១៦), ២-៦។

# ជំពូកទី៣
# ការព្យាករណ៍កំណើនអនុ
# វិស័យកសិកម្មសំខាន់ៗ

# ជំពូកទី៣
# ការព្យាករណ៍កំណើនអនុវិស័យកសិកម្មសំខាន់ៗ

នៅក្នុងជំពូកទី៣ នេះ ខ្ញុំមានគោលបំណងធ្វើការព្យាករណ៍ និងពិភាក្សាទៅលើទិដ្ឋភាពកំណើនអនុវិស័យកសិកម្មសំខាន់ៗ របស់ប្រទេសកម្ពុជាដែលយល់ថាមានការពាក់ព័ន្ធទៅនឹងការវិភាគក្នុងការសិក្សាស្រាវជ្រាវ ដែលបាននឹងកំពុងកើតមានឡើងក្នុងវិស័យកសិកម្ម ដើម្បីសិក្សាវែកញែកជុំវិញដំណើរវិវត្តន៍នៃវិស័យកសិកម្មនេះ ថាតើដំណោះស្រាយបែបណាដែរ ដែលសមស្របទៅនឹងបញ្ហាទាំងអស់នោះ។ ទាំងនេះ គឺជាគោលបំណងនៃជំពូកទី៣ និងជាការឆ្លើយតបផងដែរ ទៅនឹងគោលបំណងនៃការស្រាវជ្រាវលើប្រធានបទមួយនេះ។

## ៣.១ ការវិភាគលើកំណើនអនុវិស័យសំខាន់ៗ

ដើម្បីព្យាករណ៍លើការកើនឡើងនៅឆ្នាំបន្ទាប់យើងប្រើប្រាស់រូបមន្តះ

Naive Trend Model

$$Y_{t+1} = Y_t + (Y_t - Y_{t-1})$$

ការសិក្សាលើកំណើនកសិកម្មតាមបណ្តាផ្នែកនីមួយៗ វាជាគោលបំណងយ៉ាងសំខាន់មួយនៃកិច្ចការស្រាវជ្រាវ របស់ខ្ញុំបាទ និងសមស្របតាមទិសដៅនៃប្រធានបទ។ ដើម្បីវិភាគទៅលើកំណើន តាមវិស័យកសិកម្មរបស់ប្រទេសកម្ពុជាចន្លោះឆ្នាំ ២០១៦-២០២១។

### ៣.១.១ ការប៉ាន់ស្មានការវិវត្តនៃផលិតកម្មដំណាំស្រូវ

នៅប្រទេសកម្ពុជា ស្រូវគឺជាដំណាំដែលប្រជាកសិករនិយមដាំដុះជាងគេ ពីព្រោះផ្ទៃដីដាំដុះស្រូវមានទំហំរហូតដល់ ៣,០៩០,០០០ ហិកតា នៅឆ្នាំ២០១៦ នៃផ្ទៃដីកសិកម្មទាំងមូល។ ផ្ទៃដីដាំដុះនេះនឹងមានការកើនឡើងដល់ទៅ ៣,២៨២,៩៥០ ហិកតា នៅឆ្នាំ២០២១ (តួលេខព្យាករណ៍នៅក្នុងតារាងខាងក្រោម) ដោយសារការអភិវឌ្ឍកើនឡើងនៃប្រព័ន្ធធារាសាស្ត្រ ដែលធ្វើឱ្យមានការរីកលូតលាស់ នៃផ្ទៃដីដាំដុះនារដូវប្រាំង និងរដូវវស្សាបន្ថែមទៀត។ គួររំលឹកផងដែរថា ផលិតកម្មដំណាំស្រូវ បានកើនឡើងពី ៩.២៩លានតោន នៅឆ្នាំ២០១២ ដល់ ៩.៨២លានតោននៅឆ្នាំ២០១៦នេះ (កើនប្រហែល ៥.៦%)។ ទិន្នផលស្រូវជាមធ្យមទាំងប្រាំង និងវស្សា បានកើនពី ៣.១១៧តោន/ហិកតា ដល់ ៣.១៨៩តោន/ហិកតា ពីឆ្នាំ២០១២ដល់ឆ្នាំ២០១៦ (កើនប្រមាណជាង ២.២៤%)។

តារាងទី ៣.១៖ ការប៉ាន់ស្មានផលិតកម្មដំណាំស្រូវនៅកម្ពុជាឆ្នាំ២០១៥-២០២១

| បរិយាយ | ២០១៥ | ២០១៦ | ២០១៧ (ប៉ាន់ស្មាន) | ២០១៨ (ប៉ាន់ស្មាន) |
|---|---|---|---|---|
| ផ្ទៃដីដាំដុះ (ហ.ត) | ៣,០៥១,៥១២ | ៣,០៩០,០០០ | ៣,១២៨,៥៨៨ | ៣,១៦៧,១៧៦ |
| ផ្ទៃដីប្រមូលផល (ហ.ត) | ៣,០២៥,៦៣០ | ៣,០៨០,០០០ | ៣,១៣៥,៣៧០ | ៣,១៨៨,៧៤០ |
| ទិន្នផល (តោន/ហ.ត) | ៣.០៨៥ | ៣.១៨៩ | ៣.២៩៣ | ៣.៣៩៧ |
| បរិមាណផល (តោន) | ៩,៣៣៥,២៨៤ | ៩,៨២០,០០០ | ១០,៣០៥,៧១៦ | ១០,៧៨៩,៤៣២ |
| បរិមាណអង្ករសល់ (តោន) | ២,៩៧៥,៨០៩ | ៣,២០០,០០០ | ៣,៤២៤,១៩១ | ៣,៦៤៨,៣៨២ |
| គិតជាស្រូវសល់ (តោន) | ៤,៦៤៩,៧០២ | ៤,៩៩០,០០០ | ៥,៣៣០,២៩៨ | ៥,៦៧០,៥៩៦ |

| បរិយាយ | ២០១៩ (ប៉ាន់ស្មាន) | ២០២០ (ប៉ាន់ស្មាន) | ២០២១ (ប៉ាន់ស្មាន) | ផ្សេងៗ |
|---|---|---|---|---|
| ផ្ទៃដីដាំដុះ (ហ.ត) | ៣,២០៥,៧៦៤ | ៣,២៤៤,៣៥២ | ៣,២៨២,៩៤០ | |
| ផ្ទៃដីប្រមូលផល (ហ.ត) | ៣,២៤៣,១១០ | ៣,២៩៧,៤៨០ | ៣,៣៥១,៨៥០ | |
| ទិន្នផល (តោន/ហ.ត) | ៣.៥០១ | ៣.៦០៥ | ៣.៧០៩ | |
| បរិមាណផល (តោន) | ១១,២៧៤,១៤៨ | ១១,៧៥៨,៨៦៤ | ១២,២៤៣,៥៨០ | |
| បរិមាណអង្ករសល់ (តោន) | ៣,៨៧២,៥៧៣ | ៤,០៩៦,៧៦៤ | ៤,៣២០,៩៥៥ | |
| គិតជាស្រូវសល់ (តោន) | ៦,០១០,៨៩៤ | ៦,៣៥១,១៩២ | ៦,៦៩១,៤៩០ | |

នៅឆ្នាំ ២០១៦ ទិន្នផលស្រូវក្នុងប្រទេសកម្ពុជាមានចំនួន ៣.១៨៩តោន/ហិកតា ដែលទិន្នផលនេះអាចកើនទៅដល់ ៣.៧០៩តោន/ហិកតា នៅឆ្នាំ២០២១ ខាងមុខ ឬកើនឡើង ១៦.៣១% ថែមទៀតបើធៀបទៅនឹងឆ្នាំ ២០១៦។ ដោយសារ ការរីកចម្រើនលូតលាស់ នៃផ្ទៃដីដាំដុះ និងទិន្នផលស្រូវនៅឆ្នាំ២០២១ ប្រទេសកម្ពុជា នឹងមានអតិរេកស្រូវ ប្រមាណ ៦,៦៩១,៤៩០ តោន គិតជាអង្ករស្មើនឹង ៤,៣២០,៩៥៥តោនអង្ករ។ លទ្ធផលដែលសង្ឃឹមនឹងទទួលបាននេះ ក៏អាស្រ័យនឹងការអនុវត្តនូវប្រព័ន្ធប្រពលវប្បកម្មស្រូវតាមគោលការណ៍ធម្មជាតិ ដែលមានការចូលរួមយ៉ាងសកម្មរវាងប្រជាពលរដ្ឋ និងអង្គការក្រៅរដ្ឋាភិបាលនានាដែលប្រតិបត្តិការលើជំនាញដូចជាអង្គការសេដាក់ជាដើម។ ជាមួយគ្នានេះដែរការកើនឡើងនូវការប្រើប្រាស់គ្រឿងយន្តទំនើបបានចូលរួមចំណែកយ៉ាងសំខាន់ នៅក្នុងការបង្កើនផលិតកម្មរបស់ប្រជាកសិករឱ្យកាន់តែប្រសើរឡើងថែមមួយកម្រិតទៀត។

តារាងទី ៣.២៖ ការប៉ាន់ស្មាននៃបរិមាណផលស្រូវវស្សា និងប្រាំងចាប់ពីឆ្នាំ ២០១៦-២០២១

| បរិយាយ (តោន) | ២០១៥ | ២០១៦ | ២០១៧ (ប៉ាន់ស្មាន) | ២០១៨ (ប៉ាន់ស្មាន) |
|---|---|---|---|---|
| បរិមាណផល | ៩,៣៣៥,០០០ | ៩,៨២០,០០០ | ១០,៣០៥,០០០ | ១០,៧៩០,០០០ |
| ស្រូវវស្សា | ៧,១៧១,០០០ | ៧,៦២០,០០០ | ៨,០៦៩,០០០ | ៨,៥១៨,០០០ |
| ស្រូវប្រាំង | ២,១៦៥,០០០ | ២,២០០,០០០ | ២,២៣៥,០០០ | ២,២៧០,០០០ |
| **បរិយាយ (តោន)** | **២០១៩ (ប៉ាន់ស្មាន)** | **២០២០ (ប៉ាន់ស្មាន)** | **២០២១ (ប៉ាន់ស្មាន)** | **ផ្សេងៗ** |
| បរិមាណផល | ១១,២៧៥,០០០ | ១១,៧៦០,០០០ | ១២,២៤៥,០០០ | |
| ស្រូវវស្សា | ៨,៩៦៧,០០០ | ៩,៤១៦,០០០ | ៩,៨៦៥,០០០ | |
| ស្រូវប្រាំង | ២,៣០៥,០០០ | ២,៣៤០,០០០ | ២,៣៧៥,០០០ | |

បរិមាណផលដែលទទួលបាននៅឆ្នាំ ២០១៦ គឺមានចំនួន ៩,៨២០,០០០ តោន ដែលបរិមាណផលនេះនឹងកើនឡើងប្រមាណជា ១២,២៤៥,០០០ តោន នៅឆ្នាំ ២០២១ នេះដោយសារការរីកលូតលាស់នៃផ្ទៃដីដាំដុះ និងទិន្នផលកាន់តែប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ ផលនេះជាលទ្ធផលដ៏ប្រសើរមួយ សម្រាប់ប្រជាកសិករដែលរំពឹងថា គាត់នឹងមានស្រូវអង្ករសល់ពីការប្រើប្រាស់ច្រើនជាងមុន និងទុកសម្រាប់ការលក់ដូរ។ ទាំងនេះនឹងរឹតតែធ្វើឱ្យប្រជាកសិករមានជីវភាពកាន់តែប្រសើរជាងមុន មានន័យថា ភាពក្រីក្រនឹងធ្លាក់ចុះថែមទៀត ទៅតាមការកើនឡើងនូវបរិមាណផលស្រូវអង្ករ ដែលប្រជាកសិករសល់អាចដោះដូរបាន បន្ទាប់ពីទុកពូជ និងបរិភោគ។ ចំណែកឯអ្នកដែលជាអ្នកទិញស្បៀងសម្រាប់បរិភោគ ក៏នឹងទទួលបានផលប្រយោជន៍ពីការថយចុះនូវការចំណាយលើអាហារប្រចាំថ្ងៃផងដែរ។ នៅក្នុងប្រទេសកម្ពុជា ការប្រើប្រាស់ស្បៀងគិតជាមធ្យមក្នុងមួយគ្រួសារប្រហែល ១.៨តោនស្រូវ ប្រសិនបើប្រៀបធៀបទៅនឹងទិន្នផលជាមធ្យម ៣.១៨៩តោន/ហិកតា នាឆ្នាំ២០១៦ មានន័យថា កម្រិតផលិតកម្មមានផលលើសមានប្រមាណ ១.៤តោន (ករណីមួយគ្រួសារមានដីមួយហិកតា)។ ដោយតម្លៃស្រូវ ក្នុងមួយគីឡូក្រាមថ្លៃពី ៨០០ រៀល គិតជាទឹកប្រាក់ប្រហែលជា ២៨០ ដុល្លារអាមេរិក នៅសល់សម្រាប់ធ្វើការទូទាត់ទៅលើ ថ្លៃដី ថ្នាំពុល និងជួលកម្លាំងពលកម្ម។

សរុបសេចក្ដីមក ការអភិវឌ្ឍដំណាំស្រូវនៅប្រទេសកម្ពុជានឹងអាចទទួលបានលទ្ធផលល្អប្រសើរ ដោយទិន្នផលស្រូវអាចមានការកើនឡើងជាមធ្យមប្រមាណ ១០% ពីមួយឆ្នាំទៅមួយឆ្នាំ។

ដូចនេះ វាបានចូលរួមចំណែកក្នុង ការលើកកម្ពស់កម្រិតជីវភាពប្រជាជន និងសេដ្ឋកិច្ចជាតិបានមួយកម្រិតទៀត។

### ៣.១.២ ការប៉ាន់ស្មានដំណាំរួមផ្សំ និងឧស្សាហកម្ម ពីឆ្នាំ ២០១៦-២០២១

បន្ទាប់ពីដំណាំស្រូវ ដែលជាដំណាំដ៏សំខាន់បំផុតរបស់ប្រទេសកម្ពុជា គឺនៅមានដំណាំរួមផ្សំ និងដំណាំកសិ-ឧស្សាហកម្ម មួយចំនួនទៀតដែលបានចូលរួមចំណែក យ៉ាងសំខាន់ក្នុងខឿនសេដ្ឋកិច្ចជាតិ និងកម្រិតជីវភាពប្រចាំថ្ងៃរបស់ប្រជាជនទាំងនៅជនបទ និងទីក្រុង។ ក្នុងចំណោមដំណាំទាំងនោះ គេសង្កេតឃើញ មានដំណាំដូចជា ពោត សណ្តែកសៀង ដំឡូងឈើ សណ្តែកបាយថ្នាំជក់ និងដំឡូងជ្វា ដែលកំពុងធ្វើការដាំដុះលើផ្ទៃដីប្រមាណជា ៨២២,៤៩៦ ហិកតា នៅឆ្នាំ ២០១៥ (ឆ្នាំ២០១៤ មានប្រមាណ ៨០៧,៤២៣ហិកតា) ហើយផ្ទៃដីដាំដុះនេះ នឹងអាចកើនឡើងដល់ប្រហែល ៩២៨,០០៧ហិកតា នៅឆ្នាំ២០២១។

តារាងទី ៣.៣៖ បង្ហាញអំពីការព្យាករណ៍ផ្ទៃដីដាំដុះដំណាំរួមផ្សំ និងឧស្សាហកម្មសំខាន់ៗ

| បរិយាយ (ហិកតា) | ២០១៥ | ២០១៦ (ប៉ាន់ស្មាន) | ២០១៧ (ប៉ាន់ស្មាន) | ២០១៨ (ប៉ាន់ស្មាន) | ២០១៩ (ប៉ាន់ស្មាន) | ២០២០ (ប៉ាន់ស្មាន) | ២០២១ (ប៉ាន់ស្មាន) |
|---|---|---|---|---|---|---|---|
| ពោត | ១១២,៥៧៤ | ៨១,៦៣១ | ៥០,៦៨៨ | ១៩,៧៤៥ | -១១,១៩៨ | -៤២,១៤១ | -៧៣,០៨៤ |
| ដំឡូងឈើ | ៥៧៣,៦២៤ | ៦២៥,៧៨៩ | ៦៧៧,៩៥៤ | ៧៣០,១១៩ | ៧៨២,២៨៤ | ៨៣៤,៤៤៩ | ៨៨៦,៦១៤ |
| ដំឡូងជ្វា | ៥,៧៥៧ | ៥,៥៩៩ | ៥,៤៤១ | ៥,២៨៣ | ៥,១២៥ | ៤,៩៦៧ | ៤,៨០៩ |
| បន្លែ | ៤៧,៣៧៣ | ៤៣,១០៩ | ៣៨,៨៤៥ | ៣៤,៥៨១ | ៣០,៣១៧ | ២៦,០៥៣ | ២១,៧៨៩ |
| សណ្តែកបាយ | ៥៧,១៧២ | ៦១,០៥០ | ៦៤,៩២៨ | ៦៨,៨០៦ | ៧២,៦៨៤ | ៧៦,៥៦២ | ៨០,៤៤០ |
| សណ្តែកដី | ១៥,៥១៩ | ១៣,២២០ | ១០,៩២១ | ៨,៦២២ | ៦,៣២៣ | ៤,០២៤ | ១,៧២៥ |
| សណ្តែកសៀង | ៦៦,៨២៤ | ៦១,១៣៧ | ៥៥,៤៥០ | ៤៩,៧៦៣ | ៤៤,០៧៦ | ៣៨,៣៨៩ | ៣២,៧០២ |
| ល្ង | ២៦,៥៤៤ | ២៤,៩១៨ | ២៣,២៩២ | ២១,៦៦៦ | ២០,០៤០ | ១៨,៤១៤ | ១៦,៧៨៨ |
| អំពៅ | ១៩,៥១៤ | -៩,៣២៩ | -៣៨,១៧២ | -៦៧,០១៥ | -៩៥,៨៥៨ | -១២៤,៧០១ | -១៥៣,៥៤៤ |
| ក្រចៅ | ១៣៥ | ៧៨ | ២១ | -៣៦ | -៩៣ | -១៥០ | -២០៧ |
| ថ្នាំជក់ | ៦,៥៤៥ | ២,៣៦៣ | -១,៨១៩ | -៦,០០១ | -១០,១៨៣ | -១៤,៣៦៥ | -១៨,៥៤៧ |

តាមការប៉ាន់ស្មាន បង្ហាញឱ្យឃើញថា មានតែដំណាំ ដំឡូងឈើ និងសណ្តែកបាយ គឺមានការកើនឡើងនៃផ្ទៃដីដាំដុះ។ ដែលនៅឆ្នាំ ២០១៥ ផ្ទៃដីដាំដុះ ដំឡូងឈើមានចំនួន ៥៧៣,៦២៤ ហិកតា ហើយបរិមាណនេះនឹងកើនឡើងដល់ ៨៨៦,៦១៤ហិកតា នៅឆ្នាំ២០២១ ដែលមានកំណើនប្រមាណជា ៥៤.៥៦% បើប្រៀបធៀបនឹងឆ្នាំ២០១៥។ ចំណែកឯ ដំណាំ

សណ្តែកបាយ បានផ្តល់បរិមាណផលចំនួន ៥៧,១៧២ហិកតា នៅឆ្នាំ ២០១៥ ហើយចំនួននេះ អាចនឹងកើនឡើងដល់ ៨០,៩៤០ហិកតា នៅឆ្នាំ២០២១ ដែលមានកំណើនប្រមាណជា ៤០.៧០% បើប្រៀបធៀបទៅនឹងឆ្នាំ២០១៥។

តារាងទី ៣.៥៖ បង្ហាញអំពីការព្យាករណ៍បរិមាណផលដំណាំរួមផ្សំ និងឧស្សាហកម្មសំខាន់ៗ

| បរិយាយ (តោន) | ២០១៥ | ២០១៦ (ប៉ាន់ស្មាន) | ២០១៧ (ប៉ាន់ស្មាន) | ២០១៨ (ប៉ាន់ស្មាន) |
|---|---|---|---|---|
| ពោត | ៣៩៩,៦៤៩ | ២៤៩,៦៩១ | ៩៩,៧៣៣ | -៥០,២២៥ |
| ដំឡូងឈើ | ១៣,២៩៨,១០៨ | ១៤,៦៥៣,០១២ | ១៦,០០៧,៩១៦ | ១៧,៣៦២,៨២០ |
| ដំឡូងជ្វា | ៤៥,៤២៤ | ៣៦,៥៨៩ | ២៧,៧៥៤ | ១៨,៩១៩ |
| បន្លែ | ៤០៥,៥២៧ | ៣៩៥,៨១៥ | ៣៨៦,១០៣ | ៣៧៦,៣៩១ |
| សណ្តែកបាយ | ៥៩,២២០ | ៥៧,៧៨៨ | ៥៦,៣៥៦ | ៥៤,៩២៤ |
| សណ្តែកដី | ២៥,១៤៩ | ៨៩,៧០៤ | ១៩,៩២៧ | ១៧,៣១៦ |
| សណ្តែកសៀង | ៩៦,៩៤២ | ១៨,៤៧៨ | ៨២,៥៦៦ | ៧៥,២២៨ |
| ល្ង | ១៧,៨៦៩ | -១២២,៦៤៦ | ១៩,០៨៧ | ១៩,៦៩៦ |
| អំពៅ | ៧០៩,១៧៥ | -១៧ | -៩៥៥,៤៦៧ | -១,៧៨៦,២៨៨ |
| ក្រចៅ | ៧៥ | ២,១៧៧ | -១០៩ | -២០១ |
| ថ្នាំជក់ | ៨,០៥៨ | | -៣,៧០៤ | -៩,៥៨៥ |

| បរិយាយ (តោន) | ២០១៩ (ប៉ាន់ស្មាន) | ២០២០ (ប៉ាន់ស្មាន) | ២០២១ (ប៉ាន់ស្មាន) | ផ្សេងៗ |
|---|---|---|---|---|
| ពោត | -២០០,១៨៣ | -៣៥០,១៤១ | -៥០០,០៩៩ | |
| ដំឡូងឈើ | ១៨,៧១៧,៧២៤ | ២០,០៧២,៦២៨ | ២១,៤២៧,៥៣២ | |
| ដំឡូងជ្វា | ១០,០៨៤ | ១,២៤៩ | -៧,៥៨៦ | |
| បន្លែ | ៣៦៦,៦៧៩ | ៣៥៦,៩៦៧ | ៣៤៧,២៥៥ | |
| សណ្តែកបាយ | ៥៣,៤៩២ | ៥២,០៦០ | ៥០,៦២៨ | |
| សណ្តែកដី | ១៤,៧០៥ | ១២,០៩៤ | ៩,៤៨៣ | |
| សណ្តែកសៀង | ៦៧,៩៩០ | ៦០,៧៥២ | ៥៣,៥១៤ | |
| ល្ង | ២០,៣០៥ | ២០,៩១៤ | ២១,៥២៣ | |
| អំពៅ | -២,៦១៨,១០៩ | -៣,៤៤៩,៩៣០ | -៤,២៨១,៧៥១ | |
| ក្រចៅ | -២៩៣ | -៣៨៥ | -៤៧៧ | |
| ថ្នាំជក់ | -១៥,៤៦៦ | -២១,៣៤៧ | -២៧,២២៨ | |

តាមការប៉ាន់ស្មាន បង្ហាញឱ្យឃើញថា មានតែដំណាំ ដំឡូងឈើ និងល្ង គឺ ទទួលបានផលល្អ។ ដែលនៅឆ្នាំ ២០១៥ ដំឡូងឈើបានផ្តល់បរិមាណផលចំនួន ១៣,២៩៨,១០៨ តោន ហើយបរិមាណនេះនឹងកើនឡើងដល់ ២១,៤២៧,៥៣២តោន នៅឆ្នាំ២០២១ ដែលមានកំណើនប្រមាណជា ៦១.១៣% បើប្រៀបធៀបនឹងឆ្នាំ២០១៥។ ចំណែកឯ ដំណាំល្ង បានផ្តល់បរិមាណផលចំនួន ១៧,៨៥៩តោន នៅឆ្នាំ ២០១៥ ហើយចំនួននេះអាចនឹងកើនឡើងដល់ ២១,៥២៣តោន នៅឆ្នាំ ២០២១ ដែលមានកំណើនប្រមាណជា ២០.៥២% បើប្រៀបធៀបទៅនឹងឆ្នាំ២០១៥។ ថ្វីបើបរិមាណផល នៃផលិតផលដំណាំផ្សេងៗទៀត មាននិន្នាការថយចុះពិតមែន ក៏ប៉ុន្តែការនាំចេញផលិតផលកសិកម្មសំខាន់ៗ នៅតែបន្តជាលំដាប់ ដែលមានដូចជា ចំណិតដំឡូងមី ដំឡូងមីស្រស់ ម្សៅដំឡូងមី ពោតក្រហម ម្រេច ផ្លែស្វាសស្រស់ និងដូងប្រេងឆៅ ដែលមានការកើនឡើងជារៀងរាល់ឆ្នាំតាំងពីឆ្នាំ២០១២ ពិសេសដំឡូងមី ម្រេច និងផ្លែស្វាយស្រស់។ នៅពេលដែលបរិមាណផល ពោត និងដំឡូងមី កើនឡើងល្អប្រសើរឡើងវិញនោះ វានឹងធ្វើឱ្យផលិតភាពសម្រាប់ផ្គត់ផ្គង់នៅលើទីផ្សារបានគ្រប់គ្រាន់ និងសម្រាប់ការនាំចេញទៅក្រៅប្រទេស ព្រមទាំងសម្រាប់ការវិនិយោគពី រោងចក្រប្រេងអេតាណុល និងរោងចក្ររបស់កូរ៉េ ដែលបានមកវិនិយោគនៅប្រទេសកម្ពុជានាពេលថ្មីៗនេះផងដែរ។ ជាសរុបមក ប្រសិនបើមានការវិនិយោគទៅលើការកែច្នៃកសិផល និងសេដ្ឋកិច្ចដំណើរការទៅបានល្អ នោះការអភិវឌ្ឍដំណាំកសិកម្មនឹងទទួលបានជោគជ័យ។

### ៣.១.៣ ការវិវត្ត ការនេសាទទឹកសាប ទឹកសមុទ្រ និងវារីវប្បកម្ម

ប្រទេសកម្ពុជា ជាប្រទេសមួយដែលសម្បូរទៅដោយប្រភពទឹក ដូចជា បឹងបួរ ព្រែក ស្ទឹង ជាពិសេសបឹងទន្លេសាប និងទន្លេមេគង្គ ជាប្រភពផ្គត់ផ្គង់ត្រីទឹកសាបដ៏សំខាន់មួយសម្រាប់បំពេញតម្រូវការបរិភោគនៅក្នុងស្រុក និងនៅសល់សម្រាប់នាំចេញទៅប្រទេសជិតខាង។

តារាងទី ៣.៥៖ បង្ហាញអំពីស្ថិតិព្យាករណ៍ផលនេសាទទឹកសាប សមុទ្រ និងវារីវប្បកម្ម

| បរិយាយ (តោន) | ២០១៥ | ២០១៦ | ២០១៧ (ប៉ាន់ស្មាន) | ២០១៨ (ប៉ាន់ស្មាន) | ២០១៩ (ប៉ាន់ស្មាន) | ២០២០ (ប៉ាន់ស្មាន) | ២០២១ (ប៉ាន់ស្មាន) |
|---|---|---|---|---|---|---|---|
| នេសាទទឹកសាប | ៤៨៧,៩០៥ | ៥០៩,៣៥០ | ៥៣០,៧៩៥ | ៥៥២,២៤០ | ៥៧៣,៦៨៥ | ៥៩៥,១៣០ | ៦១៦,៥៧៥ |
| នេសាទសមុទ្រ | ១២០,៥០០ | ១២០,៦០០ | ១២០,៧០០ | ១២០,៨០០ | ១២០,៩០០ | ១២១,០០០ | ១២១,១០០ |
| វារីវប្បកម្ម | ១៤៣,១៤១ | ១៧២,៥០០ | ២០១,៨៥៩ | ២៣១,២១៨ | ២៦០,៥៧៧ | ២៨៩,៩៣៦ | ៣១៩,២៩៥ |

តាមរយៈរបាយការណ៍ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅឆ្នាំ២០១៦ ផលិតផលនេសាទទឹកសាបទទួលផលបាន ៥០៩,៣៥០តោន និងការនេសាទសមុទ្រទទួលផលបាន ១២០,៦០០តោន។ តាមរយៈកំណែទម្រង់ស៊ីជម្រៅ វិស័យជលផល ដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល ដែលបានសម្រេចលុបឡូត៍នេសាទទាំងអស់ ទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ និងធ្វើជាកន្លែងអភិរក្សជលផល កំពុងបានផ្តល់ផលជាវិជ្ជមាន ដល់ប្រជាពលរដ្ឋទូទាំងប្រទេស តាមរយៈការនេសាទតាមគ្រួសារដែលមានប្រជានេសាទប្រមាណ ១.៥ លាននាក់កំពុងចូលរួម[31]។ បើផ្អែកទៅលើការព្យាករណ៍ខាងលើ បូករួមនឹងគោលនយោបាយថ្មីនោះ ទិន្នផលទឹកសាបអាចនឹងកើនឡើងដល់ចំនួនប្រមាណជា ៦១៦,៥៧៥ តោន នៅឆ្នាំ ២០២១ ដែលត្រូវជា ២១.០៥% បើធៀបទៅនឹងឆ្នាំ ២០១៦ រីឯការនេសាទសមុទ្រអាចកើនឡើងដល់ ១២១,១០០តោន នៅឆ្នាំ ២០២១ ខាងមុខ (តាមការព្យាករណ៍)។

### ៣.១.៤ ការវិវត្តនៃផលិតផលបសុសត្វ ២០១៦-២០២១

ការចិញ្ចឹមសត្វ គឺជាមុខរបរបន្ទាប់បន្សំមួយរបស់ប្រជាកសិករខ្មែរ ដែលវាបានចូលរួមចំណែកយ៉ាងសំខាន់ដល់ជីវភាពប្រចាំថ្ងៃ ជាពិសេសសត្វគោ និងក្របី ដែលជាកម្លាំងអូសទាញដ៏សំខាន់ក្នុងវិស័យកសិកម្ម។ ក្រៅពីនេះ នៅមាន មាន់ ទា និងជ្រូក ដែលភាគច្រើនឃើញមានការចិញ្ចឹមនៅតាមផ្ទះ ច្រើនជាងនៅកសិដ្ឋាន។

បើផ្អែកលើទិន្នន័យដែលបានព្យាករណ៍តាមតារាងខាងក្រោម ចំនួនសត្វគោចិញ្ចឹម ឃើញថាមានការកើនឡើងខ្ពស់ពី ២,៩២០,០០០ក្បាល ក្នុងឆ្នាំ២០១៦ ចំនួននេះនឹងអាចឡើងដល់ទៅ ៣,០០២,៩០០ក្បាល នៅឆ្នាំ២០២១ ដែលត្រូវជាប្រមាណ ២.៨៥%។ នេះដោយសារការរីកលូតលាស់នៃផ្ទៃដីដាំដុះ ដែលត្រូវការគោដើម្បីភ្ជួររាស់បន្ថែម។ ប៉ុន្តែ ទោះជាមានការរីកលូតលាស់នៃបច្ចេកវិទ្យា ជាពិសេសការប្រើប្រាស់គោយន្ត ដែលត្រូវបានប្រើប្រាស់ ជំនួសសត្វគោដើម្បីជាមធ្យោបាយសម្រាប់ភ្ជួររាស់ដីកសិកម្មក៏ដោយ ក៏កំណើននៃការចិញ្ចឹមសត្វគោគឺពុំមានការថយចុះឡើយ ដោយមូលហេតុតែប្រជាកសិករ មួយចំនួនបានប្រើប្រាស់គោយន្តសម្រាប់ភ្ជួររាស់ដីកសិកម្មផង បូករួមទាំងការចិញ្ចឹមសត្វគោ សម្រាប់ធ្វើការជួញដូរជាលក្ខណៈគ្រួសារផង ដែលបានផ្តល់ប្រាក់ចំណូលបន្ថែម ពីលើវិស័យកសិកម្មរបស់ប្រជាកសិករផងដែរ។ ដោយឡែកនៅឆ្នាំ ២០១៥ ប្រទេសកម្ពុជាបាននាំចេញសត្វគោ ក្របីចំនួន ៧,៣៣៥ក្បាល។ បើវិភាគទៅលើសត្វ

[31] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ២០១៥-២០១៦* (ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ២០១៦), ៣២។

ជ្រូកវិញគឺ នឹងមានការកើនឡើងជាលំដាប់ពី ២,៩៧១,០០០ក្បាល នៅឆ្នាំ២០១៦ កើនដល់ ៦,០៣៦,៨០៥ក្បាល នៅឆ្នាំ២០២១។ ការកើនឡើងនេះបណ្តាលមកពីការចំណាយពេលវេលា និងថវិកាតិច ប៉ុន្តែទទួលបានលទ្ធផលខ្ពស់អាចប្រកួតប្រជែងនៅលើទីផ្សារបាន និងដោយសារ កំណើននៃតម្រូវការសាច់ជ្រូកប្រចាំថ្ងៃ មានការកើនឡើងជាលំដាប់។ ចំណែកឯសត្វស្លាបវិញ ទោះបីជាមានការលេចឡើងនូវជំងឺផ្តាសាយបក្សីក៏ដោយ ក៏បរិមាណនៃការចិញ្ចឹមនៅតែមានការ កើនឡើងផងដែរ ដែលអាចមានចំនួនពី ៣៥,៧៣៤,០០០ក្បាល នៅឆ្នាំ២០១៦ ដល់ ៨០,៩៦០,៦២៥ក្បាល នៅឆ្នាំ២០២១។ ទាំងនេះ មួយផ្នែកបណ្តាលមកពីការហាមឃាត់ ការនាំចូលសត្វស្លាបពីប្រទេសជិតខាង ដែលធ្វើឱ្យប្រជាកសិករមានទឹកចិត្តក្នុងការចិញ្ចឹម ជាពិសេស ដោយមានការផ្សព្វផ្សាយ យ៉ាងទូលំទូលាយអំពីការថែទាំសត្វស្លាប មិនឱ្យឆ្លងជំងឺផ្តាសាយបក្សី និងបានតាមដានយ៉ាងត្រឹមត្រូវពីភ្នាក់ងារក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការ ជាមួយក្រសួងសុខាភិបាល និងអង្គការនានា សហការជាមួយប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

តារាងទី ៣.៦៖ បង្ហាញពីស្ថិតិការព្យាករណ៍ការចិញ្ចឹមសត្វពីឆ្នាំ ២០១៦-២០២១

| បរិយាយ (ក្បាល) | ២០១៥ | ២០១៦ | ២០១៧ (ប៉ាន់ស្មាន) | ២០១៨ (ប៉ាន់ស្មាន) |
|---|---|---|---|---|
| គោ | ២,៩០៣,៩២០ | ២,៩២០,០០០ | ២,៩៣៦,៥៨០ | ២,៩៥៣,១៦០ |
| ក្របី | ៥០៦,១៦៥ | ៥២៤,០០០ | ៥៤១,៨៣៥ | ៥៥៩,៦៧០ |
| ជ្រូក | ២,៣៥៧,៨៣៩ | ២,៩៧១,០០០ | ៣,៥៨៤,១៦១ | ៤,១៩៧,៣២២ |
| សត្វស្លាប | ២៦,៦៨៨,៦៧៥ | ៣៥,៧៣៤,០០០ | ៤៤,៧៧៩,៣២៥ | ៥៣,៨២៤,៦៥០ |

| បរិយាយ (ក្បាល) | ២០១៩ (ប៉ាន់ស្មាន) | ២០២០ (ប៉ាន់ស្មាន) | ២០២១ (ប៉ាន់ស្មាន) | ផ្សេងៗ |
|---|---|---|---|---|
| គោ | ២,៩៦៩,៧៤០ | ២,៩៨៦,៣២០ | ៣,០០២,៩០០ | |
| ក្របី | ៥៧៧,៥០៥ | ៥៩៥,៣៤០ | ៦១៣,១៧៥ | |
| ជ្រូក | ៤,៨១០,៤៨៣ | ៥,៤២៣,៦៤៤ | ៦,០៣៦,៨០៥ | |
| សត្វស្លាប | ៦២,៨៦៩,៩៧៥ | ៧១,៩១៥,៣០០ | ៨០,៩៦០,៦២៥ | |

ដូច្នេះ យើងសង្កេតឃើញថា ការចិញ្ចឹមសត្វ គោ ក្របី ជ្រូក និងសត្វស្លាប មានការកើន ឡើងជាលំដាប់ ដែលធ្វើឱ្យជីវភាពរបស់គាត់កាន់តែប្រសើរឡើងជាងមុន។ ម៉្យាងវិញទៀត ប្រជា កសិករ ត្រូវតែយកចិត្តទុកដាក់ និងប្រុងប្រយ័ត្នខ្ពស់ ក្នុងការក្តាប់យកពត៌មានទីផ្សារឱ្យបាន ច្បាស់លាស់មុននឹងសម្រេចចិត្តក្នុងការចិញ្ចឹម។

### ៣.១.៤.១ ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម

ការចិញ្ចឹមសត្វលក្ខណៈពាណិជ្ជកម្ម ហាក់មានការរីកចម្រើន គួរឱ្យកត់សម្គាល់ផងដែរ ពីព្រោះបរិមាណនៃការចិញ្ចឹម មានកម្រិតកើនឡើងជាលំដាប់។ នៅឆ្នាំ២០១៥ ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មនេះ មានការកើនឡើង ដោយកសិដ្ឋានចិញ្ចឹមសត្វ មានចំនួនរហូតដល់ ២,៨៥៦កន្លែង កើន ២១% ចំណែកឯចំនួនសត្វមាន ៨,១៧០,៥២៥ក្បាល កើន ២៨,៩៧% ក្នុងនោះជ្រូកកើន ១១.៤៥% សត្វស្លាបកើន ២៩.៩៩% និងគោកើនចំនួន ១០៦.១១%[32]។

តារាងទី ៣.៧៖ បង្ហាញពីស្ថិតិការព្យាករណ៍ការចិញ្ចឹមសត្វលក្ខណៈពាណិជ្ជកម្ម

| ប្រភេទសត្វ | ២០១៤ | | ២០១៥ | | ២០១៦ (ប៉ាន់ស្មាន) | |
|---|---|---|---|---|---|---|
| | ចំនួនកសិដ្ឋាន | ចំនួនសត្វ (ក្បាល) | ចំនួនកសិដ្ឋាន | ចំនួនសត្វ (ក្បាល) | ចំនួនកសិដ្ឋាន | ចំនួនសត្វ (ក្បាល) |
| គោ ក្របី | ៤០ | ៦,៤៧៨ | ៨៦ | ១៣,៣៥២ | ១៣២ | ២០,២២៦ |
| ជ្រូក | ៣៨៥ | ៣៧៤,៨៩៤ | ៥០០ | ៤១៧,៧៧៥ | ៦១៥ | ៤៦០,៦៥៦ |
| សត្វស្លាប | ១,៩៣៤ | ៥,៩៥៣,៦៣០ | ២,២៧០ | ៧,៧៣៩,៣៩៨ | ២,៦០៦ | ៩,៥២៥,១៦៦ |

| ប្រភេទសត្វ | ២០១៧ (ប៉ាន់ស្មាន) | | ២០១៨ (ប៉ាន់ស្មាន) | | ២០១៩ (ប៉ាន់ស្មាន) | |
|---|---|---|---|---|---|---|
| | ចំនួនកសិដ្ឋាន | ចំនួនសត្វ (ក្បាល) | ចំនួនកសិដ្ឋាន | ចំនួនសត្វ (ក្បាល) | ចំនួនកសិដ្ឋាន | ចំនួនសត្វ (ក្បាល) |
| គោ ក្របី | ១៧៨ | ២៧,១០០ | ២២៤ | ៣៣,៩៧៤ | ២៧០ | ៤០,៨៤៨ |
| ជ្រូក | ៧៣០ | ៥០៣,៥៣៧ | ៨៤៥ | ៥៤៦,៤១៨ | ៩៦០ | ៥៨៩,២៩៩ |
| សត្វស្លាប | ២,៩៤២ | ១១,៣១០,៩៣៤ | ៣,២៧៨ | ១៣,០៩៦,៧០២ | ៣៦១៤ | ១៤,៨៨២,៤៧០ |

| ប្រភេទសត្វ | ២០២០ (ប៉ាន់ស្មាន) | | ២០២១ (ប៉ាន់ស្មាន) | | ផ្សេងៗ | |
|---|---|---|---|---|---|---|
| | ចំនួនកសិដ្ឋាន | ចំនួនសត្វ (ក្បាល) | ចំនួនកសិដ្ឋាន | ចំនួនសត្វ (ក្បាល) | | |
| គោ ក្របី | ៣១៦ | ៤៧,៧២២ | ៣៦២ | ៥៤,៥៩៦ | | |
| ជ្រូក | ១,០៧៥ | ៦៣២,១៨០ | ១,១៩០ | ៦៧៥,០៦១ | | |
| សត្វស្លាប | ៣,៩៥០ | ១៦,៦៦៨,២៣៨ | ៤,២៨៦ | ១៨,៤៥៤,០០៦ | | |

[32] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ២០១៥-២០១៦* (ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ២០១៦), ២៧។

ជាក់ស្តែង ការចិញ្ចឹមគោ-ក្របី ទូទាំងប្រទេសនៅឆ្នាំ២០១៥ មានចំនួន ៣,៤០៩,៥៨៥ក្បាល (គោមានចំនួន ២,៩០៣,៤២០ក្បាល និងក្របីចំនួន ៥០៦,១៦៥ក្បាល)។ ក្នុងបរិមាណ គោ-ក្របី ចិញ្ចឹមសរុបទូទាំងប្រទេសកម្ពុជា ចំនួនគោ-ក្របី ចិញ្ចឹមក្នុងកសិដ្ឋានមាន ១៣,៣៥២ក្បាល នៅឆ្នាំ២០១៥។ ចំណែកតម្រូវការសាច់គោវិញ មានចំនួនប្រមាណជា ៤៦១,៦៦៧ គ.ក្រ/ថ្ងៃ ឬ ១៦៨,៥០៨,៤៥៥ គ.ក្រ/ឆ្នាំ។ ដោយសាច់គោនៅលើទីផ្សារមានតម្លៃប្រហែល ៩ ដុល្លារ[33]/គ.ក្រ នោះប្រជាជនកម្ពុជា ត្រូវចំណាយប្រមាណ ៤,១៥៥,០០៣ ដុល្លារ/ថ្ងៃ ឬ ១,៥១៦,៥៧៦,០៩៥ ដុល្លារ/ឆ្នាំ។

ដោយយោងទៅតាមការព្យាករណ៍ ដែលទទួលបាន សត្វគោ ក្របីចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្មនឹងមានការកើនឡើងពី ១៣,៣៥២ក្បាល នៅឆ្នាំ២០១៥ ដល់ ៥៤,៥៩៦ក្បាលនៅឆ្នាំ ២១២១ និង ចំនួនកសិដ្ឋានកើនឡើងផងដែរពី ៨៦កសិដ្ឋាន នៅឆ្នាំ២០១៥ ដល់ ៣៦២កសិដ្ឋាន នៅឆ្នាំ២០២១។ ចំណែកឯការចិញ្ចឹមជ្រូក ជាលក្ខណៈពាណិជ្ជកម្មវិញ ក៏ដូចជាការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារដែរ គឺមាននិន្នាការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ ដោយនៅឆ្នាំ២០១៥ ការចិញ្ចឹមជ្រូកជាលក្ខណៈពាណិជ្ជកម្មមានចំនួន ៩១៧,៧៧៥ក្បាល ដែលមានចំនួនកសិដ្ឋាន ៥០០កន្លែង ហើយចំនួននេះអាចកើនដល់ ៦៧៥,០៦១ក្បាល ដែលមានចំនួនកសិដ្ឋាន ១,១៩០កន្លែង នៅឆ្នាំ២០២១។ ទាំងនេះដោយសារតែ កសិដ្ឋាននីមួយៗមានបទពិសោធន៍ ព្រមទាំងបច្ចេកទេសក្នុងការថែទាំច្បាស់លាស់ និងបានសហការយ៉ាងជិតស្និតជាមួយស្ថាប័នដែលពាក់ព័ន្ធលើផ្នែកបសុសត្វ។ ចំពោះសាច់ជ្រូកនេះ ប្រជាជនប្រើប្រាស់ប្រមាណជា ៦១៥,៥៥៦ គ.ក្រ/ថ្ងៃ ឬ ២២៤,៦៧៧,៩៤០ គ.ក្រ/ឆ្នាំ ដោយសាច់ជ្រូក ៤.៥ ដុល្លារ/គ.ក្រ នោះប្រជាជនកម្ពុជាត្រូវចំណាយ ២,៧៧០,០០២ ដុល្លារ/ថ្ងៃ ឬ ១,០១១,០៥០,៧៣០ ដុល្លារ/ឆ្នាំ។ ថ្មីៗនេះ ក្រសួងកសិកម្ម បាន អនុញ្ញាតឱ្យនាំចូលសត្វជ្រូកពីប្រទេសជិតខាងប្រមាណជាង ១,២០០ក្បាលក្នុង១ថ្ងៃ។ ប៉ុន្តែកង្វះសាច់ជ្រូក ប្រមាណជាង ១ពាន់ក្បាលនេះ តិចតួចបំផុតសម្រាប់វិស័យឯកជន ដែលចិញ្ចឹមជ្រូកក្នុងស្រុក វាជារឿងងាយណាស់ ដោយគ្រាន់តែបង្កើនការចិញ្ចឹមបន្ថែមបន្តិចគឺគ្រប់គ្រាន់ហើយ ដោយមិនចាំបាច់នាំចូលជ្រូកពីក្រៅប្រទេស ដែលនាំឱ្យមានហានិភ័យនោះទេ។ ជាមួយគ្នានេះ ក្រុមអ្នកចិញ្ចឹមជ្រូកក្នុងស្រុកអាចផលិត ជ្រូកបានជាង ៧ពាន់ក្បាល ក្នុង១ថ្ងៃ ក្នុងនោះក្រុមហ៊ុនធំៗ ក្នុងស្រុកអាចផលិតបានជាង៤ពាន់ក្បាល និងអ្នកចិញ្ចឹមខ្នាតតូចអាចផលិតបាន ៣ពាន់

[33] ទូរទស្សន៍បាយ័ន BTV news, *ព័ត៌មានប្រចាំថ្ងៃ* (ភ្នំពេញ៖ ស្ថានីយទូរទស្សន៍បាយ័ន BTV news), ចូលទស្សនាថ្ងៃទី ២៤ ឧសភា ២០១៧ ម៉ោង ៨:៣០នាទីយប់។

ក្បាល ក្នុង១ថ្ងៃ ពោលគឺជិតគ្រប់នឹងតម្រូវការទីផ្សារទូទាំងប្រទេស ដែលត្រូវការជ្រូកប្រមាណ ៨ ពាន់ក្បាល ក្នុង១ថ្ងៃ នៅខ្វះតិចតួចបំផុតដែលត្រូវនាំចូលពីក្រៅប្រទេស[34]។ ដូចនេះ កំណើននៃការចិញ្ចឹមសត្វនៅកម្ពុជា វាបានបង្កើននូវកាលានុវត្តភាពមួយដ៏ធំសម្រាប់សេដ្ឋកិច្ចកម្ពុជា ដែលពឹងផ្អែកច្រើនលើវិស័យកសិកម្ម។

### ៣.១.៥ ការវិវត្តផ្នែករុក្ខកម្ម

វិស័យព្រៃឈើ កំពុងតែត្រូវធានាឱ្យមាននិរន្តរភាព តាមរយៈកម្មវិធីកំណែទម្រង់ផ្នែកព្រៃឈើរបស់រាជរដ្ឋាភិបាល ដោយខិតខំបង្កើនសមត្ថភាពបច្ចេកទេស សំដៅជំរុញការងារគ្រប់គ្រងឱ្យមានប្រសិទ្ធភាពខ្ពស់ និងពិសេសយកចិត្តទុកដាក់ជាសំខាន់ លើការត្រួតពិនិត្យតាមដានដ៏តឹងរ៉ឹង លើការធ្វើអាជីវកម្មព្រៃឈើ សំដៅរក្សាការពារ និងនិរន្តរភាពព្រៃឈើ។ កម្មវិធីព្រៃឈើជាតិ កំពុងត្រូវបានអនុវត្តយ៉ាងពេញទំហឹង ដើម្បីឈានទៅសម្រេចបាន តាមគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ដែលបានកំណត់ថា ត្រូវថែរក្សាគម្របព្រៃឈើឱ្យបាន ៦០% នៃផ្ទៃដីសរុបនៅឆ្នាំ២០១៥។

តារាងទី ៣.៨៖ ស្ថិតិការព្យាករណ៍ ការដាំដើមឈើ បណ្តុះកូនឈើ និងសហគមន៍ព្រៃឈើ

| **បរិយាយ** | **២០១៤** | **២០១៥** | **២០១៦ (ប៉ាន់ស្មាន)** | **២០១៧ (ប៉ាន់ស្មាន)** |
|---|---|---|---|---|
| ការដាំដុះដើមឈើ (ហ.ត) | ៤,៦៩០ | ៣,៩៥៨ | ៣,២២៦ | ២,៤៩៤ |
| ការបណ្តុះកូនឈើ (ដើម) | ៤,៣៧៨,៥៩០ | ៤,៥៤៧,២៣៥ | ៤,៧១៥,៨៨០ | ៤,៨៨៤,៥២៥ |
| ចំនួនសហគមន៍ព្រៃឈើ | ៤៨៥ | ៥១៣ | ៥៤១ | ៥៦៩ |
| **បរិយាយ (ក្បាល)** | **២០១៨ (ប៉ាន់ស្មាន)** | **២០១៩ (ប៉ាន់ស្មាន)** | **២០២០ (ប៉ាន់ស្មាន)** | **២០២១ (ប៉ាន់ស្មាន)** |
| ការដាំដុះដើមឈើ (ហ.ត) | ១,៧៦២ | ១,០៣០ | ២៩៨ | -៤៣៤ |
| ការបណ្តុះកូនឈើ (ដើម) | ៥,០៥៣,១៧០ | ៥,២២១,៨១៥ | ៥,៣៩០,៤៦០ | ៥,៥៥៩,១០៥ |
| ចំនួនសហគមន៍ព្រៃឈើ | ៥៩៧ | ៦២៥ | ៦៥៣ | ៦៨១ |

[34] ហង្ស ទេព, *ការនាំចូលជ្រូកពីប្រទេសជិតខាងមិនអាចហាមឃាត់បានទេ* (ភ្នំពេញ៖ គេហទំព័រដើមអម្ពិល, ២០១៧), (ថតចម្លងថ្ងៃទី ២៤ ឧសភា ២០១៧)។

នៅក្នុងឆ្នាំ ២០១៥ ការដាំដុះដើមឈើមានចំនួន ៣,៩៥៨ហិកតា ដែលមាននិន្នានាការថយចុះជាលំដាប់ គួរឱ្យកត់សម្គាល់ផងដែរ ប្រសិនបើពុំមានគោលការណ៍ និងវិធានការ ក្នុងការបង្កើនផ្ទៃដីដាំដុះទេនោះ វានឹងធ្វើឱ្យធនធានគម្របព្រៃឈើថយចុះជាក់ជាពុំខានឡើយ។ ដោយឡែកសំទុះនៃការបណ្ដុះកូនឈើឃើញថាមានការកើនឡើងជាបន្តបន្ទាប់ ពី ៤,៥៤៧,២៣៥ ដើម នៅឆ្នាំ២០១៥ ហើយនឹងអាចកើនដល់ ៥,៥៥៩,១០៥ ដើម នៅឆ្នាំ២០២១។ ចំណែកឯ ចំនួនសហាគមន៍ព្រៃឈើក៏មានការកើងឡើងប្រមាណពី ៥១៣សហាគមន៍ នៅឆ្នាំ២០១៥ ហើយចំនួននេះអាចនឹងកើនដល់ ៦៨១សហាគមន៍ នៅឆ្នាំ២០២១ ខាងមុខ។ លទ្ធផលនេះ នឹងជួយដល់ការកាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋដែលប្រកបរបរចូលព្រៃ។ ទោះជាមិនបានមួយរយភាគរយក៏ដោយ ប៉ុន្តែពួកគាត់អាចរួមគ្នាបង្កើតជាសហាគមន៍ទេសចរណ៍ធម្មជាតិ ដើម្បីទាញយកផលប្រយោជន៍ ពីការកើនឡើងនូវចំនួនអ្នកទេសចរមកទស្សនា នៅតំបន់ដែលជាសហាគមន៍របស់គាត់។ ដែលការបង្កើតសហាគមន៍ព្រៃឈើនេះហើយ វាបានចូលរួមចំណែក ក្នុងការកាត់បន្ថយនូវបម្រែបម្រួលអាកាសធាតុ ដែលអាចធ្វើឱ្យមានភ្លៀងធ្លាក់ទៀងទាត់ ជួយដល់ការដាំដុះដំណាំរបស់ប្រជាកសិករបានមួយផ្នែកធំ។

# ជំពូកទី៤

# ការសិក្សាលើបញ្ហាប្រឈម

# និង ដំណោះស្រាយ

# ជំពូកទី៤

# ការសិក្សាលើបញ្ហាប្រឈម និងដំណោះស្រាយ

នៅក្នុងជំពូកទី៤ នេះ ខ្ញុំបានមានគោលបំណងពិភាក្សា ទៅលើបញ្ហាទិដ្ឋភាពសំខាន់ៗ ដែលយល់ថាមានការពាក់ព័ន្ធ ទៅនឹងកត្តាវិភាគក្នុងការសិក្សាស្រាវជ្រាវ ដែលបាននឹងកំពុងកើតមានឡើងក្នុងវិស័យកសិកម្ម ដើម្បីវែកញែកជុំវិញដំណើរវិវត្តន៍វិស័យកសិកម្ម សំដៅឈានឆ្ពោះទៅរកដំណោះស្រាយដ៏សមស្រប ទៅនឹងបញ្ហាប្រឈមនានាដែលកើតមានឡើងនៅក្នុងវិស័យកសិកម្ម។

## ៤.១ បញ្ហាប្រឈមនៅក្នុងវិស័យកសិកម្ម

### ៤.១.១ បញ្ហាប្រឈមចំពោះវិស័យកសិកម្មក្នុងឆ្នាំ ២០១២

ទន្ទឹមនឹងសមិទ្ធផលដែលទទួលបាននៅក្នុងឆ្នាំ ២០១២ មានភាពល្អប្រសើរ ក៏ប៉ុន្តែនៅមានបញ្ហាប្រឈមមួយចំនួនដែលកើតមានដូចជា៖

-ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅតាមកសិដ្ឋាន ស្ថានីយ៍ពិសោធន៍ និងមណ្ឌលអភិវឌ្ឍន៍កសិកម្មនូវមានការខ្វះខាត (ប្រព័ន្ធស្រោចស្រព អគារបណ្តុះបណ្តាល ផ្លូវថ្នល់...) ខ្វះឧបករណ៍ សម្ភារៈ និងមធ្យោបាយផលិតកម្ម នៅតាមកសិដ្ឋាន ស្ថានីយ៍ពិសោធន៍ និងមណ្ឌលអភិវឌ្ឍន៍កសិកម្ម។

-ការរក្សាពូជដំណាំបានជួបប្រទះបញ្ហាប្រឈម ដោយសារឃ្លាំងទុកដាក់ មិនបានស្រមស្របតាមបទដ្ឋានបច្ចេកទេស ដែលធ្វើឱ្យមានបញ្ហាប្រឈមនៅតាមមូលដ្ឋានខ្លះក្នុងពេលកន្លងមក។

-ថវិកាសម្រាប់ការងារស្រាវជ្រាវ និងអភិវឌ្ឍន៍វិស័យកសិកម្មនៅមានកម្រិត ពិសេសការងារអនុវត្តសកម្មភាពសម្រាប់គោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ។ ក្រៅពីនេះទៀត ខ្វះខាតថវិកា សម្ភារៈ និងមធ្យោបាយសម្រាប់ដំណើរការ វិស័យព្រៃឈើឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា។

-ខ្វះធនធាន (ធនធានមនុស្ស និងធនធានសម្ភារៈ) ទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ លើសពីនេះ មន្ត្រីរាជការមួយចំនួនខ្វះសមត្ថភាព មិនទាន់មានវិន័យ និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការបំពេញកាតព្វកិច្ចនៅឡើយ។ ជាមួយគ្នានេះ ខ្វះខាតធនធានមនុស្ស និងការលើកទឹកចិត្តដល់មន្ត្រីរដ្ឋបាលព្រៃឈើឱ្យទៅបម្រើការការនៅតំបន់ដាច់ស្រយាល។ ម្យ៉ាងវិញទៀត ចំណេះដឹង

កសិករ នៅមូលដ្ឋាននៅមានកម្រិត ធ្វើឱ្យមានការលំបាកក្នុងការបញ្ជ្រាបបច្ចេកទេសកសិកម្មថ្មី និងងាយរងគ្រោះពីការឆបោកពីឈ្មួញទុច្ចរិត។

-ខ្វះការវិនិយោគពីវិស័យឯកជនពាក់ព័ន្ធនឹងវិស័យកសិកម្ម។

-ចំណាកស្រុករបស់ប្រជាជន បាននឹងកំពុងក្លាយ ជាបញ្ហាចោទមួយសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម។ តាមការស្រាវជ្រាវបង្ហាញផងដែរថា ប្រជាជនមូលដ្ឋានដែលរស់នៅតំបន់ព្រៃឈើ នៅតែពឹងអាស្រ័យខ្លាំងលើ ព្រៃឈើ ហើយការគ្រប់គ្រងជនចំណាកស្រុក នៅមានការធូររលុងពីសំណាក់អាជ្ញាធរមូលដ្ឋាន ដែលជាសម្ពាធធ្ងន់ធ្ងរចំពោះធនធានព្រៃឈើ។

-ជនប្រព្រឹត្តបទល្មើសតែងតែផ្លាស់ប្តូរវិធីសាស្ត្រក្នុងការប្រមូលផលឈើ ដឹកជញ្ជូន និងកាប់រានដីព្រៃឈើយកមកធ្វើជាកម្មសិទ្ធិក្រោមរូបភាពផ្សេងៗ។

-កិច្ចសហការ និងការចូលរួមរបស់អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធនៅមានកម្រិតជាពិសេសក្នុងការត្រួតពិនិត្យបង្ក្រាបបទល្មើសព្រៃឈើ និងការកំណត់ព្រំប្រទល់ដែនដីព្រៃឈើតែងជួបប្រទះការលំបាក យឺតយ៉ាវ និងមានវិវាទ ជាមួយជនល្មើស ព្រមទាំងមានការលួចវាយបំផ្លាញបង្គោលព្រំដែលបានបោះរួចទៀតផង។

### ៤.១.២ បញ្ហាប្រឈមចំពោះវិស័យកសិកម្មក្នុងឆ្នាំ ២០១៣

បញ្ហាប្រឈមចំពោះមុខនៅក្នុងការអភិវឌ្ឍវិស័យកសិកម្មនៅឆ្នាំ ២០១៣ រួមមាន៖

-ការបង្កើនផលិតភាព និងពិពិធកម្មកសិកម្ម ពិសេសនៅក្នុងផលិតកម្មដំណាំស្រូវ និងដំណាំផ្សេងៗទៀត នៅជួបបញ្ហាប្រឈមមួយចំនួននៅឡើយ ទោះបីជាសកម្មភាពដ៏ច្រើនសន្ធឹកសន្ធាប់ត្រូវបានអនុវត្ត ដែលទាំងនេះទាមទារឱ្យមានការបង្កើនបន្ថែមទៀត នូវធនធាន ទាំងផ្នែកថវិកា និងបច្ចេកទេស ព្រមទាំងការចូលរួមពីគ្រប់ស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញ និងបង្កើនលទ្ធភាពទទួលបាននូវសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ឥណទាន បម្រើផលិតកម្មកសិកម្ម និងធាតុចូលកសិកម្ម។ ការដោះស្រាយទឹកស្រោចស្រពក្នុងការបង្កបង្កើនផល គឺជាបញ្ហាដែលត្រូវបន្តយកចិត្តទុកដាក់ ដែលទាមទារឱ្យមានការបង្កើនការវិនិយោគបន្ថែម ដើម្បីបង្កើនការស្រោចស្រពឱ្យបានសមស្របតាមតម្រូវការ។

-ពូជស្រូវ១០មុខ ដែលត្រូវបានជ្រើសរើសសម្រាប់ជំរុញ និងបង្កើនផលិតភាព នៅមិនទាន់ផ្សព្វផ្សាយចូលជ្រៅដល់ស្រទាប់កសិករនៅឡើយ ពិសេសទៀតនោះ បរិមាណពូជទាំង១០មុខនេះ មិនមានគ្រប់គ្រាន់សម្រាប់កសិករប្រើប្រាស់នៅឡើយ។ ដូច្នេះ ការរៀបចំសហគមន៍

កសិករផលិតពូជ នឹងត្រូវបង្កើនការយកចិត្តទុកដាក់បន្ថែមទៀត។ ទន្ទឹមនឹងនេះ ក៏ត្រូវយកចិត្តទុកដាក់អំពីការផលិតពូជផ្សេងៗទៀត ដែលមានសក្តានុពលសម្រាប់តម្រូវការទីផ្សារផងដែរ។

-ការធានាឱ្យមាននូវអត្ថប្រយោជន៍ កាន់តែប្រសើរជាងមុនសម្រាប់កសិករតាមរយៈ ការរកទីផ្សារលក់ផលិតផល គឺជាបញ្ហាដែលត្រូវបន្តអនុវត្តបន្ថែមទៀត ព្រោះថាកសិករនៅមានការលំបាកក្នុងការស្វែងរកទីផ្សារលក់ផលិតផល និងការលំបាកក្នុងការប្រកួតប្រជែង ទីផ្សារក្នុងបរិបទនៃសេដ្ឋកិច្ចទីផ្សារសេរី។ សេវាផ្តល់ពត៌មានទីផ្សារកសិកម្ម នឹងត្រូវពង្រឹងបន្ថែមសម្រាប់ជួយដល់កសិករ។

-ការយល់ដឹងរបស់កសិករក្នុងការប្រើប្រាស់ សម្ភារកសិកម្ម ឱ្យបានត្រឹមត្រូវតាមបច្ចេកទេស និងការគ្រប់គ្រងដីជាតិដី ក៏នៅតែជាបញ្ហាប្រឈមនៅឡើយ ដែលសកម្មភាពនានាពាក់ព័ន្ធនឹងបញ្ហានេះ នឹងត្រូវយកចិត្តទុកដាក់អនុវត្តបន្តឱ្យបានខ្លាំងក្លា។ ទន្ទឹមនឹងនោះ លិខិតបទដ្ឋានគតិយុត្ត និងសមត្ថភាពបច្ចេកទេស ក្នុងការអនុវត្តលើការគ្រប់គ្រងធនធានដី និងដីជាតិដីកសិកម្មនៅខ្វះខាត ដែលទាមទារឱ្យមានច្បាប់ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ដីកសិកម្មសម្រាប់អនុវត្តនាពេលខាងមុខ។

-ការកែលម្អការគ្រប់គ្រងក្រោយពេលប្រមូលផលហាក់នៅមានកម្រិតនៅឡើយ ការជំរុញផ្នែកកសិឧស្សាហកម្ម រួមទាំងការកែច្នៃក្រោយពេលប្រមូលផល ការកែលម្អគុណភាពស្របតាមស្តង់ដារកសិផល គឺត្រូវបានវាយតម្លៃថានៅមានកម្រិត។ សមត្ថភាពបច្ចេកទេសផ្នែកអនាម័យ និងភូតគាមអនាម័យ នឹងត្រូវបង្កើន និងពង្រឹងបន្ថែមទៀត។

-ការបង្កើតសហគមន៍កសិកម្មក្នុងគោលបំណងដើម្បីបង្កើនអំណាចតថ្លៃ ការទទួលបាននូវបច្ចេកទេស និងឥណទាន និងការប្រើប្រាស់ឱ្យអស់លទ្ធភាពនូវធនធានគឺត្រូវបានអនុវត្ត ប៉ុន្តែក៏អាចទទួលស្គាល់ថា នៅមិនទាន់គ្រប់គ្រាន់ ដែលត្រូវបន្តពង្រឹងឱ្យបានប្រសើរជាងនេះ។ សហគមន៍កសិករដាំកៅស៊ូ នៅមិនទាន់ត្រូវបានពង្រីកនៅឡើយ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ទៅលើកិច្ចការនេះ។

-ការលើកទឹកចិត្តឱ្យមានការចូលរួមរបស់ផ្នែកឯកជន ក្នុងការអភិវឌ្ឍវិស័យកសិកម្ម គឺជាកត្តាចាំបាច់ សំដៅបង្កើនការវិនិយោគក្នុងវិស័យនេះ។ កន្លងមក មានក្រុមហ៊ុនវិនិយោគជាច្រើនបានបណ្តាក់ទុនវិនិយោគលើផលិតកម្មដំណាំកសិ-ឧស្សាហកម្មតាមរូបភាពសម្បទានដីសេដ្ឋកិច្ច ហើយមានករណីមួយចំនួនដែលជាបញ្ហារាំងស្ទះដល់ការអនុវត្ត និងទាមទារដោះស្រាយ។ ប៉ុន្តែក៏មានករណីដែលវិនិយោគិនខ្លះ មិនបានអនុវត្តកិច្ចសន្យា ដោយទុកដីឱ្យនៅទំនេរមិនបានដាំដុះ

និងប្រឈមនឹងការដកហូតមកវិញ។ សកម្មភាពត្រួតពិនិត្យការអនុវត្តកិច្ចសន្យា នឹងត្រូវបង្កើនឱ្យបានខ្លាំងក្លានាពេលខាងមុខ។

-ដោយឡែក ការប្រឈមដែលជាតម្រូវការក្នុងការជួយទ្រទ្រង់ដល់វិស័យនេះ ឱ្យសម្រេចជោគជ័យ គឺការបង្កើនក្របខណ្ឌច្បាប់បន្ថែម រួមទាំងសមត្ថភាពអនុវត្តច្បាប់នៅគ្រប់កម្រិត ការអភិវឌ្ឍធនធានមនុស្ស ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការបង្កើតនិងអភិវឌ្ឍន៍សមត្ថភាពអង្គភាពជំនាញកសិកម្មថ្នាក់មូលដ្ឋាន ដែលមានសមត្ថភាពបម្រើសេវាកម្មបច្ចេកទេសដល់កសិករផ្ទាល់ និងការជំរុញកម្មវិធីផ្សព្វផ្សាយនៅក្នុងមូលដ្ឋាន។ មន្ត្រីជំនាញកសិកម្ម នេសាទ និងព្រៃឈើ នឹងទាមទារឱ្យត្រូវបង្កើនបន្ថែមទៀត សម្រាប់បម្រើការនៅថ្នាក់មូលដ្ឋាន។

-ផលិតកម្មសត្វនៅកម្ពុជា មានបម្រែបម្រួលកំណើនយឺត ដោយមានការលំបាកកន្លងមក និងការប្រឈមដូចជា ជំងឺឆ្លងរាតត្បាត និងកង្វះមធ្យោបាយគ្រប់គ្រាន់ លើការការពារ និងកម្ចាត់ ការប្រកួតប្រជែងនៃទីផ្សារសាច់សត្វ ដោយសារថ្លៃដើមផលិតកម្មខ្ពស់ ពិសេសថ្លៃចំណីសត្វ និងថ្នាំព្យាបាលសត្វជាដើម។

-ព្រៃលិចទឹក ត្រូវបានប្រឈមនឹងការកាប់បំផ្លាញ ដែលត្រូវតែមានវិធានការជាបន្តទៀតដោយម៉ឺងម៉ាត់។ ធនធានមនុស្សនិងថវិកាក្នុងការចាត់វិធានការបង្ក្រាបបទល្មើសនេសាទ ការពារកន្លែងអភិរក្ស ទាំងទឹកសាប និងសមុទ្រ នៅមានការខ្វះខាត។ ការបោះបង្គោលព្រំប្រទល់ព្រៃលិចទឹក និងការលុបបំបាត់ បទល្មើសជលផល នៅមានកម្រិតនៅឡើយ។ សមត្ថភាពរបស់គណៈកម្មការសហគមន៍នេសាទ ក៏នៅមានកម្រិតដែរ ដោយសហគមន៍ភាគច្រើនពុំមានការជួយឧបត្ថម្ភគាំទ្រគ្រប់គ្រាន់។ ការកំណត់ព្រំប្រទល់ដែននេសាទ និងការបោះបង្គោលព្រំតែងជួបប្រទះការលំបាក។ ការព្រួយបារម្ភមួយទៀត គឺការសាងសង់ទំនប់វារីអគ្គិសនីនៅដងទន្លេមេគង្គខាងលើដែលអាចប៉ះពាល់ដល់ធនធានជលផល។

-នៅក្នុងផ្នែកព្រៃឈើ ការធ្វើឱ្យសម្រេចបាននូវការពង្រីកគម្របព្រៃឈើ ៦០% នៅឆ្នាំ ២០១៥ គឺជាភារកិច្ចមួយដ៏ធំធេង និងត្រូវមានការយកចិត្តទុកដាក់ខ្ពស់។ ការធ្លាក់ចុះនូវផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើក្នុងដំណាក់កាលចុងក្រោយនេះ គឺបណ្តាលមកពីកំណើននៃការប្រើប្រាស់ដីកសិកម្ម ស្របទៅនឹងកំណើនប្រជាពលរដ្ឋ និងការរីកលូតលាស់ផ្នែកសេដ្ឋកិច្ចកសិកម្ម។ កិច្ចសហការ និងការចូលរួមរបស់អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធនៅមានកម្រិត ជាពិសេសក្នុងការទប់ស្កាត់ការកាប់រានទន្ទ្រានយកដីព្រៃឈើ និងការកំណត់ព្រំប្រទល់ដែនព្រៃឈើ ដែលតែងជួបប្រទះការលំបាក និងមានវិវាទ ព្រមទាំងមានការលួចវាយបំផ្លាញបង្គោលព្រំដែលបាន

បោះរួច។ ប្រជាជនមូលដ្ឋានដែលរស់នៅក្នុងនិងក្បែរតំបន់ព្រៃឈើ នៅតែពឹងអាស្រ័យខ្លាំងលើព្រៃឈើ ហើយការគ្រប់គ្រងជនចំណាកស្រុក នៅមានភាពធូររលុង ដែលជាសម្ពាធធ្ងន់ធ្ងរចំពោះធនធានព្រៃឈើ។

### ៤.១.៣ បញ្ហាប្រឈមចំពោះវិស័យកសិកម្មក្នុងឆ្នាំ ២០១៤

- **បញ្ហាប្រឈមក្នុងផលិតកម្មដំណាំកសិកម្ម៖**

-កង្វះធនធានមនុស្ស អ្នកភ្នាក់ងារបច្ចេកទេស អ្នកបច្ចេកទេសមធ្យមនៅមូលដ្ឋានថ្នាក់ក្រោម ដើម្បីអប់រំផ្សព្វផ្សាយបច្ចេកទេសឱ្យដល់កសិករ។

-ភាពងាយរងគ្រោះនៃប្រព័ន្ធដាំដុះ ដោយសារកត្តាប្រែប្រួលអាកាសធាតុ និងកង្វះខាតប្រព័ន្ធស្រោចស្រព គឺជាបញ្ហាមួយដែលបានជួបប្រទះជារៀងរាល់ឆ្នាំ បន្ថែមលើនេះ កង្វះខាតធនធានសម្រាប់ការងារស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកទេសទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គឺជាបញ្ហាមួយដែលត្រូវពិនិត្យពិចារណាបន្ថែម ឱ្យស្របតាមទំហំការងារដែលចេះតែកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ ការស្រាវជ្រាវ អភិវឌ្ឍន៍ ផលិត និងផ្សព្វផ្សាយពូជដំណាំដែលមានគុណភាពនៅមានកម្រិត។

-សមត្ថភាពសហគមន៍កសិកម្ម ដែលជាតួអង្គសេដ្ឋកិច្ចជនបទ នៅមានកម្រិតនៅឡើយ ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ខ្ពស់នាពេលខាងមុខ។ ម្យ៉ាងទៀត លទ្ធភាពទទួលបានសេវាផ្សព្វផ្សាយកសិកម្មក៏នៅមានកម្រិតដែរ។ សមត្ថភាពស្រូវយកចំណេះដឹងបច្ចេកទេសដាំដុះ និងការប្រើប្រាស់ធាតុចូលកសិកម្ម ឱ្យបានត្រឹមត្រូវតាមបទដ្ឋាន បច្ចេកទេស ក៏ដូចជាក្នុងការកែច្នៃផលិតផលក្នុងចំណោមប្រជាកសិករនៅមានកម្រិត។ សមត្ថភាពសហគមន៍កសិកម្ម ដែលប្រមូលផ្តុំគ្រួសារកសិករ អ្នកផលិតករ ត្រូវយកចិត្តទុកដាក់ការវិនិយោគលើកទឹកចិត្ត ដើម្បីពង្រឹងសមត្ថភាព និងលទ្ធភាពផលិតកម្ម កែច្នៃ និងលក់ដូរ។

-ការចូលរួមវិនិយោគ ក្នុងវិស័យកសិកម្មរបស់ផ្នែកឯកជន ក្នុងការអភិវឌ្ឍផលិតកម្មដំណាំកសិកម្មនៅមានទំហំតូច បើប្រៀបធៀបនឹងវិស័យពីរផ្សេងទៀត ជាពិសេសការវិនិយោគជាលក្ខណៈសហគ្រាសខ្នាតមធ្យម និងធំក្នុងការកែច្នៃផលិតផលកសិកម្ម ដើម្បីបង្កើនតម្លៃបន្ថែមនៅមានកម្រិតទាបនៅឡើយ។

-ចំពោះផលិតកម្មដំណាំកៅស៊ូ បញ្ហាកំពុងគំរាមកំហែងការអភិវឌ្ឍដំណាំនេះ។

➢ **បញ្ហាប្រឈមក្នុងផលិតកម្មសត្វ៖**

-ផលិតកម្មសត្វ មិនសូវមានការរីកចម្រើនខ្លាំងក្លានៅឡើយ ផលិតកម្មគោក្របីមានការថយចុះ ដោយសារកំណើនគ្រឿងយន្តកសិកម្ម ការថយចុះវាលស្មៅចិញ្ចឹមសត្វ ការបម្រែបម្រួលអាកាសធាតុ ខ្វះប្រភពទឹក ខ្វះកម្លាំងពលកម្ម ចំណាកស្រុក កំណើននៃការនាំចេញ និងកំណើននៃតម្រូវការសាច់ក្នុងស្រុក។

-អត្រាឈឺ ស្លាប់សត្វ និងជំងឺឆ្លងសត្វនៅតែជាការគំរាមកំហែងដល់ផលិតកម្មសត្វ ធ្វើឱ្យផលិតភាពសត្វថយចុះ ខ្វះខាតថ្នាំការពារ ព្យាបាលសត្វ និងឧបករណ៍សម្ភារបរិក្ខាបសុពេទ្យ។

-នៅមានបទល្មើសដឹកជញ្ជូនសត្វ និងផលិតផលសត្វ ការគ្រប់គ្រងសត្តឃាតដ្ឋាន និងការត្រួតពិនិត្យអនាម័យសត្វនៅអនុវត្តមិនទាន់មានប្រសិទ្ធភាពនៅឡើយ។

-ការស្រាវជ្រាវផលិតកម្ម និងបសុព្យាបាល ការផ្សព្វផ្សាយបច្ចេទេសផលិតកម្មបសុព្យាបាលអនុវត្តនៅមានកម្រិតអាស្រ័យដោយធនធាន និងមធ្យោបាយមានកម្រិត។

➢ **បញ្ហាប្រឈមក្នុងផ្នែកជលផល៖**

-បទល្មើសនេសាទនៅតែកើតមាន និងការទន្ទ្រានយកដីក្នុងដែននេសាទ ធ្វើជាកម្មសិទ្ធឯកជន នៅតែមានសកម្មភាព។

-ការយល់ដឹងរបស់ប្រជានេសាទពីសារៈប្រយោជន៍នៃធនធានជលផលនៅមានកម្រិត។

-ការអនុវត្តច្បាប់នៅមានកម្រិត និងកិច្ចសហការពីអាជ្ញាធរពាក់ព័ន្ធ មួយចំនួននៅមានកម្រិត

-សហគមន៍នេសាទពុំមានធនធានគ្រប់គ្រាន់ សម្រាប់អនុវត្តផែនការសកម្មភាពរបស់ខ្លួន និងសមត្ថភាពរបស់សមាជិកសហគមន៍នេសាទនៅមានកម្រិត។

➢ **បញ្ហាប្រឈមក្នុងផ្នែកព្រៃឈើ៖**

-ការយល់ដឹងពីសារៈសំខាន់ធនធានព្រៃឈើ ក្នុងចំណោមប្រជាជនមូលដ្ឋានពឹងអាស្រ័យអនុផលព្រៃឈើនៅមានកម្រិតទាបនៅឡើយ ដែលទាមទារឱ្យមានការពន្យល់ផ្សព្វផ្សាយបន្ថែមទៀត។

-ការងារបង្ក្រាបបទល្មើស និងការកាប់រានដីព្រៃយកដីធ្វើជាកម្មសិទ្ធល្មើសច្បាប់ មានការលំបាក ពីព្រោះជនប្រព្រឹត្តបទល្មើស តែងតែផ្លាស់ប្តូរវិធីសាស្ត្រក្នុងការដឹកជញ្ជូន និងបំផ្លាញព្រៃឈើក្រោមរូបភាពផ្សេងៗ។

-កង្វះខាតកិច្ចសហប្រតិបត្តិការ និងការចូលរួមពេញលេញពីអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ។

-ការតាំងទីលំនៅរបស់ជនចំណាកស្រុក ក្នុងតំបន់ព្រៃការពារ និងតំបន់អភិរក្សសត្វព្រៃ។

-ថវិកាដៃគូអភិវឌ្ឍន៍ចូលរួមបោះបង្គោលព្រំនៅមានកម្រិត។

-សហគមន៍ព្រៃឈើ ដែលមានទីតាំងក្នុងព្រៃសម្បទាន ឬសម្បទានដីសេដ្ឋកិច្ច ពុំមានប្រកាសទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឡើយ ប្រសិនបើគ្មានការឯកភាពពីសម្បទានិក។

-ថវិការដ្ឋដែលគាំទ្រដល់ដំណើរការអនុវត្ត សហគមន៍ព្រៃឈើមានចំនួនតិចតួច ស្របពេលការគាំទ្រថវិកាពីដៃគូអភិវឌ្ឍន៍មានការថយចុះ។

-អង្គការសង្គមស៊ីវិលរៀបចំសហគមន៍ព្រៃឈើ ពុំមានកិច្ចសហការពីមន្ត្រីខណ្ឌរដ្ឋបាលព្រៃឈើ ក្នុងការកំណត់ទីតាំងត្រូវបង្កើត។

-ដំណើរការនៃការរៀបចំបង្កើត ព្រៃការពារមានភាពស្មុគ្រស្មាញ និងត្រូវការពេលវេលាយូរ។

### ៤.១.៤ បញ្ហាប្រឈមចំពោះវិស័យកសិកម្មក្នុងឆ្នាំ ២០១៥

ក្នុងឆ្នាំ ២០១៥ បញ្ហាប្រឈមក្នុងផលិតកម្មដំណាំកសិកម្ម ត្រូវបានកត់សម្គាល់ឃើញថាភាពងាយរងគ្រោះនៃប្រព័ន្ធដាំដុះ ដោយសារកត្តាប្រែប្រួលអាកាសធាតុ និងកង្វះខាតប្រព័ន្ធស្រោចស្រព គឺជាបញ្ហាមួយដែលបានជួបប្រទះជារៀងរាល់ឆ្នាំ។ បន្ថែមលើនេះ កង្វះខាតធនធានសម្រាប់ការងារស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកទេសទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គឺជាបញ្ហាមួយទៀតដែលត្រូវពិនិត្យពិចារណាបន្ថែម ឱ្យស្របតាមទំហំការងារដែលចេះតែកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ ការស្រាវជ្រាវ អភិវឌ្ឍន៍ ការផលិត និងផ្សព្វផ្សាយពូជដំណាំដែលមានគុណភាពខ្ពស់នៅមានកម្រិត។ ម៉្យាងវិញទៀត សមត្ថភាពសហគមន៍កសិកម្ម ដែលជាតួអង្គសេដ្ឋកិច្ចជនបទដ៏សំខាន់ ក៏នៅមានកម្រិតនៅឡើយ តម្រូវឱ្យមានការយកចិត្តទុកដាក់ខ្ពស់នាពេលខាងមុខ។ លើសពីនេះ លទ្ធភាពទទួលបានសេវាផ្សព្វផ្សាយកសិកម្ម ក៏នៅមានកម្រិតផងដែរ។ សមត្ថភាពស្រូបយកចំណេះដឹងបច្ចេកទេសដាំដុះ និងការប្រើប្រាស់ធាតុចូលកសិកម្មឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ក៏ដូចជាក្នុងការកែច្នៃផលិតផល ក្នុងចំណោមប្រជាកសិករនៅមានកម្រិត។ ការចូលរួមវិនិយោគ ក្នុងវិស័យកសិកម្មរបស់ផ្នែកឯកជន ក្នុងការអភិវឌ្ឍផលិតកម្មកសិកម្មនៅមានទំហំតូច បើប្រៀបធៀបនឹងវិស័យពីរផ្សេងទៀត ជាពិសេសការ

វិនិយោគជាលក្ខណៈសហគ្រាសខ្នាតមធ្យម និងធំក្នុងការកែច្នៃផលិតកម្មកសិកម្ម ដើម្បីបង្កើនតម្លៃបន្ថែមនៅមានកម្រិតទាប។ ចំពោះផលិតកម្មកៅស៊ូបញ្ហាកំពុងគំរាមកំហែងដល់ការអភិវឌ្ឍដំណាំនេះ គឺបញ្ហាថ្លៃធ្លាក់ចុះ ដែលបណ្តាលមកពីកត្តាទីផ្សារខាងក្រៅជះឥទ្ធិពលជាអវិជ្ជមានដល់ផលិតករកៅស៊ូ។ កង្វះធនធានមនុស្ស អ្នកបច្ចេកទេសនៅថ្នាក់មូលដ្ឋាន ពិសេសថ្នាក់ស្រុក ដើម្បីអប់រំផ្សព្វផ្សាយបច្ចេកទេសឱ្យដល់កសិករកំពុងជួបបញ្ហាប្រឈម និងទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់បំផុត។

ផលិតកម្មសត្វមិនសូវមានការរីកចម្រើនខ្លាំងក្លានៅឡើយ ពិសេសផលិតកម្មគោក្របីមានការថយចុះ ដោយសារកង្វះកម្លាំងពលកម្មនៅជនបទ ចំណាកស្រុក ជាហេតុធ្វើឱ្យកសិករភាគច្រើនប្រើប្រាស់សេវាគ្រឿងយន្តកសិកម្ម ការថយចុះវាលស្មៅចិញ្ចឹមសត្វ ការបម្រែបម្រួលអាកាសធាតុ ខ្វះប្រភពទឹក។ ជាការកត់សម្គាល់ អត្រាឈឺ ស្លាប់សត្វ និងជំងឺឆ្លងសត្វនៅតែជាការគំរាមកំហែងដល់ផលិតកម្មសត្វធ្វើឱ្យផលិតភាពសត្វថយចុះ ហើយកង្វះខាតថ្នាំការពារ ព្យាបាលសត្វ និងឧបករណ៍សម្ភារបរិក្ខាបសុពេទ្យនៅតែត្រូវបានជួបប្រទះ។ លើសពីនេះ បទល្មើសដឹកជញ្ជូនសត្វ និងផលិតផលសត្វ ការគ្រប់គ្រងសត្តឃាតដ្ឋាន និងការត្រួតពិនិត្យអនាម័យសត្វនៅអនុវត្តមិនទាន់មានប្រសិទ្ធភាពនៅឡើយ។ ការស្រាវជ្រាវផលិតកម្ម និងបសុព្យាបាល ការផ្សព្វផ្សាយបច្ចេកទេសផលិតកម្មបសុព្យាបាល អនុវត្តនៅមានកម្រិតអាស្រ័យដោយធនធាន និងមធ្យោបាយមានកម្រិត។

បទល្មើសនេសាទនៅតែកើតមាន និងការទន្ទ្រានយកដីក្នុងដែនព្រៃលិចទឹកធ្វើជាកម្មសិទ្ធិឯកជននៅតែមានសកម្មភាព។ ការយល់ដឹងរបស់ប្រជានេសាទ ពីសារៈប្រយោជន៍នៃធនធានជលផលនៅមានកម្រិត ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់។ ការអនុវត្តច្បាប់នៅមានកម្រិត និងកិច្ចសហការពីអាជ្ញាធរ ពាក់ព័ន្ធមួយចំនួននៅមិនទាន់ស៊ីជម្រៅ។ សហគមន៍នេសាទពុំមានធនធានគ្រប់គ្រាន់ សម្រាប់អនុវត្តផែនការសកម្មភាពរបស់ខ្លួន និងសមត្ថភាពរបស់សមាជិកសហគមន៍នេសាទនៅមានកម្រិត។

ការយល់ដឹងពីសារៈសំខាន់ព្រៃឈើ ក្នុងចំណោមប្រជាជនមូលដ្ឋាន ពឹងអាស្រ័យអនុផលព្រៃឈើនៅមានកម្រិតទាបនៅឡើយ ដែលទាមទារឱ្យមានការពន្យល់ផ្សព្វផ្សាយបន្ថែមទៀត។ ការងារបង្ក្រាបបទល្មើស និងការកាប់រានដីព្រៃយកដីធ្វើជាកម្មសិទ្ធិល្មើសច្បាប់មានការលំបាក។ ការតាំងទីលំនៅរបស់ជនចំណាកស្រុក ក្នុងតំបន់ព្រៃការពារ និងតំបន់អភិរក្សសត្វព្រៃត្រូវបានពិនិត្យឃើញមានការកើនឡើង។ ថវិកាដៃគូអភិវឌ្ឍន៍ ចូលរួមក្នុងការបោះបង្គោលព្រំនៅមាន

កម្រិត។ សហាគមន៍ព្រៃឈើមួយចំនួនដែលមានទីតាំងក្នុងព្រៃសម្បទាន ឬសម្បទានដីសេដ្ឋកិច្ច ពុំទាន់មានប្រកាសទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅឡើយ។ ថវិការដ្ឋ ដែលគាំទ្រដល់ដំណើរការអនុវត្តសហាគមន៍ព្រៃឈើ មានចំនួនតិចតួច ស្របពេលការគាំទ្រថវិកា ពីដៃគូអភិវឌ្ឍន៍មានការថយចុះ និងដំណើរការនៃការរៀបចំបង្កើត ព្រៃការពារមានភាពស្មុគ្រស្មាញ និងត្រូវការពេលវេលាយូរ។

**៤.១.៥ ការចែកចាយកម្មសិទ្ធិដីធ្លីដោយគ្មានប្រសិទ្ធភាព និងសមធម៌**

កម្ពុជាមានអត្រាអវិសមភាពដីធ្លី ស្ថិតក្នុងចំណោមអត្រាខ្ពស់ៗ ជាងគេក្នុងតំបន់ហើយ កសិករជាច្រើនត្រូវរងគ្រោះ ដោយសារអសន្តិសុខក្នុងការកាន់កាប់ដី។ មានឯកសារជាច្រើន បញ្ជាក់ថា ការបែងចែកដីធ្លីដោយស្មើភាព និងកម្មសិទ្ធិដីធ្លីរឹងមាំ គឺជាគ្រឹះដ៏រឹងមាំនៃកំណើន សម្រាប់គ្រប់គ្នា។ ដូច្នេះ បញ្ហាជុំវិញសិទ្ធិកាន់កាប់ដីធ្លីនៅកម្ពុជា គឺជាឧបសគ្គដ៏ធំបំផុតដែលរារាំង កំណើនផលិតកម្មស្រូវ និងជាកត្តាចម្បងដែលនាំឱ្យមានភាពក្រីក្រ។

ក្នុងកសិកម្មប្រើពលកម្មច្រើន គេឃើញមានទំនាក់ទំនងបញ្ច្រាសរវាងទំហំដី និងផលិតភាពពីព្រោះកសិដ្ឋានតូចៗ អាចប្រើប្រាស់កម្លាំងពលកម្មបានល្អជាង ដូច្នេះហើយគេក៏ទទួលបាន ទិន្នផលស្រូវខ្ពស់ជាងកសិដ្ឋានធំៗ។ ទំនាក់ទំនងបញ្ច្រាសនេះ ពិតជាត្រឹមត្រូវសម្រាប់ប្រទេស កម្ពុជា។ ប៉ុន្តែនៅតាមតំបន់ដែលមានអវិសមភាពដីធ្លីខ្ពស់ ឧត្តមភាពផ្នែកទិន្នផលនេះ ពុំធ្វើឱ្យ គ្រួសារម្ចាស់ដីតូចៗ មានអតិរេកស្រូវអង្ករនោះទេ ព្រោះទំហំដីតូចវាមិនគ្រប់គ្រាន់ សម្រាប់ដោះស្រាយតម្រូវការចិញ្ចឹមពោះរបស់គ្រួសារកសិករផង កុំថាឡើយដល់ទៅសល់ស្រូវសម្រាប់លក់ដូរ។

នាបច្ចុប្បន្ន ៥៥% នៃគ្រួសារនៅជនបទជួបកង្វះដីធ្លី ពោលគឺ ១៥% គ្មានដីសោះ និង ៤០%មានដីតិចជាង១ហិកតា។ ការបែងចែកប្រសើរបំផុតនូវដីកសិកម្ម វានាំឱ្យមានការប្រើប្រាស់ កម្លាំងល្អបំផុតនៅក្នុងសេដ្ឋកិច្ចនៃជនបទកម្ពុជា ហើយគេអាចសម្គាល់បានតាមលក្ខណៈគ្រួសារនានាមានដីធ្លីគ្រប់គ្រាន់ សម្រាប់ប្រើប្រាស់កម្លាំងពលកម្មរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

**៤.១.៦ បញ្ហាប្រឈមជារួមដែលរាំងស្ទះដល់កំណើនវិស័យកសិកម្ម**

ការលំបាកតែងតែកើតមានឡើងនៅក្នុងផលិតកម្មកសិកម្ម ប៉ុន្តែការលំបាកនោះមានភាព ខុសប្លែកគ្នាទៅតាមប្រភេទនៃសកម្មភាព ដែលរួមមាន ស្រូវ ដំណាំផ្សេងៗ ផលិតកម្មចិញ្ចឹមសត្វ កត្តាដទៃផ្សេងៗទៀត។ ដូចនេះ ការវិភាគទៅលើបញ្ហាលំបាកនៃផ្នែករូបសាស្ត្រ គឺចាំបាច់ណាស់ ដើម្បីរៀបចំនូវយុទ្ធសាស្ត្រដែលល្អត្រឹមត្រូវមួយ។ បញ្ហាទាំងនេះរួមមាន របាយទឹកភ្លៀង ទឹកជំនន់

ភាពរាំងស្ងួត ដីជាតិដី កត្តាសត្វល្អិតចង្រៃ និងជំងឺដែលបង្កផលវិបាកយ៉ាងធ្ងន់ធ្ងរ ដល់ផលិតកម្មកសិកម្មរបស់ប្រទេសកម្ពុជា។ ការកែលម្អបញ្ហានេះ ទាមទារចាំបាច់នូវបច្ចេកទេសគ្រប់គ្រាន់ (ការស្រោចស្រព ការប្រើប្រាស់ជីគីមី និងថ្នាំពុល) ដើម្បីបង្កើនផលិតកម្មកសិកម្មនាពេលអនាគត។

- **បញ្ហាប្រឈមចំពោះផលិតកម្មដំណាំស្រូវៈ**

ចំពោះផលិតកម្មដំណាំស្រូវ ក្រៅពីបញ្ហាប្រព័ន្ធធារាសាស្ត្រ របាយទឹកភ្លៀងមិនទៀងទាត់ កង្វះខាតបច្ចេកទេស កង្វះខាតកម្លាំងពលកម្ម និងការជ្រើសរើសពូជមិនត្រឹមត្រូវ នៅមានបញ្ហាមួយចំនួនទៀតដូចជាៈ ១-បញ្ហាដីគ្មានជីជាតិៈ ដីភាគច្រើននៅប្រទេសកម្ពុជាយើងជាប្រភេទដីខ្សោះជីជាតិ ដែលបណ្តាលមកពីការដាំដំណាំដដែលៗរាប់សតវត្សមកហើយក៏គ្មានការបំពេញបន្ថែមឱ្យបានគ្រប់គ្រាន់នូវជីវជាតិដែលបានបាត់បង់នោះដែរ។ ហើយដីភាគច្រើនខ្វះជាតិអាសូត និងជាតិផូស្វ័រ ហើយនៅកន្លែងខ្លះទៀតខ្វះជាតិប៉ូតាស្យូម ចំពោះបញ្ហាដទៃទៀតមានដូចជា ដីដែលមានទម្រង់រូសាស្ត្រ និងជាតិគីមីខ្សោយរួមមាន ដីដែលមានជាតិអាស៊ីត សមត្ថភាពបម្លាស់ប្តូរនៃដីចុះខ្សោយបរិមាណសរីរាង្គចុះទាប ដីពុលជាតិដែក និងមានជាតិប្រៃ។ ២-បញ្ហារុក្ខជាតិសត្វល្អិតចង្រៃៈ បញ្ហាស្មៅ និងរុក្ខជាតិតូចៗដែលដុះតាមវាលស្រែ ធ្វើឱ្យស្រូវមិនអាចលូតលាស់បានល្អ។ កសិករប្រមាណជា ៨៥% នៅតាមតំបន់ខ្ពង់រាបបានបញ្ជាក់ថា ស្មៅគឺជាបញ្ហាចម្បងបំផុត ព្រោះថាភាគច្រើនគ្រាប់ស្មៅតែងតែដុះមុនគ្រាប់ពូជស្រូវចម្ការទៅទៀត។ លើសពីនេះទៀតកត្តាសត្វល្អិតមានដូចជា ដង្កូវស៊ីរូងដើម ដង្កូវបំពង់កាត់ស្លឹក មមាចខៀវ មមាចត្នោត ទ្រីប កណ្តូប និងដង្កូវមូរស្លឹកជាដើម។ ក្រៅពីនេះ ប្រភេទសត្វមួយចំនួនទៀតដូចជា សត្វក្តាមតែងតែកាត់សំណាបដែលធ្វើឱ្យដំណាំស្រូវទទួលរងនូវការខូចខាត ប្រភេទសត្វស្លាបដូចជា សត្វជ្រឹងជញ្ជក់ទឹកដោះ ដែលតែងតែចឹកស្រូវ ដែលនាំឱ្យគុណភាពស្រូវថយចុះ និងសត្វកណ្តុរ នៅវគ្គលូតលាស់ ដែលជាសត្វបំផ្លាញដំណាំស្រូវ ដែលធ្វើឱ្យដំណាំស្រូវដុះលូតលាស់មិនស្មើគ្នា ដូចជាបែកគុម្ព ឬបែកខ្នែងយឺត ដែលធ្វើឱ្យស្រូវទុំមិនស្មើគ្នា។ ៣-បញ្ហាជំងឺៈ ជំងឺក៏ជាកត្តាចម្បងមួយដែលបង្កការរាតត្បាតដល់ដំណាំស្រូវ និងបង្កផលប៉ះពាល់ដល់គុណភាពគ្រាប់ស្រូវអង្ករ។ ជំងឺប្លាស (Rice Blast) បានបង្កការរាតត្បាតដល់ ដើម ស្លឹក និងកួរស្រូវដែលធ្វើឱ្យដំណាំស្រូវថយទិន្នផល និងគុណភាពថយចុះ។ ជំងឺធ្យូងគ្រាប់ (Kernel smut) ជំងឺដុះផ្សិតគ្រាប់ (False smut) បានធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់គុណភាពនៃដំណាំស្រូវ បើមានការរាតត្បាតខ្លាំង។

- **បញ្ហាប្រឈមចំពោះផលិតកម្មដំណាំរួមផ្សំ និងឧស្សាហាកម្មះ**

ផលិតកម្មដំណាំពោត ក៏បានជួបនូវបញ្ហាប្រឈមដូចជាៈ បញ្ហាអាកាសធាតុ បញ្ហាសត្វល្អិត និងការធ្លាក់ចុះតម្លៃពោតលើទីផ្សារ។ បើកាលណាមេឃភ្លៀងខ្លាំងជ្រុល វាអាចធ្វើឱ្យពោតដែលកំពុងលូតលាស់រលួយគល់ និងទឹកសន្សើមប្រៃ អាចធ្វើឱ្យដើមមានការប្រែប្រួល។ រីឯ បញ្ហាសត្វល្អិតមានដូចជាសត្វដង្កូវ សត្វកណ្តុរ ដែលពួកវាតែងមកយាយីផលដំណាំគ្រប់ប្រភេទមិនថាតែដំណាំពោតនោះឡើយ។ ចំណែកឯ បញ្ហាធ្លាក់ចុះតម្លៃពោតលើទីផ្សារៈ នៅពេលដែលពោតផ្តល់ទិន្នផលបានល្អគ្រប់ចម្ការ វាក៏អាចជាការជះឥទ្ធិពលដល់តម្លៃពោតលើទីផ្សារផងដែរ គឺមានតម្លៃថោកជាងការរំពឹងទុករបស់យើង និងនៅពេលដែលបានផលគឺគ្មានឈ្មួញចុះមកទិញ។

ផលិតកម្មដំណាំដំឡូងមី ក្រៅពីកង្វះខាតនូវប្រព័ន្ធធារាសាស្ត្រ កង្វះខាតបច្ចេកទេស កង្វះខាតកម្លាំងពលកម្ម នៅមានបញ្ហាមួយចំនួនដូចជាៈ បញ្ហាអាកាសធាតុ បញ្ហាសត្វល្អិតចង្រៃ និងការធ្លាក់ចុះតម្លៃដំឡូងមីលើទីផ្សារ។ បញ្ហាអាកាសធាតុ សំខាន់ណាស់ ព្រោះថាវាអាចធ្វើឱ្យបរិមាណផលដែលទទួលបានប្រែប្រួល និងធ្លាក់ចុះនូវគុណភាពដំឡូងមី។ ការជ្រើសរើសពូជ មិនមានភាពធន់ទៅនឹងការបំផ្លាញពីពពួកសត្វល្អិត និងជំងឺគ្រប់ប្រភេទ។

ផលិតកម្មដំណាំ សណ្តែកបាយ សណ្តែកសៀង ល្ង និងដំណាំផ្សេងៗទៀត ជួបនូវបញ្ហាដែលប៉ះពាល់ដល់កំណើនផលិតកម្មមានដូចជាៈ ១-ការបំផ្លាញនៃសត្វល្អិត និងជំងឺឆ្លងះ ដំណាំដែលដាំដុះលើផ្ទៃដីកម្ពុជា កំពុងតែជួបប្រទះនឹងបញ្ហាសត្វល្អិតចង្រៃដូចជាៈ ដង្កូវ ចៃ កណ្តូបជាដើមដែលធ្វើឱ្យគ្រប់ផ្នែកនៃដំណាំត្រូវបានបំផ្លាញ។ ម៉្យាងវិញទៀត តំបន់ដីខ្លះសម្បូរដោយជំងឺរុក្ខជាតិដូចជាៈ Mosaic disease, Root rot, Brown steak diseases ជាដើម ដែលបានរាលដាលពីរុក្ខជាតិមួយទៅរុក្ខជាតិមួយទៀត។ ដែលបញ្ហាទាំងពីរខាងលើ បានជះឥទ្ធិពលអវិជ្ជមានលើទិន្នផលរបស់ប្រជាកសិករ។ ២-បញ្ហាចំណេះដឹង និងជីវភាពប្រជាកសិករនៅមានកម្រិតះ ប្រជាពលរដ្ឋដែលរស់នៅតាមជនបទប្រមាណ ៨០% ដែលមិនទទួលបានការអប់រំខ្ពស់ពោលគឺកម្រិតនៃការយល់ដឹងគឺនៅទាប ទាំងផ្នែកចំណេះដឹងទូទៅ ក៏ដូចជាចំណេះដឹងផ្នែកកសិកម្ម ហើយភាគច្រើនដាំដុះតាមទម្លាប់ពីដូនតា និងពឹងផ្អែកលើទឹកភ្លៀង។ ពួកគាត់ពុំទាន់មានបច្ចេកទេស និងលទ្ធភាពគ្រប់គ្រាន់ក្នុងការទិញឧបករណ៍បច្ចេកទេស ក៏ដូចជាការរៀបចំបង្កើតប្រព័ន្ធស្រោចស្រពត្រៀមបម្រុងនោះទេ។ កាលណាមានបម្រែបម្រួលអាកាសធាតុកើតឡើង ជាពិសេសគ្រោះរាំងស្ងួត ពួកគាត់នឹងគ្មានទឹកសម្រាប់ធ្វើការបង្កបង្កើនផលនោះឡើយ។ ៣-បញ្ហាកង្វះខាតការវិនិយោគពីវិស័យឯកជនះ ផ្ទៃដីដាំដុះតាមទីជនបទ នៅសេសសល់ជាច្រើនហិកតាដែលនៅទំនេរ

ចោលគ្មានសកម្មភាពដាំដុះ នេះដោយសារតែវិនិយោគិនភាគច្រើនពុំសូវមានទំនុកចិត្តក្នុងការវិនិយោគលើវិស័យនេះ ដោយហេតុថាពួកគេពិបាក ស្វែងរកជួលកសិករជំនាញ និងអ្នកបច្ចេកទេសមកបម្រើការក្នុងអាជីវកម្មរបស់ពួកគេ ព្រោះកសិករកម្ពុជាភាគច្រើនពុំសូវមានជំនាញបច្ចេកទេសខ្ពស់លើការដាំដុះធៀបជាមួយប្រទេសដទៃ។ ៤-ការធ្លាក់ចុះតម្លៃកសិផល និងការកេងចំណេញពីឈ្មួលកណ្តាលៈ ការហូរចូលនូវផលិតផលពីបរទេស ជាមូលហេតុចម្បងដែលធ្វើឱ្យតម្លៃផលិតផលក្នុងស្រុកធ្លាក់ទាប។ ជារៀងរាល់ថ្ងៃ ដំណាំកសិកម្មជាច្រើនមុខពីបរទេស (ថៃ, វៀតណាម...) បានវាយលុកទីផ្សារក្នុងស្រុកយ៉ាងខ្លាំងក្លា ដែលធ្វើឱ្យកសិករពិបាកក្នុងការប្រកួតប្រជែងតម្លៃក្នុងការលក់ចេញ។ ជាលទ្ធផល នាំឱ្យកសិករមួយចំនួន អស់ទឹកចិត្តក្នុងការធ្វើស្រែចម្ការ។ ដោយសារតែទីផ្សារនៅឆ្ងាយពីប្រជាកសិករ ធ្វើឱ្យកសិករពិបាកក្នុងការទាក់ទងផ្ទាល់ជាមួយអតិថិជន និងអ្នកប្រើប្រាស់ ដូចនេះផលដំណាំរបស់ពួកគាត់ភាគច្រើនត្រូវបានប្រមូលទិញដោយពួកឈ្មួញកណ្តាល។ ម៉្យាងទៀត ដោយសារតែប្រជាកសិករភាគច្រើនពុំមានពត៌មានច្បាស់អំពីតម្លៃ និងតម្រូវការទីផ្សារ ពួកឈ្មួញកណ្តាលបានឆ្លៀតឱកាសទិញផលដំណាំពីប្រជាកសិករក្នុងតម្លៃទាប ហើយយកទៅចែកចាយលក់បន្តក្នុងតម្លៃខ្ពស់ ដែលនេះជាមូលហេតុចម្បងមួយដែលធ្វើឱ្យជីវភាពរបស់ប្រជាកសិករមិនអាចរីកចម្រើនបាន ព្រោះពួកគាត់ទទួលបានផលចំណេញតិចតួចបំផុត។

- **បញ្ហាប្រឈមចំពោះផលិតកម្មដំណាំកៅស៊ូ**

ជាមួយគ្នានេះ ក្រៅពីកង្វះខាតនូវ ហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធស្រោចស្រព កង្វះបច្ចេកទេសក៏នៅមានបញ្ហាផ្សេងទៀត ដែលបានជះឥទ្ធិពលដល់ផលិតកម្មដំណាំកៅស៊ូរួមមានៈ ១-បញ្ហាអាកាសធាតុៈ ការធ្វើកសិកម្មភាគច្រើន មិនថាតែលក្ខណៈគ្រួសារ ឬក្រុមហ៊ុនទេ ភាគច្រើនគឺពួកគាត់ពឹងផ្អែកទៅលើធម្មជាតិ។ ជាពិសេសបញ្ហាទឹក ដែលធ្វើឱ្យពួកគាត់រងនូវការលំបាក និងជួបផលលំបាកក្នុងកំឡុងពេលដាំដុះ ដែលពេលខ្លះមានភ្លៀងធ្លាក់មិនគ្រប់គ្រាន់ ធ្វើឱ្យការដាំកៅស៊ូដំណើរការលូតលាស់មិនបានល្អ។ តែពេលខ្លះកត្តាធម្មជាតិធ្វើឱ្យមានទឹកជំនន់ហូរលិច កូនដើមកៅស៊ូធ្វើឱ្យរលួយងាប់ក៏មាន។ ពេលខ្លះខ្យល់បក់ខ្លាំងក៏ធ្វើឱ្យប៉ះពាល់ដល់ដើមកៅស៊ូផងដែរ ព្រោះខ្យល់ខ្លាំងតែងតែធ្វើឱ្យដើមកៅស៊ូបាក់ ដែលធ្វើឱ្យមានការពិបាកមិនអាចទាញទឹកជ័របាន។ ២-បញ្ហាជំងឺចំពោះដំណាំកៅស៊ូៈ មានដូចជា *ជំងឺស្លឹកអូអ៊ីដ្យូម ឬប្រផេះស*(ជំងឺនេះរីករាលដាលដោយសារកត្តាអាកាសធាតុសំខាន់ជាងគេ ពីព្រោះស្ព័រហើរតាមខ្យល់ និងបង្កបញ្ហាខ្លាំងនៅតំបន់ខ្ពស់ និងមានតិចតួចនៅរយៈកម្ពស់ទាបជាង៩០ម៉ែត្រ) *ជំងឺជ្រុះស្លឹកករីណេស្ប៉ូរ៉ា* (ជំងឺនេះ ធ្វើឱ្យ

ស្លឹកលេចឡើងនូវស្នាមពណ៌ត្នោតប្រផេះ និងមានស្នាមអុជច្រើនភ្ជាប់គ្នាជាផ្ទាំងដែលប្រមូលផ្តុំ ផ្សិតរីកធំឡើងបង្កជាដំបៅ(lesions) ខ្លោចជ្រួញនិងមិនទ្រង់ទ្រាយមិនដូចគ្នា ជំងឺនេះរីករាលដាល បណ្តាល់ឱ្យជ្រុះស្លឹក) ជំងឺជ្រុះស្លឹកអាមេរិកខាងត្បូង(SALB) (ជំងឺនេះបង្កតែលើផ្នែកខ្ចីនៃរុក្ខជាតិ ដោយធ្វើឱ្យធ្វើឱ្យខូចទ្រង់ទ្រាយនៃកូនស្លឹក ដែលឆ្លងជំងឺធ្ងន់ធ្ងរក៏ឡើងក្រៀមស្ងួត ហើយប្រែពណ៌ ហាក់ដូចជាខ្មៅ)។ ៣-បញ្ហាទីផ្សារ និងការធ្លាក់ចុះនៃតម្លៃកៅស៊ូ៖ មិនថាផលិតផលកៅស៊ូរបស់ក្រុមហ៊ុន ផលិតផលកៅស៊ូរបស់ប្រជាពលរដ្ឋតែងតែជួបប្រទះនឹងបញ្ហាទីផ្សារ ដែលទាក់ទងនឹងតម្លៃ។ ពួកគាត់តែងតែត្អូញត្អែរចំពោះតម្លៃកៅស៊ូ ព្រោះតម្លៃជ័រវាស្ថិតតែនៅលើសម្តីរបស់ឈ្មួញកណ្តាល ហើយពេលខ្លះទៀត មិនមានទីផ្សារគ្រប់គ្រាន់ដើម្បីយកជ័រទៅលក់ ហើយខ្វះដៃគូវិនិយោគ ដើម្បីធ្វើការនាំចេញជ័រកៅស៊ូ និងកង្វះនូវពត៌មានពីតម្លៃកៅស៊ូ បានធ្វើឱ្យឈ្មួញកណ្តាលមានឱកាសកេងចំណេញបានយ៉ាងស្រួលពីពួកគាត់។

- **បញ្ហាប្រឈមចំពោះផលិតកម្មសត្វ**

ផលិតកម្មសត្វគ្រប់ប្រភេទបានជួបនូវបញ្ហាប្រឈមមួយចំនួនដូចជា៖ បញ្ហាជំងឺ: ជំងឺសត្វកើតឡើង និងរីករាលដាល មានដូចជា ជំងឺអុតក្តាម ជំងឺសារទឹក ជំងឺជ្រូកត្រចៀកខៀវ ជំងឺផ្តាសាយបក្សីជាដើម ដែលបង្កបញ្ហាដល់កំណើនផលិតកម្មសត្វ ប្រសិនបើមិនមានវិធានការការពារទាន់ពេលវេលានោះទេ ធ្វើឱ្យសត្វគោ ក្របី ជ្រូក បក្សី ឈឺ និងស្លាប់ជាបន្តបន្ទាប់។ ក្រៅពីនេះ បញ្ហាអាកាសធាតុ: ការកើនឡើងនូវអាកាសធាតុក្តៅខ្លាំងនាំឱ្យមានកង្វះ ទឹកសម្រាប់សត្វ ដំណាំចំណីសត្វ និងកែច្នៃផលិតផលសត្វធ្វើឱ្យមានការកើនឡើងនូវតម្រូវការទឹក។ ផ្ទុយទៅវិញ នៅពេលដែលមានទឹកជំនន់បណ្តាលឱ្យមានការបំផ្លិចបំផ្លាញនូវជម្រកសត្វ និងបណ្តាលឱ្យមានការកើនឡើងនូវជំងឺផ្សេងៗ។ លើសពីនេះ បញ្ហាតម្លៃនៃផលិតផលសត្វ និងទីផ្សារសត្វ: ដែលជាបញ្ហាចម្បងមួយ ដោយមានការនាំចូលសត្វពីបរទេស ធ្វើឱ្យការចិញ្ចឹមសត្វក្នុងស្រុកមិនអាចប្រកួតប្រជែងជាមួយទៅផ្សារសាច់សត្វប្រទេសជិតខាងបាន ដោយសារថ្លៃដើមផលិតកម្មខ្ពស់ ពិសេសថ្លៃចំណីសត្វ និងថ្នាំព្យាបាលសត្វជាដើម។

- **បញ្ហាប្រឈមចំពោះវិស័យជលផល**

ផលិតកម្មផលប្រឈមនឹងបញ្ហាដូចជា៖ កំណើននៃការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ នៅតែបង្ហាញខ្លួនយ៉ាងព្រោងព្រាតតាមដងទន្លេ។ ប្រជានេសាទ ដែលពឹងអាស្រ័យផលលើធនធានជលផល កំពុងបង្ហាញការព្រួយបារម្ភជាខ្លាំង នៅពេលការនេសាទដោយប្រើប្រាស់ឧបករណ៍ខុសច្បាប់ និងទំនើបៗ បន្តមាននៅក្នុងសហគមន៍នេសាទពួកគេមិនឈប់ឈរ។ បន្ថែម

ពីលើនេះដែរ បានឱ្យដឹងថាថ្មីៗនេះមានឧបករណ៍នេសាទខុសច្បាប់ប្រភេទថ្មី ដែលលេចចេញក្នុងបឹងទន្លេសាប នោះគឺជាប្រភេទឈ្នក់ដាក់អំពូលភ្លើង ដើម្បីទាក់ទាញកូនត្រី។ អ្នកនេសាទដែលប្រើប្រាស់ឧបករណ៍នេះ មានលទ្ធភាពអាចចាប់ត្រីល្អិតៗ រាប់តោនក្នុងមួយយប់ៗ។ "តាមពិតឈ្នក់អត់ខុសច្បាប់ទេ តែនៅពេលដែលគេដាក់អំពូលភ្លើងទាក់ទាញត្រី វាបានក្លាយជាឧបករណ៍ខុសច្បាប់"។ ម្យ៉ាងវិញទៀត ការកាប់ទន្រ្ទានព្រៃលិចទឹក ការវាទទីយកដីធ្វើជាកម្មសិទ្ធិ និងការលើកទំនប់ក្នុងដែននេសាទ ពីសំណាក់ជនខូចខិល និងអ្នកមានអំណាចជាដើម។

- **បញ្ហាប្រឈមចំពោះវិស័យព្រៃឈើ**

ប្រទេសកម្ពុជា ក៏ជាប្រទេសដែលមាគម្របនៃព្រៃឈើ ដ៏សំខាន់ផងដែរនៅក្នុងតំបន់។ ប៉ុន្តែដោយសារការកាប់បំផ្លាញព្រៃឈើបានធ្វើឱ្យប្រទេសនេះ ទទួលការខាតបង់ព្រៃឈើជាច្រើន ក្នុងនោះរួមមាន ខេត្តដែលទទួលរងនូវការបាត់បង់ព្រៃឈើ មានដូចជា បន្ទាយមានជ័យ បាត់ដំបង សៀមរាប ឧត្តរមានជ័យ និងខេត្តបៃលិន។ ខេត្តទាំងនេះក៏ជាតំបន់ដែលសម្បូរទៅដោយជីវៈចម្រុះផងដែរ។ ជាក់ស្តែងយើងឃើញមានបទល្មើសកាប់បំផ្លាញ និងជួញដូរ ព្រៃឈើខុសច្បាប់ជាច្រើននៅតាមតំបន់ព្រៃនៅកម្ពុជា។ អង្គការនិន្នាការព្រៃឈើ (Forest Trend) ជាក្រុមការពារបរិស្ថាននៅអាមេរិក ក៏បានរាយការណ៍ ពីគម្របព្រៃឈើនៅកម្ពុជាក្នុងឆ្នាំ២០១៥ ផងដែរ។ អង្គការនេះបានរកឃើញថា សម្បទានដីសម្រាប់ការធ្វើកសិកម្មខ្នាតធំ និងខ្នាតមធ្យម របស់ក្រុមហ៊ុន កម្ពុជា ចិន វៀតណាម បានធ្វើឱ្យគម្របព្រៃឈើមានការថយចុះជាលំដាប់។ របាយការណ៍របស់អង្គការនេះបានឱ្យដឹងទៀតថាមានអំពើពុករលួយ រវាងរដ្ឋាភិបាល និងឧញ៉ាមួយចំនួននៅក្នុងឆ្នាំ២០១៥ ក្នុងការកាប់បំផ្លាញព្រៃឈើនៅកម្ពុជាដែលជាហេតុធ្វើឱ្យព្រៃឈើបន្តការបាត់បង់កាន់តែខ្លាំងឡើង។

លើសពីនេះ នៅមានបញ្ហាមួយចំនួនទៀតដូចជា ផលប៉ះពាល់នៃថ្លៃម្ហូបអាហារ ផលវិបាកនៃការទទួលឥណទានរបស់ប្រជាកសិករ បញ្ហាទីផ្សារផលិតផលកសិកម្មរបស់ប្រជាកសិករ កង្វះខាតនូវបច្ចេកវិទ្យានិងការស្រាវជ្រាវភាពមិនស្របគ្នានៃការដាក់គោលនយោបាយនិងការអនុវត្ត។ ភាពលំបាកផ្នែកស្ថាប័នបានធ្វើឱ្យការវាយតម្លៃ ទៅលើសក្តានុពលភាពកិច្ចការអភិវឌ្ឍន៍មានភាពលំអៀង ភាពខ្វះខាតសេវាផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ការទទួលពត៌មានបច្ចេកទេសតាមចរន្តមិនផ្លូវការ ផលវិបាកនៃបញ្ហាផលិតភាពទាប ភាពមិនរីកចម្រើននៃទីផ្សារនិងឧបសគ្គក្នុងការនាំចេញ ធនធានមានកម្រិតសម្រាប់ប្រជាកសិករ និងភាពបរាជ័យនៃគម្រោងវិនិយោគកសិកម្ម។ល។

## ៤.២ ដំណោះស្រាយក្នុងការបង្កើនផលិតកម្មកសិកម្ម

វិធានការជាច្រើនបាន និងកំពុងប្រើប្រាស់ដើម្បីកែលម្អការអភិវឌ្ឍន៍កសិកម្ម និងជីវភាពរបស់ប្រជាជននៅតាមជនបទឱ្យមានភាពប្រសើរឡើង វិធានការទាំងនោះរួមមាន ការកែលម្អមធ្យោបាយផលិតកម្ម ការពង្រីក និងកែលម្អតំបន់ស្រោចស្រព វិធីសាស្ត្រកសិកម្មចម្រុះ និងការបង្កើនការកែច្នៃកសិផល ការកែលម្អពូជដំណាំគ្រប់ប្រភេទ ការកែលម្អប្រសិទ្ធភាពនៃការប្រើប្រាស់ជី និងថ្នាំពុល កាត់បន្ថយការបាត់បង់ក្រោយពេលប្រមូលផល និងថ្លៃម៉ាឃីធីង និងបង្កើនការគាំទ្រទៅដល់សេវាកសិកម្ម។

### ៤.២.១ កែលម្អមធ្យោបាយផលិតកម្មក្នុងការជំរុញកំណើនកសិកម្ម

កត្តាផលិតកម្មកសិកម្មដែលមិនអាចខ្វះបានគឺ ទឹក ដី និង ជី ដែលធ្វើឱ្យមានដំណើរការផលិតកម្មកសិកម្ម និងជាកត្តាជំរុញឱ្យផលិតភាពកើនឡើង។ នៅក្នុងវិស័យកសិកម្ម ទឹក ដី និង ជី គឺជាកត្តាសំខាន់ដែលជួយជំរុញឱ្យផលិតភាពកើនឡើង រួមផ្សំនឹងកត្តាផ្សេងៗទៀតដូចជា កត្តាបច្ចេកវិទ្យា និងដើមទុនជាដើម។ កាលពីសម័យមុនកត្តាបច្ចេកវិទ្យា និងដើមទុនមិនសូវសំខាន់ទេ ក៏ប៉ុន្តែសម័យបច្ចុប្បន្នវិស័យកសិកម្ម មិនខុសគ្នាពីវិស័យឧស្សាហកម្មនោះទេ ដែលកត្តាទាំងនោះដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញឱ្យវិស័យកសិកម្មមានភាពរីកចម្រើន។

ខាងក្រោមនេះ គឺជាការបកស្រាយនូវកត្តាផលិតកម្មសំខាន់ៗ៖

#### ៤.២.១.១ ការពង្រីក និងកែលម្អការប្រើប្រាស់ ប្រព័ន្ធស្រោចស្រព ដី និងជី

កសិកម្មដែលស្គាល់ភាពជឿនលឿន គឺត្រូវប្រើប្រាស់កត្តាផលិតកម្ម ឱ្យមានប្រសិទ្ធភាពពិសេស ទឹក ដី និង ជី ដែលជាសមាសធាតុមានទំនាក់ទំនងគ្នាទៅវិញទៅមកក្នុងការជំរុញឱ្យមានកំណើនផលិតភាពក្នុងវិស័យកសិកម្ម។ ហេតុដូចនេះហើយបានជាយើងត្រូវដឹង និងធ្វើការសិក្សាឱ្យបានច្បាស់អំពីអត្ថប្រយោជន៍ និងប្រភពបញ្ហានៃធាតុនីមួយៗ ដើម្បីស្វែងរកដំណោះស្រាយក្នុងការទាញយកនូវកត្តាផលិតកម្មទាំងនេះ មកប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព។

**-ដី៖** លក្ខណៈសណ្ឋានដីប្រទេសកម្ពុជា មានភាពអំណោយផលណាស់ សម្រាប់ធ្វើកសិកម្មស្ទើរតែគ្រប់មុខដំណាំ។ នេះដោយសារតែដីភាគច្រើនជាដីទំនាប និងស្ថិតនៅជាប់ទំនាបបឹងទន្លេសាប និងទន្លេមេគង្គដែលជាប្រភេទដីមានជីជាតិល្អ សម្បូរសារធាតុសរីរាង្គ ដែលជាប្រភពអាហារសម្រាប់ការលូតលាស់របស់ដំណាំ។ ក៏ប៉ុន្តែយើងសង្កេតឃើញថា ការប្រើប្រាស់ដីនៅកម្ពុជាមិនទាន់មានប្រសិទ្ធភាពនៅឡើយទេ ដោយសារយើងជួបប្រទះនូវបញ្ហាមួយចំនួនដូចជា ប្រទេសយើងនៅមិនទាន់បានកំណត់នូវភាពជាម្ចាស់កម្មសិទ្ធិដីធ្លី (ប្លង់ដី) ឱ្យបានច្បាស់លាស់

និងគ្រប់គ្រាន់នៅឡើយ។ ការដែលគ្មានប័ណ្ណកម្មសិទ្ធិដីធ្លីនេះហើយ ដែលជាកត្តាដែលបង្កឱ្យមានជម្លោះដីធ្លី និងជាឧបសគ្គក្នុងការប្រើប្រាស់ដីកសិកម្មគ្រប់រូបភាព។ មួយវិញទៀត ប្រហែល ៦៨% នៃដីកសិកម្មជាដីដែលចែកជាចំណែកតូចៗមានទំហំត្រឹមតែ ០.៥ហិកតា ឬតូចជាងនេះ[35] ដែលជាហេតុធ្វើឱ្យមានការលំបាកក្នុងការអភិវឌ្ឍ ដូចជាការសាងសង់ប្រព័ន្ធធារាសាស្ត្រ និងការប្រើប្រាស់ទំនើបកម្មគ្រឿងយន្តកសិកម្ម។ លើសពីនេះទៅទៀត ដីកាន់តែខ្សោះជីជាតិទៅៗ ដោយសារការប្រើប្រាស់ដី មិនត្រឹមត្រូវតាមបច្ចេកទេសដូចជា: ការប្រើប្រាស់ជីគីមី មិនសមស្រប ការដាំដំណាំដដែលៗ ដែលធ្វើឱ្យគុណភាពដីប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ រហូតដល់ក្លាយជាដីហិរតែម្តង។ បញ្ហាទាំងនេះហើយ យើងត្រូវតែយកចិត្តទុកដាក់ស្វែងរកនូវដំណោះស្រាយ នានាក្នុងការកែខៃឱ្យមានលក្ខណៈប្រសើរឡើង។ សរុបសេចក្តីមក ការប្រើប្រាស់ដី និងថ្នាំពុលគីមី គឺជាផ្នែកមួយដ៏សំខាន់ ក្នុងការបង្កើននូវសក្តានុពលផលិតកម្មដំណាំគ្រប់ប្រភេទ។ ប៉ុន្តែប្រសិនបើការប្រើប្រាស់ធនធាន ផលិតកម្មទាំងពីរមុខមាន អត្រាលើសកម្រិតកំណត់ វានិងធ្វើឱ្យកើនឡើងនូវថ្លៃផលិតកម្ម ជាលទ្ធផលធ្វើឱ្យប្រាក់ចំណូលថយចុះ។ បន្ថែមពីលើនេះ ការប្រើប្រាស់លើសកម្រិត និងពុំត្រឹមត្រូវអាចនាំឱ្យប៉ះពាល់ដល់សុខភាពរបស់កសិករ សម្លាប់ត្រី និងបំពុលដល់ការប្រើប្រាស់ទឹកស្អាត។ ដូចនេះ ការដាក់ផ្លាកសញ្ញា អក្សរណែនាំជាភាសាជាតិ និងការផ្តល់អាជ្ញាប័ណ្ណក្នុងការនាំចូលជី និងថ្នាំគ្រប់ប្រភេទគឺជាចំនុចមួយដែលរាជរដ្ឋាភិបាលគួរតែចាត់វិធានការជាបន្ទាន់។

-**ទឹក៖** ទឹកមានសារៈសំខាន់ណាស់ សម្រាប់ភាវៈរស់ទាំងអស់នៅលើពិភពលោកយើងនេះ ដែលស្របតាមសុភាសិតមួយឃ្លាពោលថា គ្មានទឹក គឺគ្មានជីវិត។ ជាភ័ព្វព្រេងសំណាងរបស់ប្រទេសកម្ពុជាដែលប្រទេសយើង មានទំហំផ្ទៃទឹកធំជាងប្រទេសណាណា ទាំងអស់លើពិភព-លោក ដែលប្រហែល ៩០% នៃផ្ទៃដីកម្ពុជាសុទ្ធតែមានកន្លែងរក្សាទឹកពីទន្លេ ស្ទឹង បឹងបួរ ជ្រោះដែលជាប្រភពមិនចេះរីងស្ងួត[36]។ ហេតុដូចនេះ វាមានលក្ខណៈអំណោយផលល្អ ដល់ការទាញយកទឹកមកប្រើប្រាស់ គ្រប់រូបភាពទាំងអស់ ជាពិសេសសម្រាប់វិស័យកសិកម្មដែលបានប្រើប្រាស់ទឹកច្រើនជាងគេបំផុត មានអត្រា៩៤% វិស័យឧស្សាហកម្ម១.៥% និងការប្រើប្រាស់ក្នុង

[35] UNDP, *របាយការណ៍អភិវឌ្ឍន៍មនុស្សនៅកម្ពុជា* (ភ្នំពេញ៖ UNDP, ២០០៧), ៥៥។
[36] UNDP, *របាយការណ៍អភិវឌ្ឍន៍មនុស្សនៅកម្ពុជា* (ភ្នំពេញ៖ UNDP, ២០០៧), ៧៦។

គេហដ្ឋាន៩.៥%[37]។ ចំពោះការប្រើប្រាស់ទឹកនៅក្នុងវិស័យកសិកម្មកម្ពុជា មិនទាន់មានប្រសិទ្ធភាពនៅឡើយទេ ដោយចាប់តាំងពីបុរាណកាល រហូតដល់បច្ចុប្បន្ន កសិកម្មកម្ពុជានៅតែពឹងផ្អែកលើលក្ខខណ្ឌអំណោយផលរបស់ធម្មជាតិ (ធ្វើស្រែប្រវាស់មេឃ) ជាពិសេសគឺដំណាំរដូវវស្សា ដែលប្រព័ន្ធស្រោចស្រពចូលរួមតិចតួចបំផុតនៅរដូវនេះ។ ការពឹងផ្អែកខ្លាំងលើលក្ខខណ្ឌអាកាសធាតុបែបនេះ ហើយដែលជាការលំបាកក្នុងការព្យាករណ៍ ពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារស្ថានភាពបរិស្ថាន កាន់តែវិចវិលទៅៗ ដែលជាឧបសគ្គដ៏ចម្បងនៅក្នុងផលិតកម្មកសិកម្មបច្ចុប្បន្ន។ បញ្ហាទាំងនេះបណ្តាលមកពីប្រទេសកម្ពុជា មានប្រព័ន្ធស្រោចស្រព នៅមានកម្រិតនៅឡើយ តាមរយៈធ្វើការប្រៀបធៀប ជាមួយបណ្តាប្រទេសជិតខាង យើងឃើញថាកម្ពុជាមានអត្រាទាបនៅឡើយ។ នៅឆ្នាំ២០០៩ ផ្ទៃដីប្រហែលជា ៤៣% បានទទួលទឹកស្រោចស្រព។ នៅតំបន់ដែលមានការដាំដុះសព្វថ្ងៃ មានតែ ៧-៨% តែប៉ុណ្ណោះដែលមានប្រព័ន្ធស្រោចស្រពល្អប្រសើរ[38]។ ដូចច្នេះ ការសាងសង់នូវប្រព័ន្ធធារាសាស្ត្រ ជាកត្តាចាំបាច់ណាស់ក្នុងការទាញយកទឹក (ទឹកលើដី និងទឹកក្រោមដី) មកប្រើប្រាស់ឱ្យអស់លទ្ធភាព ព្រោះថាទឹកមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងផលិតភាពដី និងស្ថេរភាពនៃទិន្នផល។ ជាក់ស្តែងផលិតភាពដីដែលមានប្រព័ន្ធធារាសាស្ត្រមានប្រសិទ្ធភាពចំនួនពីរដង ច្រើនជាងដីដែលផ្គត់ផ្គង់ដោយទឹកភ្លៀង[39]។ ជាការពិតណាស់ យើងទទួលស្គាល់ថា ការស្ថាបនាប្រព័ន្ធធារាសាស្ត្រ ទាមទារនូវចំណាយខ្ពស់ ក៏ប៉ុន្តែបើគ្មានប្រព័ន្ធធារាសាស្ត្រទេនោះ ផលវិបាករឹតតែមានតម្លៃចំណាយខ្ពស់ជាងនេះទៅទៀត។ ហេតុដូចនេះហើយទើប បច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការបន្តស្តារ និងសាងសង់ប្រព័ន្ធស្រោចស្រពដើម្បីបម្រើឱ្យ វិស័យកសិកម្មដែលបានដាក់ចេញនូវយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក ដែលយុទ្ធសាស្ត្រនេះ មានទស្សនៈវិស័យដើម្បីធានាឱ្យមានសុវត្ថិភាពស្បៀង និងទឹកគ្រប់គ្រាន់ដល់ប្រជាពលរដ្ឋគ្រប់រូប ធានាឱ្យមានចិរភាពធនធានធម្មជាតិពិសេសគឺ ដើម្បីកាត់បន្ថយភាពក្រីក្រ

[37] FAO, *ការប្រើប្រាស់ទឹក* (២០១១), http://www.fao.org/nr/water/aquastat/countries_regions/KHM/ (ចូលទស្សនាថ្ងៃទី ០១ ឧសភា ២០១៧) ។

[38] ឈុន ពហុ, *ការអភិវឌ្ឍជនបទ* (ភ្នំពេញ៖ ស.ភ.ន.វ.ស, ២០០៩)។

[39] UNDP, *Cambodia Human Development Report*, [អភិវឌ្ឍន៍មនុស្សនៅកម្ពុជា], (Ministry of Planning, Phnom Penh, 2007), 17 ។

និងរួមចំណែកលើកស្ទួយសេដ្ឋកិច្ចជាតិ[40]។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ រួមមានការបន្តការអនុវត្តនយោបាយទឹក តាមរយៈការគ្រប់គ្រងធនធានទឹកឱ្យបានល្អ ដោយជំរុញឱ្យមាននូវការថែរក្សាស្ថាបនា និងស្តារប្រព័ន្ធធារាសាស្ត្រទាំងខ្នាតតូច មធ្យម និងធំ។ ជាលទ្ធផល គេសង្កេតឃើញថាផ្ទៃដីស្រោចស្រពមានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ សរុបសេចក្តីមក ការបង្កើននូវផលិតម្មកសិកម្ម ចាំបាច់ត្រូវមាននូវប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់ ព្រោះផលិតផលដីដែលមានប្រព័ន្ធស្រោចស្រព មានចំនួនពីរដងច្រើនជាងប្រសិទ្ធភាពដីដែលផ្គត់ផ្គង់ដោយទឹកភ្លៀង។ ការពង្រីកការស្រោចស្រព ព្រមទាំងកែលម្អការគ្រប់គ្រង់ទឹក គឺជាផ្នែកមួយដ៏សំខាន់សម្រាប់បំពេញនូវទឹកភ្លៀង ដែលភ្លៀងពុំទៀងទាត់នៅរដូវវស្សា និងខ្វះទឹកនៅរដូវប្រាំង។ គេកត់សម្គាល់ឃើញថា តំបន់ដាំដុះយ៉ាងធំទូលាយនៅក្នុងមានដង្ហើមទឹករាក់ និងមានទឹកដក់នៅលើដីគ្រប់គ្រាន់ ដើម្បីធ្វើការស្រោចស្រពនៅលើផ្ទៃដីយ៉ាងហោចណាស់ ១លានហិកតា នៅក្នុង កំឡុងរដូវប្រាំង។ ហើយការសិក្សាថ្មីៗនេះអំពីគុណភាពដី បានបង្ហាញថា ផ្ទៃដីដាំដុះជាង ៥០% នៅកម្ពុជាជាដីមានគុណភាពអន់ និងមានសក្តានុពលទាបដើម្បីបង្កើនទិន្នផល។

**-ជី៖** គឺជាវត្ថុធម្មជាតិ ឬសមាសធាតុគីមីទាំងឡាយណាដែលរួមមាន សមាសធាតុគីមីអាចម៍សត្វ (Manure) នីត្រូសែន (Nitrogen) ផូស្វ័រ (Phosphorus) និង ប៉ូតាស្យូម (Potassium) ដែលវាមានមុខងារសម្រាប់បង្កើនផលិតភាពរបស់ដី និងដើម្បីផ្គត់ផ្គង់ដល់ការលូតលាស់របស់រុក្ខជាតិ[41]។ ជាការពិតណាស់ ការដែរកសិករប្រើប្រាស់ជីគឺ ដើម្បីចង់ឱ្យផលិតផលកសិកម្មរបស់ខ្លួនទទួលបានទិន្នផលខ្ពស់។ ជាឧទាហរណ៍ ប្រទេសថៃ វៀតណាម ឡាវ ដែលជាប្រទេសប្រើប្រាស់ជីក្នុងបរិមាណច្រើនលើសប្រទេសកម្ពុជាពី ៣-៦ដង នោះទិន្នផលស្រូវដែលគេទទួលបានក៏ច្រើនដែរពី ២.៨២តោន ទៅ ៩.៨២តោនក្នុងមួយហិកតា។ នេះបញ្ជាក់ឱ្យឃើញថា ផលិតភាពរបស់កម្ពុជា គឺនៅខ្សោយណាស់បើប្រៀបធៀបជាមួយប្រទេសជិតខាងយើង ហើយការដែលកើនឡើងផលិតផលមួយផ្នែកធំដែលទទួលបានគឺ បានមកពីការពង្រីកដីធ្វើកសិកម្ម មិនមែនដោយសារការបង្កើនទិន្នផលនោះទេ។ ការប្រើប្រាស់ជី និងបច្ចេកវិទ្យានៅក្នុងវិស័យកសិកម្មនៅមានកម្រិតទាបនៅឡើយ ដែលប្រជាកសិករភាគច្រើន មិនបានយល់ដឹងច្បាស់ អំពីគុណវិបត្តិ

[40] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ២០០៩-២០១០* (ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ២០១០), ៩។

[41] AHPC, The American Heritage dictionary of the English language, [វចនានុក្រមបេតិកភណ្ឌអាមេរិកនៃភាសាអង់គ្លេស], (Houghton Mifflin company, 2012) ។

និងអត្ថប្រយោជន៍ក្នុងការប្រើប្រាស់ជី (ជីធម្មជាតិ និងជីគីមី)។ ជីគីមីប្រើប្រាស់ច្រើននឹងទទួលបានទិន្នផលខ្ពស់នៅក្នុងបរិមាណកំណត់មួយ ប៉ុន្តែវាមានគុណវិបត្តិច្រើន ក្នុងការប្រើប្រាស់វាដូចជា ផ្តល់នូវទិន្នផលខ្ពស់រយៈពេលខ្លី ហើយពេលដែលប្រើយូរៗទៅធ្វើឱ្យខូចគុណភាពដី និងប៉ះពាល់ដល់បរិស្ថាន។ លើសពីនេះទៅទៀតចំណាយថ្លៃដើមខ្ពស់។ រីឯជីធម្មជាតិ (ជីកំប៉ុស ជីស្រស់ ជីលាមកសត្វ) គឺជាប្រភេទជីដែលផ្តល់នូវទិន្នផលខ្ពស់ ជំនួយដីឱ្យមានជីជាតិអាចរកបានងាយៗ និងមិនសូវចំណាយថ្លៃដើមខ្ពស់ទេ ហើយការប្រើប្រាស់ជីធម្មជាតិក្នុងកសិកម្ម គឺជាការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយចិរភាព។

### ៤.២.២ ទីផ្សារផលិតកម្មកសិកម្ម និងការក្បាលំនឹងថ្លៃលក់

ការស្វែងរកទីផ្សារ សម្រាប់ផលិតផលកសិកម្ម គឺជាកូនសោរចាក់ទំលុះភាពរាំងស្ទះ និងភាពយឺតយ៉ាវ ក្នុងការអភិវឌ្ឍវិស័យកសិកម្ម ដើម្បីកំណើនសេដ្ឋកិច្ចកម្ពុជា ជាពិសេសគឺការកាត់បន្ថយភាពក្រីក្រនៅជនបទ ព្រោះបើតាមន័យសេដ្ឋកិច្ច បើតម្រូវការទីផ្សារធំនោះធ្វើឱ្យផលិតផលកើនឡើង ហើយចំណូលអ្នកផលិតក៏កើនឡើងដែរ។ ដូច្នេះប្រជាជនកម្ពុជាជាង ៧០% ដែលជាកសិករនឹងទទួលបានចំណូលកើនឡើង ក៏ប៉ុន្តែអ្វីដែលជាបញ្ហា គឺទីផ្សារផលិតផលកសិកម្មនៅមានភាពរាំងស្ទះនៅឡើយ ដោយសារកង្វះខាតពត៌មាន។ នេះបើតាមការអង្កេតរបស់ EIC បានឱ្យដឹងថា មានប្រជាកសិករតែ១០% ប៉ុណ្ណោះដែលទទួលបានពត៌មាន តាមរយៈប្រព័ន្ធផ្សព្វផ្សាយ[42]។ រីឯបញ្ហាតម្លៃទីផ្សារឡើងចុះ ដែលមិនអាចកំណត់បាន និងជាពិសេសគឺពេលប្រមូលផល តម្លៃផលិតផលបែរជាមានតម្លៃថោក ដែលជាឧបសគ្គដ៏ធំក្នុងការធ្វើឱ្យវិស័យកសិកម្មមានភាពរីកចម្រើននៅមុខ។ ដូច្នេះដើម្បីឱ្យទីផ្សារផលិតផលកសិកម្ម មានការរីកចម្រើនចំណុចសំខាន់ត្រូវតែស្វែងរក និងពង្រីកទាំងទីផ្សារក្នុងស្រុក និងក្រៅស្រុកឱ្យខានតែបាន។ ជាក់ស្តែងទីផ្សារក្នុងស្រុកសំខាន់ៗ គឺភាគច្រើនជាតំបន់ទីប្រជុំជនធំៗដូចជា៖ ទីក្រុងភ្នំពេញ ក្រុងតាខ្មៅ ក្រុងសៀមរាប ខេត្តព្រះសីហនុ ដែលក្នុងនោះទីក្រុងភ្នំពេញ ជាទីផ្សារក្នុងស្រុកដែលធំជាងគេបំផុតក្នុងប្រទេស។ ចំណែកទីផ្សារបរទេសសម្រាប់ផលិតផលកសិកម្មដែលកម្ពុជាបាននាំចេញទៅកាន់តែមានការរីកចម្រើនគួរសមដែរ ព្រោះមានការសហការជាមួយ ប្រទេសក្រៅជាច្រើនដែលភាគច្រើនផ្តោតទៅលើការនាំចេញ អង្ករ និងស្រូវ។

[42] EIC, *Cambodia Agriculture Development Report*, [របាយការណ៍អភិវឌ្ឍន៍កសិកម្មកម្ពុជា], (EIC, 2006) 34-35។

**កសិករអាចប្រើប្រាស់មធ្យោបាយ ៥ជម្រើសក្នុងការរក្សាលំនឹងថ្លៃលក់៖**

- **ជម្រើសទី១៖ បង្កើតក្រុមជាឃ្លាំងស្តុកផលិតផលកសិកម្ម**

កសិករម្នាក់ៗមិនអាចធ្វើអ្វីកើតទេ ទៅលើតម្លៃលក់ផលិតផលរបស់ខ្លួន ប៉ុន្តែបើរួមកម្លាំងគ្នា គេអាចលក់ផលិតផលទាំងនោះបានតម្លៃខ្ពស់។ អង្គការកសិករដែលជួយឱ្យកសិករ អាចលក់ផលិតផលកសិកម្មរបស់ខ្លួនបានកម្រៃខ្ពស់ មិនមានទាល់តែសោះនៅកម្ពុជា។ មានអង្គការមិនមែនរដ្ឋាភិបាលច្រើនកំពុងប្រឹងប្រែងក្នុងទិសដៅនេះ។ ដើម្បីឱ្យកសិករលក់ផលិតផលបានថ្លៃល្អ គម្រោងមួយកំពុងតែដាក់ឱ្យល្បងពិសោធន៍នៅខេត្តព្រៃវែង និងខេត្តកំពត តាមរយៈអង្គការកសិករមួយឈ្មោះ ទីផ្សារចំហាសម្រាប់ផលិតផលកសិកម្ម។ ក្នុងគម្រោងនេះត្រូវមានឃ្លាំងស្តុកផលិតផលកសិកម្មរួមមួយ ដើម្បីឱ្យកសិករខ្ចីលុយផ្អែកលើចំនួនផលិតផលកសិកម្មរបស់ខ្លួន ជាជាងលក់ផលិតផលកសិកម្មទាំងបង្ខំចិត្ត ហើយទុកផលិតផលគាត់ សម្រាប់លក់នៅពេលណាដែលតម្លៃកសិផលរបស់គាត់ឡើងថ្លៃខ្ពស់បំផុត។ ការដកពិសោធន៍នេះ គួរពិនិត្យពិច័យឱ្យបានហ្មត់ចត់ ដើម្បីត្រៀមពង្រីកការល្បងពិសោធន៍នៅទីកន្លែងដទៃទៀត[43]។

- **ជម្រើសទី២៖ បង្កើតតំណាងក្រុមផលិតផលកសិកម្ម**

កសិករច្រើននាក់រួមគ្នាចុះកិច្ចសន្យាជាមួយ ក្រុមហ៊ុន ឬរោងចក្រកែច្នៃផលិតផលកសិកម្ម ឬរោងម៉ាស៊ីនកិនស្រូវ ឬឈ្មួញដែលទិញផលិតផលកសិកម្មគ្រប់ប្រភេទ...ក្នុងតម្លៃមួយដែលបានចរចារ និងព្រមព្រៀងគ្នា ដោយកសិករសន្យាថា នៅពេលប្រមូលផលគាត់ នឹងលក់ផលិតផលកសិកម្មរបស់ខ្លួន ឱ្យទៅភាគី ដែលពួកគាត់បានចុះកិច្ចសន្យា។ កិច្ចព្រមព្រៀងត្រូវធ្វើជាមួយ ភាគីដែលពាក់ព័ន្ធជាមួយនឹងផលិតផលកសិកម្មដែលប្រជាកសិករផលិត ហើយកិច្ចព្រមព្រៀងនេះត្រូវតែចរចារសារជាថ្មីរាល់ៗឆ្នាំ ទើបកសិករបានផលប្រយោជន៍ច្រើនបំផុត។ ជម្រើសនេះខុសអំពីជម្រើសទី១ ត្រង់ចំណុចដែលកសិករទាំងអស់មិនចាំបាច់មានឃ្លាំងស្តុកផលិតផលកសិកម្មរួមទេ។ ដើម្បីឱ្យជម្រើសនេះសម្រេចជោគជ័យ ត្រូវមានរោងចក្រ ឬក្រុមហ៊ុនកែច្នៃ និងឧបករណ៍កសិកម្មទំនើបៗ នៅមូលដ្ឋានឱ្យបានច្រើន និងឆាប់បំផុត[44]។

- **ជម្រើសទី៣៖ កិច្ចព្រមព្រៀងផ្លូវការជាមួយក្រុមហ៊ុន**

នេះជាជម្រើសថ្មី ដែលមានទ្រង់ទ្រាយកាន់តែប្រិតប្រៀងជាងមុន ពោលគឺជាកិច្ចព្រមព្រៀងផ្លូវការមួយរវាងកសិករជាច្រើនជាមួយនឹងក្រុមហ៊ុនកែច្នៃ (ផលិតផលកសិកម្ម) ធ្វើជាម្ចាប

[43] ឈុន ពហុ, *ការអភិវឌ្ឍជនបទ* (ភ្នំពេញ៖ ស.ភ.ន.វ.ស, ២០០៩), ៨៥។

[44] ឈុន ពហុ, *ការអភិវឌ្ឍជនបទ* (ភ្នំពេញ៖ ស.ភ.ន.វ.ស, ២០០៩), ៨៥។

អាហារ។ នៅកម្ពុជា កិច្ចព្រមព្រៀងបែបនេះ នៅមានកម្រិតខ្លាំងណាស់ ប៉ុន្តែយ៉ាងហោចណាស់ក៏មានកិច្ចព្រមព្រៀងដែលបានជោគជ័យ ២ករណីហើយដែរ គឺករណីអង្ករក្រអូប និងថ្នាំជក់។

**ទ្រង់ទ្រាយកសិករក្នុងកិច្ចសន្យាមានដូចតទៅៈ**

១. ក្រុមហ៊ុនកែច្នៃកសិផលធំមួយ ចុះកិច្ចសន្យាទិញកសិផលពីកសិករតូចតាចជាច្រើនក្នុងតម្លៃ និងចំនួនដែលបានកំណត់ជាមុន។

២. ត្រូវមានការត្រួតពិនិត្យយ៉ាងម៉ឺងម៉ាត់លើគុណភាព និងសម្ភារៈបរិក្ខារដែលប្រើប្រាស់ក្នុងការផលិតកសិផល។

៣. កសិផលត្រូវតែមានបរិមាណក្នុងកម្រិតអប្បបរមាមួយជាដាច់ខាត បើពុំនោះសោតក្រុមហ៊ុននឹងមិនឃើញផលប្រយោជន៍អ្វីក្នុងការចុះកិច្ចសន្យាជាមួយកសិករទេ។ ដើម្បីធ្វើយ៉ាងនេះបាន កសិករត្រូវមានឧបករណ៍គ្រប់គ្រាន់ដូចជា ប្រព័ន្ធស្រោចស្រព ដែលអាចគ្រប់គ្រងបាន និងគ្រឿងយន្តផ្សេងៗសម្រាប់ប្រើក្នុងការផលិត។

៤. កសិករអាចចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនដោយផ្ទាល់ ឬកសិករបង្កើតសហករណ៍ធំៗសិន ហើយឱ្យសហករណ៍ទាំងនោះ ចុះកិច្ចសន្យាជាមួយក្រុមហ៊ុន (ជាជំនួសកសិករទាំងអស់)។ ក្នុងកណីខ្លះទៀត សហករណ៍ខ្លួនឯងក៏អាចបង្កើតសិប្បកម្មកែច្នៃដែរ ប៉ុន្តែគំនិតនេះនៅមិនទាន់អាចធ្វើទៅបានទេបច្ចុប្បន្ន[45]។

**តើកសិករខ្មែរបានផលប្រយោជន៍ពីកសិកម្មជាប់កិច្ចសន្យា ឬពីប្រព័ន្ធលក់ដូរជាក្រុមដែរឬទេ?**

១. នៅកសិដ្ឋានទាំងឡាយណាដែលនៅជិតផ្លូវឡាន និងផ្លូវរថភ្លើង កសិករអាចទទួលបានផលប្រយោជន៍ច្រើន។

២. កសិករទាំងឡាយណា ដែលអាចប្រើប្រាស់ដីរបស់ខ្លួនទាំងអស់ ឬក៏មួយផ្នែក ដើម្បីផលិតផលដំណាំសម្រាប់លក់នៅទីផ្សារឱ្យបានច្រើន ទោះបីជាកសិករតូចតាចក៏ដោយ ក៏អាចទទួលផលចំណេញបានដែរ។ កសិករក្រីក្រជាងគេបំផុត ប្រហែលជាមិនអាចទទួលផលពីប្រព័ន្ធនេះភ្លាមៗបានទេ ដោយហេតុថាកសិករទាំងនោះ ពុំអាចផលិតកសិផលតាមគុណភាព និងបរិមាណដែលត្រូវការ។ ប៉ុន្តែកសិករតូចៗ ដែលអាចផលិតបានច្រើនលើសពីសេចក្តីត្រូវការក្នុងគ្រួសារ ក៏អាចចូលរួមប្រកបដោយជោគជ័យបានដែរ។

[45] ឈុន ពហុ, *ការអភិវឌ្ឍជនបទ* (ភ្នំពេញៈ ស.ភ.ន.វ.ស, ២០០៩), ៨៥។

៣. ការប្រមូលផ្តុំកសិករជាក្រុម គឺជាការលំបាកបំផុត ប៉ុន្តែមិនមែនធ្វើមិនកើតទេ។ មានករណីច្រើនដែរដែលធ្លាប់បានជោគជ័យ។ សមាជិកនៃអង្គការដែលបានជោគជ័យ ពិតជាបានផលប្រយោជន៍។

៤. កសិករប្រាកដជាចំណេញ ប្រសិនបើថ្លៃលក់កសិផលមិនធ្លាក់ចុះ និងមានការចរចាគ្នាទៅវិញទៅមក អំពីទំនាក់ទំនងរវាងថ្លៃផលិត និងទំនិញឡើងថ្លៃ។

៥. ដូចគ្នានេះដែរ កសិករអាចចំណេញប្រសិនបើបច្ចេកវិទ្យានានា និងមធ្យោបាយសម្រាប់ប្រើប្រាស់បច្ចេកវិទ្យា ទាំងនោះត្រូវបានផ្ទេរទៅឱ្យកសិករ។

៦. រក្សាតម្លៃនៅមូលដ្ឋានបានកាន់តែខ្ពស់ ផលប្រយោជន៍នៅមូលដ្ឋាន ក៏បានកាន់តែច្រើនផងដែរ[46]។

- **ជម្រើសទី៤៖ លក់ក្នុងតម្លៃណាមួយជាកំហិតទៅឈ្មួញ ដោយធានាពីរដ្ឋ**

នៅក្នុងប្រទេសជាច្រើន ជាពិសេសគឺអាស៊ីអាគ្នេយ៍ អាស៊ីខាងកើត អាស៊ីបូព៌ា និងនៅអឺរ៉ុបភាគច្រើន កសិផលកសិកម្មតែងតែទទួលបានការធានាថ្លៃលក់ យ៉ាងហោចណាស់ ក៏ក្នុងកម្រិតអប្បបរមាតាមរយៈ ប្រព័ន្ធថ្លៃគាំទ្រអប្បបរមា (MSP)។ ប្រព័ន្ធ MSP នេះ មិនចាំបាច់ឱ្យរដ្ឋាភិបាលទិញទាំងអស់ទេ។ មិនដូចកាលពីទសវត្សរ៍ឆ្នាំ ១៩៨០ ដែលត្រូវតែលក់កសិផលទាំងអស់ទៅជូនរដ្ឋាភិបាលក្នុងតម្លៃមួយដែលត្រូវបានកំណត់ជាមុន។ ប្រព័ន្ធ MSP គ្រាន់តែកំណត់តម្លៃក្នុងកម្រិតមួយ ដើម្បីការពារកសិករទប់ទល់នឹងការធ្លាក់ថ្លៃប្រចាំរដូវតែប៉ុណ្ណោះ។ ឈ្មួញឯកជនក៏អនុវត្តប្រព័ន្ធនេះបានដែរ ឱ្យតែមានការឧបត្ថម្ភបន្ថែមពីរដ្ឋាភិបាល សម្រាប់បំពេញគម្លាតនៃតម្លៃរវាងថ្លៃលក់នៅទីផ្សារ និងថ្លៃដែលប្រព័ន្ធ MSP នេះបានទិញ ជាពិសេសនៅពេលណាដែលថ្លៃលក់នៅទីផ្សារធ្លាក់ចុះទាបជាងតម្លៃដែលទិញពីកសិករ។ ផ្ទុយទៅវិញ ប្រសិនបើថ្លៃលក់នៅទៅផ្សារឡើងខ្ពស់លើសកម្រិតអប្បបរមានេះរដ្ឋាភិបាលតម្រូវឱ្យឈ្មួញឯកជនបង់ពន្ធជូនរដ្ឋ។ ប្រព័ន្ធបែបនេះត្រូវបានគេមើលឃើញថា ប្រាក់ជួយឧបត្ថម្ភ(តម្លៃដែលខាត) និងប្រាក់បង់ពន្ធ(លើប្រាក់ចំណេញ) នឹងទូទាត់គ្នាទៅវិញទៅមកបាននាពេលខាងមុខ[47]។

ប៉ុន្តែប្រព័ន្ធ MSP នេះក៏មានចំណុចខ្សោយរបស់វាដែរ។ វាមិនបានលើកទឹកចិត្តឱ្យកសិករខំប្រឹងបង្កើនប្រសិទ្ធភាព និងលើកកម្ពស់ការដាំដំណាំច្រើនមុខទេ។ នៅប្រទេសខ្លះ ប្រព័ន្ធនេះធ្វើ

[46] ឈុន ពហុ, *ការអភិវឌ្ឍជនបទ* (ភ្នំពេញ៖ ស.ភ.ន.វ.ស, ២០០៩), ៨៥។

[47] ឈុន ពហុ, *ឯកសារមេរៀនការអភិវឌ្ឍជនបទ* (ភ្នំពេញ៖ ស.ភ.ន.វ.ស, ២០១៧), ១២៩-១៣០។

ឱ្យមានឱនភាពថវិកាយ៉ាងធ្ងន់ធ្ងរ។ ដូច្នេះក្នុងបរិបទស្រុកខ្មែរប្រព័ន្ធនេះ ប្រហែលជាប្រើមិនទាន់បានទេ។

ទាំងនេះគឺជាជម្រើស៤ បែប ប៉ុន្តែក៏អាចមានជម្រើសដទៃៗទៀតដែរ។ គោលបំណង គឺការពារផលប្រយោជន៍កសិករ ទប់ទល់នឹងសម្ពាធបញ្ចុះថ្លៃផលិតផលកសិកម្ម ក្នុងអំឡុងពេលប្រមូលផល ហើយដាក់បញ្ចូលចំណាយផ្សេងៗទៅជាបន្ទុករបស់ឈ្មួញ។ ចំណាយទាំងអស់នេះមិនគួរឱ្យកសិករទទួលបន្ទុកទេ។

### ៤.២.៣ ដំណោះស្រាយទៅនឹងបញ្ហាប្រឈមចំពោះអនុវិស័យកសិកម្ម

**ផលិតកម្មដំណាំស្រូវ៖** ត្រូវជ្រើសរើសពូជធន់ទ្រាំ ធ្វើការសំអាតស្រែមុនពេលដាំ ធ្វើការពន្លិចទឹកនៅពេលស្រូវមានពន្លក ដាក់ជីឱ្យបានសមស្របទៅតាមតម្រូវការរបស់រុក្ខជាតិ ព្រមទាំងធ្វើការសំអាតគ្រាប់មុនពេលដាំ ទើបពុំបណ្ដាលឱ្យមានការបង្កជំងឺលើដំណាំស្រូវ។ កសិករប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតឱ្យបានត្រឹមត្រូវ ចៀសវៀងបង្កផលប៉ះពាល់ដល់សុខភាព។ ធ្វើការថែទាំ សម្អាតស្មៅ និងរុក្ខជាតិផ្សេងៗដែលដុះរំខានដំណាំស្រូវ ដើម្បីកុំឱ្យបរិមាណផលស្រូវ និងគុណភាពស្រូវថយចុះ។

**ផលិតកម្មដំណាំរួមផ្សំ និងឧស្សាហកម្ម៖** ដំណាំពោត ត្រូវរៀបចំប្រព័ន្ធស្រោចស្រពឱ្យបានគ្រប់គ្រាន់ វាអាចធ្វើឱ្យពោតដែលកំពុងលូតលាស់ធំធាត់ល្អ អាចធ្វើឱ្យដើមមានការប្រែប្រួលយ៉ាងឆាប់រហ័ស។ រីឯ បញ្ហាសត្វល្អិតមានដូចជាសត្វដង្កូវ សត្វកណ្ដុរ ដែលពួកវាតែងមកយាយីផលដំណាំ គួរតែប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត ឱ្យបានត្រឹមត្រូវ តាមលក្ខណៈបច្ចេកទេស។ ចំណែកឯបញ្ហាធ្លាក់ចុះតម្លៃពោតលើទីផ្សារ គួរមានវិធានការតាមរយៈ បង្កើតជាសហគមន៍ផលិតផលដំណាំពោត ការអន្តរាគមន៍ពីសំណាក់ស្ថាប័ននានា អង្គការក្រៅរដ្ឋាភិបាល និងដៃគូ វិនិយោគនានាក្នុងការជំរុញការលក់ និងការនាំចេញផលិតផលពោត ទៅលក់នៅលើទីផ្សារ[48]។ ជាមួយគ្នានេះ ដំណាំដំឡូងមី ក៏ត្រូវមានការរៀបចំប្រព័ន្ធស្រោចស្រព ដើម្បីការពារពីគ្រោះរាំងស្ងួតជាយថាហេតុ ដែលបង្កការខូចខាតដល់ផលដំណាំដំឡូងមី។ បណ្ដុះចំណេះដឹងដល់កសិករក្នុងការថែទាំ និងបច្ចេកទេសក្នុងការការពារសត្វល្អិត មកបំផ្លាញផលដំណាំរបស់ពួកគាត់។ ចំណែកឯផលិតកម្មដំណាំសណ្ដែកបាយ សណ្ដែកសៀង ល្ង និងដំណាំដទៃទៀត ត្រូវមានវិធានការក្នុងការកំចាត់សត្វល្អិតចង្រៃ ដែលមកបំផ្លាញផលដំណាំ តាមរយៈការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតឱ្យ

[48] ឈុន ពហុ, *ឯកសារមេរៀនសេដ្ឋកិច្ចកសិកម្ម* (ភ្នំពេញ៖ ស.ភ.ន.វ.ស, ២០១៧)។

បានត្រឹមត្រូវ និងទៀងទាត់ ពោលគឺជ្រើសរើសប្រភេទថ្នាំសម្លាប់សត្វល្អិតឱ្យស្របទៅតាមប្រភេទដំណាំ និងការប្រើប្រាស់ទៅតាមកម្រិត និងបរិមាណ ដែលបានណែនាំត្រឹមត្រូវជាប្រចាំ។ លើសពីនេះទៀត ដើម្បីការពារជំងឺឆ្លង កសិករត្រូវជ្រើសរើសពូជដំណាំដែលធន់នឹងជំងឺហើយដាំលើផ្ទៃដីដែលបានកំចាត់មេរោគ បាតេរីរួចរាល់។ កសិករអាចផ្លាស់ដំណាំគ្នារវាងប្រភេទដំណាំរួមផ្សំផ្សេងៗដើម្បីកាត់បន្ថយសត្វល្អិត និងពន្យាពេលខ្សោះជីជាតិនៃដី។ បណ្តុះចំណេះដឹងដល់កសិករ ដូចជាបច្ចេកទេសដាំដុះថ្មី ការរៀបចំប្រព័ន្ធស្រោចស្រព ដើម្បីបង្ការពីការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយការខូចខាតក្រោយប្រមូលផល។

**ផលិតកម្មដំណាំកៅស៊ូ៖** ត្រូវក្តាប់ឱ្យច្បាស់អំពីស្ថានភាពអាកាសធាតុ ដីធ្លី និងទីតាំងនៅតំបន់ដែលគ្រោងដាំដំណាំកៅស៊ូ ព្រមទាំងរៀបចំប្រព័ន្ធស្រោចស្រពឱ្យមានប្រសិទ្ធភាព។ បណ្តុះបណ្តាលជំនាញបច្ចេកទេសដល់ប្រជាកសិករ ដើម្បីទប់ស្កាត់ពីនានា ជំងឺដែលកើតមានលើដើមកៅស៊ូ និងការថែទាំកៅស៊ូ។ លើសពីនេះទៀត ត្រូវបង្កើននូវការយកចិត្តទុកដាក់ ការប្រើប្រាស់នូវឧបករណ៍ ថ្នាំសម្លាប់សត្វល្អិត និងការព្យាបាលកូនកៅស៊ូដល់ប្រជាកសិករ និងក្រុមហ៊ុនផងដែរ។ ម៉្យាងវិញទៀត គួរបង្កើតសហគមន៍ ឬអង្គភាព ចុះពិនិត្យផ្ទាល់នូវសកម្មភាពដាំដុះរបស់កសិករ ដើម្បីស្វែងយល់ពីចំណុចខ្វះខាត ក្នុងគោលបំណងជំរុញ ឱ្យទិន្នផលដែលទទួលបានមានភាពប្រសើរជាងមុន។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលគួរតែធ្វើអន្តរាគមន៍លើការរកដៃគូ និងទីផ្សារឱ្យកសិករ និងក្រុមហ៊ុនហើយត្រូវធ្វើការកំណត់ថ្លៃឱ្យបានច្បាស់លាស់ ចៀសវាងការដាក់តម្លៃតាមតែភាពចង់បានរបស់ពួកឈ្មួញ។ ហើយតម្លៃត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងរកដៃគូធ្វើការនាំចេញឱ្យបានច្រើន និងបង្កើនសមត្ថភាពនៃការប្រកួតប្រជែងនៅក្នុងស្រុក ព្រោះសព្វថ្ងៃនេះការនាំចេញភាគច្រើនទៅតែប្រទេសវៀតណាមតែប៉ុណ្ណោះ[49]។

**ផលិតកម្មសត្វ៖** ចំពោះផលិតកម្មសត្វគ្រប់ប្រភេទ: ១-ការធ្វើពិពិធកម្មប្រព័ន្ធផលិតកម្មសត្វតាមរយៈ ពីការចិញ្ចឹមសត្វលែង មកការចិញ្ចឹមដាក់ក្នុងទ្រុង កែលម្អស្តុកទឹក ស្តុកចំណី វិធានការអនាម័យ និងជីវសុវត្ថិភាព វិធានការពារ(ចាក់វ៉ាក់សាំង) ដើម្បីការពារសត្វចិញ្ចឹមគ្រប់ប្រភេទពីការឆ្លងជំងឺ និងការរីករាលដាលនៃមេរោគ។ ២-ការកាត់បន្ថយការបំភាយឧស្ម័នមេតាន កែលម្អការគ្រប់គ្រងសត្វ និងកាកសំណល់សត្វតាមរយៈ ការចិញ្ចឹមសត្វដាក់ទ្រុង ក្រោល ដោយប្រមូលកាកសំណល់លាមកសត្វ សម្រាប់បញ្ចូលក្នុងឡជីវឧស្ម័នដែលជាប្រភពថាមពល កកើតឡើងវិញ

[49] ឈី មួយទាង និង ហ៊ល សុខហ៊ួង, *"ការជំរុញដំណើរការកែច្នៃផលិតកម្មដំណាំកៅស៊ូ,"* (របាយការណ៍កម្មសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច), ៩១។

តាមធម្មជាតិ និងមានស្ថេរភាព (ជាមធ្យមឡជីវឧស្ម័នមួយក្នុងរយៈពេល១ឆ្នាំ អាចកាត់បន្ថយការបំភាយឧស្ម័នមេតានបាន ៥តោន)។ លើសពីនេះ ត្រូវកែលម្អយុទ្ធសាស្ត្រជ្រើសរើស និងបង្កាត់ពូជសត្វ ដើម្បីជ្រើសរើសពូជនិងបង្កើតពូជថ្មីមួយដែលអាចធន់នឹងការបម្រែបម្រួលអាកាសធាតុ និងធានាការបង្កើនផលិតភាពខ្ពស់របស់សត្វ។ ៣-ការកែលម្អទីផ្សារសត្វស្រុក និងជួយឱ្យកសិករក្រីក្រអាចរកបានទីផ្សារសត្វ ដោយជំរុញ និងលុបបំបាត់ឧបសគ្គដល់ពាណិជ្ជកម្មក្នុងតំបន់ និងអន្តរជាតិលើផលិតផលសត្វ។

**វិស័យជលផល៖** ការគ្រប់គ្រងវិស័យជលផល ត្រូវបានពង្រឹងដោយរាប់បញ្ចូលនូវការបង្កើតចំនួននៃការចុះបញ្ជីសហគមន៍នេសាទ នៅជុំវិញបឹងទន្លេសាប ការបង្កើនសកម្មភាពវារីវប្បកម្ម និងការបង្កើនការសើបអង្កេតទៅលើការនេសាទខុសច្បាប់។ រដ្ឋបាលជលផលក៏បានរឹតបន្តឹង និងបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការការពារ និងទប់ស្កាត់ការរំលោភកាន់កាប់ព្រៃលិចទឹក។ លើសពីនេះ ចំពោះប្រជាកសិករដែលចិញ្ចឹមត្រីក្នុងស្រះ គួររៀបចំស្រះឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ជីកស្រះឱ្យមានជម្រៅជ្រៅ ឬជីកស្រះបន្ថែមដើម្បីធានាដល់ការស្តុកទឹកបានយូរ។ កសិករគួររួតរះធ្វើការចិញ្ចឹមត្រីឱ្យបាននៅដើមរដូវភ្លៀងធ្លាក់ និងត្រួតពិនិត្យគុណភាពទឹកស្រះ ដើម្បីឱ្យទឹកស្រះមានពណ៌បៃតង ត្រូវតាមដាននូវប្រភេទសត្វផ្សេងៗដែលបណ្តាលឱ្យមានមហន្តរាយដល់ការចិញ្ចឹមត្រី។ បន្ថែមលើកពីនេះទៀត រដ្ឋាភិបាលត្រូវធ្វើការបង្កើននូវការផ្សព្វផ្សាយពីវិធីសាស្ត្រថ្មីដល់ប្រជាកសិករក្នុងការចិញ្ចឹម ការថែទាំ និងការពារពីជំងឺដែលកើតមានក្នុងវិស័យជលផល ព្រមទាំងបង្កើនការយល់ដឹង និងសមត្ថភាពរបស់អ្នកកែច្នៃឱ្យកាន់តែប្រសើរឡើង លើការអនុវត្តការធ្វើអនាម័យល្អ និងការអនុវត្តការផលិតល្អ ក្នុងខ្សែសង្វាក់ផលិតកម្មកែច្នៃផលិតផលជលផល[50]។

**វិស័យព្រៃឈើ៖** ការបង្កើតឱ្យមានសហគមន៍ព្រៃឈើ សំដៅរួមចំណែកក្នុងការអភិវឌ្ឍនានា និងប្រើប្រាស់ធនធានព្រៃឈើ នៅក្នុងសហគមន៍ប្រកបដោយនិរន្តរភាព។ ឆ្លងតាមការស្រាវជ្រាវ បង្ហាញថា សហគមន៍ព្រៃឈើ មានសក្តានុពលក្នុងការដើរតួនាទីដ៏សំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ប៉ុន្តែដើម្បីឱ្យមានប្រសិទ្ធភាពត្រូវ ត្រួតពិនិត្យ គ្រប់គ្រងការកាប់បំផ្លាញព្រៃឈើខុសច្បាប់ និងអំពើពុករលួយក្នុងវិស័យព្រៃឈើ និងធ្វើការផ្លាស់ប្តូរតំបន់សហគមន៍ព្រៃឈើ ទៅ

---

[50] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ២០១៥-២០១៦* (ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ២០១៦), ៦៤-៦៥។

កាន់កន្លែងណាដែលមានព្រៃឈើច្រើនហួរហៀរ[51]។ ក្នុងសហគមន៍ព្រៃឈើ គួរតែបង្កើតជាតំបន់ទេសចរណ៍ រមណីយដ្ឋានធម្មជាតិ ក្នុងគោលបំណងស្វែងរកប្រាក់ចំណូលផង និងការចូលរួមអភិរក្សធនធានព្រៃឈើ ដែលយើងអាចទាញយកផលប្រយោជន៍មិនចេះរីងស្ងួត។ លើសពីនេះ មិនត្រឹមតែចូលរួមថែរក្សាព្រៃឈើធម្មជាតិប៉ុណ្ណោះទេ គឺពលរដ្ឋគ្រប់រូប គ្រប់ជាតិសាសន៍ ទាំងមន្ត្រីក្នុងស្ថាប័នរដ្ឋ និងអង្គការសង្គមស៊ីវិល មានតួនាទីសំខាន់ដូចគ្នាក្នុងការការពារ និងដាំដុះឡើងវិញ។ គ្មាននរណាម្នាក់មិនទាញយកផលប្រយោជន៍ពីព្រៃឈើនោះឡើយ។ ការជួយការពារថែរក្សាទាំងព្រៃ ទាំងជីវៈចម្រុះ គឺមានន័យថាបានការពារអាយុជីវិតខ្លួនឯង និងជួយរួមចំណែកធំធេងណាស់សម្រាប់ជាតិ។

### ៤.២.៤ ការកែលម្អពូជស្រូវ និងពូជបន្លែ

កត្តាពូជដែលល្អសមស្របឬស៊ាំទៅនិងអាកាសធាតុ គឺជាផ្នែកមួយ ដ៏សំខាន់ដែលជួយបង្កើនទិន្នផលកសិកម្មរបស់ប្រជាកសិករ។ ឧទាហរណ៍ ពូជស្រូវអ៊ីអ៊ែរ ៦៦ ដែលប្រជាកសិករធ្វើការដាំដុះប្រហែល៩០% នៃផ្ទៃដីស្រូវប្រាំងទាំងមូល ព្រោះវាបានផ្តល់ទិន្នផលខ្ពស់ និងចំណាយពេលខ្លី។ ប៉ុន្តែតាមរបាយការណ៍បញ្ជាក់ថា ពួកគេមិនចង់បរិភោគស្រូវពូជអ៊ីអ៊ែរទេ ដោយហេតុថា វារឹង និងគ្មានជាតិ ។ ចំពោះពូជបន្លែក្នុងស្រុក ជាទូទៅ មានទិន្នផលទាប ហើយប្រជាកសិករភាគច្រើនបានទិញពូជនាំចូល ពិសេសពូជទំនើប ពីវៀតណាម និងថៃ ទោះបីពូជទាំងនោះមិនមានការត្រួតពិនិត្យគុណភាពត្រឹមត្រូវក៏ដោយ។ កម្ពុជាមានស្ថានីយរបស់រដ្ឋចំនួនពីរ កន្លែងផ្តោតទៅលើការស្រាវជ្រាវបញ្ហាផលិតកម្មបន្លែ និងគ្រាប់ពូជ គឺក្បាលកោះ និងប្រសូត្រ។ ប្រសិនបើស្ថានីយទាំងនេះនៅតែបន្តកិច្ចស្រាវជ្រាវ និងមានការជួយឧបត្ថម្ភច្រើនថែមទៀតនោះ ទៅថ្ងៃអនាគតស្ថានីយទាំងពីរ និងក្លាយ ជាទីចែកចាយ ពូជដំណាំដ៏សំខាន់មួយនៅក្នុងប្រទេស។

### ៤.២.៥ ការបង្កើតកសិកម្មចម្រុះ និងការកែច្នៃកសិផល

ដំណាំស្រូវ គឺជាមុខព្រួញដ៏សំខាន់ក្នុងការអភិវឌ្ឍ ដើម្បីធានានូវសន្តិសុខស្បៀង និងបង្កើននូវជីវភាព រស់នៅរបស់ប្រជាជននៅទីជនបទ។ ក្នុងពេលជាងមួយទសវត្សរ៍ មកនេះ ផលិតកម្មដំណាំស្រូវរបស់កម្ពុជា ទទួលបានផលិតផលជោគជ័យ គួរឱ្យកត់សម្គាល់ ប៉ុន្តែដំណាំផ្សេងៗទៀត មានការលូតលាស់បន្តិចបន្តួចប៉ុណ្ណោះ។ ការកើនឡើងនូវផលិតកម្មដំណាំទាំងនេះ អាចធ្វើឱ្យមានភាពប្រសើរឡើងដល់សន្តិសុខស្បៀង សុខភាព អាហារូបត្ថម្ភ និងប្រាក់ចំណូល

---

[51] William D. Sunderlin, "ការកាត់បន្ថយភាពក្រីក្រតាមរយៈសហគមន៍ព្រៃឈើនៅកម្ពុជា ឡាវ និងវៀតណាម៖ ការវាយតម្លៃសក្តានុពល," *គោលនយោបាយ និងសេដ្ឋកិច្ចព្រៃឈើ,* Volum 8, Issue 4 (មិថុនា ២០០៦): ៣៨៦-៣៩៦។

របស់កសិករ។ ការអភិវឌ្ឍកសិកម្មចម្រុះ និងប្រពលវប្បកម្មស្រូវតាមគោលការណ៍ធម្មជាតិ អាចជួយពង្រឹងនូវសន្តិសុខស្បៀងអាហារ និងបង្កើនការកែច្នៃកសិផលតាមរយៈ អ្នកវិនិយោគទុនកាន់តែច្រើនឡើងក្នុងវិស័យនេះ។ ដូចនេះវាអាចជួយបង្កើនតម្លៃបន្ថែមចំពោះផលិតផល កែលម្អគុណភាពផលិតផល ម៉ាឃីធីងឱ្យកាន់តែប្រសើរឡើងព្រមទាំងបង្កើតឡើងនូវឱកាសការងារ។

### ៤.២.៦ ការកាត់បន្ថយនៃការខាតបង់ក្រោយពេលប្រមូលផល និងថ្លៃម៉ាឃីធីង

ការកែច្នៃ ការទុកដាក់ ការដឹកជញ្ជូន និងការធ្វើម៉ាឃីធីង មិនត្រឹមត្រូវ និងធ្វើឱ្យមានការខាតបង់ដល់ប្រាក់ចំណេញ។ ឧទាហរណ៍ ដោយសារតែគ្មានប្រសិទ្ធភាព និងបច្ចេកទេស ម៉ាស៊ីនកិនស្រូវនៅតាមភូមិនានាជាច្រើន បានធ្វើឱ្យមានអង្ករដែលបានកិនរួចមានអត្រាមួយ ជាមធ្យមតែ៣៥%នៃទម្ងន់ស្រូវប៉ុណ្ណោះ។ ផ្ទុយពីម៉ាស៊ីនកិនស្រូវទំនើប ដែលមានលទ្ធភាពកិនបានអង្ករប្រមាណ៧០%នៃទម្ងន់ស្រូវ។ ការកើតមាននូវសំណើម និងបញ្ហាសត្វល្អិត បានធ្វើឱ្យបាត់បង់ស្រូវដែលស្តុកក្នុងជង្រុកក្នុងអត្រាមួយដ៏ខ្ពស់ ចំពោះការដឹកជញ្ជូនជារឿយៗ ធ្វើឱ្យបាត់បង់ដោយសារការវិចខ្ចប់ និងការប្រើប្រាស់មិនល្អ។ ចំពោះដំណាំបន្លែ លោក Ungsa និង Hean បានរកឃើញថា ការខាតបង់ក្រោយពេលប្រមូលផល នៅក្នុងខេត្តកណ្តាល មានរហូតដល់១៧% ដោយសារការថែរក្សាទុកនិង វិធីសាស្ត្រវេចខ្ចប់មិនបានល្អ។ ការខាតបង់ក្រោយពេលប្រមូលផលមានសភាពកាន់តែធ្ងន់ធ្ងរឡើងដោយសារហេដ្ឋារចនាសម្ព័ន្ធមិនសូវល្អ និងថ្លៃប្រេងខ្ពស់ ខ្វះខាតម៉ាឃីធីង និងសេវាកម្មឥណទានជនបទ ព្រមទាំងបង់ថ្លៃក្រៅផ្លូវការតាមចំណុចត្រួតពិនិត្យនានានៅតាមបណ្តោយផ្លូវ។

### ៤.២.៧ បង្កើនការគាំទ្រដល់សេវាកម្មកសិកម្ម

ដោយសារខ្វះខាតនូវធនធាន និងសមត្ថភាព របស់រដ្ឋាភិបាល ក្នុងការផ្សព្វផ្សាយបច្ចេកទេសឱ្យដល់ទីជនបទ បច្ចុប្បន្នពត៌មានសំខាន់ៗ ដូចជាបច្ចេកទេសកែលម្អផលិតកម្ម និងបច្ចេកទេស កែលម្អផលិតផលក្រោយពេលប្រមូលផល តម្រូវការទីផ្សារ និងតម្លៃ តម្រូវការគុណភាព និងពូជថ្មី ត្រូវបានផ្តល់ទៅឱ្យកសិករតាមរយៈ បណ្តាញផ្សព្វផ្សាយក្រៅផ្លូវការដូចជា តាមរយៈកសិករជិតខាង អ្នកចែកចាយផលិតផលកសិកម្ម អង្គការក្រៅរដ្ឋាភិបាល និងតាមរយៈអ្នកវិនិយោគ។ ឧទាហរណ៍ តាមរយៈការបំពាក់បំប៉នកសិករ និងការលើកទឹកចិត្តដើម្បីកែគុណភាពទៅលើផលិតកម្មដំណាំកសិកម្ម ដើម្បីធ្វើការនាំចេញ ដោយវិនិយោគក្នុងបែបផែន ធ្វើកិច្ចសន្យាកសិកម្មដោយផ្តល់សេវាកម្មផ្សព្វផ្សាយ និងការផ្គត់ផ្គង់ផលិតកម្ម ព្រមទាំងមានម៉ាស៊ីនកិនស្រូវថ្មី

អាចដើរតួយ៉ាងសំខាន់ នៅក្នុងការបញ្ជូនបច្ចេកវិទ្យាជំនាញ និងពត៌មានឱ្យបានដល់កសិករនាពេលអនាគត។

### ៤.២.៨ លើកទឹកចិត្តដល់កសិករដែលប្រើប្រាស់បច្ចេកវិទ្យាកសិកម្ម

ក្នុងរយៈពេលកន្លងមកនេះ ដើម្បីលើកទឹកចិត្តដល់កសិករ រដ្ឋាភិបាលបានធ្វើការផ្សព្វផ្សាយ និងបណ្តុះបណ្តាលស្តីពី ដំណាំចំណីសត្វ បច្ចេកទេសធ្វើផ្សិតចំបើង និងរបៀបធ្វើឡជីវៈឧស្ម័ន ការធ្វើពិសោធន៍ពូជបន្លែ និងស្រូវគ្រប់ប្រភេទ ដើម្បីចែកចាយដល់លើប្រជាកសិករធ្វើការផ្សព្វផ្សាយប្រព័ន្ធប្រពលវប្បកម្មតាមគោលការណ៍ធម្មជាតិ និងអប់រំធ្វើជីកំប៉ុស។ មិនត្រឹមតែប៉ុណ្ណោះរដ្ឋាភិបាល បានផ្តល់វិញ្ញាបនបត្រធ្វើអាជីវកម្មសម្ភារៈកសិកម្ម ដល់ក្រុមហ៊ុនចំនួន១៧៥ក្រុមហ៊ុនដើម្បីផ្គត់ផ្គង់សម្ភារៈកសិកម្មដល់កសិករ។ ជាក់ស្តែងនៅក្នុងឆ្នាំ ២០១៥ កន្លងមកនេះ សម្ភារៈកសិកម្មមានដូចជា ត្រាក់ទ័រនៅទូទាំងប្រទេសចំនួន ១៣,៧០១ គ្រឿង ចំណែកគោយន្តវិញមាន ២៦៦,០០៤ ម៉ាស៊ីនច្រូតស្រូវមាន ៥,៨៩៣ គ្រឿង ម៉ាស៊ីនបោកស្រូវមានចំនួន ១៧,១៦៩ គ្រឿង ម៉ាស៊ីនកិនស្រូវទូទាំងប្រទេសមានចំនួន ៥៥,៣៦៤គ្រឿង និងម៉ាស៊ីនបូមទឹកមានចំនួន ៣៩៤,៦៣៣ គ្រឿង។ ដែលគ្រឿងចក្រទាំងនេះ ត្រូវបានគេភ្ជួររាស់លើដីកសិកម្មចំនួន ២,៩៦៦,៧៨៣ហិកតា។ ចំណែកឯជីគីមី និងធម្មជាតិបាននាំចូលចំនួន ៧៩៧,៩៤២ តោន និង ១៤,២០០លីត្រ ថ្នាំសម្រាប់កសិកម្ម ២៧,៨០៤តោននិង៧២០,៧៤០លីត្រ បសុឱសថ ២,៣៨២,៧៩៤តោន និងគ្រាប់ពូជដំណាំ ៤,៦២៣តោន។ ទាំងនេះសុទ្ធតែបានចូលរួមចំណែកដល់ការបង្កើនផលិតភាព ក្នុងវិស័យកសិកម្មឱ្យទទួលបាននៅផលវិជ្ជមានកន្លងមក។ ដោយមើលឃើញ ពីផលប្រយោជន៍ នៃការប្រើប្រាស់បច្ចេកទេសទាំងនេះ ដែលស្តែងចេញពីការផ្លាស់ប្តូរទស្សនៈរបស់កសិករ រាជរដ្ឋាភិបាលគួរតែកាត់បន្ថយពន្ធ លើការនាំចូលសម្ភារៈកសិកម្មជាពិសេសគ្រឿងយន្តកសិកម្ម និងធាតុផ្សំ កសិកម្មផ្សេងទៀត។

### ៤.២.៩ ការបន្តស្តារ និងការកសាងហេដ្ឋារចនាសម្ព័ន្ធ

ការកសាងនូវហេដ្ឋារចនាសម្ព័ន្ធ គឺវាមានសារៈសំខាន់ណាស់ ដែលវាប្រៀបបានដូចជាសរសៃឈាមក្នុងការដឹកជញ្ជូន ផលិតផលវត្ថុធាតុដើម ពូជ សម្ភារៈធាតុចូលកសិកម្ម ទៅកាន់កន្លែងកសិដ្ឋាន ឬទីតាំងបង្កបង្កើនផលរបស់ប្រជាកសិករនៅជនបទ។ ជាមួយគ្នានេះ ហេដ្ឋារចនាសម្ព័ន្ធ ក៏បានជួយសម្រួលដល់ប្រជាកសិករ ក្នុងការដឹកជញ្ជូនផលិតផលកសិកម្ម ទៅកាន់ទីផ្សារដែលវាជួយសម្រួលបន្ទុក និងបានរួមចំណែកក្នុងការកាត់បន្ថយ នូវការចំណាយមួយចំនួនដោយសារការរៀបចំហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ពីទីជនបទមកកាន់ទីប្រជុំជន។

### ៤.២.១០ ការជំរុញវិស័យកសិ-ឧស្សាហកម្ម

វិស័យកសិឧស្សាហកម្ម គឺជាវិស័យទីមួយផង និងជាវិស័យទីពីរផង ដែលជាសកម្មភាពចម្បងទាក់ទងនឹងការកែច្នៃកសិផល និងជលផល ទៅជាផលិតផលឧស្សាហកម្ម ឬពាក់កណ្តាលឧស្សាហកម្ម។ ការអភិវឌ្ឍវិស័យកសិកម្ម នឹងបង្កើនតម្លៃបន្ថែមលើកសិផល ដែលនឹងជំរុញកសិករឱ្យចាកចេញពី ការធ្វើកសិកម្មសម្រាប់ហូប និងលើកទឹកចិត្តឱ្យមានការចូលរួមក្នុងសកម្មភាពទីផ្សារកសិកម្ម។ ផ្នែកសំខាន់ៗនៃការអភិវឌ្ឍវិស័យកសិកម្មមាន ដូចខាងក្រោម៖

-ការជំរុញឧស្សាហកម្មកែច្នៃ៖ កម្ពុជាមានសក្តានុពល សម្រាប់ការកែច្នៃផលិតផលកសិកម្មដែលរួមមានផ្លែឈើតំបន់ត្រូពិក អាហារសមុទ្រដូចជា ត្រី បង្គារ សិប្បិសត្វ និងសត្វប្រភេទខ្ចង ខ្ចៅ គ្រំ។

-ការពង្រីកសកម្មភាពកសិឧស្សាហកម្ម៖ ក្នុងវិស័យឯកជន សម្រាប់ផ្គត់ផ្គង់ធាតុចូលកសិកម្ម និងការផ្តល់សេវាកសិកម្មដល់សហគមន៍ជនបទ។

-ការលើកទឹកចិត្តឱ្យមានការវិនិយោគពីវិស័យឯកជន៖ ក្នុងការធ្វើធុរកិច្ចផ្នែក កសិ-ឧស្សាហកម្ម ទាំងផ្នែកស្តុកទុក ការវេចខ្ចប់ និងកិច្ចការទីផ្សារនៃកសិផល។

-ការបង្កើតទំនាក់ទំនងរវាងពាណិជ្ជកម្មឯកជន និងគ្រួសារតាមជនបទ៖ តាមរយៈផលិតកម្មកសិកម្មតាមកិច្ចសន្យា និងចម្ការភូមិ។

-ការផ្តល់ពត៌មាន និងការព្យាករណ៍ពីស្ថានភាពទីផ្សារក្នុងស្រុក និងបរទេស។

### ៤.២.១១ កំណែទម្រង់ស្ថាប័ន និងគោលនយោបាយ

#### ៤.២.១១.១ ការវិនិយោគសាធារណ:

ការវិនិយោគសាធារណៈ គឺជាផ្នែកមួយដ៏សំខាន់ដែលជួយដល់កំណើនកសិកម្ម និងក្នុងការកាត់បន្ថយភាពក្រីក្រ។ ចាប់តាំងពីបង្កើតរដ្ឋាភិបាលថ្មីមក ប្រទេសកម្ពុជាមិនដែលយកពន្ធលើដី កសិកម្មឡើយ មិនត្រឹមប៉ុណ្ណោះ រាជរដ្ឋាភិបាលបានបង្កើតដីសម្បទានសង្គមកិច្ច និងសេដ្ឋកិច្ចដល់អ្នកវិនិយោគ និងកសិករក្រីក្រដើម្បីប្រើប្រាស់។ ទាំងនេះក៏ជាផ្នែកមួយនៃការវិនិយោគរបស់រាជរដ្ឋាភិបាលផងដែរជាពិសេសការវិនិយោគលើប្រព័ន្ធធារាសាស្ត្រ ផ្លូវថ្នល់ និងអគ្គិសនី ដែលបម្រើដល់វិស័យកសិកម្ម។

#### ៤.២.១១.២ ការលើកកម្ពស់ផលិតភាព និងពិពិធកម្មកសិកម្ម

វិស័យនេះផ្តោតទៅលើដំណាំគ្រប់មុខ និងការចិញ្ចឹមសត្វ ដែលគោលដៅទាំងអស់នោះធ្វើឱ្យមានសន្តិសុខស្បៀង សម្រាប់ប្រជាពលរដ្ឋក្រីក្រដែលរស់នៅតាមជនបទ និងការបង្កើន

ផលិតភាពកសិកម្មដើម្បីកាត់បន្ថយភាពក្រីក្រ និងចូលរួមចំណែក ក្នុងការលើកកម្ពស់កំណើនសេដ្ឋកិច្ច។ ជាលទ្ធផលនៃគោលនយោបាយ របស់រាជរដ្ឋាភិបាលយើងឃើញថា ផ្ទៃដីដាំដុះស្រូវបានកើនឡើងពី ២.៩លានហិកតា នៅឆ្នាំ២០១១ ដល់ ៣.០លានហិកតា ឆ្នាំ២០១៦ ហើយទិន្នផលស្រូវក្នុងមួយហិកតា ក៏បានកើនឡើងជាលំដាប់ផងដែរពី ៣.១៧៣តោន ក្នុងឆ្នាំ២០១១ ដល់ ៣.១៨៩តោន នៅឆ្នាំ២០១៦។ គោលនយោបាយនោះរួមមាន៖

-ពង្រឹងសេវាគាំទ្រដល់ការអភិវឌ្ឍន៍វិស័យកសិកម្ម (ធារាសាស្ត្រ និងបច្ចេកទេសទំនើប)

-ការផ្តល់ដីសម្បទានសង្គមកិច្ច និងពង្រឹងធនធានមនុស្សនៅមូលដ្ឋាន

-ការបង្កើតឱ្យមានសហគមន៍កសិករ

-ជំរុញលើកទឹកចិត្តឱ្យមានទីផ្សារសម្រាប់នាំចេញ

-អនុម័ត និងអនុវត្តវិធានការថ្មីៗ ដើម្បីផ្តល់ជំនួយដល់កសិករក្រីក្រ និងបង្កើនការកែច្នៃកសិផល។

ទោះបីជាយ៉ាងណាក៏ដោយ ក៏ទិន្នផលកសិកម្មរបស់ប្រទេសកម្ពុជា នៅមានកម្រិតទាបនៅឡើយ បើប្រៀបធៀបទៅនឹងប្រទេសជិតខាង (ពី ៣ ទៅ ៥តោនក្នុងមួយហិកតា)[52] ដែលបញ្ហានេះដោយសារវិស័យកសិកម្មនៅប្រទេសកម្ពុជាពឹងផ្អែកលើធម្មជាតិ ដោយផ្ទៃដីស្រោចស្រពមានតែ ២០% ប៉ុណ្ណោះ រីឯការស្រាវជ្រាវបច្ចេកវិទ្យានៅមានកម្រិតទាបនៅឡើយ និងការប្រើប្រាស់ពូជមិនបានល្អក្នុងការដាំដុះ។ ដើម្បីជាដំណោះស្រាយបញ្ហាកំណើនកសិកម្ម រាជរដ្ឋាភិបាលបានប្រើយុទ្ធសាស្ត្រមួយចំនួនជាអាទិភាពដូចជា៖

-ផលិតពូជដែលមានទិន្នផលខ្ពស់ និងស៊ាំទៅនឹងបម្រែបម្រួលអាកាសធាតុ

-កែលម្អ និងអនុវត្តនីតិវិធីនៃការចុះបញ្ជីដីធ្លី និងផ្តល់ប័ណ្ណកម្មសិទ្ធិដល់ប្រជាពលរដ្ឋ

-ពិនិត្យឡើងវិញនូវដីសម្បទានសេដ្ឋកិច្ចដែលមានបញ្ហា

-រៀបចំ និងអនុវត្តកម្មវិធីដីសម្បទានសង្គមកិច្ច និងបន្តបោសសម្អាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។

ឆ្លើយតបទៅនឹងបញ្ហាកំណើនកសិកម្មខាងលើ យើងពិនិត្យឃើញថា រាជរដ្ឋាភិបាលបានធ្វើការបែងចែកកម្មសិទ្ធិ និងសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី ដែលមានសារៈសំខាន់ណាស់សម្រាប់បង្កើនផលិតកម្ម និងទាក់ទាញនូវទំនុកចិត្តរបស់អ្នកវិនិយោគ។

[52] រាជរដ្ឋាភិបាលកម្ពុជា, *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១០* (ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា, ២០០៦), ២៨-១៦៣។

#### ៤.២.១១.៣ កំណែទម្រង់ដីសម្បទានកសិកម្ម

គិតមកទល់ឆ្នាំ២០១៥ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តល់ដីសម្បទានដល់ក្រុមហ៊ុនចំនួន ១១៣ ក្រុមហ៊ុន ស្ថិតនៅ ១៧ខេត្ត លើផ្ទៃដីសរុបតាមកិច្ចសន្យាចំនួន ១,០៩០,៣២២ហិកតា និង ផ្ទៃដីអាជីវកម្ម-ផលិតកម្ម សរុបចំនួន ៧៣៥,៧៥៩ ហិកតា[53]។

តែទោះជាយ៉ាងនេះក្តី វាក៏ជាផ្នែកមួយដែលជួយជំរុញដល់ការវិនិយោគលើវិស័យកសិកម្ម ដែរគ្រាន់តែត្រូវដាក់លក្ខខ័ណ្ឌ ឱ្យបានគ្រប់គ្រាន់ថែមទៀត ដើម្បីជៀសវាងនូវការប្រើប្រាស់ដីសម្បទានក្នុងគោលបំណងណាមួយផ្សេង។ ជាពិសេសការយកពន្ធ លើទ្រព្យសម្បត្តិដែលមិនបានប្រើប្រាស់ និងដាក់ចេញជាបន្ទាន់នូវអនុក្រឹត្យព្រមទាំងបទបញ្ញត្តិមួយចំនួន ដើម្បីអនុវត្តច្បាប់ភូមិបាលដែលបានអនុម័តរួចមកហើយនៅឆ្នាំ២០០១។

#### ៤.២.១១.៤ កំណែទម្រង់នេសាទ និងជលផល

ការនេសាទ គឺមានសារៈសំខាន់ណាស់ សម្រាប់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា រាប់លាននាក់ក្នុងរូបភាពជាស្បៀងអាហារ អាហាររូបត្ថម្ភ និងជាចំណូលប្រចាំថ្ងៃ។ វិស័យជលផល និងនេសាទបានចូលរួមចំណែក ២៥%នៃវិស័យកសិកម្មទាំងមូល និងស្រូបយកកម្លាំងពលកម្ម ១ភាគ៦ នៃពលកម្មសរុប។ ដើម្បីធានានូវសន្តិសុខស្បៀង និងការទទួលបាននូវធនធានត្រីជានិរន្តន៍ រាជរដ្ឋាភិបាលបានអនុវត្តគោលនយោបាយមួយចំនួនដូចខាងក្រោម៖

-ការរំសាយឡូត៍នេសាទទាំងអស់ នៅទូទាំងប្រទេសនៅឆ្នាំ២០១២ ទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ និងធ្វើជាកន្លែងអភិរក្សជលផល

-បង្កើតសហគមន៍នេសាទ និងទប់ស្កាត់ការនេសាទដែលមានលក្ខណៈបំផ្លិចបំផ្លាញ

-រៀបចំគម្រោងវិនិយោគខ្នាតតូចសម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ

-ជំរុញការងារត្រួតពិនិត្យ និងតាមដានការបង្ក្រាបបទល្មើសជលផល

-បន្តផលិតឯកសារបច្ចេកទេសជលផលដើម្បីផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ។

ដូច្នេះ ដើម្បីធានានូវកំណើនអនុវិស័យខាងលើនេះ ទាមទារឱ្យមានការជំរុញបន្ថែមទៀតទៅលើកម្មវិធីនយោបាយដែលមានស្រាប់ដូចបានថែងខាងលើ។

[53] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ២០១៥-២០១៦* (ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ២០១៦), ៩១។

#### ៤.២.១១.៥ កំណែទម្រង់ព្រៃឈើ

ព្រៃឈើ គឺជាផ្នែកមួយយ៉ាងសំខាន់សម្រាប់និរន្តរភាពបរិស្ថាន ជាពិសេសការការពារនឹងបម្រែបម្រួលអាកាសធាតុ។ បច្ចុប្បន្ននេះ ដីព្រៃឈើធំៗត្រូវបានផ្តល់សម្បទានទៅឱ្យឯកជន ដើម្បីធ្វើវិនិយោគទៅលើចម្ការដំណាំធំៗ ការធ្វើបែបនេះ បានធ្វើឱ្យរីកសាយភាយនូវឧស្ម័នផ្ទះកញ្ចក់ (២០% ទៅ ៣០% និងផ្ទៃដី ១៣លានហិកតានៃព្រៃឈើ ត្រូវបានកាប់បំផ្លាញជារៀងរាល់ឆ្នាំនៅទូទាំងពិភពលោក[54]) ធ្វើឱ្យមានបម្រែបម្រួលអាកាសធាតុ។ ស្របពេលជាមួយនឹងការរីកធំធាត់នៃចំនួនប្រជាជន ការកាប់ទន្ទ្រានព្រៃឈើ ដើម្បីសង់លំនៅស្ថាន និងពង្រីកផ្ទៃដីដាំដុះ ដើម្បីបំពេញនូវតម្រូវការស្បៀង។ ការកើនឡើងនូវកម្តៅអាកាសធាតុ បានប៉ះពាល់យ៉ាងខ្លាំងដល់ដំណាំគ្រប់ប្រភេទ និងការធ្វើវារីវប្បកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាទាំងអស់នេះ រាជរដ្ឋាភិបាលបានបង្កើតសហគមន៍ព្រៃឈើនៅទូទាំងប្រទេសចំនួន ៥៨០ សហគមន៍នៅឆ្នាំ២០១៦។ បានបង្កើតសហគមន៍តំបន់ការពារធម្មជាតិ សរុបចំនួន ១៣៣ សហគមន៍ ដែលមានប្រជាពលរដ្ឋសរុបចំនួន ៣២,០២៨គ្រួសារ រស់នៅក្នុងភូមិ ២៤៣ភូមិ លើផ្ទៃដី ១៩៣ពាន់ហិកតា និងបានលើកកម្ពស់ជីវភាពសហគមន៍ តាមរយៈការបង្កើតជម្រើសមុខរបរថ្មីក្នុងវិស័យកសិកម្ម និងចិញ្ចឹមសត្វ ការកែច្នៃផលនិងអនុផលព្រៃឈើជំនួសឱ្យការពឹងអាស្រ័យទាំងស្រុងលើធនធានធម្មជាតិ។ កំណែទម្រង់គម្រោងវិនិយោគដីសម្បទានសេដ្ឋកិច្ច ដោយបាននិរាករណ៍គម្រោងចំនួន ២៧ បានកាត់បន្ថយរយៈពេលជួលពី ៩៩ឆ្នាំ ឬ ៧០ឆ្នាំ មកនៅត្រឹម៥០ឆ្នាំ[55]។ បានបង្កើនផ្ទៃដីតំបន់ការពារធម្មជាតិបន្ថែមលើតំបន់ដែលមានស្រាប់ទាំង ៤៥កន្លែង ដោយបានបង្កើតរបៀងអភិរក្សជីវចម្រុះ ដែលក្នុងនោះផ្ទៃដីសរុបនឹងកើនដល់ប្រមាណជាង ៧.៣លានហិកតា។ ដីព្រៃឈើដែលបានកាប់រានដោយខុសច្បាប់មានចំនួន ២,៧០៩ហិកតា និងបានដកហូតរណារយន្តបានចំនួន ៤៨៦គ្រឿង។ ដើម្បីជាការជំរុញបន្ថែមទៀត រដ្ឋាភិបាលគួរតែផ្តល់សិទ្ធិអំណាចថែមទៀតដល់សហគមន៍ និងបង្កើតប្រព័ន្ធបច្ចេកវិទ្យាត្រួតពិនិត្យ និងគ្រប់គ្រងព្រៃឈើឱ្យកាន់តែមានប្រសិទ្ធភាព។

---

[54] ធនាគារពិភពលោក, *របាយការណ៍អភិវឌ្ឍន៍ពិភពលោកឆ្នាំ២០០៨ កសិកម្មសម្រាប់ការអភិវឌ្ឍ* (ភ្នំពេញ៖ ធនាគារពិភពលោក, ២០០៨), ៣២។

[55] ទីស្តីការគណៈរដ្ឋមន្ត្រី, *សមិទ្ធផលសំខាន់ៗមួយចំនួនរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១២-២០១៦* (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០១៧), ៣១។

### ៤.២.១១.៦ ការប្រកួតប្រជែងនៃផលិតផលកសិកម្មកម្ពុជា

ការវិភាគអំពីកសិកម្មកម្ពុជាបង្ហាញថា ដើម្បីលើកកម្ពស់ការប្រកួតប្រជែង ការនាំចេញផលិតផលកសិកម្មកម្ពុជា ចាំបាច់ត្រូវអនុវត្តកំណែទម្រង់គោលនយោបាយមួយចំនួនដូចតទៅៈ

-កាត់បន្ថយចំណាយចំពោះការនាំចូលជី និងល្បាយជីគីមីតាមរយៈការសម្របសម្រួលពាណិជ្ជកម្ម និងការកែទម្រង់លើការចេញអាជ្ញាប័ណ្ណ។

-ពង្រឹងលទ្ធភាពទទួលហិរញ្ញប្បទានដោយលុបបំបាត់ឧបសគ្គនានាចំពោះសាខាធនាគារនៅជនបទ និងការកែលម្អការផ្តល់កម្មសិទ្ធិដីធ្លី ពង្រឹងស្ថាប័នច្បាប់សម្រាប់ការអនុវត្តច្បាប់កិច្ចសន្យា និងវត្ថុបញ្ចាំ។

-ជំរុញកសិ-ឧស្សាហកម្ម ដោយបង្កើតយន្តការធានា និងឥណទានផ្សេងៗ។

-លើកទឹកចិត្តដល់ការបង្កើតមជ្ឈមណ្ឌលឯកជន សម្រាប់កែច្នៃកសិផល ដោយធានាការផ្តល់ទំនិញ ឬសេវាសាធារណៈចាំបាច់ផ្សេងៗ។

-លើកកម្ពស់លទ្ធភាពប្រកួតប្រជែង ក្នុងការនាំចេញម្ហូបអាហារកែច្នៃក្នុងស្រុក តាមរយៈការកែទម្រង់វិស័យថាមពលអគ្គិសនី ការផ្តល់កិច្ចសន្យាមានការប្រកួតប្រជែងចំពោះអ្នកផ្គត់ផ្គង់សេវាឯកជន។

-ការលុបបំបាត់ប៉ុស្តិ៍ត្រួតពិនិត្យខុសច្បាប់ និងកាត់បន្ថយចំណាយនៃការបញ្ជូនទំនិញតាមគយក្រៅផ្លូវការ។

-ជំរុញការនាំចេញ ដោយបង្កើតមជ្ឈមណ្ឌលពត៌មានអំពីវិស័យកសិកម្ម។

-បង្កើតមជ្ឈមណ្ឌលភូតគាមអនាម័យ និងអនាម័យ ពង្រឹងការពិសោធន៍ ការទិញវិញ្ញាបនបត្រផលិតផលសម្រាប់ការនាំចេញ។

-ផ្តួចផ្តើមអនុវត្តទស្សនាទានភូមិមួយ-ផលិតផលមួយ ដើម្បីជំរុញកែលម្អជំនាញ និងគុណភាពផលិតផលកសិកម្ម។

គោលនយោបាយដ៏សំខាន់ខាងលើនេះ វាទាមទារនូវការអនុវត្តឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ទើបអាចសម្រេចនូវគោលដៅអភិវឌ្ឍន៍កសិកម្ម ដែលរាជរដ្ឋាភិបាលបានដាក់ចេញ។

### ៤.២.១១.៧ ការកសាងសមត្ថភាពក្នុងការរៀបចំផែនការអភិវឌ្ឍកសិកម្ម

សមត្ថភាពផ្នែកស្ថាប័ន សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រ និងគោលនយោបាយស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធនឹងវិស័យកសិកម្មនៅមានកម្រិតនៅឡើយ។ ដើម្បីឆ្លើយតបតម្រូវការ

អភិវឌ្ឍន៍ធនធានមនុស្សសម្រាប់វិស័យកសិកម្ម ជាពិសេសនៅថ្នាក់ខេត្ត ស្រុក រាជរដ្ឋាភិបាលនឹងចាប់អនុវត្តប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ឱ្យបានល្អប្រសើរ និងលើកស្ទួយសមត្ថភាពអ្នកគ្រប់គ្រង និងមន្ត្រីនានានៅក្នុងកម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លី និងរយៈពេលវែង៖

-វគ្គសិក្សាកសាងសមត្ថភាពរយៈពេលខ្លី សម្រាប់មន្ត្រីថ្នាក់គ្រប់គ្រងជាន់ខ្ពស់ និងមន្ត្រីជំនាញកសិកម្មសំខាន់ រួមមាននៅកម្រិតមូលដ្ឋាន ដើម្បីលើកកម្ពស់សមត្ថភាព និងផ្សព្វផ្សាយពត៌មាន។

-គាំទ្របន្ថែមទៀតចំពោះក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីរៀបចំ និងអនុវត្តគម្រោង ហេដ្ឋារចនាសម្ព័ន្ធជនបទ និងលើកកម្ពស់ការផ្តល់សេវាសេដ្ឋកិច្ច និងសង្គម។

-វគ្គបណ្តុះបណ្តាលកសាងសមត្ថភាពរយៈពេលវែង សម្រាប់មន្ត្រីថ្នាក់គ្រប់គ្រងជាន់ខ្ពស់ និងមន្ត្រីជំនាញនៅគ្រប់កម្រិត ផ្តោតលើការបណ្តុះបណ្តាលយកសញ្ញាបត្រ កម្រិតខ្ពស់នៅបរទេស[56]។

សរុបមក ការពង្រឹងសមត្ថភាពជំនាញមន្ត្រីកសិកម្ម គឺមានសារៈសំខាន់ណាស់ក្នុងការគាំទ្រ និងជំរុញកំណើនកសិកម្មលើគ្រប់បណ្តាអនុវិស័យកសិកម្ម។

**៤.២.១១.៨ ច្បាប់**

ច្បាប់ គឺជាផ្នែកមួយដ៏សំខាន់ ដែលត្រូវបានបង្កើតឡើងជាជំនួយដល់ការគ្រប់គ្រង ប្រកបដោយប្រសិទ្ធភាព។ ការអភិវឌ្ឍមួយដ៏ប្រសើរចាំបាច់ណាស់ នូវច្បាប់ដ៏ស៊ីជម្រៅមានលក្ខខណ្ឌគ្រប់គ្រាន់។ កន្លងមកដោយសារតែមានការអភិវឌ្ឍរីកចម្រើននៃប្រទេសជាតិ ជារឿយៗច្បាប់ត្រូវបានកែលម្អឱ្យសមស្របទៅតាមសម័យកាល។ អស់រយៈពេលជាងមួយទស្សវត្សរ៍ បញ្ហាទំនាស់ដីធ្លី និងការលក់ដី ដើម្បីកាត់បន្ថយហានិភ័យបាន ធ្វើឱ្យប្រជាជនប្រមាណជា១២% គ្មានដីធ្លីសម្រាប់ធ្វើកសិកម្ម។ ជាលទ្ធផលសរុបនៃការចុះបញ្ជីដីធ្លី គិតចាប់ពីពេលចាប់ផ្តើម មកដល់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦សម្រេចចែកប័ណ្ណដល់ដៃប្រជាពលរដ្ឋបានចំនួន ៤,៤៥១,៨១៧ប័ណ្ណ (ស្មើនឹង ៦៣.៦% នៃក្បាលដីប៉ាន់ស្មាន ៧លានក្បាលដី)។ ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចសម្រេចបានចំនួន ១៤សហគមន៍ ស្មើនឹង ៥៥៩ប័ណ្ណ ទំហំ ១២,៣៥៧.៧៩ហិកតា ស្មើនឹង ១,៤៧៨គ្រួសារ[57]។ ចំណែកបទល្មើសនៃការកាប់ព្រៃឈើខុសច្បាប់នៅក្នុងឆ្នាំ២០១៦ មាន

[56] ឈុន ពហុ, *ការអភិវឌ្ឍជនបទ* (ភ្នំពេញ៖ ស.ភ.ន.វ.ស, ២០០៩), ១០៧-១០៨។

[57] ទីស្តីការគណៈរដ្ឋមន្ត្រី, *សមិទ្ធផលសំខាន់ៗមួយចំនួនរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១២-២០១៦* (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០១៧), ២៧។

ចំនួន៣,៦៥០ករណី។ រីឯការនេសាទ ក៏កើតមានបទល្មើសផងដែរនៅឆ្នាំ២០១៦ មានចំនួន ១,៤៩០ករណី ដែលបញ្ហាទាំងអស់នេះបានធ្វើឱ្យ មានការរាំងស្ទះដល់ដំណើរការនៃការអភិវឌ្ឍវិស័យកសិកម្ម។ ដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងអស់នេះ រាជរដ្ឋាភិបាលបានប្រើប្រាស់ច្បាប់ដូចខាងក្រោម៖

**ក. ច្បាប់ចំពោះដីធ្លី**

ច្បាប់ភូមិបាល ដែលជាច្បាប់ដ៏សំខាន់ សម្រាប់គ្រប់គ្រងដីធ្លី ត្រូវបានអនុម័តនៅឆ្នាំ ២០០១ ដែលបានចែងអំពីវិធាននានា អំពីកម្មសិទ្ធិ និងការប្រើប្រាស់ដី ការបែងចែក និងការធ្វើប្លង់កម្មសិទ្ធិដីធ្លី ក្នុងគោលបំណងធ្វើឱ្យការគ្រប់គ្រង និងការបែងចែកកម្មសិទ្ធិដីធ្លីប្រកបដោយប្រសិទ្ធភាព។ អនុក្រឹត្យស្តីពីការធ្វើដីសម្បទានសង្គមកិច្ច សេដ្ឋកិច្ច និងគ្រប់គ្រងដីរដ្ឋ ត្រូវបានអនុម័តរួចរាល់ ក្នុងគោលបំណងបង្កើតសកម្មភាពកសិកម្ម តាមបែបប្រពលវប្បកម្មដែលជាដំបូងតម្រូវឱ្យមានការវិនិយោគត្រឹមត្រូវ។ រាជរដ្ឋាភិបាលបានចេញបទបញ្ជាលេខ ០១ បប ស្តីពីវិធានការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងដី សម្បទានដីសេដ្ឋកិច្ច ចុះថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១២ ក្នុងទិសដៅត្រួតពិនិត្យតាមដានការ អនុវត្តកិច្ចសន្យាចំពោះសម្បទានដីសេដ្ឋកិច្ច។ លើសពីនេះ យន្តការសម្រាប់ដោះស្រាយទំនាស់ ដីធ្លីតាមរយៈគណកម្មការសូរិយោដីត្រូវបានបង្កើតឡើង ដើម្បីជួយសម្រួលដល់ការបែងចែកកម្មសិទ្ធិដីធ្លីកសិកម្ម ឱ្យស្របទៅនឹងបរិបទថ្មី និងរួមចំណែកក្នុងការដោះស្រាយវិវាទដីធ្លី ដែលកើតមានឡើងដោយសន្តិវិធី និងមានតម្លាភាព។ ជាងនេះទៅទៀត រដ្ឋាភិបាលបានដាក់ចេញនូវបទបញ្ជា ០១ នៅឆ្នាំ២០១២ ស្តីពី ការអនុវត្តគោលនយោបាយគោលនយោបាយចាស់ សកម្មភាពថ្មី លើវិស័យដីធ្លី ក្នុងទិសដៅដោះស្រាយបញ្ហាទំនាស់ដីធ្លី ដើម្បីសម្រេចឱ្យបានការចេញប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋ និងជនជាតិដើមភាគតិច ។

**ខ. ច្បាប់ក្នុងការការពារព្រៃឈើ**

រាជរដ្ឋាភិបាលបានចេញសេចក្តីសម្រេចលេខ ០៩ សសរ ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណកម្មការជាតិ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ ក្នុងគោលដៅជំរុញការកែលម្អសកម្មភាព ឱ្យសមស្របទៅនឹងបញ្ហាជាក់ស្តែង។ រៀបចំអនុក្រឹត្យស្តីពីការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃ។ ជាមួយគ្នានេះ ក៏បានបង្កើត ឱ្យមានគណកម្មការការពារតំបន់ឆ្នេរ និងការបង្កើតឱ្យមានសហគមន៍ព្រៃឈើ សំដៅចូលរួមក្នុងការថែរក្សាធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាពខ្ពស់។

**គ. ច្បាប់ការការពារបទល្មើសនេសាទ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីជលផល ដើម្បីដាក់ឱ្យអនុវត្តស្របតាមការអភិវឌ្ឍជាក់ស្តែង និងបញ្ហានានាដែលត្រូវដោះស្រាយសម្រាប់គ្រប់គ្រងធនធានជលផល ការនេសាទទឹកសាប នេសាទសមុទ្រ និងវារីវប្បកម្មជាដើម។ ការចេញសរាចរណែនាំពី ការហាមនេសាទនូវរដូវត្រីពង និងការកាប់បំផ្លាញព្រៃលិចទឹក។ ការរំសាយឡូត៍នេសាទទាំងអស់នៅទូទាំងប្រទេសឆ្នាំ២០១២ ដើម្បីឱ្យប្រជាពលរដ្ឋធ្វើការនេសាទជាលក្ខណ:គ្រួសារ និងធ្វើជាកន្លែងអភិរក្សធនធានជលផល។ បង្កើតគណកម្មការជាតិ និងអនុកម្មការជាតិ ដើម្បីទប់ស្កាត់នូវបទល្មើស និងគ្រប់គ្រងលើសកម្មភាពនៃការប្រព្រឹត្តបទល្មើសនានា និងអនុវត្តទៅតាមក្របខណ្ឌច្បាប់ឱ្យបានម៉ឺងមាត់ ទៅនឹងស្ថានភាពជាក់ស្តែង។

ដូច្នេះ យើងពិនិត្យឃើញថា ការបង្កើតច្បាប់បទដ្ឋានសំខាន់ៗ ក៏ដូចជាគោលនយោបាយមួយចំនួន ក្នុងការគ្រប់គ្រងវិស័យកសិកម្ម ពិតជាទង្វើដ៏ត្រឹមត្រូវ ដើម្បីតម្រង់ទិសនៃការអភិវឌ្ឍ។ ប្រសិនបើគ្មានច្បាប់អភិរក្សព្រៃឈើ ច្បាប់នេសាទ និងច្បាប់ផ្សេងៗទេនោះ វានឹងកើតមានបញ្ហាអនាធិបតេយ្យក្នុងការអភិវឌ្ឍកសិកម្ម ដែលជាឧបសគ្គធ្ងន់ធ្ងរដល់ការជំរុញកំណើនប្រកបដោយចីរភាព។

# សន្និដ្ឋាន និង អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការស្រាវជ្រាវ និងការវិភាគនូវលទ្ធផលក្នុងអនុវិស័យកសិកម្មនីមួយៗ បានបង្ហាញថា ស្ថានភាពនៃវិស័យកសិកម្មកម្ពុជាបច្ចុប្បន្ន កំពុងមានការរីកចម្រើនយឺត។ ប៉ុន្តែទោះជាយ៉ាងណាវិស័យកសិកម្ម ពិតជាមានទំនាក់ទំនងជាមួយសេដ្ឋកិច្ចយ៉ាងស្អិតរមួត ហើយកម្ពុជាគឺជាប្រទេសមួយដែលពឹងផ្អែកលើកសិកម្ម ដើម្បីកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ យើងសង្កេតឃើញថា ស្រូវនូវតែជាផលិតផលសំខាន់ជាងគេនៃកសិកម្មកម្ពុជា ហើយប៉ុន្មានឆ្នាំចុងក្រោយនេះ មានទិន្នផលកើនឡើងជាលំដាប់ ដោយសារតែមានការបញ្ចូលនូវបច្ចេកទេស និងពូជថ្មីមួយចំនួន។ ចំពោះផលិតកម្មដំណាំរួមផ្សំហាក់មិនមានកំណើនណាមួយគួរឱ្យកត់សម្គាល់ឡើយ។ យើងឃើញមានការវិនិយោគធំៗមួយចំនួន ទៅលើដំណាំឧស្សាហកម្មដូចជា កៅស៊ូ ដូងប្រេង ស្វាយចន្ទីជាដើម។ ចំពោះវិស័យជលផល ហាក់មានការរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរ ក្រោយពីមានការកំណែទម្រង់ នៃការរំសាយឡូត៍នេសាទទាំងអស់ នៅទូទាំងប្រទេសនៅឆ្នាំ២០១២ កន្លងមក។ វិស័យព្រៃឈើបច្ចុប្បន្ននេះ បាននិងកំពុងយកចិត្តទុកដាក់ពីសំណាក់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍនានា ក្នុងការចូលរួមអភិរក្សនូវធនធានធម្មជាតិឱ្យមានប្រសិទ្ធភាព។ ចំពោះផលិតកម្មសត្វ មានការរីកចម្រើនគួរសម ហើយកាន់តែប្រសើរទៀតដោយសារ ការបង្ការជំងឺឆ្លង និងពង្រីកចំណេះដឹងបច្ចេកទេស ហើយសង្កេតឃើញថាការចិញ្ចឹមសត្វជាលក្ខណៈកសិដ្ឋានកំពុងតែកើនឡើងជាបន្តបន្ទាប់។ ជាមួយគ្នានេះ បញ្ហារាំងស្ទះធំៗជាច្រើនដែលធ្វើឱ្យការអភិវឌ្ឍកសិកម្មមានការយឺតយ៉ាវជាពិសេស គឺប្រព័ន្ធស្រោចស្រព ហេដ្ឋា-រចនាសម្ព័ន្ធ កង្វះឥណទាន ផលិតភាពទាប កង្វះទីផ្សារ និងភាពមិនគ្រប់គ្រាន់នៃសេវាគាំទ្រផ្សេងៗ ពិសេសគឺការអនុវត្តនូវគោលនយោបាយ របស់រដ្ឋាភិបាលរបស់មន្ត្រីថ្នាក់ក្រោមនៅមានកម្រិតនៅឡើយ។ ដែលបញ្ហាទាំងអស់នេះហើយ ដែលរាំងស្ទះដល់ការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាកសិករយើង និងមិនបង្កលក្ខណៈងាយស្រួល ដល់ការវិនិយោគលើវិស័យកសិកម្ម។

ដើម្បីដោះស្រាយបញ្ហារាំងស្ទះផ្សេងៗ រដ្ឋាភិបាលជាអ្នកដើរតួនាទីសំខាន់ជាងគេ ក្នុងការសម្របសម្រួល ខិតខំរិះរកមធ្យោបាយដែលមានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។ ដោយលទ្ធភាពរបស់រដ្ឋាភិបាល មិនអាចដោះស្រាយគ្រប់បញ្ហាបានក្នុងពេលភ្លាមៗ ដូចនេះ រាជរដ្ឋា-ភិបាលត្រូវកំណត់បញ្ហាជាអាទិភាព និងស្ថិតក្នុងលទ្ធភាពដែលមាន។ យើងសង្កេតឃើញថា

បញ្ហាដែលមានឥទ្ធិពលខ្លាំងមកលើការអភិវឌ្ឍកសិកម្មកម្ពុជាមានដូចជា ប្រព័ន្ធស្រោចស្រព ហេដ្ឋារចនាសម្ព័ន្ធ ឥណទាន និងការប្រើប្រាស់បច្ចេកវិទ្យាបុរាណ។ រាជរដ្ឋាភិបាលក្រៅពីបង្ក លក្ខណៈងាយស្រួល ដល់អង្គការមិនមែនរាជរដ្ឋាភិបាល ក៏គួរឱ្យមានការគៀងគរផ្នែកឯកជនទៅ ក្នុងការអភិវឌ្ឍកសិកម្មតាមរយៈគម្រោងវិនិយោគ របស់ពួកគេលើវិស័យកសិកម្ម និងវិស័យផ្សេង ទៀតដែលមានទំនាក់ទំនងនឹងកសិកម្ម។ លើសពីនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបង្កើនការលើកកម្ពស់ការស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មបន្ថែមទៀត ក្នុងទិសដៅបង្កើន បរិមាណ និងបង្កើនគុណភាពផលិតផលកសិកម្ម តាមរយៈការប្រើប្រាស់បច្ចេកវិទ្យា បច្ចេកទេស និងនុវានុវត្តថ្មីៗ ក្នុងបរិបទបម្រែបម្រួលអាកាសធាតុ និងឆ្លើយតបទៅនឹងតម្រូវការទីផ្សារក្នុង ប្រទេស តំបន់ និងអន្តរជាតិ។

## ២. អនុសាសន៍

យោងទៅតាមការបកស្រាយវាយតម្លៃ និងសេចក្តីសន្និដ្ឋាននៅទំព័រមុន ធ្វើឱ្យខ្ញុំអាចចូល រួមបញ្ចេញមតិយោបល់ខ្លះ ដើម្បីធ្វើឱ្យសកម្មភាពការងារ នៅក្នុងការអភិវឌ្ឍវិស័យកសិកម្មកម្ពុជា កាន់តែមានភាពងាយស្រួល និងទទួលបានភាពជោគជ័យជាងនេះទៅទៀត។

ចំណុចដែលគួរពង្រឹងបន្ថែម និងកែលម្អមានដូចជា៖

- ពង្រីកប្រព័ន្ធគមនាគមន៍ ប្រព័ន្ធស្រោចស្រពបន្ថែមដល់តំបន់គោលដៅ ដែលមិនទាន់ មានប្រភពសម្រាប់ប្រើប្រាស់គ្រប់គ្រាន់ ដូចជាអាងស្តុកទឹក ប្រឡាយបង្ហូរទឹកជាដើម។
- បន្តសាងសង់ និងជួសជុល នូវប្រព័ន្ធធារាសាស្ត្រឡើងវិញ ដោយពង្រឹងគុណភាព និង បច្ចេកទេសនៃការគ្រប់គ្រងប្រព័ន្ធស្រោចស្រពឱ្យមានប្រសិទ្ធភាព។
- កសិករគួរទទួលបានការអប់រំបណ្តុះបណ្តាលដ៏សមស្របអំពី ប្រព័ន្ធប្រពលវប្បកម្ម និង ការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម ដើម្បីបង្កើនផលិតកម្មកសិកម្ម និងកាត់បន្ថយជា អតិបរមានូវការប៉ះពាល់ដល់សុខភាព និងប្រព័ន្ធអេកូឡូស៊ី។
- ជំរុញនូវសមត្ថភាពកសិករបន្ថែមទៀត តាមរយៈ បច្ចេកវិទ្យាកសិកម្មសមស្រប ដូចជា គ្រឿងយន្តកសិកម្ម គ្រាប់ពូជផ្សេងៗ និងទុនចាំបាច់នានា ដូចជាជី និងចំណេះដឹងរបស់ កសិករសម្រាប់ធ្វើពិពិធកម្មដំណាំដាំដុះ និងបង្កើនផលិតកម្ម។
- ជំរុញឱ្យមានការបង្កើតទីផ្សារតាមមូលដ្ឋានសម្រាប់លក់កសិផលរបស់កសិករ។
- ត្រូវបង្កើតឱ្យមានការប្រកួតប្រជែង លើទីផ្សារឥណទាន ជាពិសេសឥណទានតាម ជនបទ ដើម្បីជាប្រយោជន៍ដល់ប្រជាកសិករ។

- បង្កើនការផ្សព្វផ្សាយ បច្ចេកទេសកសិកម្ម គ្រួសារតាមរយៈ វិទ្យុ ទូរទស្សន៍ និងបណ្តាញទំនាក់ទំនងសង្គមនានា ដោយធ្វើការសហការណ៍ជាមួយរដ្ឋាភិបាល ពោលគឺភាពជាដៃគូ រវាងរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល។
- រាជរដ្ឋាភិបាលគួរធ្វើការឧបត្ថម្ភធនដល់កសិករក្នុងការពង្រីកវិស័យកសិកម្ម។
- ពង្រឹងការសម្របសម្រួល រវាងក្រសួងស្ថាប័នផ្សេងៗ ដោយធ្វើឱ្យសាមញ្ញនូវនីតិវិធីរដ្ឋបាល ដូចជាតាមការបង្កើតសេវាច្រកចេញចូលតែមួយ ជាដើម ដែលនឹងលើកទឹកចិត្តឱ្យមានការវិនិយោគកាន់តែច្រើនទៅលើការកែច្នៃម្ហូបអាហារ និងការនាំចេញផលិតផលកែច្នៃ។
- កែសម្រួលគោលនយោបាយគ្រប់គ្រងដីធ្លី ដើម្បីឱ្យប្រជាពលរដ្ឋក្រីក្រ កសិករតូចតាច និងជនជាតិភាគតិចនានា ទទួលបានផលប្រយោជន៍ដោយផ្ទាល់កាន់តែច្រើនឡើង។
- រដ្ឋាភិបាលគួរពន្លឿនសកម្មភាពនៃការចេញប័ណ្ណកម្មសិទ្ធកាន់កាប់ដីធ្លី និងការបែងចែកដីធ្លីដល់ប្រជាពលរដ្ឋដែលគ្មានដីធ្លីសម្រាប់ប្រកបរបរកសិកម្ម។
- ជំរុញលើកទឹកចិត្តលើការវិនិយោគខ្នាតតូច មធ្យម និងធំ លើវិស័យកសិកម្មគ្រប់ប្រភេទ។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាណិជ្ជកម្ម គួរតែសហការគ្នាក្នុងការស្វែងរកទីផ្សារសម្រាប់ផលិតផលកសិកម្ម។
- បង្កើតគម្រោងរកទីផ្សារកសិកម្មដល់ប្រជាកសិករ ដើម្បីលើកស្ទួយជីវភាពប្រជាពលរដ្ឋតាមរយៈការបង្កើតជាមជ្ឈមណ្ឌលសម្រួលរកទីផ្សារកសិកម្ម ឱ្យប្រជាកសិករក្រីក្រ។
- អនុវត្តច្បាប់ឱ្យបានពេញលេញ ចំពោះជនល្មើសដែលបានប្រព្រឹត្តខុស៕

# ឯកសារយោង

# ឯកសារយោង


ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ. ២០១៦. *របាយការណ៍បូកសរុប ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៥-២០១៦ និងទិសដៅការងារសម្រាប់ឆ្នាំ២០១៦-២០១៧*. ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ. ២០១៥. *របាយការណ៍បូកសរុប ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៤-២០១៥ និងទិសដៅការងារសម្រាប់ឆ្នាំ២០១៥-២០១៦*. ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ. ២០១៤. *របាយការណ៍បូកសរុប ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៣-២០១៤ និងទិសដៅការងារសម្រាប់ឆ្នាំ២០១៤-២០១៥*. ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ. ២០១០. *របាយការណ៍បូកសរុប ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០០៩-២០១០ និងទិសដៅការងារសម្រាប់ឆ្នាំ២០១០-២០១១*. ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ. ២០០៩. *របាយការណ៍បូកសរុប ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០០៨-២០០៩ និងទិសដៅការងារសម្រាប់ឆ្នាំ២០០៩-២០១០*. ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ. ២០១៣. *សមិទ្ធផលសំខាន់ៗរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់សន្តិសុខស្បៀង និងកំណើនសេដ្ឋកិច្ច ចីរភាព ការអភិវឌ្ឍ*. ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, *ការវាយតម្លៃកំណើនសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០១៦*, ចូលមើលថ្ងៃទី ៣០ ធ្នូ ២០១៦, http://www.mef.gov.kh/ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ. ២០១៥. *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨*. ភ្នំពេញ៖ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ឈុន ពហុ. ២០០៩. *ការអភិវឌ្ឍជនបទ*. ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

តាំង សំអៀង និងស្វាយ ច័ន្ទតារា. ២០០៩. ការព្យាករណ៍អនុវិស័យកសិកម្មសំខាន់ ដើម្បីកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ. សារណាបញ្ចប់ការសិក្សា, សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

ទីស្តីការគណៈរដ្ឋមន្រ្តី. ២០១៧. *របាយការណ៍សង្ខេបស្តីពីសមិទ្ធផលសំខាន់ៗមួយចំនួនរបស់រាជ រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១២-២០១៦*. ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្រ្តី។

ធនាគារពិភពលោក. ២០០៨. *របាយការណ៍អភិវឌ្ឍន៍ពិភពលោកឆ្នាំ២០០៨ កសិកម្មសម្រាប់ការអភិវឌ្ឍ*. ភ្នំពេញ៖ ធនាគារពិភពលោក។

ព្រុំ តុលា, និង Brue Mckenney. ២០០២. *ធនធានធម្មជាតិ និងជីវភាពនៅតាមជនបទប្រទេសកម្ពុជា* .ភ្នំពេញ៖ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា។

យ៉ែម សំបូរ. ២០១២. សេដ្ឋកិច្ចអភិវឌ្ឍន៍. មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

រាជរដ្ឋាភិបាលកម្ពុជា. ២០១៣. *យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា*. ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជា. ២០០៦. *ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១០*. ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា។

វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា. ២០១៣. *សង្ខេបរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០១២-២០១៣*. ភ្នំពេញ៖ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា។

សារពត៌មានកោះសន្តិភាព, *កំណើនផលិតផលក្នុងស្រុកសរុប GDP នៅកម្ពុជាក្នុងឆ្នាំ២០១៤ នឹងកើនឡើង ៧.២%* ,ផ្សាយថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៤, អាចរកបាននៅ https://kohsantepheapdaily.com.kh/article/89700.html (ចូលមើលថ្ងៃទី ៣០ ធ្នូ ២០១៦)

ហង្ស ទេព. ២០១៧. *ការនាំចូលជ្រូកពីប្រទេសជិតខាងមិនអាចហាមឃាត់បានទេ*. ភ្នំពេញ៖ គេហទំព័រដើមអម្ពិល, អាចរកបាននៅ https://www.dap-news.com/index.php/kh/%E1%9E%96%E1%9F%90%E1%9E%8F%E1%9F%8C%E1%9E%98%E1%9E%B6%E1%9E%93%E1%9E%80%E1%9F%92%E1%9E%93%E1%9E%BB%E1%9E%84%E1%9E%94%E1%9F%92%E1%9E%9A%E1%9E%91%E1%9F%81%E1%9E%9F/37084.html (ថតចម្លងថ្ងៃទី ២៤ ឧសភា ២០១៧)។

ហាង ជូនណារ៉ុន. ២០១៥. *សេដ្ឋកិច្ចកម្ពុជា*. ភ្នំពេញ។

AHPC. 2012. The American Heritage dictionary of the English language [វចនានុក្រមបេតិកភណ្ឌអាមេរិកនៃភាសាអង់គ្លេស]. Houghton Mifflin company។

FAO. ២០១១. *ការប្រើប្រាស់ទឹក*, http://www.fao.org/nr/water/aquastat/countries_regions/KHM/ (ចូលទស្សនាថ្ងៃទី ០១ ឧសភា ២០១៧)។

EIC. 2006. *Cambodia Agriculture Development Report* [របាយការណ៍អភិវឌ្ឍន៍កសិកម្មកម្ពុជា]. Phnom Penh: EIC។

UNDP. 2011. *Cambodia Human Development Report* [របាយការណ៍អភិវឌ្ឍន៍មនុស្សនៅកម្ពុជា]. Phnom Penh: UNDP។

William D. Sunderlin. ២០០៦. ការកាត់បន្ថយភាពក្រីក្រតាមរយៈសហាគមន៍ព្រៃឈើនៅកម្ពុជា ឡាវ និងវៀតណាម៖ ការវាយតម្លៃសក្តានុពល. *គោលនយោបាយ និងសេដ្ឋកិច្ចព្រៃឈើ*. Volum 8, Issue 4 (មិថុនា): ៣៨៦-៣៩៦។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ ១

## ផលិតកម្មដំណាំស្រូវរយៈពេល ១០ ឆ្នាំ ២០០៦-២០១៥

ក

| ឆ្នាំ-កំរិតកំណត់ | ឯកតា | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | មធ្យមភាគ ១០ ឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ផ្ទៃដីដាំដុះប្រចាំឆ្នាំ | ហិកតា | **2,541,433** | **2,585,905** | **2,615,741** | **2,719,080** | **2,795,892** | **2,968,529** | **3,007,545** | **3,052,420** | **3,055,507** | **3,051,412** | **2,839,346** |
| - វស្សា | ហិកតា | *2,212,015* | *2,241,114* | *2,255,104* | *2,334,228* | *2,391,016* | *2,496,569* | *2,512,038* | *2,567,723* | *2,564,572* | *2,561,957* | *2,413,634* |
| - ប្រាំង | ហិកតា | *329,418* | *344,791* | *360,637* | *384,852* | *404,876* | *471,960* | *495,507* | *484,697* | *490,935* | *489,455* | *425,713* |
| ផ្ទៃដីប្រមូលផលប្រចាំឆ្នាំ | ហិកតា | **2,516,415** | **2,566,952** | **2,613,363** | **2,674,603** | **2,777,323** | **2,766,617** | **2,980,297** | **2,968,967** | **3,028,836** | **3,025,630** | **2,791,900** |
| - វស្សា | ហិកតា | *2,188,726* | *2,222,596* | *2,252,733* | *2,290,552* | *2,372,519* | *2,294,784* | *2,484,832* | *2,485,521* | *2,537,976* | *2,536,175* | *2,366,641* |
| - ប្រាំង | ហិកតា | *327,689* | *344,356* | *360,630* | *384,051* | *404,804* | *471,833* | *495,465* | *483,446* | *490,860* | *489,455* | *425,259* |
| ទិន្នផលប្រចាំឆ្នាំ |ត/ហិកតា | **2.489** | **2.621** | **2.746** | **2.836** | **2.970** | **3.173** | **3.117** | **3.163** | **3.079** | **3.085** | **2.928** |
| - វស្សា | ត/ហិកតា | *2.272* | *2.413* | *2.540* | *2.620* | *2.760* | *2.920* | *2.872* | *2.925* | *2.815* | *2.827* | *2.696* |
| - ប្រាំង | ត/ហិកតា | *3.938* | *3.959* | *4.030* | *4.126* | *4.201* | *4.406* | *4.349* | *4.383* | *4.443* | *4.422* | *4.226* |
| បរិមាណផលប្រចាំឆ្នាំ | តោន | **6,264,123** | **6,727,127** | **7,175,473** | **7,585,870** | **8,249,452** | **8,779,365** | **9,290,940** | **9,389,961** | **9,324,416** | **9,335,284** | **8,212,201** |
| - វស្សា | តោន | *4,973,694* | *5,363,690* | *5,722,142* | *6,001,385* | *6,548,709* | *6,700,439* | *7,136,139* | *7,271,251* | *7,143,521* | *7,170,684* | *6,403,165* |
| - ប្រាំង | តោន | *1,290,429* | *1,363,437* | *1,453,331* | *1,584,485* | *1,700,743* | *2,078,926* | *2,154,801* | *2,118,710* | *2,180,896* | *2,164,600* | *1,809,036* |
| ត្រូវការស្បៀងក្នុង១ឆ្នាំ | តោន | **2,053,983** | **2,096,025** | **1,970,270** | **1,979,214** | **2,076,542** | **2,108,022** | **2,142,178** | **2,137,878** | **2,178,050** | **2,222,078** | **2,096,424** |
| ស្បៀងសល់ ឬខ្វះ (អង្ករ) | តោន | **1,433,880** | **1,649,640** | **2,025,033** | **2,244,598** | **2,516,752** | **2,780,328** | **3,031,017** | **3,090,452** | **3,013,783** | **2,975,809** | **2,476,129** |
| ស្បៀងសល់ ឬខ្វះ (ស្រូវ) | តោន | *2,240,438* | *2,577,562* | *3,164,114* | *3,507,185* | *3,932,425* | *4,344,263* | *4,735,964* | *4,828,832* | *4,709,036* | *4,649,702* | **3,868,952** |

# តុល្យភាពស្បៀងផលិតផលស្រូវឆ្នាំ ២០១៦

ខ

| កម្រិតកំណត់ | ឯកតា | រដូវវស្សា | រដូវប្រាំង | សរុប |
|---|---|---|---|---|
| ផែនការដាំដុះ | ហ.ត | ២,៥៦៧,១៣០ | ៩១៧,៣២៥ | **២,៩៨៤,៤៥៥** |
| ផ្ទៃដីអនុវត្ត | ហ.ត | ២,៥៦១,៩៥៧ | ៤៨៩,៤៥៥ | **៣,០៥១,៤១២** |
| ផ្ទៃដីខូចខាត | ហ.ត | ២៥,៧៨២ | | **២៥,៧៨២** |
| ផ្ទៃដីប្រមូលផល | ហ.ត | ២,៥៣៦,១៧៥ | ៤៨៩,៤៥៥ | **៣,០២៥,៦៣០** |
| ទិន្នផលមធ្យម | ត/ហ.ត | ២.៨២៧ | ៤.៤២២ | **៣.០៨៥** |
| បរិមាណផល | តោន | ៧,១៧០,៦៨៤ | ២,១៦៤,៦០០ | **៩,៣៣៥,២៨៤** |

<u>កំណត់សម្គាល់៖</u>

| | |
|---|---|
| –កាត់ចេញ ១៣ភាគរយ លើបរិមាណសរុបសម្រាប់ទុកពូជ និងបាត់បង់ពេលប្រមូលផល | ១,២១៣,៥៨៧ តោន |
| –ស្រូវចំណីនៅសល់ ក្រោយពីកាត់ចេញ ១៣% | ៨,១២១,៦៩៧ តោន |
| –សរុបស្បៀងដែលមាន គិតជាអង្ករ | ៥,១៩៧,៨៨៧ តោន |
| –តម្រូវការស្បៀងមួយឆ្នាំ | ២,២២២,០៧៨ តោន |
| –បរិមាណអង្ករលើស | **២,៩៧៥,៨០៩ តោន** |
| –គិតជាស្រូវលើស | **៤,៦៤៩,៧០២ តោន** |

# ឧបសម្ព័ន្ធ ២

## ផែនការផលិតកម្មដំណាំស្រូវឆ្នាំ២០១៦-២០១៧

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានឆ្នាំ២០១៥-២០១៦ | | | ទិសដៅសម្រាប់ឆ្នាំ២០១៦-២០១៧ | |
|---|---|---|---|---|---|---|---|
| | | | ផែនការ | សម្រេចបាន | % ធៀបផែនការ | ផែនការ | បញ្ជាក់មូលហេតុបម្រែបម្រួល |
| ១ | **ផ្ទៃដីដាំដុះស្រូវប្រចាំឆ្នាំ** | **ហ.ត** | **2,984,455** | **3,051,412** | **102.24** | **2,903,801** | ដោយសារលក្ខខណ្ឌធម្មជាតិ (ជំនន់និងរាំងស្ងួត) មិនអាចព្យាករណ៍ជាមុនបាន។ ដូចនេះផែនការដាំដុះស្រូវរដូវវស្សានឹងអាចសម្រេចបាន ២,៤៧ លានហិកតានៅឆ្នាំ២០១៦។ |
| | ផ្ទៃដីដាំដុះស្រូវវស្សា | ហ.ត | 2,567,130 | 2,561,957 | 99.80 | 2,474,446 | |
| | ផ្ទៃដីដាំដុះស្រូវប្រាំង | ហ.ត | 417,325 | 489,455 | 117.28 | 429,355 | |
| ២ | **ទិន្នផលស្រូវ** | **តោន/ហ.ត** | **3.090** | **3.085** | **99.84** | **3.090** | |
| | ទិន្នផលស្រូវវស្សា | តោន/ហត | 2.900 | 2.827 | 97.48 | 2.855 | |
| | ទិន្នផលស្រូវប្រាំង | តោន/ហត | 4.448 | 4.422 | 99.42 | 4.444 | |
| ៣ | **បរិមាណផលប្រចាំឆ្នាំ** | **តោន** | **9,220,699** | **9,335,284** | 101.24 | **8,973,312** | |
| | បរិមាណផលស្រូវវស្សា | តោន | 7,386,677 | 7,170,684 | 97.08 | 7,065,211 | |
| | បរិមាណផលស្រូវប្រាំង | តោន | 1,834,022 | 2,164,600 | 118.02 | 1,908,101 | |

# ឧបសម្ព័ន្ធ ៣

## សរុបផ្ទៃដីដាំដុះ និងបរិមាណដំណាំរួមផ្សំនិងឧស្សាហកម្មឆ្នាំ ២០១៥-២០១៦

| រាយមុខដំណាំ | ផ្ទៃដីអនុវត្ត (ហត) | | | ផ្ទៃដីប្រមូលផល (ហត) | | | ទិន្នផល (តោន, ហ.ត) | | | បរិមាណផល (តោន) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | វស្សា | ប្រាំង | សរុប | វស្សា | ប្រាំង | សរុបប្រចាំឆ្នាំ | វស្សា | ប្រាំង | សរុបប្រចាំឆ្នាំ | វស្សា | ប្រាំង |
| ពោត | **112,574** | 82,473 | 30,101 | **104,157** | 76,522 | 27,635 | 3.84 | 3.95 | 3.53 | **399,649** | 302,134 | 97,515 |
| ក្នុងនោះពោតក្រហម | **87,495** | 62,815 | 24,680 | **79,337** | 57,076 | 22,261 | 4.20 | 4.36 | 3.77 | **333,058** | 249,045 | 84,013 |
| ដំឡូងឈើ | **573,624** | 535,732 | 37,892 | **546,406** | 512,574 | 33,832 | 24.34 | 24.38 | 23.70 | **13,298,108** | 12,496,175 | 801,933 |
| ដំឡូងជ្វា | **5,757** | 3,658 | 2,099 | **5,743** | 3,658 | 2,085 | 7.91 | 7.95 | 7.84 | **45,424** | 29,087 | 16,337 |
| បន្លែ | **47,373** | 27,196 | 20,177 | **47,285** | 27,150 | 20,135 | 8.58 | 8.24 | 9.03 | **405,527** | 223,735 | 181,793 |
| សណ្ដែកបាយ | **57,172** | 42,973 | 14,199 | **53,962** | 39,785 | 14,177 | 1.10 | 1.06 | 1.21 | **59,220** | 42,066 | 17,154 |
| *សរុប I* | *796,500* | *692,032* | *104,468* | *757,553* | *659,689* | *97,864* | | | | *14,207,928* | *13,093,197* | *1,114,731* |
| សណ្ដែកដី | **15,519** | 13,531 | 1,988 | **15,487** | 13,524 | 1,963 | 1.62 | 1.66 | 1.39 | **25,149** | 22,417 | 2,733 |
| សណ្ដែកសៀង | **66,824** | 66,087 | 737 | **66,606** | 65,869 | 737 | 1.46 | 1.46 | 1.42 | **96,942** | 95,895 | 1,047 |
| ល្ង | **26,544** | 24,796 | 1,748 | **24,673** | 22,925 | 1,748 | 0.72 | 0.73 | 0.60 | **17,859** | 16,815 | 1,044 |
| អំពៅ | **19,514** | 15,666 | 3,848 | **19,243** | 15,395 | 3,848 | 36.85 | 39.39 | 26.72 | **709,175** | 606,351 | 102,823 |
| ក្រចៅ | **135** | 102 | 33 | **135** | 102 | 33 | 0.56 | 0.52 | 0.67 | **75** | 53 | 22 |
| ថ្នាំជក់ | **6,545** | 67 | 6,478 | **6,520** | 67 | 6,453 | 1.24 | 1.06 | 1.24 | **8,058** | 71 | 7,987 |
| *សរុប II* | *135,081* | *120,249* | *14,832* | *132,664* | *117,882* | *14,782* | | | | *857,258* | *741,602* | *115,656* |
| *សរុបរួម* | *931,581* | *812,281* | *119,300* | *890,217* | *777,571* | *112,646* | | | | *15,065,186* | *13,834,799* | *1,230,387* |
| **តួលេខឆ្នាំមុន** | **953,597** | **823,629** | **129,968** | **937,521** | **815,379** | **122,142** | | | | **14,727,262** | **13,484,064** | **1,243,198** |
| **ប្រៀបធៀប** | -22,016 | -11,348 | -10,668 | -47,304 | -37,808 | -9,496 | - | - | - | 337,923 | 350,735 | -12,811 |

# ឧបសម្ព័ន្ធ ៤

## ស្ថិតិផ្ទៃដីកៅស៊ូសរុប ឆ្នាំ២០០៧-២០១៥ (ហិកតា)

| ប្រភេទចម្ការកៅស៊ូ | ឆ្នាំ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 |
| ១- ចម្ការកៅស៊ូកសិ-ឧស្សាហកម្ម | | 45,707 | 53,674 | 67,143 | 99,620 | 117,174 | 172,658 | 191,354 | 217,463 | 239,102 |
| ក. អតីតចម្ការរដ្ឋ | | 43,967 | 45,469 | 43,794 | 47,092 | 50,715 | 54,209 | 55,908 | 55,786 | 54,850 |
| ខ. ចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ច | | 1,740 | 8,205 | 23,349 | 52,528 | 66,459 | 118,449 | 135,446 | 161,677 | 184,252 |
| ២- ចម្ការកៅស៊ូគ្រួសារ | | 36,351 | 54,227 | 60,680 | 81,813 | 95,930 | 107,696 | 137,417 | 140,346 | 149,853 |
| **សរុប** | | **82,058** | **107,901** | **127,823** | **181,433** | **213,104** | **280,354** | **328,771** | **357,809** | **388,955** |
| **កើន-ថយ** | ហិកតា | | 25,843 | 19,922 | 53,610 | 31,671 | 67,250 | 48,417 | 29,038 | 31,146 |
| | ភាគរយ | | 31.5% | 18.5% | 41.9% | 17.5% | 31.6% | 17.3% | 8.8% | 8.7% |

*ប្រភព: អគ្គនាយកដ្ឋានកៅស៊ូ*

# ឧបសម្ព័ន្ធ ៥

## គំនូសបំព្រួញស្តីពី " យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ "
## របស់រាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា (២០១៣-២០១៨)



# ឧបសម្ព័ន្ធ ៦






# ឧបសម្ព័ន្ធ ៧



ដំណាំដំឡូងមី



ដំណាំកៅស៊ូ

# ឧបសម្ព័ន្ធ ៨






## ឧបសម្ព័ន្ធ ៩



ការចិញ្ចឹមមាន់



ការចិញ្ចឹមត្រីក្នុងស្រះ